# ព្រះ
# ត្រៃបិដកបាលី
នឹង
សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
ខុទ្ទកនិកាយ អបទាន

បឋមភាគ

# ៧២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស. ២៥០៦

សុត្តន្តបិដក

ខុទ្ទកនិកាយេ អបទាន

បឋមភាគ

៧៦

ព.ស. ២៥០៦

# សុត្តន្តបិដកេ

## ខុទ្ទកនិកាយស្ស អបទានំ

## បឋមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### បឋមោ ពុទ្ធវគ្គោ

### បឋមំ ពុទ្ធាបទានំ(១)

[១] តថាគតំ ជេតវនេ វសន្តំ
អបុច្ឆិ វេទេហមុនី នតង្គោ
សព្វញ្ញុពុទ្ធា កិរ នាម ហោន្តិ
ភវន្តិ តេ ហេតុភិ កេហិ ធីរ(២) ។
តទាហ សព្វញ្ញុវរោ មហេសី
អានន្ទភទ្ទំ មធុរស្សរេន

១ ម. បឋមំ ពុទ្ធាបទានន្តិ ន ទិស្សតិ ។ ២ ម. វីរ ។

# សុត្តន្តបិដក

## ខុទ្ទកនិកាយ អបទាន

## បឋមភាគ

---

សូមនមស្ការចំពោះព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

### ពុទ្ធវគ្គ ទី ១

### ពុទ្ធាបទាន ទី ១

[១] អានន្ទៈ ជាអ្នកប្រាជ្ញ ជាបុត្រនៃនាងវេទេហី ក្នុងដែនវេទេហៈ បានសួរព្រះតថាគត កាលគង់នៅក្នុងវត្តជេតពនថា បានឮថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយ តែងមាន តើព្រះសព្វញ្ញុពុទ្ធ ជាអ្នកប្រាជ្ញទាំងនោះ ទ្រង់កើតមាន ដោយហេតុដូចម្តេច ។ គ្រានោះ ព្រះសព្វញ្ញុពុទ្ធដ៏ប្រសើរ ទ្រង់ស្វែងរកនូវគុណដ៏ធំ ទ្រង់បានត្រាស់ នឹងព្រះអានន្ទដ៏ចម្រើន ដោយព្រះសូរសៀងដ៏ពីរោះថា

យេ សព្វពុទ្ធេសុ(១) កតាធិការា

អលទ្ធមោក្ខា ជិនសាសនេសុ ។

តេនេវ សំវេគមុខេន ធីរា

អជ្ឈាសយេនាបិ មហាពលេន

បញ្ញាយ តេជេន សុតិក្ខបញ្ញា

សព្វញ្ញុភាវំ អនុបាបុណន្តិ ។

អហម្បិ បុព្វពុទ្ធេសុ ពុទ្ធត្តំ អភិបត្ថយឹ(២)

តិំសបារមិសម្បុណ្ណា ធម្មរាជា អសង្ខិយា ។

សម្ពោធឹ ពុទ្ធសេដ្ឋានំ សសង្ឃេ លោកនាយកេ

ទសង្គុលី នមស្សិត្វា សិរសា អភិវាទយេ(៣) ។

យាវតា ពុទ្ធខេត្តេសុ រតនា វិជ្ជន្តិសង្ខិយា

អាកាសដ្ឋា ច ភូមដ្ឋា មនសា សព្វមាហរឹ(៤) ។

១ ម. បុព្វពុទ្ធេសុ ។ ២ ម. ឯត្ថន្តរេ មនសាយេវ ហុត្វាន ធម្មរាជា អសង្ខិយា អថ ពុទ្ធាបទានានិ សុណាថ សុទ្ធមានសា តិ ទិស្សន្តិ ។ ៣ ម. អភិវាទយឹ ។ ៤ ម. សព្វមាហរឹ ។



ពោធិសត្វទាំងឡាយណា មានការកសាងបានធ្វើទុកហើយ ក្នុងសំណាក់នៃព្រះពុទ្ធទាំងពួង តែមិនទាន់បានមោក្ខធម៌ ក្នុងសាសនានៃព្រះជិនស្រីទេ ពោធិសត្វទាំងនោះ ជាអ្នកប្រាជ្ញ មានបញ្ញាមុតថ្លា រមែងបាននូវភាពជាសព្វញ្ញុពុទ្ធ ព្រោះប្រមាណនៃការក្រាស់ដឹងនោះផង ព្រោះអធ្យាស្រ័យមានកម្លាំងធំនោះផង ព្រោះតេជះនៃបញ្ញានោះផង ។

សូម្បីតថាគត ក៏បានប្រាថ្នានូវភាពជាព្រះពុទ្ធ ក្នុងសំណាក់នៃព្រះពុទ្ធមុនៗ ទាំងឡាយកប់មិនអស់ ដែលជាព្រះរាជានៃធម៌ បរិបូណ៌ដោយបារមី ៣០ ។ តថាគតបាននមស្ការថ្វាយបង្គំ ដោយប្រណម្យដៃ ១០ ដោយក្បាល ចំពោះព្រះសម្ពោធិញ្ញាណ របស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយផង ចំពោះព្រះសម្ពុទ្ធទាំងឡាយ ជានាយកនៃសត្វលោក ព្រមទាំងព្រះសង្ឃផង ។ រតនៈទាំងឡាយ កប់មិនអស់ មានក្នុងពុទ្ធក្ខេត្តទាំងប៉ុន្មាន ទោះតែដែលឋិតនៅក្នុងអាកាសផង ឋិតនៅលើផែនដីផង រមែងនាំមកនូវរតនៈទាំងអស់នោះ ដោយចិត្ត ។

តត្ថ រូបិយកុម្ភិយំ ចាសាជំ អាបយេ(១) អហំ
ទេកកុម្ភំ រតនមយំ ឧក្ខិត្តំ(២) ឯកមុត្តិកំ ។
វិជិត្តជម្ពុំ សុភាតំ សុរិកត្តំ មហារហំ
កាឧកាមយសជ្ឈុជំ កោដ្ឋជ្ជកេដ្ឋហំ មណ្ឌិតំ ។
បវេមា វេឡុរិយា ភូមិ វិមលក្ខសមា សុភា
ឧឡោជលជាតិណ្ណា(៣) វិកាញ្ចនភូមិយា ។
បហដ្ឋសាទាបកំឡ- វណ្ណា លោហិតកា សុភា(៤)
វេឡុកោបកាវណ្ណាកា ភូមិ និកាសតី ទិសា ។
សុរិកត្តា យរមុទា ជិយ្យុហា សីហបញ្ជរ
ចតុរោ វេទិកា ជាលា គន្ធា វេឡា មតោរមា ។
ជីលា បីតា លោហិតកា និលាត សុទ្ធកាឡ្យកា
កូដាគារវរុបេតា សត្តរតនភូសិតា ។

១ ម. អាបយិ ។ ២ ម. ឧក្ខិត្តំ ។ ៣ ម. ឧឡោជលជាតិណ្ណា ។ ៤ ម. បវាឡសា បវាឡវណ្ណា កាចិ លោហិតកា សុភា ។





កន្លែងនោះ គឺជានគរបានសាងប្រាសាទជាវិការៈនៃកែវ មានជាន់ច្រើន ខ្ពស់ត្រដែតទៅកណ្ដាលអាកាស ក្រឡឹងក្បឿងជាវិការៈនៃប្រាក់ មានសសរល្អ ដ៏វិចិត្រហើយ ចែកជាថ្លែងល្អហើយ ជាប្រាសាទមានកំពូលច្រើន មានគ្រែជាវិការៈនៃមាស ប្រដាប់ដោយគ្រឿងក្រាលស្រេច ។ ជាន់ទីមួយ ជាវិការៈនៃកែវពិទូរ្យ ប្រាសាទកម្ទិល ល្អស្មើពពក ដ៏រុងរឿងដោយឈូក ដ៏ល្អជាងជាន់ផែនក្រាល ដោយមាសដ៏ប្រសើរ ។ (ជាន់ខ្លះ) វិចិត្រដោយកែវប្រពាឡ មានពណ៌នៃកែវប្រពាឡ (ជាន់ខ្លះ) មានពណ៌ក្រហមល្អ (ជាន់ខ្លះ) មានពន្លឺដូចស្លាបអណ្ដើកមាស (ជាន់ខ្លះ) ភ្លឺផ្លេកគ្រប់ទិស ។ ទីអង្គុយនៃកែវ បង្អួច សុទ្ធសឹងតាក់តែងរបៀប មានកម្រងក្លិនក្រអូបជាទីគាប់ចិត្ត (សំយុងចុះមក) តាមបម្រើងទាំង ៤ ទិសតាមសន្ទះបង្អួច ។ (ជាន់ប្រាសាទទាំងឡាយ) មានពណ៌ខៀវ លឿង ក្រហម ស និង ពណ៌ខ្មៅសុទ្ធ ដែលប្រដាប់ដោយផ្ទះកំពូលដ៏ប្រសើរ តាក់តែងហើយដោយកែវ ៧ ប្រការ ។

ទុំលោកមយា បទុមា ភិង្ការវិហង្គសោភិតា
ឧក្កន្តតារកាកិណ្ណា ចន្ទសុរិយេហិ មណ្ឌិតា ។
ហេមជាលេន សញ្ឆន្នា សោណ្ណកឹង្កណិកាយុតា
វាតវេគេន កូជន្តិ សោណ្ណមាលា មនោរមា ។
មញ្ជេដ្ឋកំ លោហិតកំ បីតកំ ហរិបិញ្ជរំ
នានារង្គេហិ សំចិត្តំ ឧស្សិតទ្ធជមាលិនី ។
នានា(១) ពហុនេកសតា ផលិកា រជតាមយា
មណិមយា លោហិតង្គា មសារគល្លមយា តថា ។
នានាសយនចិត្តិតា(២) សណ្ហកាសិកសណ្ឋតា
កម្ពលា ទុកុលា ចីនា បត្តុណ្ណា បណ្ឌុបាវុរា ។
វិវិធត្ថរណំ(៣) សព្វំ មនសា បញ្ញបេមហំ
តាសុ តាសេវ ភូមីសុ រតនកូដលង្កតា ។

---

១ ម. ឥទំ ។ ២ ម. នានាសយនវិចិត្តា ។ ៣ ម. វិវិធត្ថរណំ ។



មានក្បាច់ផ្កាឈូកគួរក្រឡេកមើល ស្រស់ដោយរស្មីនិងពន្លឺ ដេរដាសដោយរូបផ្កាយនក្ខត្តឫក្ស ដោយរូបព្រះចន្ទ និង ព្រះអាទិត្យ ទាំងដាសពាសដោយបណ្តាញមាស ប្រកបដោយកណ្តឹងមាស សន្ទឹកផ្កាមាស ជាទីត្រេកអរនៃចិត្ត រមែងលាន់ឮដោយកម្លាំងខ្យល់ ។ (ផ្ទៃនៃប្រាសាទនោះ) មានទង់ពណ៌ហង្សបាទ ពណ៌ក្រហម ពណ៌លឿង ពណ៌លឿងទុំ មានទង់វិចិត្រល្អដោយពណ៌ផ្សេង ៗ ប្រកបរបៀបទង់ដែលគេលើកឡើង ។ មានផែនក្តារផ្សេង ៗ ច្រើនរយជាអនេក ជាក្តារប្រាក់ខ្លះ ក្តារកែវមណីខ្លះ ក្តារកែវទទឹមខ្លះ ក្តារកែវមរកតខ្លះ ។ (ផ្ទៃខាងក្នុងប្រាសាទនោះ) វិចិត្រដោយសយនៈផ្សេង ៗ ក្រាលដោយសំពត់កាសិកៈ មានសាច់ល្អិត សំពត់កម្ពល សំពត់សូត្រ សំពត់ស្រុកចិនៈ សំពត់ស្រុកបត្តុណ្ណៈ សំពត់ស្រុកបណ្ឌុ ៗ កម្រាល ផ្ទាំងក្រាល ខ្នើយក្រាលផ្សេង ៗ ទាំងអស់ ដោយចិត្តឯង ខ្ញុំបានតាក់តែង ខ្នើយហោជាន់ក៏តែង ក្នុងជាន់នោះ ៗ ។

## បឋម ពុទ្ធាបទានំ

មណិវេរោចនា ឧក្កា ធារយន្តា សុវិជ្ជរេ
សោភន្តិ ឯសិកា ថម្ភា សុភា កញ្ចនតោរណា ។
ជម្ពោនទា សារមយា អថោ រជតមយាបិ ច
នេកាសន្ទី[១] សុវិភត្តា កច្ឆន្តរចិត្តិតា ។
ឧគតោ បុណ្ណយជានេកា បទុមុប្បលសំយុតា
អតីតេ សព្វពុទ្ធេ ច សសង្ឃេ លោកនាយកេ ។
បកតិវណ្ណរូបេន និម្មិតា សសាវកេ
តេន ទ្វារេន បវិសិត្វា សព្វពុទ្ធា សសាវកា ។
សព្វសោវណ្ណមយេ[២] បីឋេ និសិន្នា អរិយមណ្ឌលា
យេ ច ឯតរហិ អត្ថិ ពុទ្ធា លោកេ អនុត្តរា ។
អតីតា វត្តមានា ច ភវនំ សព្វេ សមាហរុំ[៣]
បច្ចេកពុទ្ធេនេកសតេ សយម្ភូ អបរាជិតេ ។

---

១ ម. នេកាសន្ធិ ។ ២ ម. សព្វសោណ្ណមយេ ។ ៣ ម. សមាហរិ ។



## ពុទ្ធាបទាន ទី ១

មានពួកជន ឈរកាន់ប្រទីបកែវមណីភ្លឺរុងរឿង ឯសសរទឿន សសរផ្ទះ ក្លោងទ្វារ ជាវិការៈនៃមាស ជាវិការៈនៃមាសជម្ពូនទៈ ជាវិការៈនៃឈើខ្លឹម ជាវិការៈនៃប្រាក់ដ៏ស្រស់ល្អ តាំងទីកណ្ដាលដ៏ច្រើនដែលវែកល្អ វិចិត្រដោយសន្ទុះក្ដារទ័ន្តខ្ទះ សុទ្ធសឹងល្អ ៗ ក្អមពេញ (ដោយទឹក) ច្រើន ដែលដាក់ជាឈូកនិងឧប្បលជាតិ រៀបតាំងតាំងសនទាន់ នៃប្រាសាទនោះ ។ ព្រះបច្ចេកពុទ្ធទាំងពួង ព្រមទាំងសាវ័ក និមន្តព្រះសព្វញ្ញុពុទ្ធ ជានាយកនៃសត្វលោក ព្រមទាំងព្រះសង្ឃ ក្នុងកាលដ៏កន្លងទៅហើយផង (ទូលព្រះបច្ចេកពុទ្ធទាំងឡាយ) ព្រមទាំងសាវ័ក ដោយរូបភេទជាប្រក្រតីផង ហើយចូលទៅតាមទ្វារនោះ រួចគង់ជាអរិយ-មណ្ឌល លើតាំងជាវិការៈ នៃមាសទាំងអស់ ព្រះពុទ្ធទាំងឡាយណា ប្រសើរផុត ក្នុងលោក មានក្នុងកាលឥឡូវនេះក្ដី ព្រះពុទ្ធទាំងឡាយណា កន្លងទៅហើយក្ដី ព្រះពុទ្ធទាំងអស់អង្គនោះ បានចូលមកគង់ ក្នុងប្រាសាទរបស់តថាគត ឯតថាគត ក៏បាននិមន្តព្រះបច្ចេកពុទ្ធជាច្រើនរយអង្គ ដែលជាអ្នកត្រាស់ដឹងឯង ជាអ្នកឈ្នះមារ

អតីតេ វត្តមានេ ច ភវំ សព្វេ សមាហរិំ

កប្បរុក្ខា ច យេ អត្ថិ យេ ទិព្វា យេ ច មានុសា ។

សព្វំ ទុស្សំ សមាហន្ត្វា(១) អច្ឆាទេមិ តិចីវរំ

ខជ្ជំ ភោជ្ជំ សាយនីយំ សម្បន្នំ បានភោជនំ ។

មណិមយេ សុភេ បត្តេ សម្បូរេត្វា អទាសហំ

និព្វត្តា សមាហុត្វា មដ្ឋា ចីវរសំយុតា ។

មធុក សក្ខរ ចេវ គុឡា ច មធុផាណិតា

តប្បិតា បរមន្នេន សព្វេ អរិយមណ្ឌលា(២) ។

រតនគ្គំ បវិសិត្វា កោសេយ្យ គុហាសយេ(៣)

មហារហម្ហិ សយនេ សីហសេយ្យមកប្បយុំ ។

---

១ អដ្ឋកថាយម្ពិ សមាហត្វាតិ ទិស្សតិ ។ ២ ម. សព្វេ តេ អរិយមណ្ឌលា ។ ៣ ម. គុហាសយា ។



ក្នុងអតីតកាលនិងបច្ចុប្បន្នកាល (ឲ្យឆ្អែតស្កប់ស្កល់) ។ មាន
ដើមកប្បព្រឹក្សច្រើនដើម ទាំងជាទិព្វ ទាំងជារបស់មនុស្ស គ-
ជាតតថាគតយកសំពត់ទាំងពួង (អំពីដើមកប្បព្រឹក្សនោះ)
មកធ្វើជាត្រៃចីវរ ហើយថ្វាយ (ព្រះបច្ចេកពុទ្ធ) ឲ្យស្លៀក
ដណ្តប់ (រួចនិមន្តឲ្យឆាន់) នូវចំណីចំណាប់ទំពាស៊ី ដែលមាន
សេចក្តីឆ្ងាញ់ ព្រមទាំងទឹកនិងភោជន ។ តថាគតបានញ៉ាំង
បាត្រដ៏ល្អ ជាវិការៈនៃកែវមណីឲ្យពេញ (ដោយវត្ថុទាំង
នោះ) ហើយប្រគេនសំពត់ទិព្វ មានសាច់ដ៏ល្អិត ដែលគួរ
ដល់ចីវរ ។ មណ្ឌលនៃព្រះអរិយៈទាំងអស់ ឆ្អែតស្កប់ស្កល់
ហើយ ដោយទឹកឃ្មុំផង ស្ករក្រាមផង ប្រេងផង ទឹកឃ្មុំ
និងស្ករអំពៅផង បាយដ៏ប្រសើរផង ។ (ព្រះអរិយៈទាំង
នោះ) ចូលទៅកាន់បន្ទប់កែវ សម្រេចសីហសេយ្យាលើ
សយនៈ មានតម្លៃច្រើន ដូចកេសរាជសីហ៍ក្នុងគុហា ។

បឋម ពុទ្ធវចនំ

សព្វជាតា សមុដ្ឋាយ សេយ្យេ បល្លង្កមាភុជិំ(១)
កោចរំ សព្វពុទ្ធានំ ឈានរតិសមប្បិតា ។
អញ្ញេ ធម្មានំ ទេសេន្តិ អញ្ញេ កីឡន្តិ ឥទ្ធិយា
អប្បនាយមិ កីឡន្តិ(២) អភិញ្ញាវសិការិតា ។
វិកុព្វនា វិកុព្វន្តិ អនេកសតសហស្សិយោ
ពុទ្ធាបិ ពុទ្ធេ បុច្ឆន្តិ វិសយំ សព្វញ្ញុមាលយំ ។
គម្ភីរំ និបុណំ ឋានំ បញ្ញាយ វិនិពុជ្ឈរេ
សាវកា ពុទ្ធេ បុច្ឆន្តិ ពុទ្ធា បុច្ឆន្តិ សាវកេ ។
អញ្ញមញ្ញំ បុច្ឆន្តិ(៣) អញ្ញមញ្ញំ ព្យាករោន្តិ តេ
ពុទ្ធា បច្ចេកពុទ្ធា ច សាវកា បរិចារកា ។
ឯវំ រតីសុ រមមានា(៤) បាសាទេភិរមន្តិ តេ
ឆត្តាតិឆត្តា តិដ្ឋន្តិ រតនាវេឡុសន្និកា(៥) ។

១ ម. សយនេ បល្លង្កមាភុជិំ ។ ២ ម. អញ្ញេ អភិញ្ញា អប្បេន្តិ ។ ៣ ម. បុច្ឆិត្វា ។
៤ ម. ឯវំ សកាយ រតិយា ។ ៥ ម. ឆត្តា និន្នុ រតនាកញ្ចនវេឡុបន្តិកា ។



ពុទ្ធវចនទី ១

(ព្រះអរិយៈទាំងនោះ) មានសម្បជញ្ញៈ ក្រោកឡើង ហើយផ្គត់ព្រះភ្លៅក្នុងលើសំណាក់ បំពេញសេចក្តីត្រេកអរ ក្នុងឈានជាអារម្មណ៍ របស់ព្រះពុទ្ធទាំងពួង ។ ពួកព្រះអរិយៈខ្លះ សម្តែងធម៌ ពួកខ្លះក្រសាលដោយឫទ្ធិ ពួកខ្លះក្រសាលដោយអប្បនាសមាបត្តិ ពួកខ្លះបម្រើនូវវសីក្នុងអភិញ្ញា ធ្វើវិកុព្វនាឫទ្ធិ(១) ច្រើនសែន ។ ព្រះពុទ្ធទាំងឡាយ ទ្រង់សួរនូវប្រស្នាជាវិស័យព្រះពុទ្ធ ជារបៀបនៃសព្វញ្ញុពុទ្ធ ចំពោះព្រះពុទ្ធទាំងឡាយ ដែលត្រាស់ដឹងហេតុដ៏ជ្រៅល្អិត ដោយប្រាជ្ញា សាវកទាំងឡាយ សួរព្រះពុទ្ធទាំងឡាយ ឯព្រះពុទ្ធទាំងឡាយក៏សួរសាវកទាំងឡាយ ។ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកជាអ្នកបម្រើទាំងនោះ សួរគ្នានិងគ្នាផង ឆ្លើយដល់គ្នានិងគ្នាផង ។ ព្រះអរិយបុគ្គលទាំងនោះ កាលត្រេកអរក្នុងពុទ្ធកិច្ច យ៉ាងនេះហើយ រមែងរីករាយលើប្រាសាទ ឯឆត្រ ប្រាកដស្មើដោយរបៀបនៃកែវ ក៏បិតនៅ ។

១ បានដល់ឫទ្ធិដែលធ្វើមនុស្សម្នាក់ឲ្យទៅជាមនុស្សច្រើននាក់ ។

សុវណ្ណជាលសំយុត្តំ រជតជាលឧចិតំ
មុត្តាជាលបរិក្ខិត្តំ សព្វេ ធារេន្តុ មត្ថកេ ។
ករត្ថិ ចេលវិតានា សោណ្ណតារកចិត្តិតា
វិចិត្តា មល្យវិតតា[1] សព្វេ ធារេន្តុ មត្ថកេ ។
វិតតា មល្យទាមេហិ គន្ធទាមេហិ សោភិតា
ទុស្សទាមេហិ បរិកិណ្ណា[2] រតនទាមភូសិតា ។
បុប្ផាភិកិណ្ណា សុវិចិត្តា[3] សុរភិគន្ធធូបិតា[4]
គន្ធបញ្ចង្គុលង្កតា[5] ហេមច្ឆទនឆាទិតា ។
ចតុទ្ទិសា បោក្ខរញ្ញោ បទុមុប្បលសន្ថតា
សោវណ្ណរូបា ខាយន្តុ បទ្មរេណុរជុគ្គតា ។
បុប្ផន្តុ បាទបា សព្វេ បាសាទស្ស សមន្តតោ
សយញ្ច បុប្ផា មុញ្ចិត្វា គន្ត្វា ភវនមោកិរុំ ។
សិខិនោ តត្ថ នច្ចន្តុ ទិព្វា ហំសា បកូជរេ[6]
ករវិកា ច គាយន្តុ ទិជសង្ឃា សមន្តតោ ។

១ ម. វិចិត្តមល្យវិតតា ។ ២ ម. ទុស្សទាមបរិកិណ្ណា ។ ៣ ម. សុចិត្តា ។ ៤ ម. សុរភិគន្ធូបិតា ។ ៥ ម. គន្ធបញ្ចង្គុលិកតា ។ ៦ ម. ទិព្វហំសា បកូជិរេ ។



តង់តែងប្រកបដោយ ឆត្រដែលប៉ាក់ដោយបណ្ដាញមាស ដែលរចនាដោយបណ្ដាញប្រាក់ ដែលព័ទ្ធព័ទ្ធដោយបណ្ដាញកែវមុក្តា ឆត្រទាំងអស់នោះ សូមទ្រង់លើព្រះកេសព្រះពុទ្ធ ។ ពិតានសំពត់ ដែលវិចិត្រដោយផ្កាយមាស ដែលវិចិត្រដោយរបៀបផ្កា ពិតានទាំងនោះ សូមទ្រង់លើព្រះកេសព្រះពុទ្ធ ។ សូមស្រះបោក្ខរណី ដេរដាសដោយចង្កោមផ្កា (មានក្លិនក្រអូប) និងចង្កោមផ្កាឈើមានក្លិនក្រអូប ល្អដោយចង្កោមផ្កាក្រអូប ដេរដាសដោយផ្ទាំងសំពត់ តាក់តែងដោយចង្កោមកែវ ។ សូមស្រះបោក្ខរណី ដេរដាសដោយផ្កាវិចិត្រល្អ អប់ដោយក្លិនក្រអូប តាក់តែងដោយគ្រឿងប្រស់ព្រំដ៏ក្រអូប បិទបាំងដោយពិតានមាស ។ សូមស្រះបោក្ខរណី ក្នុងទិសទាំង ៤ ក្រាលព្រាតដោយឈូកនិងឧប្បល កោយកយដោយលំអងផ្កាឈូក កើតប្រាកដក្បែរប្រាសាទមាស ។ ដើមឈើទាំងអស់ ជុំវិញប្រាសាទ សូមបញ្ចេញផ្កា លុះបញ្ចេញផ្កាហើយ សូមរោយរាយក្លិនទៅលើប្រាសាទ ។ សូមពួកក្ងោករាំលើប្រាសាទនោះ សូមពួកហង្សជាទិព្វ ស្រែកកញ្ជ្រៀវ សូមពួកករវិកយំ សូមពួកបក្សីរងាវ ជុំវិញប្រាសាទនោះ ។

## បឋមំ ពុទ្ធបាទំ

ភេរិយោ សត្ត វត្ថូ   វីណា សត្ត វត្ថុ[១] តា
សត្ត សត្តិដ្ឋ វត្ថូ   ទានសាលស្ស សមន្តតោ ។
យាវតា ពុទ្ធខេត្តម្ហិ   ចក្កវាឡា ចតុប្បរា[២]
បមាណា ជោតិសម្បន្នា   អច្ចិមា[៣] រតនាមយា ។
តិដ្ឋន្តុ ហោន្តុ បល្លង្កា   ទីបរុក្ខា ផលន្តុ តេ
កវេន្តុ ឯកបជ្ជោតា   ជលសហស្សបរម្បរា ។
កណិការា លោហិតា ចេវ   ចន្ទន អគ្គិកណា
នានាវណ្ណា បដិស្សន្តុ   ទានសាលស្ស សមន្តតោ ។
ធុវន្តុ បក្ខកេតុ ច   សីហេតុកិរិយុទ្ធេ
ទស្សេមន្តិ ជដំ សត្តំ   វិចិត្តំ បញ្ចវណ្ណិកំ ។
ចក ចាត ច គន្ធព្វា   សត្ត ទេវ ឧបេន្តុ តេ
ចរស្សន្តា បញ្ជលិកា   ទានសាលំ បរិក្ខយំ ។
បិណ្ឌិតំ កុសលំ កម្មំ   កត្តព្វំ តិរិយំ មម
កាយេន វាចាមនសា   តិទសេ សុគតិំ គតិំ ។

១ ម. វត្ថុ ។ ២ ម. បញ្ជលិទៀ តតោ បរំ ។ ៣ ម. អច្ចិមា ។



## ពុទ្ធបាទ ទី ១

សូមពួកស្គរទាំងអស់ លាន់ឮខ្ទរខ្ទារ សូមពួកពិណទាំងអស់
លាន់ឮ សូមពួកចង្រៀងទាំងអស់ច្រៀង ជុំវិញព្រះសាល ។
សូមបល្ល័ង្កមាសដ៏ធំ ដែលបរិបូណ៌ដោយគន្ធមិនដាច់ ដែល
រចនាដោយកែវ ឋិតនៅក្នុងចក្រវាឡ ជាពុទ្ធក្ខេត្តទាំងប៉ុន្មាន
ផង ក្នុងចក្រវាឡ (ដោយពន្លឺនោះផង) ។ សូមពួកឈើប្រទីបភ្លឺរុង
រឿង សូមឈើទាំងហ្នឹង មានពន្លឺតែមួយៗ គ្នា ។ សូម
ពួកស្រីកណ្ណិកា ពួកស្រីរាំទាំងពួកស្រីអប្សរ ដែលប្រដាប់
ដោយពណ៌ផ្សេងៗ រាំគ្នាក់ រាំគ្នាច្រៀង ជុំវិញព្រះសាល ។
សូមទង់ទម្បរលើកទង់ជ័យទាំងអស់ ដ៏វិចិត្រមានពណ៌៥ លើ
ចុងឈើខ្លះ លើកំពូលភ្នំខ្លះ លើកំពូលភ្នំសិនេរុខ្លះ ។ សូមគន្ធ
ប្រកាសថា សូមពួកមនុស្ស នាគ គន្ធព្វ និងទេវតាទាំងអស់
នោះ នាំគ្នាមកនមស្ការ ធ្វើអញ្ជលីកម្ម ជោមរោមព្រះសាល
របស់យើងនេះ ។ អំពើជាកុសលណាមួយ ដែលខ្ញុំសន្សំធ្វើ
ដោយកាយ វាចា ចិត្ត (អំពើជាកុសលនោះ) ដែលខ្ញុំបានធ្វើ
ហើយ ជាកុសលនាំឲ្យកើតក្នុងសុគតិ ក្នុងត្រៃត្រិង្ស ។

យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ ។
យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ[១] ន ជានន្តិ ទេវា គន្ត្វា និវេទយុំ ។
សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ[២] លភន្តុ មម ចេតសា ។
មនសា ទានំ មយា ទិន្នំ មនសា បសាទមាវហិំ[៣]
បូជិតា សព្វសម្ពុទ្ធា បច្ចេកានញ្ច បូជយិំ[៤] ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតិំសំ អគញ្ឆហំ ។
ទុវេ ភវេ បជានាមិ ទេវត្តេ[៥] អថ មានុសំ[៦]

---

១ ម. តស្មិំ ។ ២ ម. សព្វំ ។ ៣ ម. បសាទមាវហិំ ។ ៤ ម. បូជិតា សព្វសម្ពុទ្ធា បច្ចេកា ជិនសាវកា ។ ៥ ម. ទេវត្តំ ។ ៦ មានុសេ ។





សត្វទាំងឡាយណា មានសញ្ញា និងសត្វទាំងឡាយណា មិនមានសញ្ញា សត្វទាំងអស់នោះ ចូរបានចូលចំណែកផលនៃបុណ្យដែលខ្ញុំបានធ្វើហើយ សត្វទាំងឡាយណា បានដឹងច្បាស់ នូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ សត្វទាំងនោះ (ចូរបានទទួល) នូវផលនៃបុណ្យដែលខ្ញុំឲ្យហើយ ម្យ៉ាងទៀត បណ្ដាសត្វទាំងនោះ សត្វទាំងឡាយណា មិនបានដឹង សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹង (ដល់សត្វទាំងនោះ) ផង ។ សត្វទាំងអស់ណាក្នុងលោក ដែលអាស្រ័យអាហារហើយរស់នៅ សត្វទាំងអស់នោះ ចូរបាននូវភោជនជាទីគាប់ចិត្ត តាមចិត្តខ្ញុំចុះ ។ តថាគតបានឲ្យទានដោយចិត្ត តថាគតបាននាំនូវសេចក្ដីជ្រះថ្លា ដោយចិត្ត បានបូជាចំពោះព្រះសម្ពុទ្ធទាំងពួង បូជាចំពោះព្រះបច្ចេកពុទ្ធទាំងឡាយ ។ តថាគតលះបង់នូវកាយ ជារបស់មនុស្សហើយ ទៅកើតក្នុងឋានតាវត្តិង្ស ព្រោះកម្មដែលតថាគតធ្វើល្អនោះផង ព្រោះការតាំងចេតនានោះផង ។ តថាគតស្គាល់ច្បាស់ នូវភពទាំងពីរ គឺភពជារបស់ទេវតា ១

អញ្ញំ គតឹ ន ជានាមិ  មនសា បត្ថិតំ ផលំ ។
ទេវានំ អធិកោ ហោមិ  ភវាមិ មនុជាធិបោ
រូបលក្ខណសម្បន្នោ  បញ្ញាយ អសមោ ភវេ ។
ភោជនំ វិវិធំ សេដ្ឋំ  រតនញ្ច អនប្បកំ
នានាវិតានំ វត្ថានិ(១)  នភសា ខិប្បំ ឧបេន្តុ មំ ។
បព្វតេ បាទបេ វាបិ  អាកាសេ ឧទកេ វនេ
យត្ថ(២) ហត្ថំ បសារេមិ  ទិព្វា ភក្ខា ឧបេន្តុ មំ ។
បព្វតេ បាទបេ វាបិ  អាកាសេ ឧទកេ វនេ
យត្ថ ហត្ថំ បសារេមិ  រតនា សព្វេ ឧបេន្តុ មេ ។
បព្វតេ បាទបេ វាបិ  អាកាសេ ឧទកេ វនេ
យត្ថ ហត្ថំ បសារេមិ  សព្វេ គន្ធា ឧបេន្តុ មេ ។
បព្វតេ បាទបេ វាបិ  អាកាសេ ឧទកេ វនេ
យត្ថ ហត្ថំ បសារេមិ  សព្វេ យានា ឧបេន្តុ មេ ។
បព្វតេ បាទបេ វាបិ  អាកាសេ ឧទកេ វនេ
យត្ថ ហត្ថំ បសារេមិ  សព្វេ មាលា ឧបេន្តុ មេ ។

---
១ ម. វិតានំ ច វត្ថានិ ។ ២ ម. យញ្ញ ។



ជារបស់មនុស្ស ១ តថាគតមិនស្គាល់គតិដទៃឡើយ នេះជាផលនៃសេចក្តីប្រាថ្នាដោយចិត្ត ។ តថាគតបានជាបុគ្គលប្រសើរជាងទេវតាទាំងឡាយ ជាធំកន្លងមនុស្សបរិបូណ៌ដោយរូបលោមនិងលក្ខណៈ ឥតមានបុគ្គលស្មើដោយប្រាជ្ញា ។ ភោជនីយ៍ប្រសើរផ្សេង ៗ ផង កែវច្រើនយ៉ាងផង សំពត់មានរបៀបផ្សេង ៗ ផង ក៏ធ្លាក់ចុះចាកអាកាស មកកាន់ទីជិតតថាគតគ្រប់ហើយ ។ តថាគតលាតដៃក្នុងទីណា គឺផែនដីក្តី អាកាសក្តី ទឹកនិងព្រៃ អាហារជាទិព្វ ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាតដៃ ក្នុងទីណា គឺផែនដី ក្តី អាកាស ទឹកនិងព្រៃ កែវទាំងពួង ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាតដៃ ក្នុងទីណា គឺផែនដី ក្តី អាកាស ទឹកនិងព្រៃ គ្រឿងក្រអូបទាំងពួង ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាតដៃ ក្នុងទីណា គឺផែនដី ក្តី អាកាស ទឹកនិងព្រៃ យានទាំងពួង ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាតដៃ ក្នុងទីណា គឺផែនដី ក្តី អាកាស ទឹកនិងព្រៃ កម្រងផ្កា ទាំងពួង ក៏មកដល់

បឋព្យា បព្វតេ ចេវ   អាកាសេ ឧទកេ វនេ
យត្ថ ហត្ថំ បសារេមិ   អលង្ការា ឧបេន្តិ មេ ។
បឋព្យា បព្វតេ ចេវ   អាកាសេ ឧទកេ វនេ
យត្ថ ហត្ថំ បសារេមិ   សព្វា កញ្ញា ឧបេន្តិ មេ ។
បឋព្យា បព្វតេ ចេវ   អាកាសេ ឧទកេ វនេ
យត្ថ ហត្ថំ បសារេមិ   មធុសក្ខរា ឧបេន្តិ មេ ។
បឋព្យា បព្វតេ ចេវ   អាកាសេ ឧទកេ វនេ
យត្ថ ហត្ថំ បសារេមិ   សព្វេ ទព្វា ឧបេន្តិ មេ ។
អទេន អត្ថិកេ ជនេ   យាចកេ ច បថាវិនោ
ទទាមិ តំ ទានវរំ   សម្ពោធិវរបត្តិយា ។
ចាលេន្តោ បថវឹ សេលំ   តជ្ជេន្តោ(១) ពហលំ គិរឹ
សទេវកំ ហាសយន្តោ   ពុទ្ធោ លោកេ អភវំ ហំ ។
ទិសា ទសវិធា លោកេ   យាយតោ នត្ថិ អន្តកំ
តស្មិំ ទិសាភាគម្ហិ   ពុទ្ធក្ខេត្តា អសង្ខិយា ។

១ ម. គជ្ជេន្តោ ។



តថាគត (អំពីទីនោះ) ។ តថាគតលាដៃ ក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹកនិងព្រៃ គ្រឿងអលង្ការទាំងឡាយ ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃ ក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹកនិងព្រៃ ស្រីកញ្ញាទាំងអស់ ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃ ក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹកនិងព្រៃ ទឹកឃ្មុំនិងស្ករ ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃ ក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹកនិងព្រៃ គ្រឿងបរិក្ខារ គ្រប់យ៉ាង ក៏មកដល់តថាគត (អំពីទីនោះ) ។ ដើម្បីដល់នូវសម្ពោធិញ្ញាណដ៏ប្រសើរ តថាគត ឲ្យនូវទានដ៏ប្រសើរនោះ ដល់ជនអ្នកត្រូវការ (ជនអ្នកដើរសុំ) យាចក និងអ្នកដើរតាមផ្លូវ ។ តថាគតញ៉ាំងដីភ្នំឲ្យលាន់ឮ ញ៉ាំងភ្នំដ៏ក្រាស់ឲ្យគ្រហឹមខ្ទារ ញ៉ាំងលោក ព្រមទាំងទេវតាឲ្យរីករាយ ទើបបានជាព្រះពុទ្ធក្នុងលោក ។ ទីបំផុតនៃសត្វ កាលទៅកាន់ទិសទាំង ១០ ក្នុងលោក មិនមានឡើយ ចំណែកខាង ពុទ្ធក្ខេត្ត ក្នុងចំណែកនៃទិសនោះ គេមិនអាចរាប់បាន ។

បឋម ពុទ្ធវចនំ

បភា បភង្គិកា មយ្ហំ យថា វិសិកាហតា
ឯត្ថន្តរេ វិសិជាលំ អាលោកោ វិបុលោ ភវេ ។
ឯត្តកេ លោកធាតុម្ហិ សព្វេ បស្សន្តុ មំ ជនា
សព្វេ បមុទិតា ហោន្តុ សព្វេ មំ អនុវត្តរេ(១) ។
វិសដ្ឋមធុរនាទេន អមតំ ភេរិយាហរេ(២)
ឯត្ថន្តរេ ជនា សព្វេ សុណន្តុ មធុរំ គិរំ ។
ធម្មមេឃេន វស្សន្តេ សព្វេ ហោន្តុ អនាសវា
យេ តត្ថ បច្ឆិមកា សត្តា សោតាបន្នា ភវន្តុ តេ ។
ទត្វា ទាតព្វកំ ទានំ សីលំ បូរេ អសេសតោ
នេក្ខម្មបារមឹ គន្ត្វា បត្តោ សម្ពោធិមុត្តមំ ។
បណ្ឌិតេ បរិបុច្ឆិត្វា កត្វា វីរិយមុត្តមំ
ខន្តិយា បារមឹ គន្ត្វា បត្តោ សម្ពោធិមុត្តមំ ។

១ ម. សព្វេ មំ អនុវត្តន្តុ យាវ ព្រហ្មនិវេសនា វិវដ្ដិ ។ ២ ម. អមតភេរិមាហនេ ។



ពុទ្ធវចនៈ ទី ១

ពន្លឺជាគ្រឿងនាំទៅនូវស្នេហ៍ចាំងទុក ព្រោះដូចហើយដល់តថាគត ពន្លឺគឺបណ្តាញនៃស្នេហ៍ ដ៏ធំទូលាយ កំកើតឡើងក្នុងចន្លោះនៃលោកធាតុនេះ ។ ដូចពួកជនទាំងអស់នេះ ក្នុងលោកធាតុ ឃើញនូវតថាគតចុះ ពួកជនទ្រាំគ្នាមានចិត្តល្អចុះ ពួកជនជនកល់រូប ប្រព្រឹត្តតាមតថាគតចុះ ។ តថាគតខ្ទួនស្គរ គឺព្រះនិព្វានឈ្មោះអមតៈ ដោយពាក្យពីរោះប្រសើរក្រៃលែង ពួកជនទ្រាំគ្នា ក្នុងលោកធាតុនេះ ស្តាប់នូវសំឡេងដ៏ពីរោះចុះ ។ កាលបើតថាគតបង្អុរចុះ ដោយទឹកភ្លៀងគឺធម៌ ពួកជនទ្រាំគ្នា ជាអ្នកមិនមានអាសវៈចុះ បណ្តាសត្វទាំងនោះ ពួកសត្វណា មានទិសស្រយដាន់ក្រោយ ពួកសត្វទាំងនោះ បានជាសោតាបន្នបុគ្គលចុះ ។ ព្រោះតថាគតឲ្យទានដែលគួរឲ្យ បានបំពេញសីល ឥតមានសេសសល់ ដល់នូវនេក្ខម្មបារមី ទើបបាននូវសម្ពោធិញាណដ៏ឧត្តម ។ ព្រោះតថាគតបានប្រឹក្សាទីពួកបណ្ឌិត ហើយធ្វើនូវវីរិយបារមី ឲ្យខ្ពង់ខ្ពស់ ដល់នូវខន្តិបារមី ទើបបាននូវសម្ពោធិញាណ ដ៏ឧត្តម ។

កត្វា ទឡ្ហមធិដ្ឋានំ សច្ចបារមិំ បូរិយ
មេត្តាយ បារមី គន្ត្វា បត្តា សម្ពោធិមុត្តមំ ។
លាភាលាភេ សុខទុក្ខេ សម្មានេច[1] វិមានេ
សព្វត្ថ សមកា ហុត្វា បត្តា សម្ពោធិមុត្តមំ ។
កោសជ្ជំ ភយតោ ទិស្វា វីរិយញ្ចាបិ ខេមតោ
អារទ្ធវីរិយា ហោថ ឯសា ពុទ្ធានុសាសនី ។
វិវាទំ ភយតោ ទិស្វា អវិវាទញ្ច ខេមតោ
សមគ្គា សខិលា ហោថ ឯសា ពុទ្ធានុសាសនី ។
បមាទំ ភយតោ ទិស្វា អប្បមាទញ្ច ខេមតោ
ភាវេថដ្ឋង្គិកំ មគ្គំ ឯសា ពុទ្ធានុសាសនី ។

១ ឱ. សម្មានេ ប ។



ព្រោះតថាគតធ្វើអធិដ្ឋានបារមីឲ្យមាំមួន បំពេញនូវសច្ចបារមី ដល់នូវមេត្តាបារមី ទើបបាននូវសម្ពោធិញាណដ៏ឧត្តម ។ ព្រោះតថាគតជាអ្នកមានចិត្តស្មើ ក្នុងលោកធម៌ទាំងអស់ គឺលាភនិងឥតលាភ សុខនិងទុក្ខ ការសរសើរនិងនិន្ទា ទើបបាននូវសម្ពោធិញាណដ៏ឧត្តម ។ អ្នកទាំងឡាយ ចូរឃើញនូវកោសជ្ជៈ ថាជាភ័យផង ឃើញនូវវីរិយៈ ថាជាធម៌ក្សេមផង ហើយចូរជាអ្នកប្រារព្ធព្យាយាមឡើង នេះជាអនុសាសនីរបស់ព្រះពុទ្ធ ។ អ្នកទាំងឡាយ ចូរឃើញនូវវិវាទ ថាជាភ័យផង ឃើញនូវការមិនវិវាទ ថាជាគុណដ៏ក្សេមផង ហើយចូរជាអ្នកព្រមព្រៀងស្រុះស្រួលនឹងគ្នាចុះ នេះជាអនុសាសនីរបស់ព្រះពុទ្ធ ។ អ្នកទាំងឡាយ ចូរឃើញនូវបមាទៈ ថាជាភ័យផង ឃើញនូវអប្បមាទៈ ថាជាគុណដ៏ក្សេមផង ហើយចូរចម្រើនមគ្គមានអង្គ ៨ នេះជាអនុសាសនីរបស់ព្រះពុទ្ធ ។

បឋមំ ពុទ្ធវចនំ

សមាគតា ពហូ ពុទ្ធា អរហន្តា ច សព្វសោ
សម្ពុទ្ធេ អរហន្តេ ច វន្ទមានា នមស្សថ ។
ឯវំ អចិន្តិយា ពុទ្ធា ពុទ្ធធម្មា អចិន្តិយា
អចិន្តិយេសុ បសន្នានំ វិបាកោ ហោតិ អចិន្តិយោតិ ។

ឥត្ថំ សុទំ ភគវា អត្តនោ ពុទ្ធចរិយំ សម្ភាវយមានោ ពុទ្ធាបទានិយំ នាម ធម្មបរិយាយំ អភាសិត្ថាតិ ។

ពុទ្ធាបទានំ សមត្តំ ។

---



ពុទ្ធាបទាន ទី ១

ព្រះពុទ្ធនិងព្រះអរហន្តច្រើនអង្គ បានមកជួបជុំដោយសព្វគ្រប់
ហើយ អ្នកទាំងឡាយចូរថ្វាយបង្គំនមស្ការ ចំពោះព្រះសម្ពុទ្ធ
និងព្រះអរហន្តចុះ ។ ព្រះពុទ្ធទាំងឡាយ ជាអចិន្តិយ-
បុគ្គល (បុគ្គលដែលគេមិនគប្បីគិតកើត) ធម៌របស់ព្រះពុទ្ធ
ជាអចិន្តិយធម៌ យ៉ាងនេះ កាលបុគ្គលជ្រះថ្លា ចំពោះគុណ
ជាអចិន្តិយៈ រមែងបានផលជាអចិន្តិយៈ ។

បានឮថា ព្រះមានព្រះភាគ កាលត្រាស់សំដែងនូវពុទ្ធចរិត របស់ព្រះអង្គ ទើបសំដែងនូវធម្មបរិយាយ ឈ្មោះពុទ្ធាបទាន ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធាបទាន ។

# ទុតិយំ បច្ចេកពុទ្ធាបទានំ

អថ បច្ចេកពុទ្ធាបទានំ សុណាថ

[៦] តថាគតំ ជេតវនេ វសន្តំ
អបុច្ឆិ វេទេហមុនី នតង្គោ
បច្ចេកពុទ្ធា កិរ នាម ហោន្តិ
ភវន្តិ តេ ហេតុភិ កេហិ ធីរ ។
តទាហ សព្វញ្ញុវរោ មហេសី
អានន្ទភទ្ទំ មធុរស្សរេន
យេ បុព្វពុទ្ធេសុ កតាធិការា
អលទ្ធមោក្ខា ជិនសាសនេសុ ។
តេនេវ សំវេគមុខេន ធីរា
វិនាបិ ពុទ្ធេហិ សុតិក្ខបញ្ញា
អារម្មណេនាបិ បរិត្តកេន
បច្ចេកពោធឹ អនុបាបុណន្តិ ។





# បច្ចេកពុទ្ធាបទាន ទី២

អ្នកទាំងឡាយ ចូរស្តាប់បច្ចេកពុទ្ធាបទាន ដូចតទៅនេះ

[៦] នតង្គៈ ជាអ្នកប្រាជ្ញ ជាបុត្រនៃនាងវេទេហី ក្នុងដែនវេទេហៈ បានសួរព្រះតថាគត កាលគង់នៅក្នុងវត្តជេតពនថា ឮថា ព្រះបច្ចេកពុទ្ធទាំងឡាយរមែងមាន តើព្រះបច្ចេកពុទ្ធជាអ្នកប្រាជ្ញទាំងនោះ រមែងកើតឡើង ដោយហេតុដូចម្តេចខ្លះ ។ គ្រានោះ ព្រះសព្វញ្ញុពុទ្ធដ៏ប្រសើរ ព្រះមហេសីស្វែងរកនូវគុណដ៏ធំ ទ្រង់បែរទៅត្រាស់នឹងព្រះអានន្ទដ៏ចម្រើន ដោយព្រះសូរសៀងដ៏ពីរោះថា

ពួកជនណា មានការកសាងបានធ្វើទុកហើយ ក្នុងសំណាក់នៃព្រះពុទ្ធទាំងឡាយ តែមិនទាន់បានមោក្ខធម៌ ក្នុងសាសនានៃព្រះជិនស្រីទេ ។ ជនទាំងនោះ ជាអ្នកប្រាជ្ញ ជាអ្នកមានប្រាជ្ញាមុតថា វៀរលែងតែព្រះពុទ្ធទាំងឡាយ រមែងបាននូវបច្ចេកពោធិញ្ញាណ ដោយប្រធាននៃសង្វេគនោះឯង ដោយអារម្មណ៍ដ៏ស្តើងស្តួចនោះឯង

## ទុតិយំ បច្ចេកពុទ្ធាបទានំ

សព្វម្ហិ លោកម្ហិ មមំ វមេត្វា
បច្ចេកពុទ្ធេ(១) សមោវ ឧត្តិ
តេសំ ឥមំ វណ្ណបទេសមត្តំ
វក្ខាមហំ សាធុ មហាមុនីនំ ។
សយមេវ ពុទ្ធានំ មហាឥសីនំ
សាធូនិ វាក្យានិ មធុំវ(២) ខុទ្ទំ
អនុត្តរំ ភេសជំ បត្ថយន្តា
សុណាថ សព្វេ សុបសន្នចិត្តា ។
បច្ចេកពុទ្ធាន សមាគតានំ
បរម្បរំ ព្យាការណានិ យានិ
អាទីនវោ យញ្ច វិរាគវត្ថុំ
យថា ច ពោធិំ អនុបាបុណឹសុ ។

១ ឱ. បច្ចេកពុទ្ធេហិ ។ ២ ឱ. មធុំវ ។



## បច្ចេកពុទ្ធាបទានទី ២

ក្នុងលោកទាំងមូល វៀរលែងតែតថាគតចេញ មិនមានបុគ្គលណាស្មើ នឹងព្រះបច្ចេកពុទ្ធឡើយ តថាគតនឹងសម្តែងនូវគុណ ត្រឹមតែសង្ខេបនេះ របស់ព្រះបច្ចេកពុទ្ធទាំងឡាយនោះ (អ្នកទាំងឡាយចូរស្តាប់នូវគុណ) របស់ពួកព្រះបច្ចេកពុទ្ធ ជាមហាមុនី ដោយប្រពៃចុះ ។ អ្នកទាំងឡាយ កាលប្រាថ្នានូវឱសថៈដ៏ប្រសើរផុតពីព្រះនិព្វាន ចូរមានចិត្តជ្រះថ្លាទាំងអស់គ្នា ស្តាប់នូវពាក្យដ៏ពីរោះ ដូចជាទឹកឃ្មុំផ្អែម របស់ព្រះមហាឥសី ដែលត្រាស់ដឹងឯង ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលមកប្រជុំគ្នា មានព្យាករណ៍ មានទោស មានវត្ថុ នៃសេចក្តីរសាយចិត្ត ទាំងមានហេតុដែលបានសម្រេច នូវពោធិញ្ញាណ ផ្សេងៗគ្នា ។

សារត្តរត្តេសុ វិរត្តសញ្ញី
រត្តម្ហិ លោកម្ហិ វិរត្តចិត្តា
ហិត្វា បបញ្ចំ ជិតផន្ទិតានិ(១)
តត្ថេវ ពោធឹ អនុបាបុណឹសុ ។
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អវិហេឋយំ អញ្ញតរម្បិ តេសំ
មេត្តេន ចិត្តេន ហិតានុកម្បី
ឯកោ ចរេ ខគ្គវិសាណកប្បោ(២) ។
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អវិហេឋយំ(៣) អញ្ញតរម្បិ តេសំ
ន បុត្តមិច្ឆេយ្យ កុតោ សហាយំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

---

១ ម. បបញ្ចេ ជិតផន្ទិតានិ ។ ២ ឱ. សព្វេសុ ភូតេសុ និធាយ ទណ្ឌំ អវិហេឋយំ អញ្ញតរម្បិ តេសំ មេត្តេន ចិត្តេន ហិតានុកម្បី ឯកោ ចរេ ខគ្គវិសាណកប្បោតិ នត្ថិ ។ ៣ ម. អវិហេឋយំ ។



(ព្រះបច្ចេកពុទ្ធទាំងនោះ) មានសេចក្តីសំគាល់ ក្នុងការណាយចិត្ត ក្នុងវត្ថុដែលប្រកបដោយរាគៈ មានចិត្តណាយក្នុងលោក ដែលគេត្រេកត្រអាល លះបង់នូវបបញ្ចធម៌(១) និងកិលេសជាត ដែលញ៉ាំងសត្វឲ្យអន្ទះសា ហើយបានសម្រេចនូវពោធិញ្ញាណ ក្នុងទីនោះឯង ។ បុគ្គលម្នាក់ដាក់ចុះនូវអាជ្ញា ចំពោះសត្វទាំងពួង មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយឡើយ ជាអ្នកអនុគ្រោះ ចំពោះប្រយោជន៍ ដោយមេត្តាចិត្ត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលម្នាក់ដាក់ចុះនូវអាជ្ញា ចំពោះពួកសត្វទាំងពួង មិនបៀតបៀន ចំពោះសត្វទាំងនោះ សូម្បីសត្វណាមួយឡើយ មិនបានប្រាថ្នានូវបុត្រ (ទៅហើយ) កើតនឹងប្រាថ្នានូវសម្លាញ់អំពីណា គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

---

១ បានដល់ធម៌ ៣ យ៉ាងគឺ រាគៈ ១ ទោសៈ ១ កិលេសទាំងអស់ ១ ដែលធ្វើឲ្យដំណើរសត្វឲ្យយឺតយូរ ។ អដ្ឋកថា ។

## ទុតិយំ បច្ចេកពុទ្ធាបទានំ

សំសគ្គជាតស្ស ភវន្តិ ស្នេហា
ស្នេហន្វយំ ទុក្ខមិទំ បហោតិ
អាទីនវំ ស្នេហជំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
មិត្តេ សុហជ្ជេ អនុកម្បមានោ
ហាបេតិ អត្ថំ បដិពទ្ធចិត្តោ
ឯតំ ភយំ សន្ថវេ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
វំសោ វិសាលោវ យថា វិសត្តោ
បុត្តេសុ ទារេសុ ច យា អបេក្ខា
វំសក្កឡីរោវ អសជ្ជមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
មិគោ អរញ្ញម្ហិ យថា អពទ្ធោ
យេនិច្ឆកំ គច្ឆតិ គោចរាយ
វិញ្ញូ នរោ សេរិតំ បេក្ខមានោ



## បច្ចេកពុទ្ធាបទានទី ២

សេចក្តីស្រឡាញ់ របស់សត្វដែលនៅប្រឡូកប្រឡំគ្នា រមែងមាន ឯសេចក្តីទុក្ខនេះមានឡើង ព្រោះអាស្រ័យសេចក្តីស្រឡាញ់ បុគ្គលកាលឃើញទោស ដែលកើតអំពីសេចក្តីស្រឡាញ់ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមានចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះពួកមិត្តនិងសំឡាញ់ រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស បុគ្គលកាលឃើញនូវភ័យ គឺសេចក្តីស្និទ្ធស្នាលនុ៎ះ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ សេចក្តីស្រឡាញ់ ក្នុងបុត្រនិងភរិយា ដូចជាឫស្សីមានមែកតក់កណ្តាញ់ បុគ្គលកាលមិនជាប់ចំពាក់ ដូចជាទំពាំងឫស្សី គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ម្រឹគក្នុងព្រៃ មិនជាប់ចំណង ដើរទៅរកចំណីតាមចំណង់ចិត្ត យ៉ាងណា វិញ្ញូជនកាលបើប្រាថ្នាសេរីភាព

ឯកោ ចរេ ខគ្គវិសាណកប្បោ ។

អាមន្តនា ហោតិ សហាយមជ្ឈេ
វាសេ(១) ឋានេ គមនេ ចារិកាយ
អនភិជ្ឈិតំ សេរិតំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ខិឌ្ឌា រតី ហោតិ សហាយមជ្ឈេ
បុត្តេសុ បេមំ វិបុលញ្ច ហោតិ
បិយវិប្បយោគំ វិជិគុច្ឆមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ
សន្តុស្សមានោ ឥតរីតរេន
បរិស្សយានំ សហិតា អឆម្ភី
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

១ ម. ឋានេ ច ។



(យ៉ាងនោះ) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ការហៅរក រមែងមាន ក្នុងកណ្តាលនៃសម្លាញ់ គឺ ក្នុងលំនៅ ក្នុងទីឈរ ក្នុងការដើរ ក្នុងការត្រាច់ចារិក បុគ្គលកាលប្រាថ្នាសេរីភាព ដែលពួកជនពាលមិនប្រាថ្នា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ល្បែងនិងតម្រេក រមែងមាន ក្នុងកណ្តាលនៃសម្លាញ់ ទាំងសេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងបុត្រទាំងឡាយ បុគ្គលកាលខ្ពើមរអើម ចំពោះការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនមានថ្នាំងថ្នាក់ចិត្ត ត្រេកអរក្នុងវត្ថុតាមមានតាមបាន ជាអ្នកអត់ធន់ ចំពោះអន្តរាយ ជាអ្នកមិនតក់ស្លុត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

ទុស្សង្គហា បព្វជិតាបិ ឯកេ
អថោ គហដ្ឋា ឃរមាវសន្តា
អប្បោស្សុក្កោ បរបុត្តេសុ ហុត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ឱរោបយិត្វា គិហិព្យញ្ជនានិ
សញ្ឆិន្នបត្តោ យថា កោវិឡារោ
ឆេត្វាន វីរោ គិហិពន្ធនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
សចេ លភេថ និបកំ សហាយំ
សទ្ធិំចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធិំចរំ សាធុវិហារិ ធីរំ





បព្វជិតពួកខ្លះ ឬពួកគ្រហស្ថ ដែលនៅគ្រប់គ្រងផ្ទះខ្លះ គេសង្គ្រោះបានដោយក្រ បុគ្គលអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ចំពោះពួកកូននៃបុគ្គលដទៃ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ វីរបុគ្គលលះបង់ នូវភេទទាំងឡាយ ជាគ្រឿងប្រាកដរបស់គ្រហស្ថ កាត់បង់នូវចំណង របស់គ្រហស្ថទាំងឡាយ ដូចដើមល្ហុសផ្ទុង ជ្រុះស្លឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បើបុគ្គលបានសម្លាញ់ ជាអ្នកប្រាជ្ញ មានបញ្ញាខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អ គប្បីជាអ្នកមានស្មារតីគ្របសង្កត់ នូវអន្តរាយទាំងពួង ហើយមានចិត្តរីករាយ ប្រព្រឹត្តជាមួយសម្លាញ់នោះចុះ ។ បើបុគ្គលមិនបានសម្លាញ់ ជាអ្នកប្រាជ្ញ មានបញ្ញាខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អទេ

រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។
អទ្ធា បសំសាម សហាយសម្បទំ
សេដ្ឋា សមា សេវិតព្វា សហាយា
ឯតេ អលទ្ធា អនវជ្ជភោជី
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ទិស្វា សុវណ្ណស្ស បភស្សរានិ
កម្មារបុត្តេន សុនិដ្ឋិតានិ
សង្ឃដ្ដមានានិ ទុវេ ភុជស្មឹ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ឯវំ ទុតិយេន សហា មមស្ស
វាចាភិលាបោ អភិសជ្ជនា វា
ឯតំ ភយំ អាយតឹ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។



គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចព្រះរាជាទ្រង់លះបង់នូវដែន ដែលទ្រង់ឈ្នះហើយ ឬដូចដំរីឈ្មោះមាតង្គៈ (លះបង់នូវហ្វូង កាលត្រាច់ទៅ) ក្នុងព្រៃ ។ តាមពិត យើងសរសើរនូវការបរិបូណ៌ ដោយសម្លាញ់ហើយ តែបុគ្គលគួរគប់រកសម្លាញ់ ដែលមានគុណប្រសើរជាងខ្លួន ឬសម្លាញ់មានគុណស្មើនឹងខ្លួន បើរកមិនបាន ពួកសម្លាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគនូវបច្ច័យ ដែលមិនទោស ហើយប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលឃើញនូវកងមាសពីរ ដែលកូនជាងមាសធ្វើសម្រេចល្អហើយ រណ្ដំគ្នា ត្រង់កដៃ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ឯការឆ្លើយឆ្លងដោយវាចាក្ដី ការជាប់ចំពាក់ក្ដី ជាមួយនឹងបុគ្គលគម្រប់ពីរ របស់អញ ដូចកងមាសមួយគូមានយ៉ាងនុ៎ះ បុគ្គលកាលរំពឹងឃើញ នូវភ័យនុ៎ះ ក្នុងកាលខាងមុខ គប្បីប្រព្រឹត្ត តែម្នាក់ឯង ដូចកុយរមាស ។

### ទុតិយំ បញ្ចកាមគុណូបការំ

កាមា ហិ ចិត្រា មធុរា មនោរមា
វិរូបរូបេន មថេន្តិ ចិត្តំ
អាទីនវំ កាមគុណេសុ ទិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ឦតី ច គណ្ឌោ ច ឧបទ្ទវោ ច
រោគោ ច សល្លញ្ច ភយញ្ច មេតំ
ឯតំ ភយំ កាមគុណេសុ ទិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសំ
វាតាតបេ ឌំសសរីសបេ ច
សព្វានិបេតានិ អភិភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
នាគោវ យូថានិ វិវជ្ជយិត្វា
សញ្ជាតខន្ធោ បទុមី ឧឡារោ
យថាភិរន្តំ វិហរំ អរញ្ញេ

### បញ្ចកាមគុណូបការ ទី ២

ពិតណាស់ កាមគុណទាំងឡាយដ៏វិចិត្រ មានរសផ្អែម ជាទីត្រេកអរនៃចិត្ត វែងតែញាំញីនូវចិត្ត ដោយសភាពផ្សេងៗ បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលឃើញនូវភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាសរ ទាំងជាភ័យ របស់អញហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលគ្របសង្កត់ នូវសេចក្ដីទាំងអស់នុ៎ះ គឺត្រជាក់ ក្ដៅ ឃ្លាន ស្រេក ខ្យល់ និងកំដៅថ្ងៃ របោមនិងសត្វលូនហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ដំរីមានខន្ធសមរម្យមាំមួន មានសម្បុរដូចផ្កាឈូក កាលលះបង់ហ្វូងហើយនៅក្នុងព្រៃ គួរដល់សេចក្ដីស្រ័យ យ៉ាងណា

ឯកោ ចរេ ខគ្គវិសាណកប្បោ ។

អដ្ឋានតំ សង្គណិការតស្ស
យំ ផុស្សយេ សាមយិកំ វិមុត្តឹ
អាទិច្ចពន្ធុស្ស វចោ និសម្ម
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ទិដ្ឋីវិសូកានិ ឧបាតិវត្តោ
បត្តោ និយាមំ បដិលទ្ធមគ្គោ
ឧប្បន្នញាណោម្ហិ[១] អនញ្ញនេយ្យោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

និល្លោលុបោ និក្កុហោ និប្បិបាសោ
និម្មក្ខោ[២] និទ្ធន្តកសាវមោហោ
និរាសយោ សព្វលោកេ ភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

---

១ ម. ឧប្បន្នញាណម្ហិ ។ ២ ម. និម្មោ ។



បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាសយ៉ាងនោះ ឯង ។ បុគ្គលបាននូវសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គលអ្នកត្រេកអរក្នុងពួក ។ បុគ្គលពិចារណាឃ្លាពាក្យ នៃព្រះពុទ្ធជាអាទិច្ចពន្ធុហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកន្លងនូវបម្រះនៃទិដ្ឋិ ដល់នូវធម៌ទៀង គឺមគ្គទី ១ មានមគ្គ (ដ៏វិសេស) បានហើយ មិនមានអ្នកដទៃដឹកនាំ ព្រោះដឹងថា អាត្មាអញមានញាណកើតឡើងហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមិនជាប់ចិត្ត (ក្នុងអាហារ) មិនកុហក មិនស្រេកឃ្លាន មិនលុបគុណគេ កំចាត់បង់មោហៈ ដូចជាទឹកចត់ មិនមានទីពាស្រ័យនៅក្នុងលោក ក្នុងលោកទាំងពួងហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

ទុតិយំ បច្ចេកពុទ្ធាបទានំ

បាបំ សហាយំ បរិវជ្ជយេថ
អនត្ថទស្សឹ វិសមេ និវិដ្ឋំ
សយំ ន សេវេ បសុតំ បមត្តំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ពហុស្សុតំ ធម្មធរំ ភជេថ
មិត្តំ ឧឡារំ បដិភាណវន្តំ
អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ខិឌ្ឌំ រតឹ កាមសុខញ្ច លោកេ
អនលង្ករិត្វា អនបេក្ខមានោ
វិភូសនដ្ឋានា វិរតោ សច្ចវាទី
ឯកោ ចរេ ខគ្គវិសាណកប្បោ ។



បច្ចេកពុទ្ធាបទាន ទី ២

បុគ្គលគប្បីវៀរស្រឡះ នូវសម្លាញ់អាក្រក់ អ្នកមិនឃើញនូវសេចក្ដីវិនាស អ្នកអាស្រ័យនៅ ក្នុងកម្មមិនស្មើ មិនគប្បីគប់រកនូវសម្លាញ់ ដែលជាប់ចំពាក់ ដែលស្រវឹង (ក្នុងកាមគុណ) ដោយខ្លួនឯង គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលគប្បីគប់រកនូវបុគ្គល ជាពហុស្សូត អ្នកទ្រទ្រង់ធម៌ អ្នកប្រកបដោយគុណដ៏ក្រៃលែង មានប្រាជ្ញាវាងវៃ បុគ្គលដឹងច្បាស់នូវប្រយោជន៍ទាំងឡាយ គួរបន្ទោបង់សេចក្ដីសង្ស័យ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមិនអើពើ មិនអាឡោះអាល័យ នូវល្បែងផង តម្រេកផង កាមសុខក្នុងលោកផង ជាអ្នកវៀរស្រឡះចាកគ្រឿងស្អិតស្អាង អ្នកពោលនូវពាក្យសច្ចៈ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់

បុត្តញ្ច ទារំ បិតរញ្ច មាតរំ
ធនានិ ធញ្ញានិ ច ពន្ធវានិ
ហិត្វាន កាមានិ យថោធិកានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
សង្គោ ឯសោ បរិត្តមេត្ថ សោខ្យំ
អប្បស្សាទោ ទុក្ខមេវេត្ថ ភិយ្យោ
គណ្ឌោ(១) ឯសោ ឥតិ ញត្វា មតិមា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
សន្ទាលយិត្វាន សំយោជនានិ
ជាលំវ ភេត្វា សលិលម្ពុចារី
អគ្គីវ ទឌ្ឍំ អនិវត្តមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ឱក្ខិត្តចក្ខុ ន ច បាទលោលោ
គុត្តិន្ទ្រិយោ រក្ខិតមានសានោ

១ ម. គាឡ្ហ ។





ទៅកាមទាំងឡាយតាមចំណែក គឺបុត្រ ភរិយា បិតា មាតា ទ្រព្យសម្បត្តិ ស្រូវ គ្រឿង និងផៅពង្សហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ កាមគុណនេះ ជាគ្រឿងជាប់ចំពាក់ ឯសេចក្តីសុខ ក្នុងកាមគុណនុ៎ះ មានប្រមាណតិច កាមគុណនុ៎ះមានសេចក្តីត្រេកអរតិច បុគ្គលអ្នកមានគំនិតប្រាជ្ញា លុះដឹងច្បាស់ថា កាមគុណនុ៎ះ ដូចជាដំបៅពកដូច្នេះហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលទម្លាយនូវសំយោជនៈ ដូចត្រីកន្ទីទំលាយនូវសំណាញ់ មិនត្រឡប់មក រកសំយោជនៈវិញ ដូចភ្លើងនេះ (មិនត្រឡប់វិញ) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមានចក្ខុដាក់ចុះ មានជើងមិនរពឹស ជាអ្នកគ្រប់គ្រងឥន្ទ្រិយ រក្សាចិត្តទុក (ដោយល្អ) មិនជោកជាំ

ទុតិយំ បច្ចេកពុទ្ធាបទានំ

អនវស្សុតោ អបរិឌយ្ហមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ឱហារយិត្វា(១) គិហិព្យញ្ជនានិ
សញ្ឆិន្នបត្តោ យថា បារិឆត្តោ
កាសាយវត្ថោ អភិនិក្ខមិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
រសេសុ គេធំ(២) អករំ អលោលោ
អនញ្ញបោសី សបទានចារី
កុលេ កុលេ អប្បដិពទ្ធចិត្តោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
បហាយ បញ្ចាវរណានិ ចេតសោ
ឧបក្កិលេសេ ព្យបនុជ្ជ សព្វេ
អនិស្សិតោ ឆេត្វ សិនេហទោសំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

១ ម. ឱហារយិត្វា ។ ២ អដ្ឋកថាយម្បន គេធន្តិ បាឋោ ទិស្សតិ ។



បច្ចេកពុទ្ធាបទាន ទី ២

មិនរោលរាល (ដោយកិលេស) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់នូវភេទគ្រហស្ថ ដូចដើមបារិច្ឆត្តព្រឹក្ស ដែលមានស្លឹកដាច់ហើយ មានសំពត់កាសាយៈ ចេញបួសហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមិនធ្វើនូវសេចក្តីប្រាថ្នា ក្នុងរសទាំងឡាយ ជាអ្នកមិនលោភ មិនចិញ្ចឹមនូវបុគ្គលដទៃ ជាអ្នកត្រាច់ទៅសព្វត្រក មិនជាប់ចិត្ត ក្នុងត្រកូលមួយៗ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់នូវហេតុ ជាគ្រឿងកាង ៥ យ៉ាង របស់ចិត្ត បន្ទោបង់នូវឧបក្កិលេស ទាំងពួង ទាំងមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) កាត់បង់ នូវទោស នៃសេចក្តីស្រឡាញ់ហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គល

វិបិដ្ឋិកត្វាន(១) សុខញ្ច ទុក្ខំ
បុព្វេវ សោមនស្សំ ទោមនស្សំ
លទ្ធានុបេក្ខំ សមថំ(២) វិសុទ្ធំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
អារទ្ធវីរិយោ បរមត្ថបត្តិយា
អលីនចិត្តោ អកុសីតវុត្តិ
ទឡ្ហនិក្កមោ ថាមពលូបបន្នោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
បដិសល្លានំ ឈានមរិញ្ចមានោ
ធម្មេសុ និច្ចំ អនុធម្មចារី
អាទីនវំ សម្មសិតា ភវេសុ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

១ វិសិដ្ឋិកត្វាន ។ ២ បថមំ ។



ធ្វើនូវសុខ ទុក្ខ សោមនស្សនិងទោមនស្ស ក្នុងកាលមុន ឲ្យនៅពីក្រោយខ្នង បាននូវឧបេក្ខាជាសមថៈដ៏ស្អាត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលប្រារព្ធព្យាយាម ដើម្បីដល់នូវព្រះនិព្វាន មានចិត្តមិនរួញរា មានការប្រព្រឹត្តមិនខ្ជិលច្រអូស មានសេចក្តីប្រឹងប្រែងដ៏មាំមួន ប្រកបដោយកម្លាំងកាយនិងកម្លាំងបញ្ញាហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកាលមិនលះបង់នូវឈានដ៏ស្ងប់ស្ងាត់ (ចាកសត្វនិងសង្ខារ) ជាអ្នកប្រព្រឹត្ត នូវធម៌ដ៏សមគួរក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច ពិចារណានូវទោស ក្នុងភពទាំងឡាយហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

## ទុតិយំ បច្ចេកពុទ្ធាបទានំ

តណ្ហក្ខយំ បត្ថយមប្បមត្តោ
អនេឡមូគោ សុតវា សតីមា
សង្ខាតធម្មោ និយតោ បធានវា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
សីហោវ សទ្ទេសុ អសន្តសន្តោ
វាតោវ ជាលម្ហិ អសជ្ជមានោ
បទុមំវ(១) តោយេន អលិម្បមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
សីហោ យថា ទាឋពលី បសយ្ហ
រាជា មិគានំ អភិភុយ្យចារី
សេវេថ បន្តានិ សេនាសនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

១ ម. បទុំវ ។



## បច្ចេកពុទ្ធាបទាន ទី ២

បុគ្គលកាលប្រាថ្នា នូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនល្ងង់ មានការចេះដឹង មានស្មារតី មានធម៌ពិចារណាហើយ ជាបុគ្គលទៀង មានសេចក្តីព្យាយាម គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកាលមិនតក់ស្លុត ក្នុងលក្ខណៈ មានមិនទៀងជាដើម ដូចសីហៈមិនតក់ស្លុត ក្នុងសំឡេងទាំងឡាយ មិនជាប់ជំពាក់ ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ដូចខ្យល់មិនជាប់នឹងសំណាញ់ មិនប្រឡាក់ដោយលោភៈជាដើម ដូចស្លឹកឈូក មិនប្រឡាក់ដោយទឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ សីហៈជាស្តេចសត្វ មានចង្កូមជាកម្លាំង ប្រព្រឹត្តគ្របសង្កត់ កំហែងនូវពួកម្រឹគ យ៉ាងណា បុគ្គលគប់រកនូវសេនាសនៈដ៏ស្ងាត់ ( មានព្រៃជាគ្រឿងកាង ) ក៏យ៉ាងនោះដែរ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឹ
អាសេវមានោ មុទិតញ្ច កាលេ
សព្វេន លោកេន អវិរុជ្ឈមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
រាគញ្ច ទោសញ្ច បហាយ មោហំ
សន្ទាលយិត្វាន សំយោជនានិ
អសន្តសំ ជីវិតសង្ខយម្ហិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ភជន្តិ សេវន្តិ ការណត្ថា
និក្ការណា ទុល្លភា អជ្ជ មិត្តា
អត្តត្ថបញ្ញា អសុចី មនុស្សា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។



បុគ្គលកាលបើសេពនូវមេត្តា ឧបេក្ខា ករុណា វិមុត្តិ មុទិតា ជាហេតុរួចចាកកិលេស ក្នុងកាលដ៏គួរ មិនទទឹងសត្វទាំងលោកទាំងពួង គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់នូវរាគៈផង ទោសៈផង មោហៈផង ហើយទំលាយចេញនូវសំយោជនៈ មិនតក់ស្លុត ក្នុងការអស់ទៅនៃជីវិតហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ពួកជនមានប្រយោជន៍ជាហេតុ ទើបគប់រកផង បម្រើផង ឯពួកមិត្តដែលឥតហេតុ រកបានដោយក្រ ក្នុងថ្ងៃនេះ ឯពួកមនុស្សអ្នកមានបញ្ញា ព្រោះជាប្រយោជន៍ផ្ទាល់ខ្លួន ឈ្មោះថាជាមនុស្សមិនស្អាត បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ពួកព្រះបច្ចេកពុទ្ធ

### ទុតិយំ បច្ចេកពុទ្ធាបទានំ

វិសុទ្ធសីលា សុវិសុទ្ធបញ្ញា
សមាហិតា ជាគរិយានុយុត្តា
វិបស្សកា ធម្មវិសេសទស្សី
មគ្គង្គពោជ្ឈង្គគតេ វិជញ្ញា ។
សុញ្ញប្បណិធិញ្ច តថានិមិត្តំ
អាសេវយិត្វា ជិនសាសនម្ហិ
យេ សាវកត្តំ ន វជន្តិ ធីរា
ភវន្តិ បច្ចេកជិនា សយម្ភូ ។
មហន្តធម្មា ពហុធម្មកាយា
ចិត្តិស្សរា សព្វទុក្ខោឃតិណ្ណា
ឧទគ្គចិត្តា បរមត្ថទស្សី
សីហោបមា ខគ្គវិសាណកប្បា ។



### បច្ចេកពុទ្ធាបទាន ទី ២

មានសីលបរិសុទ្ធ មានប្រាជ្ញាបរិសុទ្ធល្អ មានចិត្ត
តម្កល់មាំ ប្រកបរឿយៗ នូវព្យាយាមជាគ្រឿងភ្ញាក់
រឭក អ្នកពិចារណានូវសង្ខារ ឃើញនូវធម៌វិសេស
ដឹងច្បាស់នូវធម៌ ដែលជាអង្គនៃមគ្គនិងពោជ្ឈង្គ ។
ពួកជនជាអ្នកប្រាជ្ញណា បានសេពនូវសុញ្ញតវិមោក្ខ អប្ប-
ណិហិតវិមោក្ខ និងអនិមិត្តវិមោក្ខ ក្នុងសាសនានៃព្រះ
ជិនស្រីហើយ តែមិនសម្រេច នូវភាពជាសាវ័កទេ
ពួកជនជាអ្នកប្រាជ្ញនោះ តែងបានជាព្រះបច្ចេកពុទ្ធ
ត្រាស់ដឹងឯង ។ ពួកជននោះ ជាអ្នកមានធម៌ដ៏ច្រើន
មានធម្មកាយដ៏សម្បូណ៌ មានចិត្តជាធំ ឆ្លងនូវទុក្ខនិង
ឱឃៈទាំងពួង មានចិត្តខ្ពង់ខ្ពស់ផុត ជាអ្នកឃើញនូវ
ប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន មានឧបមាដូច
សីហៈ (តែងប្រព្រឹត្តតែម្នាក់ឯង) ដូចកុយរមាស ។

សន្តិន្ទ្រិយា សន្តមនា សមាធី

បដ្ឋន្តសត្តេសុ មតិប្បទាក(១)

ហិតា បរត្ថ ឥធ វិជ្ជលន្តា

បច្ចេកពុទ្ធា សតតំហិតា មេ(២) ។

បហីនសព្វាវរណា ជនិន្ទា(៣)

លោកប្បទីបា ឃនកញ្ចនាភា

និស្សំសយំ លោកសុទក្ខិណេយ្យា

បច្ចេកពុទ្ធា សតតប្បិតា មេ ។

បច្ចេកពុទ្ធានំ សុភាសិតានិ

ចរន្តិ លោកម្ហិ សទេវកម្ហិ

សុត្វា តថា យេ ន ករោន្តិ ពាលា

ចរន្តិ ទុក្ខេសុ បុនប្បុនន្តេ ។

---

១ ម. បច្ចត្តគម្ពីរមតប្បទាក ។ ២ ម. សតតំ ហិ តាមេ ។ ៣ ម. ជិនិន្ទ ។



ព្រះបច្ចេកពុទ្ធទាំងឡាយ ជាបុគ្គលមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ស្ងាត់ មានចិត្តជាសមាធិ ប្រព្រឹត្តដោយប្រាជ្ញា ចំពោះសត្វ ក្នុងទីបំផុតដែន ដូចប្រទីបទុះបំភ្លឺ ក្នុងលោកខាងមុខ និងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ដល់ពួកសត្វ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ជាធំជាងជន លះកិលេសជាគ្រឿងរាំង ទាំងពួងហើយ ជាប្រទីបនៃលោក មានរស្មីដូចមាសទុំ ជាទក្ខិណេយ្យបុគ្គលដ៏ល្អ របស់សត្វលោក ដោយឥតសង្ស័យ ជាបុគ្គលសម្រេចដោយនិរោធសមាបត្តិ ជារឿយៗ ។ សុភាសិត របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលប្រព្រឹត្តទៅ ក្នុងមនុស្សលោក ព្រមទាំងទេវលោក ពួកជនពាលណា ស្ដាប់ហើយ តែមិនបានធ្វើតាមសុភាសិត មានសភាពដូច្នោះទេ ពួកជនពាលនោះឯង តែងធ្លាក់ទៅរងទុក្ខទាំងឡាយ រឿយៗ ។

## ទុតិយំ បច្ចេកពុទ្ធាបទានំ

បច្ចេកពុទ្ធានំ សុភាសិតានិ
មធុំ យថា ខុទ្ទមិវស្សវន្តំ
សុត្វា តថា យេ បដិបត្តិយុត្តា
ភវន្តិ សច្ចទសា សបញ្ញា ។
បច្ចេកពុទ្ធេហិ ជិនេហិ ភាសិតា
កថា ឧឡារា អភិនិក្ខមិត្វា
តា សក្យសីហេន នរុត្តមេន
បកាសិតា ធម្មវិជាននត្ថំ ។
លោកានុកម្បាយ ឥមានិ តេសំ
បច្ចេកពុទ្ធាន វិកុព្វិតានិ
សំវេគសង្គមតិវឌ្ឍនត្ថំ
សយម្ភុសីហេន បកាសិតានីតិ ។

បច្ចេកពុទ្ធាបទានំ សមត្តំ ។



## បច្ចេកពុទ្ធាបទាន ទី ២

សុភាសិត របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ផ្អែមល្ហែម ដូចទឹកឃ្មុំដែលហូរចុះ ពួកជនណា បានស្តាប់ ហើយ ប្រកបនូវសេចក្តីប្រតិបត្តិតាមយ៉ាងនោះ ពួកជននោះ ប្រកបដោយប្រាជ្ញា រមែងឃើញនូវសច្ចធម៌ ។ គាថា ទាំងនិទ្ទេសណា ដែលព្រះបច្ចេកពុទ្ធទាំងឡាយ ជាអ្នកឈ្នះកិលេស សម្តែងហើយនោះ ព្រះសម្ពុទ្ធជា សីហៈក្នុងសក្យវង្ស ទ្រង់ខ្ពង់ខ្ពស់ជាងជន ទ្រង់ចេញ បព្វជ្ជាហើយ បានប្រកាសទុក ដើម្បីការដឹងច្បាស់ នូវធម៌ ។ សុភាសិតទាំងនេះ ដែលព្រះបច្ចេកពុទ្ធ ទាំងនោះ សម្តែងផ្សេងៗ គ្នា ដើម្បីអនុគ្រោះដល់ សត្វលោក ព្រះសយម្ភូ ដូចជាសីហៈ ទ្រង់ប្រកាស ទុកហើយ ដើម្បីញ៉ាំងសំវេគធម៌ សង្គហធម៌ និង [illegible]ប្រាជ្ញា ឲ្យចម្រើនឡើង ។

ចប់ បច្ចេកពុទ្ធាបទាន ។

# តតិយំ សារីបុត្តត្ថេរាបទានំ

អថ ថេរាបទានំ សុណាថ

(៣) ហិមវន្តស្ស អវិទូរេ លម្ពកោ នាម បព្វតោ

អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា ។

ឧត្តានកូលា នទិកា សុបតិត្ថា មនោរមា

សុសុទ្ធបុលិនាកិណ្ណា អវិទូរេ មមស្សមំ ។

អសក្ខរា អបព្ភារា សាទុ អប្បដិគន្ធិកា

សន្ទតិ នទិកា តត្ថ សោភយន្តា មមស្សមំ ។

កុម្ភីលា មករា ចេត្ថ សុំសុមារា ច កច្ឆបា

សន្ទន្តិ នទិយា តត្ថ សោភយន្តា មមស្សមំ ។

បាឋីនា បាវុសា មច្ឆា វលជា មុញ្ជរោហិតា

វគ្គុឡា បបតាយន្តិ សោភយន្តា មមស្សមំ ។

ឧភោ កូលេសុ នទិយា បុប្ផិនោ ផលិនោ ទុមា

ឧភតោ អភិលម្ពន្តិ សោភយន្តា មមស្សមំ ។





# សារីបុត្តត្ថេរាបទាន ទី ៣

អ្នកទាំងឡាយចូរស្តាប់ថេរាបទាន ដូចតទៅនេះ

(៣) មានភ្នំមួយ ឈ្មោះលម្ពកៈ នៅក្នុងទីមិនឆ្ងាយអំពីភ្នំហិមពាន្ត គេបានសង់អាស្រម សាងបណ្ណសាលាឲ្យខ្ញុំ ។ ស្ទឹងមានច្រាំងដ៏រាក់ មានកំពង់ល្អ ជាទីគាប់ចិត្ត ដ៏ដេរដាសដោយខ្សាច់ដ៏ស្អាត មានក្នុងទីមិនឆ្ងាយអំពីអាស្រមខ្ញុំ ។ ស្ទឹង (នោះ) មិនមានក្រួសរាន មិនរោត មានទឹកដ៏ឆ្ញាញ់ មិនមានក្លិនអាក្រក់ តែងហូរទៅក្នុងទីនោះ ជាលំអដល់អាស្រមខ្ញុំ ។ មានក្រពើ មករ ត្វាម អណ្តើក ហែលក្នុងស្ទឹងនុ៎ះ ហែលហាលក្នុងស្ទឹងនោះ ជាលំអដល់អាស្រមខ្ញុំ ។ មានត្រីស្លាត ត្រីសណ្តាយ ត្រីក្រាញ់ ត្រីប្រ-ពុលយ ត្រីឆ្ពិន ត្រីឆ្ទឹង តែងហែលឡើងលោតទៅមក ជាលំអដល់អាស្រមខ្ញុំ ។ នៅត្រើយស្ទឹងទាំងសងខាង មានដើមឈើ ដ៏សម្បូណ៌ ដោយផ្កានិងផ្លែសំយុងចុះមកអំពីត្រើយស្ទឹងទាំងសងខាង ជាលំអដល់អាស្រមខ្ញុំ ។

### គាថា សារីបុត្តត្រោបបាន

អម្ពា សាលា ច តិលកា ជាមលី សត្តុការិកា
ទិព្វា គន្ធា(១) សម្បវន្តិ បុប្ផិតា មម អស្សមេ ។
ចម្បកា សលឡា នីបា នាគបុន្នាគកេតកា
ទិព្វា គន្ធា សម្បវន្តិ បុប្ផិតា មម អស្សមេ ។
អតិមុត្តា អសោកា ច ភគិនីមាលា ច បុប្ផិតា
អង្កោលា ពិម្ពិជាលា ច បុប្ផិតា មម អស្សមេ ។
កេតកា កន្ទលី(២) ចេវ គោធុកា តិណសូលិកា
ទិព្វា គន្ធា សម្បវន្តិ(៣) សោភយន្តា(៤) មមស្សមំ ។
ករណិកា កណ្ណិការា ច អសនា អជ្ជុនា ពហូ
ទិព្វា គន្ធា សម្បវន្តិ សោភយន្តា មមស្សមំ ។
បុណ្ណាគ គិរិបុណ្ណាគ(៥) កោវិឡារា ច បុប្ផិតា
ទិព្វា គន្ធា សម្បវន្តិ សោភយន្តា មមស្សមំ ។
ឧទ្ទាលកា ច កុដជា កទម្ពា វកុលា ពហូ
ទិព្វា គន្ធា សម្បវន្តិ សោភយន្តា មមស្សមំ ។
អាឡកា ឥសិមុគ្គា ច កទលី មាតុលុង្គិយោ

១ ម. ទិព្វគន្ធា ។ ២ ម. កន្ទលិ ។ ៣ ម. ទិព្វគន្ធំ សម្បវន្តិ ។ ៤ ម. សោភយន្តិ ។
៥ ម. បុន្នាគា គិរិបុន្នាគា ។



### សារីបុត្តត្រោបបាន ទី ៣

ស្វាយ សាលព្រឹក្ស ដង្កៀបក្តាម ព្រនៀង ឈើភ្លឹង មានផ្ការីក ផ្សាយក្លិនដូចជាទិព្វ ក្នុងអាស្រមខ្ញុំ ។ ចម្បក់ ស្រល់ ក្តុល ខ្ទឹង បុន្នាគ រំចេក មានផ្ការីក ផ្សាយក្លិនដូចជាទិព្វ ក្នុងអាស្រមខ្ញុំ ។ វល្លិ អសោក ធូនស្រី មានផ្ការីក អង្កោល ល្វើតាស មានផ្ការីក ផ្សាយក្លិនទៅក្នុងអាស្រមខ្ញុំ ។ រំចេក ចេក ខ្ញី ម្ទេស ផ្សាយក្លិនដូចជាទិព្វ ក្នុងអាស្រមខ្ញុំ ។ ឈើជាច្រើន គឺកណិកា កណ្ណិការ ខ្លឹង អញ្ចាញ់ ផ្សាយក្លិនដូចជាទិព្វ ជាលំអនៃអាស្រមខ្ញុំ ។ មានព្រូនធារ ព្រូនភ្នំ រលួស មានផ្ការីក ផ្សាយក្លិនដូចជាទិព្វ ជាលំអនៃអាស្រមខ្ញុំ ។ ឈើជាច្រើនយ៉ាង គឺកព្រឹក្ស ក្រូចគន់ ក្ទម ពកុល ផ្សាយក្លិនដូចជាទិព្វ ជាលំអនៃអាស្រមខ្ញុំ ។ អាឡ្ហក-ព្រឹក្ស សណ្ដែកព្រៃហម ចេក ក្រូចថ្លុង ដែលល្អណាស់

ករោ្វនគោធ សំវត្តា ចលាចិ ធារយន្តិ តេ ។
អញ្ញេ បុប្ផន្តិ បទុមា អញ្ញេ ជាយន្តិ កេសរី
អញ្ញេ ឱបុប្ផា បទុមា បុប្ផិតា តឡាកេ(១) តទា ។
តត្តិ កណ្ហាន្តិ បទុមា ធំក្វារន្តិ មុឡាលិយោ
សំឆ្ណាជបត្តមាកិ ព្ភោៈ សោភយន្តិ តឡាកេ តទា ។
នយិតា អម្ពគណ្ឌី ច ឧត្តរាហិ ពន្ធុជីវកា(២)
ធិញ្ញា តច្ចា សម្បវត្តិ បុប្ផិតា តឡាកេ តទា ។
បាឋីនា បាវុសា មច្ឆា វលជា មុញ្ជរោហិតា
សង្គុលា មគ្គុរា ចេវ វសន្តិ តឡាកេ តទា ។
កុម្ភីលា សុំសុមារា ច កច្ឆក្កាហា ច វហុសា
ឱគាហា(៣) អជគរា ច វសន្តិ តឡាកេ តទា ។
បារេវតា(៤) រវិហំសា ចក្កវាកា នទីចរា
កោកិលា សុវសាលិកា ឧបជីវន្តិ តំ សរំ ។
កុក្កុត្ថកា កុឡីរកា វនេ បោក្ខរសាតកា
ទិន្ទិភា សុវបោតា ច ឧបជីវន្តិ តំ សរំ ។

១ ម. តឡាកេ ។ ២ ម. ឧទ្ធលី ពន្ធុជីវកា ។ ៣ ម. ឱគុហា ។ ៤ ម. បារេវតោ ។



ដោយទឹកដ៏មានក្លិន ឈើទាំងនោះទ្រទ្រង់ផ្លែ (ជានិច្ច) ។ ឈូកខ្លះកំពុងផ្កា ខ្លះកំពុងបញ្ចេញកេសរ ខ្លះជម្រុះផ្កា រីកស្គុះស្គាយក្នុងស្រះ ក្នុងកាលនោះ ។ ពួកឈូកកំពុងលេចពន្លក មានក្រអៅ កំពុងល្អតលាស់ ដេរដាសដោយត្រ-បកផ្កាទំនងស្លឹក ល្អក្នុងស្រះ ក្នុងកាលនោះ ។ ផ្កានយិតាផង អម្ពគណ្ឌីផង ឧត្តរាហិផង ពន្ធុជីវកៈផង មានផ្ការីក ផ្សាយក្លិនដូចជាទិព្វ ទៀបស្រះ ក្នុងកាលនោះ ។ ពួកត្រីស្លាក ត្រីសណ្តាយ ត្រីក្រាញ់ ត្រីក្រពុលជាយ ត្រីឆ្ពិន ត្រីចង្វា ត្រីផ្ទក់ នៅក្នុងស្រះ ក្នុងកាលនោះ ។ ក្រពើ ក្តាម កន្ធិត-ហៈ ការក្សចឹក ខ្នោហៈ ស្ថិតនៅក្នុងស្រះ ក្នុងកាលនោះ ។ ព្រាប ព្រហ៊ីត ចាក្រពាក ខ្លែងទឹក តាវ៉េ សេកមៃសាលិកា តែងអាស្រ័យរស់នៅនឹងស្រះនោះ ។ មានបក្សីខ្វែក ក្តាម មាន់ព្រៃ ក្រវិល សេក អាស្រ័យរស់នៅនឹងស្រះនោះ ។

## តតិយំ សារីបុត្តត្ថេរបុច្ឆាគាថា

ហំសា កោញ្ចា មយូរា ច កោកិលា លម្ពចូឡកា[១]
ជម្បុកា[២] ជីវជីវក ច ឧបជីវន្តិ តំ សរំ ។
កោសិកា ពោដ្ឋសីសា ច កុរុក[៣] សេនកា ពហូ
មហាកាឡា ច សកុណា ឧបជីវន្តិ តំ សរំ ។
បសទា មិគា វរាហា ច វកា កោរណ្ឌកា ពហូ
រោហិច្ចា សុន្ទរោហា[៤] ច ឧបជីវន្តិ តំ សរំ ។
សីហា ព្យគ្ឃា ច ទីបី ច អច្ឆកោកតរច្ឆកា[៥]
តិធប្បភិន្នា មាតង្គា ឧបជីវន្តិ តំ សរំ ។
កិន្នរា វានរា ចេវ អថោបិ វនកម្មិកា
ចេតា ច លុទ្ទកា ចេវ ឧបជីវន្តិ តំ សរំ ។
តិន្ទុកានិ បិយាលានិ មធុកា[៦] កាសុមារិយោ
ធុវំ ផលានិ ធារេន្តិ អវិទូរេ មមស្សមំ ។
កោសុម្ភា សលឡា និម្ពា សាទុផលសមាយុតា[៧]
ធុវំ ផលានិ ធារេន្តិ អវិទូរេ មមស្សមំ ។

---

១ ម. គម្ពូឡកា ។ ២ ម. ជម្ពុកា ។ ៣ ម. កុរុរា ។ ៤ ប. សុក្ករោហា ។ ៥ ប. តរច្ឆកា ។
៦ ម. មធុកោ ។ ៧ ម. និម្ពា សាទុផលសមាយុតា ។



## សារីបុត្តត្ថេរបុច្ឆាគាថាទី ៣

ពួកបក្សី គឺ ហង្ស ក្រៀល ក្ងោក តាវ៉ៅ មាន់ទោ ចាក្លៀលខ្សូន ក្ដុលកោក តែងអាស្រ័យរស់នៅទីនិស្រ័យនោះ ។ ពួកបក្សីជាច្រើន គឺ មៀម ខ្វែនស្រាក លលក ខ្វែន អន្ទក់ខ្មៅ តែងអាស្រ័យរស់នៅទីនិស្រ័យនោះ ។ ពួកម្រឹគជាច្រើនគឺ បសទម្រឹគ ជ្រូក ឆ្កែព្រៃ ឆ្មាំង ប្រើស រមាស តែងអាស្រ័យរស់នៅទីនិស្រ័យនោះ ។ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លាត្រី ដំរីចុះប្រេង តែងអាស្រ័យរស់នៅទីនិស្រ័យនោះ ។ ពួកកិន្នរ ពានរ ឬពួកមនុស្សអ្នកធ្វើការក្នុងព្រៃ មនុស្សអ្នកបម្រើ ព្រានព្រៃ តែងអាស្រ័យរស់នៅទីនិស្រ័យនោះ ។ ដើមទន្លាប់ ដើមទន្លា ដើមស្រគម ពង្រ ព្រៀងដែលតែងមានផ្លែអស់កាលជានិច្ច ក្នុងទីមិនឆ្ងាយអំពីអាស្រមខ្ញុំ ។ ដើមស្រល ដើមស្រល់ ដើមក្តុម ប្រកបដោយផ្អែមនិងផ្លែ តែងទ្រទ្រង់ផ្លែជានិច្ច ក្នុងទីមិនឆ្ងាយអំពីអាស្រមខ្ញុំ ។ ដើម

ហរីតកា អាមលកា អម្ពា ជម្ពូ វិភេដកា
កោលា ភល្លាតកា ពិល្លា ផលានិ ធារយន្តិ តេ ។
អាលុវ ច កលម្ពា ច ពិឡាលិតក្កឡានិ ច
ជីវកា សុត្តកា ចេវ ពហុកា មម អស្សមេ ។
អស្សមស្សាវិទូរម្ហិ តឡាកាសុំ(១) សុនិម្មិតា
អច្ឆោទកា សីតជលា សុបតិត្ថា មនោរមា ។
បទុមុប្បលសញ្ឆន្នា បុណ្ឌរីកសមាយុតា
មន្ទាលកេហិ សញ្ឆន្នា ទិព្វោ គន្ធោ បវាយតិ ។
ឯវំ សព្វង្គសម្បន្នេ បុប្ផិតេ ផលិតេ វនេ
សុកតេ អស្សមេ រម្មេ វិហរាមិ អហំ តទា ។
សីលវា វតសម្បន្នោ ឈាយី ឈានរតោ សទា
បញ្ចាភិញ្ញាពលប្បត្តោ សុរុចិ នាម តាបសោ ។
ចតុវីសសហស្សានិ សិស្សា មយ្ហំ ឧបដ្ឋហុំ
សព្វេវ ព្រាហ្មណា ឯតេ ជាតិមន្តោ យសស្សិនោ ។

---
១ ម. តឡ្លាកាសុំ ។



សម៉ កន្ទុតព្រៃ ស្វាយ ព្រីង សម៉ពិភេទក៍ ស្តៅ កក់ខ្មៅ ព្នៅ កើតព្រមព្រៀងផ្លែជាចង្កោម ។ ដំឡូងស្រែ ដំឡូងដូង ដំឡូងដៃខ្លា ទាំងដំឡូងឈាមមាន់ ចាំងឈើជាជួរ ក៏មានច្រើននៅជិតអាស្រមខ្ញុំ ។ ស្រះដែលធម្មជាតិនិម្មិតល្អហើយ ក៏មាននៅក្បែរមិនឆ្ងាយអំពីអាស្រមខ្ញុំ មានទឹកថ្លា មានទឹកត្រជាក់ មានកំពង់ងូតទឹកល្អ គួរជាទីរីករាយចិត្ត ។ ស្រះនោះសឹងដេរដាសដោយឈូកនិងឧប្បល ប្រកបដោយឈូកស ព្រោងព្រាតដោយស្ពួន មានក្លិនផ្កាជាទិព្វ រមែងផ្សាយទៅ ។ កាលនោះ ខ្ញុំកើតនៅក្នុងអាស្រមជាទីត្រេកអរ ដែលធម្មជាតិច្នៃល្អហើយ ក្នុងព្រៃដែលមានផ្កាមានផ្លែ បរិបូណ៌ដោយអង្គគ្រប់សព្វ យ៉ាងនេះ ។ ខ្ញុំជាតាបស ឈ្មោះសុរុចិ ជាអ្នកមានសីល បរិបូណ៌ដោយវត្ត មានឈាន ត្រេកអរក្នុងឈាន ដល់នូវកម្លាំងនៃអភិញ្ញា ទាំង ៥ គ្រប់កាលទាំងពួង ។ ពួកព្រាហ្មណ៍ទាំងអស់នុ៎ះ ជាសិស្សរបស់ខ្ញុំ ចំនួន ២៤ ពាន់នាក់ ជាអ្នកមានជាតិមានយស នៅបម្រើខ្ញុំ ។

លក្ខណេ ឥតិហាសេ ច   សនិឃណ្ឌុសកេដុភេ
បទកា វេយ្យាករណា   សធម្មេ បារមឹ គតា ។
ឧប្បាតេសុ និមិត្តេសុ   លក្ខណេសុ ច កោវិទា
បថព្យា ភុម្មន្តលិក្ខេ   មម សិស្សា សុសិក្ខិតា ។
អប្បិច្ឆា និបកា ធីរា   អប្បាហារា អលោលុបា
លាភាលាភេន សន្តុដ្ឋា   បរិវេន្តិ មំ សទា ។
ឈាយី ឈានរតា ធីរា   សន្តចិត្តា សមាហិតា
អាកិញ្ចញ្ញំ បត្ថយន្តា   បរិវេន្តិ មំ សទា ។
អភិញ្ញាបារមិប្បត្តា   បេត្តិកេ គោចរេ រតា
អន្តលិក្ខចរា ធីរា   បរិវេន្តិ មំ សទា ។
សំវុតា ឆសុ ទ្វារេសុ   អនេជ្ជា រក្ខិតិន្ទ្រិយា
អសំសដ្ឋា ច តេ ធីរា   មម សិស្សា ទុរាសទា ។





(ពួកព្រាហ្មណ៍ទាំងនោះ) ជាអ្នកចេះចប់ ចេះវេយ្យាករណ៍ ដល់នូវត្រើយនៃវេទ ក្នុងសទ្ធម្ម គឺលក្ខណសាស្ត្រ ឥតិហា-សសាស្ត្រ ព្រមទាំងនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ។ ពួកសិស្សរបស់ខ្ញុំ ជាអ្នកឈ្លាសវៃក្នុងឧប្បាត ក្នុងនិមិត្តនិងលក្ខណៈទាំងឡាយ បានសិក្សាល្អក្នុងផែនដី ក្នុងទី ក្នុងអាកាស ។ ពួកសិស្សទាំងនុ៎ះ ជាអ្នកប្រាថ្នាតិច មានប្រាជ្ញាខ្ជាប់ខ្ជួន មានអាហារតិច មិនល្មោភ សន្តោសដោយលាភ និងឥតលាភ តែងចោមរោមខ្ញុំសព្វកាល ។ ពួកសិស្សទាំងនុ៎ះ ជាអ្នកប្រាជ្ញ មានឈាន ត្រេកអរក្នុងឈាន មានចិត្តស្ងប់ស្ងៀម មានសមាធិ ប្រាថ្នានូវការមិនមានកង្វល់ តែងចោមរោមខ្ញុំសព្វកាល ។ ពួកសិស្សទាំងនុ៎ះ ជាអ្នកប្រាជ្ញ ដល់នូវត្រើយនៃអភិញ្ញា ត្រេកអរក្នុងគោចរ ជារបស់នៃបិតា ត្រាច់ទៅក្នុងអាកាសបាន តែងចោមរោមខ្ញុំសព្វកាល ។ ពួកសិស្សខ្ញុំនោះ ជាអ្នកប្រាជ្ញ សង្រួមក្នុងទ្វារ ៦ មិនមានតណ្ហាជាគ្រឿងញាប់ញ័រ មានឥន្ទ្រិយរក្សាហើយ មិនច្រឡូកច្រឡំ (ដោយពួកគណៈ) ដែលគេគ្របសង្កត់បានដោយក្រ ។

បល្លង្កេន និសជ្ជាយ ឋានចង្កមនេន ច
វីតិនាមេន្តិ តេ រត្តិំ មម សិស្សា ទុរាសទា ។
រជ្ជនីយេ ន រជ្ជន្តិ ទោសនីយេ ន ទុស្សរេ
មោហនីយេ ន មុយ្ហន្តិ មម សិស្សា ទុរាសទា ។
ឥទ្ធី វីមំសមានា តេ វត្តន្តិ និច្ចកាលិកំ
បឋវី តេ បកម្បេន្តិ សារម្ភេន ទុរាសទា ។
កីឡមានា តេ សិស្សា កីឡន្តិ ឈានកីឡិតំ
ជម្ពុតោ ផលមានេន្តិ មម សិស្សា ទុរាសទា ។
អញ្ញេ គច្ឆន្តិ គោយានំ អញ្ញេ បុព្វវិទេហកំ
អញ្ញេ ច ឧត្តរកុរុំ មម សិស្សា ទុរាសទា(១) ។
បុរតោ បេសេន្តិ តេ ខារឹ បច្ឆតោ ច វជន្តិ តេ
ចតុទ្ទសសហស្សេហិ ឆាទិតំ ហោតិ អម្ពរំ ។

---
១ ម. ឯសនាយ ទុរាសទាយ ។



ពួកសិស្សរបស់ខ្ញុំទាំងនោះ ដែលគេគ្រប់សង្កត់បានដោយក្រ រមែងញាំងរាត្រីឲ្យកន្លងទៅ ដោយការអង្គុយផ្គត់ភ្នែន ការឈរនិងការចង្ក្រម ។ ពួកសិស្សរបស់ខ្ញុំ ដែលគេគ្រប់សង្កត់បានដោយក្រ រមែងមិនត្រេកត្រអាល ក្នុងអារម្មណ៍ ដែលគួរត្រេកអរ មិនទាស់ក្នុងអារម្មណ៍ដែលគួរទាស់ មិនវង្វេងក្នុងអារម្មណ៍ដែលគួរវង្វេង ។ ពួកសិស្សទាំងនោះ កាលល្បងមើលឫទ្ធិ រមែងប្រព្រឹត្តអស់កាលជានិច្ច ពួកសិស្សទាំងនោះ តែងញាំងផែនដីឲ្យញាប់ញ័រ ជាបុគ្គលដែលគេមិនងាយគ្រប់សង្កត់បាន ដោយការប្រណាំងប្រជែង ។ ពួកសិស្សទាំងនោះ កាលលេងល្បែង រមែងលេងនូវកីឡាឈាន តែងយកផ្លែព្រីងអំពីដើមព្រីង ពួកសិស្សរបស់ខ្ញុំ ជាបុគ្គលដែលគេគ្រប់សង្កត់បានដោយក្រ ។ ពួកខ្លះទៅគោយានទ្វីប ពួកខ្លះទៅបុព្វវិទេហទ្វីប ពួកខ្លះទៅកាន់ឧត្តរកុរុទ្វីប ពួកសិស្សខ្ញុំ គេគ្រប់សង្កត់បានដោយក្រ ។ ពួកសិស្សទាំងនោះ រមែងបញ្ជូនខ្សែអង្រែកទៅមុខ ពួកសិស្សទាំងនោះ រមែងទៅខាងក្រោយ ទាំងផ្ទៃអាកាសក៏សឹងតែបិទបាំង ដោយពួកតាបស ១៤ ពាន់រូប ។

អគ្គិហាកី(១) អនគ្គី ច  ទន្តោទុក្ខលិកាបិ ច
អស្មេន កោដ្ដិតា កេចិ  បវត្តផលភោជនា ។
ឧទកោរោហណា កេចិ  សាយំ បាតោ សុចីរតា
តោយាភិសេចនករា  មម សិស្សា តបស្សិនោ ។
បរូឡ្ហកច្ឆនខលោមា  បង្កទន្តា រជស្សិរា
គន្ធិតា សីលគន្ធេន  មម សិស្សា តបស្សិនោ ។
បាតោវ សន្និបតិត្វា  ជដិលា ឧគ្គតាបនា
លាភាលាភំ បកិត្តេន្តា  គច្ឆន្តិ អម្ពរេ តទា ។
ឯតេសំ បក្កមន្តានំ  មហាសទ្ទោ បវត្តតិ
អជិនចម្មសទ្ទេន  មោទិតា ហោន្តិ ទេវតា ។
ទិសោទិសំ បក្កមន្តិ  អន្តលិក្ខចរា ឥសី
សកេ ពលេនុបត្ថទ្ធា  តេ គច្ឆន្តិ យទិច្ឆិតំ(២) ។

១ ម. អគ្គិបាកី ។ ២ ម. យទិច្ឆកំ ។



(ពួកសិស្សរបស់ខ្ញុំទ្រទ្រង់អាហារ) ផ្លែឈើដែលចំអិនដោយភ្លើង (ទ្រទ្រង់អាហារ) ផ្លែឈើមិនបានចំអិនដោយភ្លើង ខ្លះទំពាដោយធ្មេញ ខ្លះបុកក្នុងត្បាល់ ខ្លះបំបែកដោយថ្ម ខ្លះបរិភោគផ្លែឈើជ្រុះឯង ។ ពួកខ្លះទៀត ចុះត្រាំទឹក ក្នុងវេលាល្ងាចព្រឹក ជាអ្នកត្រេកអរ ក្នុងអំពើដ៏ស្អាត ប្រព្រឹត្តស្រោចស្រប់ដោយទឹក ពួកសិស្សរបស់ខ្ញុំ គេត្រូវសង្កត់បានដោយព្រត ។ ជាអ្នកមានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញ ប្រឡាក់ដោយមន្ទិល មានក្បាលប្រឡាក់ដោយធូលី ក្រអូបដោយក្លិននៃសីល ពួកសិស្សរបស់ខ្ញុំ គេត្រូវសង្កត់បានដោយព្រត ។ ពួកជដិល ប្រជុំគ្នាក្នុងវេលាព្រឹក មានតបៈដ៏ខ្លាំង សម្តែងនូវលាភនិងមិនលាភក្តី ហើយទៅក្នុងអាកាស ក្នុងកាលនោះ ។ កាលពួកតាបសទាំងនុ៎ះ ចៀសចេញទៅ សូរសព្ទដ៏ធំ ក៏លាន់ឮឡើង ពួកទេវតាត្រេកអរ ដោយសូរសព្ទស្បែកខ្លា (របស់ពួកតាបសទាំងនោះ) ។ ពួកឥសីជាអ្នកត្រាច់ទៅក្នុងអាកាស តែងចេញទៅកាន់ទិសតូចទិសធំ ឥសីទាំងនោះ ជាអ្នកទីពឹងដោយកម្លាំងរបស់ខ្លួន ទៅកាន់ទីតាមប្រាថ្នា ។

បថវីកម្បកា ឯតេ  សព្វេ នភចារិនោ
ឧគ្គតេជា ទុប្បសហា  សាគរោវ អកោភិយា ។
ឋានចង្កមិយា កេចិ  កេចិ នេសជ្ជិកា ឥសី
បវត្តភោជនា កេចិ  មម សិស្សា ទុរាសទា ។
មេត្តាវិហារិនោ ឯតេ  ហិតេសី សព្វបាណិនំ
អនុក្កំសកា សព្វេ  ន តេ វម្ភេន្តិ កស្សចិ ។
សីហរាជាវសម្ភីតា  គជរាជាវ ថាមវា
ទុរាសទា ព្យគ្ឃាវ  អាគច្ឆន្តិ មមន្តិកេ ។
វិជ្ជាធរា ទេវតា ច  នាគគន្ធព្វរក្ខសា
កុម្ភណ្ឌា ទានវា គរុឡា  ឧបជីវន្តិ តំ សរំ ។
តេ ជដាខារិភរិតា  អជិនុត្តរវាសនា
អន្តលិក្ខចរា សព្វេ  ឧបជីវន្តិ តំ សរំ ។



ពួកឥសីទាំងអស់នុ៎ះឯង ជាអ្នកញុំាងផែនដីឲ្យកម្រើក ក្រាប់ទៅកាន់អាកាស ជាអ្នកមានតេជះខ្លាំង គេគ្រប់សង្កត់បានដោយក្រ មិនញាប់ញ័រ ប្រៀបដូចសាគរ ។ ពួកខ្លះជាអ្នកកាន់វត្តឈរចង្រ្កម ពួកខ្លះទៀតកាន់វត្តអង្គុយ ពួកខ្លះបរិភោគផ្លែឈើដែលជ្រុះឯង ពួកសិស្សខ្ញុំ គេគ្រប់សង្កត់បានដោយក្រ ។ ពួកឥសីទាំងនុ៎ះ ជាអ្នកនៅដោយមេត្តាធម៌ ជាអ្នកស្វែងរកប្រយោជន៍ ដល់ពួកសត្វទាំងពួង ពួកឥសីទាំងអស់នោះ ជាអ្នកមិនលើកខ្លួនឯង មិនបង្អាប់បុគ្គលណាមួយ ។ ពួកឥសីទាំងនោះ ជាអ្នកមិនញាប់ញ័រដូចស្តេចសីហៈ មានកម្លាំងដូចស្តេចដំរី ឬដូចខ្លាធំ ដែលគេគ្រប់សង្កត់បានដោយក្រ រមែងមកកាន់ទីជិតនៃខ្ញុំជានិច្ច ។ ពួកវិជ្ជាធរទេវតា នាគ គន្ធព្វ រាក្សស កុម្ភណ្ឌ អសុរ គ្រុឌ ក៏មកអាស្រ័យរស់នៅទីស្រះនោះ ។ ពួកឥសីទាំងនោះ ជាអ្នកទ្រទ្រង់ផ្នួងសក់និងបរិក្ខារ ស្លៀកដណ្តប់នូវសំពត់ ដែលធ្វើដោយស្បែកខ្លា អាចក្រាប់ទៅកាន់អាកាសបាន ក៏មកអាស្រ័យរស់នៅទីស្រះនោះ ។

## តតិយំ សារីបុត្តត្ថេរាបទានំ

តលាទុជ្ជវិតា ឋិតេ អញ្ញមញ្ញំ សគារវា
ចតុត្តិំសសហស្សានំ ទិត្តសន្តោ(១) ន វិជ្ជតិ ។
ចាគេ ចាគឹ ធិតិប្បត្តា អប្បសទ្ទា សុសំវុតា
ឧបសង្កម្ម សព្ពេ តេ(២) សិរសា វន្ទរេ មមំ ។
តេហិ សិស្សេហិ បរិវុតោ សន្តេហិ ច តបស្សិភិ
វសាមិ អស្សមេ តត្ថ ឈាយី ឈានរតោ អហំ ។
ឥសីនំ សីលគន្ធេន បុប្ផគន្ធេន ចូភយំ
ផលីនំ ផលគន្ធេន គន្ធិតោ ហោតិ អស្សមោ ។
រត្តិន្ទិវំ ន ជានាមិ អរតិ មេ ន វិជ្ជតិ
សកេ សិស្សេ ឱវទន្តោ ភិយ្យោ ហាសំ លភាមហំ ។
បុប្ផានំ បុប្ផមានានំ ផលានញ្ច វិបច្ចតំ
ទិព្វា គន្ធា បវាយន្តិ សោភយន្តា មមស្សមំ ។
សមាធិម្ហា វុដ្ឋហិត្វា អាតាបី និបកោ អហំ
ខារិភារំ គហេត្វាន វនំ អជ្ឈោគហំ អហំ ។

១ ម. វិបិសន្តោ ។ ២ ម. សព្វេ ។



## សារីបុត្តត្ថេរាបទាន ទី ៣

ពួកឥសីទាំងនុ៎ះ មានការប្រព្រឹត្តិដ៏សមគួរ ប្រកបដោយសេចក្តីគោរពដល់គ្នានិងគ្នា ទាំងសំដីប្រកោះរកគ្នារបស់ពួកឥសីទាំង ៤៤ ពាន់រូប ក៏មិនមានក្នុងកាលនោះ ។ ពួកឥសីទាំងអស់នោះ កាលនឹងដាក់ជើងក្នុងពេលឈានជើង មានសំឡេងតិច ៗ ស្ងៀមដោយល្អ ចូលមកជិតថ្វាយបង្គំខ្ញុំដោយត្បូង ។ ខ្ញុំមានឈាន ត្រេកអរក្នុងឈាន ត្រូវពួកសិស្សទាំងនោះ ដែលជាអ្នកស្ងប់ មានតបៈហោមរោមហើយ នៅក្នុងអាស្រមនោះ ។ អាស្រមក្រអូបដោយក្លិនរបស់ពួកឥសី និងក្លិនទាំងពីរ គឺ ក្លិនផ្កា និងក្លិនផ្លែឈើ របស់ឈើដែលមានផ្លែ ។ ខ្ញុំមិនស្គាល់យប់ថ្ងៃ ខ្ញុំមិនមានសេចក្តីអផ្សុក ខ្ញុំកាលទូន្មានពួកសិស្សរបស់ខ្ញុំ តែងបាននូវសេចក្តីរីករាយយ៉ាងក្រៃលែង ។ ក្លិនទាំងឡាយ របស់ផ្កាឈើ ដែលកំពុងផ្កានិងផ្លែ ដែលកំពុងទុំ ក៏មានក្លិនដូចជាទិព្វ រមែងផ្សព្វផ្សាយទៅ ញ៉ាំងអាស្រមរបស់ខ្ញុំឲ្យរុងរឿង ។ ខ្ញុំជាអ្នកមានព្យាយាមដុតកិលេស មានបញ្ញាខ្ជាប់ខ្ជួន ចេញអំពីសមាធិហើយ តែងកាន់យកខ្នូរភារៈ គឺអង្រែក ដើរទៅក្នុងព្រៃ ។

ឧប្បាតេ សុបិនេ ចាបិ លក្ខណេសុ សុសិក្ខិតោ
បវត្តមានំ មន្តបទំ ធារយាមិ អហំ តទា ។
អនោមទស្សី ភគវា លោកជេដ្ឋោ នរាសភោ
វិវេកកាមោ សម្ពុទ្ធោ ហិមវន្តំ ឧបាគមិ ។
អជ្ឈោគាហេត្វា ហិមវន្តំ អគ្គោ ការុណិកោ មុនិ
បល្លង្កំ អាភុជិត្វាន និសីទិ បុរិសុត្តមោ ។
តមទ្ទសាហំ សម្ពុទ្ធំ សប្បភាសំ មនោរមំ
ឥន្ទីវរំ ជលិតំ អាទិត្តំ ហុតាសនំ ។
ជលន្តំ ទីបរុក្ខំវ វិជ្ជុំ គគណេ យថា
សុផុល្លំ សាលរាជំវ អទ្ទសំ លោកនាយកំ ។
អយំ នាគោ មហាវីរោ ទុក្ខស្សន្តករោ មុនិ
ឥមំ ទស្សនមាគម្ម សព្វទុក្ខា បមុច្ចរេ ។
ទិស្វានាហំ ទេវទេវំ លក្ខណំ ឧបធារយិំ



ខ្ញុំជាអ្នកសិក្សាល្អហើយ ក្នុងឧប្បាត យល់សប្តិនិងលក្ខណៈទាំងឡាយ ទ្រទ្រង់នូវបទមន្តដែលគេនិយម ក្នុងកាលនោះ ។ ព្រះសម្ពុទ្ធនាមអនោមទស្សី ជាច្បងក្នុងលោក ជានរាសភៈ ទ្រង់ត្រេកអរក្នុងវិវេកធម៌ បានស្តេចមកកាន់ហិមវន្តប្រទេស ។ លុះព្រះមុនីដ៏ខ្ពង់ខ្ពស់ ប្រកបដោយករុណា ជាបុរសដ៏ឧត្តម ស្តេចចូលមកកាន់ហិមវន្តប្រទេសហើយ ទ្រង់គង់ផ្គត់ព្រះភ្លៅ (ទៀបអាស្រមរបស់ខ្ញុំ) ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធនោះប្រកបដោយរស្មី ជាទីត្រេកអរនៃចិត្ត រុងរឿងដូចផ្កាកជព្រឹក្ស ឬក៏ដូចគំនរភ្លើងនេះ ឆ្លុះត្រៀងយ៉ាញដែលគេមុត ។ លុះខ្ញុំបានឃើញព្រះសម្ពុទ្ធ ជានាយកនៃលោក ព្រះអង្គរុងរឿង ដូចដើមឈើប្រទាំងទីប ឬដូចផ្លេកបន្ទោរក្នុងអាកាស ឬក៏ដូចសាលព្រឹក្សមានផ្ការីកដ៏ល្អ ។ ខ្ញុំគិតថា ព្រះមុនីដ៏ប្រសើរនេះ ជាមហាវីរបុរស ទ្រង់ធ្វើនូវទីបំផុតទុក្ខ បុគ្គលអាស្រ័យការឃើញនេះ រមែងរួចចាកទុក្ខទាំងពួង ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធ ជាទេវតារបស់ទេវតាហើយ ក៏ពិនិត្យ

ពុទ្ធោ នុ ខោ ឯស ពុទ្ធោ ហន្ទ បស្សាមិ ចក្ខុមំ ។

សហស្សារានិ ចក្កានិ ទិស្សន្តិ ចរណុត្តមេ

លក្ខណានិស្ស ទិស្សន្តិ និដ្ឋំ គញ្ឆឹ តថាគតេ ។

សម្មជ្ជនឹ គហេត្វាន សម្មជ្ជិត្វាន តទា

អដ្ឋ បុប្ផេ សមានេត្វា ពុទ្ធសេដ្ឋំ អបូជយឹ ។

បូជយិត្វាន តំ ពុទ្ធំ ឱយតិណ្ណមជាសរឹ

ឯកំសំ អជិនំ កត្វា នមស្សឹ លោកនាយកំ ។

យេន ញាណេន សម្ពុទ្ធោ វិហរតិ អនាសវោ

តំ ញាណំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

សមុទ្ធរសិមំ លោកំ សយម្ភូ អមិតោទយ

តវ ទស្សនមាគម្ម កង្ខាសោតំ តរន្តិ តេ ។



មើលលក្ខណៈថា ព្រះពុទ្ធមែនឬហ្ន៎ ឬក៏មិនមែនជាព្រះពុទ្ធទេ
អេះ បើដូច្នោះ អាត្មាអញនឹងសង្កេតមើល នូវព្រះសម្ពុទ្ធព្រះ
អង្គមានចក្ខុ ។ ចក្រទាំងឡាយមានកាំមួយពាន់ ក៏ប្រាកដ
ក្នុងផ្ទៃព្រះបាទាដ៏ប្រសើរ លុះខ្ញុំឃើញលក្ខណៈ របស់ព្រះ
សម្ពុទ្ធនោះហើយ ក៏ដល់នូវសេចក្ដីចូលចិត្ត ចំពោះព្រះតថា-
គត ។ ក្នុងគ្រានោះ ខ្ញុំបាច់យកអំបោស មកបោសលំនៅ
រួចហើយប្រមូលយកផ្កា ៨ ក្ដាប់មកបូជា ចំពោះព្រះសម្ពុទ្ធដ៏
ប្រសើរ ។ លុះខ្ញុំបូជាចំពោះព្រះពុទ្ធអង្គនោះ ជាបុគ្គលទុន
ទយៈ មិនមានអាសវៈហើយ ទើបធ្វើនូវស្បែកខ្លាឆៀងស្មា
ម្ខាង រួចនមស្ការចំពោះព្រះសម្ពុទ្ធ ជានាយកនៃសត្វលោក ។
ព្រះសម្ពុទ្ធ ព្រះអង្គមិនមានអាសវៈ សម្រេចនៅដោយញាណ
ណា ខ្ញុំនឹងសម្ដែងនូវញាណរបស់ព្រះអង្គនោះ សូមអ្នកទាំង
ឡាយស្ដាប់ខ្ញុំសម្ដែងចុះ ។ បពិត្រព្រះអង្គ ជាព្រះសយម្ភូ
មានករុណាមិនមានប្រមាណ សូមព្រះអង្គស្រង់សត្វលោក
នេះឲ្យបាន ព្រោះពួកសត្វ ទាំងនោះឆ្លងនូវខ្សែទឹក គឺសេចក្ដី
សង្ស័យបាន ព្រោះអាស្រ័យនូវការចួបប្រទះនឹងព្រះអង្គ ។

តុំ សត្ថា ច កេតុ ច  ធជោ យូបោ ច ចាណំ
បរាយនោ បតិដ្ឋា ច  ទីបោ ច ទិបទុត្តមោ ។
សក្កា សមុទ្ទេ ឧទកំ  បមេតុំ អាឡ្ហកេន វា
ន ត្វេវ តវ សព្វញ្ញុ-  ញាណំ សក្កា បមេតវេ(១)។
ធារេតុំ បឋវឹ សក្កា  ឋបេត្វា តុលមណ្ឌលេ
ន ត្វេវ តវ សព្វញ្ញុ-  ញាណំ សក្កា បមេតវេ ។
អាកាសំ មិនិតុំ(២) សក្កា  រជ្ជុយា អង្គុលេន វា
ន ត្វេវ តវ សព្វញ្ញុ-  ញាណំ សក្កា បមេតវេ ។
មហាសមុទ្ទេ ឧទកំ  បឋវីញ្ចាខិលញ្ជហេ(៣)
ពុទ្ធញ្ញាណំ ឧបាទាយ  ឧបមាតោ ន យុជ្ជរេ ។
សទេវកស្ស លោកស្ស  ចិត្តំ យេសំ បវត្តតិ
អន្តោជាលិកតា ឯតេ  តវ ញាណម្ហិ ចក្ខុម ។

១ ម. បមេតយេ ។ ២ ម. អាកាសោ មិនិតុំ ។ ៣ ម. បឋវីញ្ចាខិលំ ។



ព្រះអង្គជាសាស្តាផងដែរ ទុកដូចជាទង់ផង ដូចជាទង់ជ័យផង ដូចជាប្រាសាទរបស់ពួកសត្វ ព្រះអង្គជាអ្នកដឹកនាំផង ជាទីពឹងផង ជាគុំពារផង ជាបុគ្គលប្រសើរជាងសត្វជើងពីរផង ។ ទឹកក្នុងសមុទ្រគេអាចវាល់ដោយអាឡ្ហកៈបាន សព្វញ្ញុតញ្ញាណរបស់ព្រះអង្គ គេមិនអាចវាល់បានឡើយ ។ គេអាចដាក់ដីក្នុងបណ្តាលនៃជញ្ជីង ហើយថ្លឹងបាន ឯសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ គេមិនអាចនឹងថ្លឹងបានឡើយ ។ គេអាចវាស់អាកាសដោយខ្សែ ឬដោយម្រាមដៃបាន ឯសព្វញ្ញុតញ្ញាណ របស់ព្រះអង្គ គេមិនអាចនឹងវាស់បានឡើយ ។ បុគ្គលគប្បីធ្វើទឹកក្នុងមហាសមុទ្រ និងផែនដី ឲ្យស្មើបាន តែមិនគប្បីយកពុទ្ធញ្ញាណ មកប្រៀបដោយឧបមាបានឡើយ ។ ចិត្តរបស់សត្វទាំងឡាយណា ប្រព្រឹត្តទៅក្នុងលោក ព្រមទាំងទេវលោក បពិត្រព្រះអង្គមានចក្ខុ សត្វទាំងឡាយនុ៎ះ តាំងនៅខាងក្នុងនៃសំណាញ់ញាណ របស់ព្រះអង្គ ។

### តតិយំ សារីបុត្តត្ថេរាបទានំ

យេន ញាណេន បត្តោសិ កេវលំ ពោធិមុត្តមំ
តេន ញាណេន សព្វញ្ញូ មទ្ទសិ បរតិត្ថិយេ ។
ឥមា គាថា ថោមេត្វាន សុរុចិ នាម តាបសោ
អជិនំ បត្ថរិត្វាន បថវិយំ និសីទិ សោ ។
ចុល្លាសីតិសហស្សានិ អជ្ឈោគាឡ្ហោ មហណ្ណវេ
អច្ចុគ្គតោ តាវទេវ គិរិរាជា បវុច្ចតិ ។
តាវ អច្ចុគ្គតោ នេរុ អាយតោ វិត្ថតោ ច សោ
ចុណ្ណិតោ សង្ខ្យាភេទេន(១) កោដិសតសហស្សិយោ ។
លក្ខេ ឋបិយមានម្ហិ បរិក្ខយមគច្ឆថ
ន ត្វេវ តវ សព្វញ្ញុ- ញាណំ សក្កា បមេតវេ ។
សុខុមច្ឆិកេន ជាលេន ឧទកំ យោ បរិក្ខិបេ
យេ កេចិ ឧទកេ បាណា អន្តោជាលីកតា សិយុំ ។

១ ឱ. អនុភាគេន ។



### សារីបុត្តត្ថេរាបទាន ទី ៣

ព្រះអង្គបានដល់ នូវពោធិញ្ញាណដ៏ឧត្តម ដោយសព្វគ្រប់ ដោយញាណណា បពិត្រព្រះសព្វញ្ញូ ព្រះអង្គរមែងញាំញី តិរ្ថិយផង ដោយញាណនោះ ។ តាបសឈ្មោះសុរុចិនោះ សរសើរដោយគាថាទាំងនេះហើយ ក៏ក្រាលនូវស្បែកខ្លា ហើយអង្គុយលើផែនដី ។ ភ្នំដែលលិចចុះទៅក្នុងមហាសមុទ្រ អស់ប្រមាណ ៨៤ ម៉ឺន ៤ ពាន់យោជន៍ ខ្ពស់ឡើងកំពុំណោះដែរ គេហៅថាស្តេចភ្នំ ។ កំពស់ក្តី បណ្តោយក្តី ទទឹងក្តី នៃភ្នំសិនេរុនោះ មានប្រមាណមួយសែនកោដិយោជន៍ ដោយចំណែកនៃការរាប់ដ៏ល្អិត ។ ភ្នំដែលគេកាត់ទុក ភ្នំនោះក៏ដល់នូវការអស់ទៅ ឯសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ គេមិនអាចរាប់បានឡើយ ។ បុគ្គលណាក៏ដោយគ្របទឹក ដោយសំណាញ់មានក្រឡាល្អិត ពួកសត្វណាមួយក្នុងទឹក គប្បីតាំងនៅខាងក្នុងសំណាញ់ យ៉ាងណាមិញ ។ បពិត្រព្រះអង្គជា

តទេវ ហិ មហាវីរ យោ កោចិ បុថុតិត្ថិយា
ទិដ្ឋិគហនបក្ខន្ទា បរាមាសេន មោហិតា ។
តវ សុត្វាន ញាណេន អនាវរណទស្សិនា
អន្តោជាលីកតា ឯតេ ញាណន្តេ នាតិវត្តរេ ។
កកក ច តម្ហិ សមយេ អនោមទស្សី មហាយសោ
វុដ្ឋហិត្វា សមាធិម្ហា ទិសំ(១) ឱលោកយី ជិនោ ។
អនោមទស្សិមុនិនោ និសភោ នាម សាវកោ
បរិវុតោ សតសហស្សេហិ សន្តចិត្តេហិ តាទិភិ ។
ខីណាសវេហិ សុទ្ធេហិ ឆឡភិញ្ញេហិ តាទិភិ
ចិន្តមញ្ញាយ ពុទ្ធស្ស ឧបេសិ លោកនាយកំ ។
អន្តលិក្ខេ ឋិតា តត្ថ បទក្ខិណមកំសុ តេ
នមស្សន្តា បញ្ជលិកា ឱរុហុំ(២) ពុទ្ធសន្តិកេ ។

---
១ អដ្ឋកថាយឡូន ទិសំ ឱលោកយីតិ ជាឃើញ អត្ថ ។ ២ ម. ឱរុំ ។



មហាវីរបុរស ពួកតិរ្ថិយជាច្រើន ណាមួយ សុះទៅកាន់ទីសំញ៉ាំគឺទិដ្ឋិ ដែលវង្វេងហើយ ដោយការប្រកាន់ខុស ក៏យ៉ាងនោះដែរ ។ ពួកសត្វទាំងអស់នុ៎ះ តាំងនៅក្នុងទាក់គឺសំណាញ់ញាណដ៏បរិសុទ្ធ របស់ព្រះអង្គ ជាគ្រឿងរើញ មិនមានអ្នកកន្លងបាន រមែងមិនកន្លងនូវញាណ របស់ព្រះអង្គបានឡើយ ។ គាប់ចួនសម័យនោះ ព្រះមានព្រះភាគជិនស្រី ព្រះនាមអនោមទស្សី ព្រះអង្គមានយសធំ (ទ្រង់ឈ្នះមារ) ចេញអំពីសមាធិ ហើយទ្រង់ប្រមើលមើលទិស ។ សាវកឈ្មោះនិសភៈ របស់ព្រះមុនីព្រះនាមអនោមទស្សី មានពួកព្រះខីណាស្រពមួយសែនអង្គ ជាអ្នកមានចិត្តស្ងប់រម្ងាប់ មិនញាប់ញ័រដោយលោកធម៌ អ្នកបរិសុទ្ធ មានអភិញ្ញា៦ មានចិត្តនឹងនឹងដោយឈានហើយ បានដឹងព្រះហឫទ័យ របស់ព្រះពុទ្ធ ក៏ចូលមកគាល់ព្រះសម្ពុទ្ធ ជាលោកនាយក ។ ពួកសាវកទាំងនោះ ឋិតនៅឰដ៏អាកាស ធ្វើប្រទក្សិណក្នុងទីនោះ ផ្គងអញ្ជលីនមស្ការ ចុះមកក្នុងសំណាក់ព្រះពុទ្ធ ។

## គាថា សារីបុត្តត្ថេរាបទាន

អនោមទស្សី ភគវា លោកជេដ្ឋោ នរាសភោ
ភិក្ខុសង្ឃេ និសីទិត្វា សិតំ បាតុករី ជិនោ ។
វរុណោ នាមុបដ្ឋាកោ អនោមទស្សិស្ស សត្ថុនោ
ឯកំសំ ចីវរំ កត្វា អបុច្ឆិ លោកនាយកំ ។
កោ នុ ខោ ភគវា ហេតុ សិតកម្មស្ស សត្ថុនោ
ន ហិ ពុទ្ធា អហេតុកំ សិតំ បាតុករោន្តិ តេ ។
អនោមទស្សី ភគវា លោកជេដ្ឋោ នរាសភោ
ភិក្ខុមជ្ឈេ និសីទិត្វា ឥមំ គាថំ អភាសថ ។
យោ មំ បុប្ផេន បូជេសិ ញាណញ្ចាបិ អនុត្ថវិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
ពុទ្ធស្ស គិរមញ្ញាយ សព្វេ ទេវា សមាគតា(១)
សទ្ធម្មំ សោតុកាមា តេ សម្ពុទ្ធំ ឧបសង្កមុំ ។

១ ឱ. សមាគមា ។



## សារីបុត្តត្ថេរាបទាន ទី ៣

ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាច្បងក្នុងលោក ជាឧសភៈ ព្រះអង្គឈ្នះមារ ទ្រង់គង់ក្នុងកណ្ដាលពួកភិក្ខុ ហើយធ្វើនូវការញញឹមឲ្យប្រាកដ ។ (លំដាប់នោះ) ភិក្ខុអ្នកបម្រើ ឈ្មោះវរុណៈ របស់ព្រះសាស្ដា ព្រះនាមអនោមទស្សី ធ្វើនូវចីវរឆៀងស្មាម្ខាង ហើយទូលសួរព្រះសម្ពុទ្ធ ជានាយកនៃលោកថា បពិត្រព្រះមានព្រះភាគ អ្វីជាហេតុនៃការញញឹម របស់ព្រះសាស្ដា ព្រោះថា ព្រះពុទ្ធទាំងឡាយ មិនដែលធ្វើនូវការញញឹមឲ្យប្រាកដ ដោយឥតហេតុទេ ។ ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាច្បងក្នុងលោក ជាឧសភៈ ទ្រង់គង់ក្នុងកណ្ដាលពួកភិក្ខុ ទ្រង់ត្រាស់គាថានេះថា ជនណា បូជាតថាគត ដោយផ្កាផង សរសើរនូវញាណផង តថាគតនឹងសម្ដែងចំពោះជននោះ ហេតុនេះ អ្នកទាំងឡាយ ចូរស្ដាប់តថាគតសម្ដែងចុះ ។ ពួកទេវតាទាំងអស់នោះ ព្រមទាំងមនុស្ស ចង់ស្ដាប់ព្រះសទ្ធម្ម ទើបនាំគ្នាចូលមកគាល់ព្រះសម្ពុទ្ធ ព្រោះដឹងច្បាស់នូវព្រះវាចា របស់ព្រះពុទ្ធ ។

ទសសុ លោកធាតុសុ  ទេវកាយា មហិទ្ធិកា
សព្វេ ធម្មំ សុណន្តា តេ  សម្ពុទ្ធំ ឧបសង្កមុំ ។
ហត្ថី អស្សា រថា បត្តី  សេនា ច ចតុរង្គិនី
បរិវារេស្សន្តិមំ និច្ចំ  ពុទ្ធបូជាយិទំ ផលំ ។
សដ្ឋី តុរិយសហស្សានិ  ភេរិយោ សមលង្កតា
ឧបដ្ឋិស្សន្តិមំ និច្ចំ  ពុទ្ធបូជាយិទំ ផលំ ។
សោឡសិត្ថីសហស្សានិ  នារិយោ សមលង្កតា
វិចិត្តវត្ថាភរណា  អាមុត្តមណិកុណ្ឌលា ។
អឡារមុខា(១) ហសុលា  សុសញ្ញា តនុមជ្ឈិមា
បរិវារេស្សន្តិមំ និច្ចំ  ពុទ្ធបូជាយិទំ ផលំ ។
កប្បសតសហស្សានិ  ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ ចក្កវត្តី  រាជា រដ្ឋេ ភវិស្សតិ ។
សហស្សក្ខត្តុំ ទេវិន្ទោ  ទេវរជ្ជំ ករិស្សតិ
បទេសរជ្ជំ វិបុលំ  គណនាតោ អសង្ខិយំ ។

១ ម. អាឡារបម្ហា ។



ពួកទេវតាមានឫទ្ធិច្រើន ក្នុងលោកធាតុទាំង១០ ចង់ស្តាប់ព្រះសទ្ធម្ម ក៏ចូលមកគាល់ព្រះសម្ពុទ្ធ ។ សេនាមានអង្គ ៤ គឺ សេនាដំរី១ សេនាសេះ១ សេនារថ១ សេនាថ្មើរជើង១ នឹងហែហមតាបសនេះ អស់កាលជានិច្ច នេះជាផលនៃពុទ្ធបូជា ។ ពួកតូរ្យតន្ត្រី ៦០ ពាន់ ស្គរទាំងឡាយដែលគេតាក់តែងល្អ នឹងបម្រើតាបសនេះ អស់កាលជានិច្ច នេះជាផលនៃពុទ្ធបូជា ។ ពួកស្ត្រី ១៦ ពាន់ ពួកនារីដែលគេតាក់តែងល្អ មានសំពត់និងគ្រឿងប្រដាប់ដ៏វិចិត្រ ពាក់កុណ្ឌលជាវិការៈនៃកែវមណី ពួកនារីទាំងនោះមានមុខទូលាយ ស្រស់ស្រាយ មានសញ្ញាដ៏ល្អ មានផ្ចិតតូចកណ្ដាលដ៏ស្រៀវ នឹងហែហមតាបសនេះ អស់កាលជានិច្ច នេះជាផលនៃពុទ្ធបូជា ។ (សុមេធតាបស) នឹងត្រេកអរក្នុងទេវលោក អស់មួយសែនកប្ប នឹងបានជាស្តេចចក្រពត្រក្នុងដែន អស់មួយពាន់ដង ។ បានជាព្រះឥន្ទ្រសោយរាជ្យ ក្នុងទេវតា អស់មួយពាន់ដង នឹងសោយរាជ្យ ក្នុងប្រទេសដ៏ទូលាយ មិនអាចរាប់បាន ។

បច្ឆិមេ ភវសម្បត្តេ   មនុស្សត្តំ គមិស្សតិ
ព្រាហ្មណី សារិយា នាម ធារយិស្សតិ កុច្ឆិនា ។
មាតុយា នាមគោត្តេន   បញ្ញាយិស្សតិយំ នរោ
សារីបុត្តោតិ នាមេន   តិក្ខបញ្ញោ ភវិស្សតិ ។
អសីតិកោដី ឆឌ្ឌេត្វា   បព្វជិស្សតិកិញ្ចនោ
គវេសន្តោ សន្តិបទំ   ចរិស្សតិ មហឹ ឥមំ ។
អបរិមេយ្យ[1] ឥតោ កប្បេ   ឱក្កាកកុលសម្ភវោ[2]
គោតមោ នាម គោត្តេន   សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
សារីបុត្តោតិ នាមេន   ហេស្សតិ អគ្គសាវកោ ។
អយំ ភាគីរសី គង្គា   ហិមវន្តា បភាវិតា
មហាសមុទ្ទមប្បេតិ   តប្បយន្តី មហោទធឹ ។

---
១ ម. អបរិមេយ្យេ ។ ២ ម. ឱក្កាកកុលសម្ភូតោ ។





តាបសនេះ នឹងទៅកាន់អត្តភាពជាមនុស្ស ក្នុងកាលដែល
ដល់នូវបច្ឆិមភព នឹងទៅកើតក្នុងផ្ទៃ នៃនាងព្រាហ្មណី
ឈ្មោះសារី ។ តាបសនេះ នឹងបានជាអ្នកមានបញ្ញាមុតថ្លា
មាននាមថាសារីបុត្ត តាមនាមនិងគោត្រ របស់មាតា ។
តាបសនេះ ជាអ្នកមិនមានកង្វល់ នឹងលះបង់នូវទ្រព្យ ៨០
កោដិ ហើយចេញបួស ស្វែងរកនូវសន្តិបទ គឺព្រះនិព្វាន
នឹងត្រាច់មកកាន់ផែនដីនេះ ។ ព្រះសាស្តា ព្រះនាមគោ-
តម កើតក្នុងត្រកូលក្សត្រិយ៍ឈ្មោះឱក្កាកៈ ក្នុងកប្បដែល
ប្រមាណមិនបាន អំពីកប្បនេះ នឹងកើតឡើងក្នុងលោក ។
តាបសនេះ នឹងបានជាទាយាទ ជាអ្នកទទួលមត៌ក ក្នុងធម៌
ទាំងឡាយ របស់ព្រះសាស្តាអង្គនោះ ជាធម្មនិម្មិត ជាអគ្គ-
សាវក មានឈ្មោះសារីបុត្ត ។ ស្ទឹងឈ្មោះភាគីរសីនេះ
ដែលបែកចេញមក អំពីភ្នំហិមពាន្ត រមែងហូរចុះទៅកាន់
មហាសមុទ្រ ញុំាងមហាសមុទ្រឲ្យឆ្អែត យ៉ាងណាមិញ ។

តេជភយំ សារីបុត្តោ   សេក្កា តីសុ វិសារទោ
បញ្ញាយ បារមី គន្ត្វា   តប្បយិស្សតិ បាណិនោ ។
ហិមវន្តំ ឧបាទាយ   សាគរញ្ច មហោទធិំ
ឯត្ថន្តរេ យំ បុឡិនំ   គណនាតោ អសង្ខិយំ ។
តម្បិ សក្កា អសេសេន   សង្ខាតុំ(១) គណនា យថា
ន ត្វេវ សារីបុត្តស្ស   បញ្ញាយន្តោ ភវិស្សតិ ។
ខីយេ គង្គាយ វាលុកា   លក្ខេ ឋបិយមានម្ហិ
ន ត្វេវ សារីបុត្តស្ស   បញ្ញាយន្តោ ភវិស្សតិ ។
មហាសមុទ្ទេ ឩម្មិយោ   គណនាតោ អសង្ខិយា
តថេវ សារីបុត្តស្ស   បញ្ញាយន្តោ ន ហេស្សតិ ។
អារាធយិត្វា សម្ពុទ្ធំ   គោតមំ សក្យបុង្គវំ
បញ្ញាយ បារមី គន្ត្វា   ហេស្សតិ អគ្គសាវកោ ។
បវត្តិតំ ធម្មចក្កំ   សក្យបុត្តេន តាទិនា
អនុវត្តិស្សតិ សម្មា   វស្សន្តោ ធម្មវុដ្ឋិយោ ។

១ ម. សង្ខាតុំ ។



ព្រះសារីបុត្តនេះ ជាបុគ្គលអង់អាច ក្លៀវក្លាក្នុងការបែកធ្លាយ ៣ យ៉ាង ដល់នូវបញ្ញាបារមី នឹងញុំាងពួកសត្វឲ្យឆ្អែត ក៏យ៉ាងនោះដែរ ។ គំនរខ្សាច់ណាក្នុងចន្លោះនេះ គប់យកតាំងពីហិមពាន្ត និងមហាសមុទ្រសាគរ គំនរខ្សាច់នោះ គេមិនគប្បីរាប់បានឡើយ ។ តែបើការរាប់នូវគ្រាប់ខ្សាច់នោះ បុគ្គលអាចរាប់ ដោយមិនសល់បាន យ៉ាងណា ទីបំផុតនៃប្រាជ្ញារបស់ព្រះសារីបុត្ត នឹងមិនមែន យ៉ាងនោះទេ ។ កាលបើគេដាក់ខ្ទង់ គ្រាប់ខ្សាច់ក្នុងស្ទឹងគង្គា គប្បីអស់ទៅ ឯទីបំផុតនៃប្រាជ្ញារបស់ព្រះសារីបុត្ត នឹងមិនអស់ដូច្នោះទេ ។ រលកក្នុងមហាសមុទ្រ ដែលគេមិនគប្បីរាប់បាន ដោយការរាប់ យ៉ាងណា ទីបំផុតនៃប្រាជ្ញា របស់ព្រះសារីបុត្ត ក៏គេនឹងមិនអាចរាប់បាន យ៉ាងនោះ ។ តាបសនេះ នឹងសម្រេចបញ្ញាបារមី បានជាអគ្គសាវក ញុំាងព្រះសម្ពុទ្ធព្រះនាមគោតម ជាខ្ទើមក្នុងសក្យឲ្យត្រេកអរ នឹងបង្អុរនូវភ្លៀងគឺធម៌ដោយប្រពៃ ប្រព្រឹត្តតាមធម្មចក្រ ដែលព្រះសម្ពុទ្ធជាសក្យបុត្រព្រះអង្គជាបុគ្គលនឹងធឹង ឲ្យប្រព្រឹត្តទៅហើយ ។

សព្វមេតំ អភិញ្ញាយ  គោតមោ សក្យបុង្គវោ
ភិក្ខុសង្ឃេ និសីទិត្វា  អគ្គដ្ឋានេ ឋបេស្សតិ ។
អហោ មេ សុកតំ កម្មំ  អនោមទស្សិស្ស សត្ថុនោ
យស្សាហំ ការំ កត្វាន  សព្វត្ថ បារមឹ គតោ ។
អបរិមេយ្យេ កតំ កម្មំ  ផលំ ទស្សេសិ មេ ឥធ
សុមុត្តោ សរវេគោវ  កិលេសេ ឈាបយឹ អហំ ។
អសង្ខតំ គវេសន្តោ  និព្វានំ អចលំ បទំ
វិចិនំ តិត្ថិយេ សព្វេ  ឯសាហំ សំសរឹ ភវេ ។
យថាបិ ព្យាធិតោ បោសោ  បរិយេសេយ្យ ឱសធំ
វិចិនេយ្យ វនំ សព្វំ  ព្យាធិតោ បរិមុត្តិយា ។
អសង្ខតំ គវេសន្តោ  និព្វានំ អមតំ បទំ
អព្ភោកិណ្ណំ បព្វតំ  បព្វជឹ ឥសិបព្វជំ ។



ព្រះសម្ពុទ្ធព្រះនាមគោតម ជាដើមវង្សពួកសក្យៈ ទ្រង់ជ្រាបច្បាស់នូវហេតុទាំងនុ៎ះ ទ្រង់គង់ក្នុងកណ្ដាលនៃពួកភិក្ខុហើយ នឹងតាំង (ព្រះសារីបុត្ត) ក្នុងទីជាអគ្គសាវក ។

ឱហ្ន៎ ខ្ញុំបានធ្វើអធិការ ចំពោះព្រះសាស្ដា ព្រះនាមអនោមទស្សីអង្គណា ហើយបានសម្រេចបារមី ក្នុងទីទាំងពួង អំពើដែលខ្ញុំធ្វើចំពោះព្រះសាស្ដាអង្គនោះ ចំជាក្រៃល្អ ។ កម្មដែលខ្ញុំធ្វើហើយក្នុងកាលប្រមាណមិនបាន ឲ្យផលហើយក្នុងជាតិនេះ ខ្ញុំរួចស្រឡះហើយ ដូចជាសន្ទុះនៃសរ ដុតបំផ្លាញហើយនូវកិលេសទាំងឡាយ ។ ខ្ញុំនុ៎ះកាលស្វែងរកនូវអសង្ខតធម៌ គឺព្រះនិព្វាន ជាធម៌មិនកម្រើក កាលពិនិត្យមើលនូវពួកតិរ្ថិយទាំងអស់ បានអន្ទោលទៅក្នុងភព ។ បុរសអ្នកមានព្យាធិ ស្វែងរកឱសថ ត្រើសរើសនូវព្រៃព្រឹក្សទាំងអស់ ដើម្បីរសះស្បើយ ចាកព្យាធិ យ៉ាងណាមិញ ។ បុគ្គលស្វែងរកផ្លូវ នៃអមតនិព្វាន ជាអសង្ខតធម៌ បួសជាឥសីមិនដែលដាច់ អស់ ៥០០ ជាតិ ក៏យ៉ាងនោះដែរ ។

ជាយ ការការេតា(១) អជិតុត្តរជិកសហី
អភិញ្ញាបារមី គន្ត្វា ព្រហ្មលោកំ អគញ្ឆហំ(២) ។
ឧត្តំ ពាហិរកោ សុទ្ធិ បរេតា ឯកសាសនំ
យេ កេចិ ពុទ្ធិមា សត្តា សុជ្ឈន្តិ ឯកសាសនេ ។
អគ្គការំ មមមេតំ ន ហិ ចសី អហំ ឥតិ(៣)
អសន្តំ គវេសន្តោ កុតិត្ថំ(៤) សញ្ចរី អហំ ។
យថា សារត្ថិកោ បោសោ កទលឹ ឆេត្វាន ផាលយេ
ន តត្ថ សារំ វិន្ទេយ្យ សារេន រិត្តកោ ហិ សោ ។
តថេវ តិត្ថិយា លោកេ នានាទិដ្ឋី ពហូ ជនា
អសង្ខតេន រិត្តា តេ សារេន កទលី យថា ។
បច្ឆិមេ ភវសម្បត្តេ ព្រហ្មពន្ធុ អហោសហំ
មហាភោគំ ឆឌ្ឌយិត្វាន បព្ពជឹ អនគារិយំ ។

បឋមភាណវារំ ។

១ ម. ឈានការេន ភរិតោ ។ ២ ម. អគច្ឆិហំ ។ ៣ ម. នយិទំ ឥតិ ហិតិហំ ។
៤ ម. កុតិត្ថេ ។



ខ្ញុំពេញហើយដោយការៈគឺផ្ចងសក់ សៀកដណ្តប់នូវស្បែកខ្លាដំប្រសើរ ដល់នូវអភិញ្ញាបារមី ហើយបានទៅកើតក្នុងព្រហ្មលោក ។ ការបរិសុទ្ធក្នុងសាសនាខាងក្រៅ វៀរលែងសាសនានៃព្រះជិនស្រី មិនមានទេ ពួកសត្វណាមួយ ជាអ្នកមានប្រាជ្ញា រមែងបរិសុទ្ធក្នុងសាសនា នៃព្រះជិនស្រី ។ ខ្ញុំមិនបានយល់ច្បាស់នៅឡើយថា ដំណើរនេះ ជាកិច្ចប្រាជ្ញនូវប្រយោជន៍របស់ខ្ញុំ ទើបខ្ញុំស្វែងរកអសង្ខតធម៌ អន្ទោលទៅកាន់លទ្ធិអាក្រក់ ។ បុរសអ្នកត្រូវការខ្លឹម កាត់ដើមចេក មិនគប្បីបានខ្លឹម ក្នុងដើមចេកនោះទេ តែណាស់បុរសនោះជាអ្នកទទេចាកខ្លឹម យ៉ាងណាមិញ ។ ពួកជនជាច្រើននាក់ ជាតិរ្ថិយ មានទិដ្ឋិផ្សេងៗគ្នា ក្នុងលោកជាអ្នកទទេសោះ ចាកអសង្ខតធម៌ ក៏យ៉ាងនោះដែរ ដូចជាបុរសកាត់ដើមចេក ទទេចាកខ្លឹម ។ ក្នុងកាលដែលដល់នូវភពចុងក្រោយ ខ្ញុំបានកើតជាព្រាហ្មណ៍ លះបង់ភោគសម្បត្តិជាច្រើន ហើយចូលទៅកាន់ផ្នួស ។

ចប់ ភាណវារៈ ទី ១ ។

## តតិយំ សារីបុត្តត្ថេរាបទានំ

អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន បារគូ
ព្រាហ្មណោ សញ្ជយោ នាម តស្ស មូលេ វសាមហំ ។
សាវកោ តេ មហាវីរ អស្សជិ នាម ព្រាហ្មណោ
ទុរាសទោ ឧគ្គតេជោ បិណ្ឌាយ ចរតី តទា ។
តមទ្ទសាសឹ[១] សប្បញ្ញំ មុនឹ មោនេ សមាហិតំ
សន្តចិត្តំ មហានាគំ សុផុល្លំ បទុមំ យថា ។
ទិស្វា មេ ចិត្តមុប្បជ្ជិ សុទន្តំ សុទ្ធមានសំ
ឧសភំ បវរំ វីរំ អរហាយំ ភវិស្សតិ ។
បាសាទិកោ ឥរិយតិ អភិរូបោ សុសំវុតោ
ឧត្តមេ ទមថេ ទន្តោ អមតទស្សី[២] ភវិស្សតិ ។
យន្នូនាហំ ឧត្តមត្ថំ បុច្ឆេយ្យំ តុដ្ឋមានសំ
សោ មេ[៣] បុដ្ឋោ កថិស្សតិ បដិបុច្ឆាមហន្តទា ។

---

១ ម. តមទ្ទសាសហំ ។ ២ ម. អមតទស្សី ។ ៣ ម. មេ ។



## សារីបុត្តត្ថេរាបទាន ទី ៣

ព្រាហ្មណ៍ ឈ្មោះសញ្ជ័យ ជាអ្នកបង្រៀនមន្ត ចេះចាំមន្ត ចេះចប់ត្រៃវេទ ខ្ញុំនៅក្នុងសំណាក់ព្រាហ្មណ៍នោះ ។ បពិត្រព្រះអង្គមានព្យាយាមធំ ព្រាហ្មណ៍ឈ្មោះអស្សជិ ដែលគេគ្របសង្កត់បានដោយក្រ មានតេជះខ្ពង់ខ្ពស់ ជាសាវ័ករបស់ព្រះអង្គ ត្រាច់ទៅបិណ្ឌបាត ក្នុងកាលនោះ ។ ខ្ញុំព្រះអង្គបានឃើញព្រះអស្សជិនោះ ជាមុនី ប្រកបដោយបញ្ញា ខ្ជាប់ខ្ជួនក្នុងញាណ មានចិត្តស្ងប់ស្ងាប់ ជាមហានាគ (លោកកែពេញដោយគុណ) ដូចជាឈូករីក ។ លុះខ្ញុំឃើញព្រះអស្សជិ មានឥន្ទ្រិយទូន្មានល្អ មានចិត្តស្អាត ដូចឧសភៈលោកប្រសើរ មានព្យាយាម ទើបគិតថា ស្រមណ៍នេះប្រាកដជាព្រះអរហន្ត ទើបមានរូបល្អ សង្រួមល្អ គួរជាទីជ្រះថ្លា ទូន្មានឥន្ទ្រិយដែលគួរទូន្មានដ៏ប្រសើរ ប្រាកដជាឃើញនូវព្រះនិព្វាន ឈ្មោះអមតៈ ។ បើដូច្នោះ មានតែអាត្មាអញសួរអត្ថដ៏ឧត្តម នឹងស្រមណ៍ ជាអ្នកមានចិត្តរីករាយ ប្រសិនបើ អញសួរទៅហើយ លោកនឹងតបបាន អាត្មាអញនឹងសួរសួរលោក តទៅទៀត ក្នុងវេលានោះ ។

បិណ្ឌចារំ(១) ចរន្តស្ស បច្ឆតោ អគមាសហំ
ឱកាសំ បដិមានេន្តោ បុច្ឆិតុំ អមតំ បទំ ។
វីថន្តរេ(២) អនុប្បត្តំ ឧបគន្ត្វាន បុច្ឆហំ
កថំ គោត្តោសិ ត្វំ វីរ កស្ស សិស្សោសិ មារិស ។
សោ មេ បុដ្ឋោ វិយាកាសិ អសម្ភីតោវ កេសរី
ពុទ្ធោ លោកេ សមុប្បន្នោ តស្ស សិស្សោម្ហិ អាវុសោ ។
កីទិសន្តេ មហាវីរ អនុជាត មហាយស
ពុទ្ធស្ស សាសនំ ធម្មំ សាធុ មេ កថយស្សុ ភោ ។
សោ មេ បុដ្ឋោ កថី សព្វំ គម្ភីរំ និបុណំ បទំ
តណ្ហាសល្លស្ស ហន្តារំ សព្វទុក្ខាបនូទនំ ។
យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ
តេសញ្ច យោ និរោធោ ច ឯវំវាទី មហាសមណោ ។

១ ម. បិណ្ឌបាតំ ។ ២ ម. វីថិន្តរេ ។



កាលព្រះអស្សជិ កំពុងនិមន្តទៅបិណ្ឌបាត ខ្ញុំក៏បានដើរតាមពីក្រោយ រង់ចាំឱកាសដើម្បីសួរនូវអមតបទ ។ ខ្ញុំបានចូលទៅសួរព្រះអស្សជិត្ថេរ ដែលនិមន្តដល់ត្រង់ចន្លោះផ្លូវថា បពិត្រលោកមានព្យាយាម លោកជាគោត្រអ្វី បពិត្រលោកនិរទុក្ខ លោកជាសិស្សរបស់អ្នកណា ។ ព្រះអស្សជិត្ថេរនោះ កាលបើខ្ញុំសួរហើយ ក៏បានដោះស្រាយថា ម្នាលអាវុសោ ព្រះសម្ពុទ្ធ ដូចកេសររាជសីហ៍ មិនរេះរាង កើតហើយក្នុងលោក អាត្មាជាសិស្សរបស់ព្រះសម្ពុទ្ធនោះ ។ បពិត្រលោកមានព្យាយាមធំ ជាអនុជាត មានយសធំ ចុះពាក្យប្រដៅនៃព្រះសម្ពុទ្ធ របស់លោក តើដូចម្តេច សូមលោកសម្តែងធម៌គឺពាក្យប្រដៅ (របស់ព្រះសម្ពុទ្ធនោះ) ដល់ខ្ញុំ ។ ព្រះអស្សជិត្ថេរនោះ កាលបើខ្ញុំសួរហើយ ទើបសម្តែងនូវសាសនធម៌ទាំងពួង ដែលល្អិតជ្រាលជ្រៅ ជាចំណែក (និព្វាន) ជាគុណកំចាត់បង់នូវសរគឺតណ្ហា ដែលបន្ទោបង់ នូវកងទុក្ខទាំងពួងថា ធម៌ទាំងឡាយណា មានហេតុជាដែនកើតមុន ព្រះតថាគតបានសម្តែង នូវហេតុរបស់ធម៌ទាំងនោះផង នូវការរលត់នៃធម៌ទាំងនោះផង ព្រះមហាសមណៈតែងពោលយ៉ាងនេះ ។

សោហំ វិស្សជ្ជិតេ បញ្ហេ   បឋមំ ផលមជ្ឈគំ
វិរជោ វិមលោ អាសឹ   សុត្វាន ជិនសាសនំ ។
សុត្វាន មុនិនោ វាក្យំ   បស្សិត្វា ធម្មមុត្តមំ
បរិយោគាឡ្ហសទ្ធម្មោ   ឥមំ គាថំ អភាសហំ ។
ឯសេវ ធម្មោ យទិ តាវទេវ   បច្ចព្យថ(១) បទមសោកំ
អទិដ្ឋំ អព្ភតីតំ   ពហុកេហិ កប្បនហុតេហិ ។
យោហំ ធម្មំ គវេសន្តោ   កុតិត្ថេ សញ្ចរឹ អហំ
សោ មេ អត្ថោ អនុប្បត្តោ   កាលោ មេ នប្បមជ្ជិតុំ ។
តោសិតោហំ អស្សជិនា   បត្វាន អចលំ បទំ
សហាយកំ គវេសន្តោ   អស្សមំ អគមាសហំ ។
ទូរតោ មមំ ទិស្វា   សហាយោ មេ សុសិក្ខិតោ
ឥរិយាបថសម្បន្នោ(២)   ឥទំ វចនមព្រវិ ។

---

១ ឱ. បច្ចព្យថំ ។ ២ ឱ. ឥរិយាបថំ ឧជុំ ទិស្វា ។



កាលព្រះអស្សជិត្ថេរ បានដោះស្រាយបញ្ហាហើយ ខ្ញុំក៏បានសម្រេចផលជាបឋម បានប្រាសចាកធូលី ប្រាសចាកមន្ទិល ព្រោះបានស្តាប់ពាក្យប្រដៅ របស់ព្រះជិនស្រី ។ លុះខ្ញុំបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះមុនីហើយ ឃើញនូវធម៌ដ៏ឧត្តម ទាំងមានចិត្តចុះស៊ប់ស្លុង ក្នុងព្រះសទ្ធម្ម ហើយបានពោលនូវគាថានេះថា ធម៌នេះ ជាគន្លងនៃសេចក្តីជាក់ច្បាស់ មិនមានសោក ដែលខ្ញុំមិនទាន់ឃើញ កន្លងទៅយូរហើយ ដោយសែនកោដិកប្បជាច្រើន ។ កាលខ្ញុំស្វែងរកធម៌ បានត្រាច់ទៅហើយក្នុងលទ្ធិអាក្រក់ ឥឡូវប្រយោជន៍នោះ ខ្ញុំបានសម្រេចហើយ វេលានេះ ជាកាលគួរខ្ញុំមិនប្រមាទ ។ ខ្ញុំដែលបានព្រះអស្សជិត្ថេរ ប្រោសប្រាណហើយ ក៏បានសម្រេចអចលបទ គឺព្រះនិព្វាន ទើបទៅស្វែងរកជួបនឹងសម្លាញ់ ក៏បានទៅឯអាស្រម ។ សម្លាញ់របស់ខ្ញុំ ជាអ្នកសិក្សាល្អ បរិបូណ៌ដោយឥរិយាបថ បានឃើញខ្ញុំអំពីចម្ងាយ ក៏សួរខ្ញុំថា

បសន្នមុខនេត្តោសិ  មុនិភាវោ ទិស្សតិ
អមតាធិគតោ កច្ចិ  និព្វានំ អច្ចុតំ បទំ ។
សុភាឡុរោ អាយាសិ  អានេញ្ជការិតោ វិយ
ទន្តោវ ទន្តទមថេ(១)  ឧបសន្តោសិ ព្រាហ្មណ ។
អមតំ មយា អធិគតំ  សោកសល្លវិនោទនំ
ត្វម្បិ តំ អធិគច្ឆាហិ  គច្ឆាម ពុទ្ធសន្តិកំ ។
សាធូតិ សោ បដិស្សុត្វា(២) សហាយោ មេ សុសិក្ខិតោ
ហត្ថេន ហត្ថំ គណ្ហិត្វា  ឧបាគម្ម តវន្តិកំ ។
ឧភោបិ បព្វជិស្សាម  សក្យបុត្ត តវន្តិកេ
តវ សាសនមាគម្ម  វិហរាម អនាសវា ។
កោលិតោ ឥទ្ធិយា សេដ្ឋោ  អហំ បញ្ញាយ បារគោ
ឧភោវ ឯកតោ ហុត្វា  សាសនំ សោភយាមសេ ។

---
១ ម. ទន្តទមថោ ។ ២ ម. សាធូតិ បដិស្សុណិត្វា ។



អ្នកមានមុខនិងភ្នែកថ្លាស្រស់បស់ មានភាពជាអ្នកប្រាជ្ញ អ្នកប្រហែលជាបានសម្រេច នូវចំណែកនៃព្រះនិព្វាន ឈ្មោះអមតៈ ជាធម៌មិនច្យុតហើយឬ នែព្រាហ្មណ៍ អ្នកមានសភាពល្អបានដើរមក អ្នកទូន្មានខ្លួនក្នុងធម៌ ដែលគប្បីទូន្មានរបស់អ្នកទូន្មានហើយ មានចិត្តស្ងប់រម្ងាប់ ដូចដំរីដែលគេបង្ហាត់បង្រៀនល្អប្រពៃ ។ ខ្ញុំប្រាប់សម្លាញ់ថា ព្រះនិព្វានឈ្មោះអមតៈ ជាគ្រឿងបន្ទោបង់នូវសរ គឺសេចក្ដីសោក ខ្ញុំបានសម្រេចហើយ អ្នកចូរសម្រេចព្រះនិព្វាននោះចុះ យើងនឹងនាំគ្នាទៅកាន់សំណាក់ព្រះពុទ្ធ ។ សម្លាញ់របស់ខ្ញុំនោះជាអ្នកសិក្សាល្អ បានទទួលពាក្យថា ប្រពៃហើយ រួចចាប់ដៃគ្នា ដើរចូលមកសំណាក់ព្រះអង្គ ក្រាបទូលថា បពិត្រព្រះសក្យបុត្រ ខ្ញុំព្រះអង្គទាំងពីរនាក់ នឹងបួសក្នុងសំណាក់នៃព្រះអង្គ ជាអ្នកមិនមានអាសវៈ ព្រោះបានអាស្រ័យនូវសាសនធម៌របស់ព្រះអង្គហើយ ។ កោលិតជាបុគ្គលប្រសើរដោយឫទ្ធិ ឯខ្ញុំព្រះអង្គ ជាបុគ្គលដល់នូវត្រើយនៃបញ្ញា យើងខ្ញុំទាំងពីរនាក់ បានញុំាងសាសនធម៌ឲ្យល្អ ដូចគ្នា ។

អបរិយោសិតសង្កប្បោ កុតិត្ថេ សញ្ចរឹ អហំ
តវ ធម្មស្សនាគម្ម សង្កប្បោ បូរិតោ មម ។
បវរំ បតិដ្ឋាយ បុប្ផន្តិ សមយេ ទុមា
ទិព្វា គន្ធា សម្បវន្តិ តោសេន្តិ សព្វបាណិនំ ។
តថេវាហំ មហាវីរ សក្យបុត្ត មហាយស
សាសនេ តេ បតិដ្ឋាយ សមយេសាមិ បុប្ផិតុំ ។
វិមុត្តិបុប្ផំ បេសន្តោ ភវសំសារមោចនំ
វិមុត្តិបុប្ផលាភេន តោសេមិ សព្វបាណិនំ ។
យាវតា ពុទ្ធខេត្តម្ហិ ឋបេត្វាន មហាមុនឹ
បញ្ញាយ សទិសោ នត្ថិ តវ បុត្តស្ស ចក្ខុម ។
សុវិនីតា ច តេ សិស្សា បរិសា ច សុសិក្ខិតា
ឧត្តមេ ទមថេ ទន្តា បរិវារេន្តិ តំ សទា ។





កាលដែលខ្ញុំព្រះអង្គ មានបំណងមិនទាន់បានសម្រេចនៅឡើយ បានត្រាច់ទៅ កាន់លទ្ធិអាក្រក់ លុះបានមកជួបប្រទះនឹងព្រះអង្គ ទើបបំណងរបស់ខ្ញុំព្រះអង្គ ពេញបរិបូណ៌ឡើង ។ ឈើទាំងឡាយ ដែលដុះលើផែនដី រមែងមានផ្កាកើតឡើង ក្លិនទាំងឡាយជាទិព្វ រមែងផ្សាយទៅ ញ៉ាំងពួកសត្វទាំងពួង ឲ្យត្រេកអរបាន (យ៉ាងណាមិញ) ។ បពិត្រព្រះអង្គ មានព្យាយាមធំ ជាសក្យបុត្រ មានយសធំ ខ្ញុំព្រះអង្គតាំងនៅ ក្នុងសាសនា របស់ព្រះអង្គ ទំរង់រីក (ឱ្យលប់យ) ដើម្បីផ្កា ទំរង់រីកផ្កាវិមុត្តិ ជាគ្រឿងរួចចាកសង្សារ ដែលធ្វើពួកសត្វទាំងពួងឲ្យត្រេកអរ ដោយការបាននូវផ្កាវិមុត្តិ គឺយ៉ាងនោះដែរ ។ បពិត្រព្រះអង្គ មានបញ្ញាចក្ខុ ក្នុងពុទ្ធខេត្ត ទាំងប៉ុន្មាន លើកលែងតែព្រះមហាមុនីចេញ មិនមានបុគ្គលណា នឹងប្រៀបផ្ទឹមដោយប្រាជ្ញា នៃបុត្ររបស់ព្រះអង្គទេ ។ ពួកសិស្សរបស់ព្រះអង្គ បានទូន្មានល្អហើយផង ពួកបរិស័ទ សិក្សាល្អហើយផង គឺជាទូន្មានឥន្ទ្រិយដ៏ប្រសើរ លោកទាំងនោះ មានឥន្ទ្រិយទូន្មានហើយ ហែងរោមរោមព្រះអង្គ សព្វ ៗ កាល ។

ឈាយី ឈានរតា ធីរា សន្តចិត្តា សមាហិតា
មុនី មោនេយ្យសម្បន្នា បរិវារេន្តិ តំ សទា ។
អប្បិច្ឆា និបកា ធីរា អប្បាហារា អលោលុបា
លាភាលាភេន សន្តុដ្ឋា បរិវារេន្តិ តំ សទា ។
អារញ្ញិកា ធុតរតា ឈាយិនោ លូខចីវរា
វិវេកាភិរតា ធីរា បរិវារេន្តិ តំ សទា ។
បដិបន្នា ផលដ្ឋា ច សេខា ផលសមង្គិនោ
អាសីសកា ឧត្តមត្ថំ បរិវារេន្តិ តំ សទា ។
សោតាបន្នា ច វិមលា សកទាគាមិនោ ច យេ
អនាគាមី ច អរហា បរិវារេន្តិ តំ សទា ។
សតិបដ្ឋានកុសលា ពោជ្ឈង្គភាវនារតា
សាវកា តេ ពហូ សព្វេ បរិវារេន្តិ តំ សទា ។



ពួកបរិស័ទដែលមានឈាន ត្រេកអរក្នុងឈាន មានប្រាជ្ញា មានចិត្តស្ងប់រម្ងាប់ មានចិត្តតំកល់មាំ ជាមុនីបរិបូណ៌ដោយញាណ តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកបរិស័ទដែលជាអ្នកប្រាថ្នាតិច មានបញ្ញាទន់ មានបញ្ញាជាគ្រឿងប្រុងប្រើ មានអាហារតិច មិនលោភ ជាអ្នកសន្តោសតាមមានតាមបាន តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកបរិស័ទដែលជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ត្រេកអរក្នុងការកំចាត់បង់នូវកិលេស មានឈាន មានចីវរសៅហ្មង ត្រេកអរតែក្នុងទីស្ងាត់ មានប្រាជ្ញាជាគ្រឿងចងចាំ តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកសេក្ខបុគ្គលក្នុងប្រតិបត្តិខ្លះ ឋិតនៅក្នុងផលខ្លះ ទាំងព្រះអរហន្តបរិបូណ៌ដោយផលខ្លះ ជាអ្នកស្វែងរកប្រយោជន៍ដ៏ខ្ពង់ខ្ពស់ តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកសោតាបន្នបុគ្គល មិនមានធម៌ជាមន្ទិលផង សកទាគាមិបុគ្គលផង អនាគាមិបុគ្គលផង អរហន្តផង តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកសាវ័កជាច្រើនរបស់ព្រះអង្គ ជាអ្នកឈ្លាសវៃ ក្នុងសតិប្បដ្ឋាន ត្រេកអរក្នុងការចំរើនពោជ្ឈង្គ តែងចោមរោមព្រះអង្គ សព្វៗ កាល ។

ឥទ្ធិបាទេសុ កុសលា សមាធិភាវនារតា
សម្មប្បធានមនុយុត្តា បរិចរន្តិ តំ សទា ។
តេវិជ្ជា ឆឡភិញ្ញា ច ឥទ្ធិយា បារមឹ គតា
បញ្ញាយ បារមិប្បត្តា បរិចរន្តិ តំ សទា ។
ឦទិសា(១) ហិ មហាវីរ តវ សិស្សា សុសិក្ខិតា
ទុរាសទា ឧគ្គតេជា បរិចរន្តិ តំ សទា ។
តេហិ សិស្សេហិ បរិវុតោ សញ្ញតេហិ តបស្សិភិ
មិគរាជាវសម្ភីតោ ឧឡុរាជាវ សោភសិ ។
មហិយា បតិដ្ឋាយ រុហន្តិ ធរណីរុហា
វេបុល្លតំ បាបុណន្តិ ផលញ្ច ទស្សយន្តិ តេ ។
មហីសទិសោ ត្វំសិ សក្យបុត្ត មហាយស
សាសនេ តេ បតិដ្ឋាយ លភន្តិ អមតំ ផលំ ។

១ ម. ឯទិសា ។



ពួកសាវ័ក អ្នកឈ្លាសវៃក្នុងឥទ្ធិបាទ ត្រេកអរក្នុងការចម្រើនសមាធិ ប្រកបនូវសម្មប្បធាន តែងចោមរោមព្រះអង្គ សព្វ ៗ កាល ។ ពួកសាវ័កអ្នកបានដល់ត្រៃវិជ្ជាផង បានអភិញ្ញា ៦ ផង ដល់នូវត្រើយនៃឫទ្ធិផង ដល់នូវត្រើយនៃប្រាជ្ញាផង តែងចោមរោមព្រះអង្គ សព្វ ៗ កាល ។ បពិត្រព្រះអង្គ មានព្យាយាមធំ ពួកសិស្សរបស់ព្រះអង្គបែបនេះ បានសិក្សាល្អ កម្របុគ្គលគ្របសង្កត់បាន មានតេជះខ្ពង់ខ្ពស់ តែងចោមរោមព្រះអង្គ សព្វ ៗ កាល ។ ព្រះអង្គ ត្រូវពួកសិស្សទាំងនោះ ដែលជាអ្នកសង្រួម មានតបៈ ចោមរោមហើយ ទ្រង់មិនភ្លាចដូចស្តេចម្រឹគ ទ្រង់រុងរឿងដូចព្រះចន្ទ ។ ឈើទាំងឡាយ ដុះនៅលើផែនដី តែងលូតលាស់ចម្រើនឡើង ឈើទាំងនោះ តែងបញ្ចេញផ្លែ ។ បពិត្រព្រះសក្យបុត្រ មានយសធំ ព្រះអង្គដូចផែនដី ពួកសាវ័កតាំងនៅ ក្នុងសាសនធម៌របស់ព្រះអង្គហើយ តែងបាននូវផ្លែ គឺអមតមហានិព្វាន ។

សិន្ធុ សរស្សតី ចេវ នន្ទិយោ ចន្ទភាគិកា
គង្គា ច យមុនា ចេវ សរភូ ច អថោ មហី
ឯតាសំ សន្ទមានានំ សាគរោ សម្បដិច្ឆតិ
ជហន្តិ បុរិមំ នាមំ សាគរោត្វេវ ញាយតិ ។
តថេវិមេ ចតុវណ្ណា បព្វជិត្វា តវន្តិកេ
ជហន្តិ បុរិមំ នាមំ ពុទ្ធបុត្តាតិ ញាយរេ ។
យថាបិ ចន្ទោ វិមលោ គច្ឆំ អាកាសធាតុយា
សព្វេ តារគណេ លោកេ អាភាយ អតិរោចតិ ។
តថេវ ត្វំ មហាវីរ បរិវុតោ ទេវមានុសេ
ពុទ្ធក្ខេត្តំ អតិក្កម្ម ជលសិ សព្វទា តុវំ ។
កម្មេ ឧជ្ជិតា ធម្មិ ឥ ហេសំ អតិវត្តតិ
សព្វេសំ បដុស្សន្តិ សព្វញ្ញា វិភវន្តិ តា ។
តថេវ តិត្ថិយា លោកេ ជាតាធិដ្ឋី ពហូ ជនា
ធម្មំ អតិក្កមា(២) តេ ជាតិវត្តន្តិ តំ មុនិ ។

១ ម. ឯតេ សព្វេ ។ ២ ម. ភិទ័ក្កមា ។



ស្ទឹងទន្លេទឹក របស់ស្ទឹងទាំងនុ៎ះ គឺ សិន្ធុ សរស្សតី ចន្ទភាគ នន្ទិ យមុនា សរភូ និងមហី ដែលហូរមក ។ ទឹកស្ទឹងទាំងនោះ តែងលះបង់ឈ្មោះដើមរៀងខ្លួនចេញ គេដឹងថាជាសាគរតែម្យ៉ាង (យ៉ាងណាមិញ) ។ វណ្ណៈទាំង ៤ នេះ(១) លុះបួសក្នុងសំណាក់របស់ព្រះអង្គហើយ តែងលះឈ្មោះដើមរៀងខ្លួនចេញ គេដឹងថាជាពុទ្ធបុត្តតែម្យ៉ាង ក៏យ៉ាងនោះដែរ ។ មួយទៀត ព្រះចន្ទប្រាសចាកមន្ទិល(២) អណ្តែតទៅក្នុងអាកាស-ធាតុ មានពន្លឺរុងរឿងក្រៃលែង ខ្ពស់ពួកផ្កាយទាំងអស់ក្នុងលោក យ៉ាងណាមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គមានពួកទេវតានិងមនុស្សចោមរោមហើយ រុងរឿងក្រៃលែង ខ្ពស់ពុទ្ធក្ខេត្ត សព្វកាល ក៏យ៉ាងនោះដែរ ។ រលកដែលតាំងឡើងក្នុងទឹកជ្រៅ មិនប្រព្រឹត្តកន្លងនូវច្រាំង រលកទាំងនោះ រមែងមកជួបនឹងច្រាំងទាំងអស់ សឹងបែកខ្ទេចខ្ទីរោយរាយទៅ (យ៉ាងណាមិញ) ។ ពួកតិរ្ថិយជាច្រើន មានទិដ្ឋិផ្សេង ៗ គ្នា ក្នុងលោក មានប្រាថ្នាដើម្បីនឹងរំលងនូវធម៌របស់ព្រះអង្គ ក៏មិនប្រព្រឹត្តកន្លង នូវព្រះអង្គជាមុនីឡើយ ក៏យ៉ាងនោះដែរ ។

១ បានដល់ ខត្តិយៈ ព្រាហ្មណៈ វេស្សៈ សុទ្ទៈ ។ ២ មន្ទិល ៥ គឺ ពពក ១ ទឹកសន្សើម ១ ធូលី ១ រាហូចាប់ ១ ផ្សែង ១ ។ (អដ្ឋកថា) ។

សរទេ ច តិ តាបុណ្ណន្តិ បដិភេហិ ចក្ខុម
តវន្តិតំ ឧតាកន្តា សញ្ញុណ្ណាវ តវន្តិ តេ ។
យថាបិ ឧទកេ ជាតា កុមុទា មន្ទាលកា ពហូ
ឧបលិម្បន្តិ តោយេន កទ្ទមកលលេន ច ។
តថេវ ពហុកា សត្តា លោកេ ជាតា វិរូហរេ
អដ្ដិតា(១) រាគទោសេន កទ្ទមេ កុមុទំ យថា ។
យថា បទុមំ ជលជំ ជលមជ្ឈេ វិរោចតិ
នោបលិម្បតិ តោយេន បរិសុទ្ធោ ហិ កេសរី ។
តថេវ ច មហាវីរោ លោកេ ជាតោ មហាមុនិ
នោបលិម្បតិ លោកេន តោយេន បទុមំ យថា ។
យថា ហិ រម្មកេ មាសេ ពហូ បុប្ផន្តិ វារិជា
នាតិក្កមន្តិ តំ មាសំ សមយោ បុប្ផនាយ សោ ។

១ ម. អដ្ដិតា ។





បពិត្រព្រះអង្គមានបញ្ញាចក្ខុ ប្រសិនបើ ពួកក្សត្រិយ៍ទាំងនោះ មកដល់ព្រះអង្គ ដោយលំដាប់នៃករណៈទាំងឡាយ ស៊ុះចូលមកកាន់សំណាក់ព្រះអង្គហើយ ពេលនេះខ្ញុំ ។ មួយទៀត ដើមកុមុទ និងចង្កុលណីជាច្រើន កើតឡើងក្នុងទឹក តែងទទឹក ដោយទឹកផង ប្រឡាក់ដោយភក់និងល្បាប់ផង យ៉ាងណាមិញ ។ ពួកសត្វជាច្រើន តែងកើតឡើង ចម្រើនឡើងក្នុងលោក ជាសត្វទទឹកដោយរាគៈ និងទោសៈ ដូចកុមុទក្នុងភក់ ក៏យ៉ាងនោះដែរ ។ ឈូកដែលដុះឡើង ក្នុងទឹករមែងរុងរឿងក្នុងកណ្ដាលទឹក ឈូកនោះមិនជាប់ដោយទឹក ទៅជាឈូកមានកេសរ ដ៏បរិសុទ្ធ យ៉ាងណាមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ជាមហាមុនី ព្រះអង្គកើតឡើងក្នុងលោក ព្រះអង្គមិនជាប់ចំពាក់ដោយលោក ដូចឈូក (មិនជាប់) ដោយទឹក ក៏យ៉ាងនោះដែរ ។ ពួកកំជាតិជាច្រើន តែងកើតក្នុងខែជាទីត្រេកអរ (ខែកត្តិក) មិនកន្លងខែនោះទៅបានឡើយ ព្រោះខែនោះជាសម័យរីក យ៉ាងណាមិញ ។

តថេវ ត្វំ សក្យបុត្ត  បុប្ផិតោ តេ វិមុត្តិយា
សាសនំ ជោតយិស្សតិ  បទុមំ ភាណុ យថា ។
សុបុប្ផិតោ សាលរាជា  ទិព្វគន្ធំ បវាយតិ
អញ្ញសាលេហិ បរិវុតោ  សាលរាជាវ សោភតិ ។
តថេវ ត្វំ មហាវីរ  ពុទ្ធញាណេន បុប្ផិតោ
ភិក្ខុសង្ឃេន បរិវុតោ[1]  សាលរាជាវ សោភសិ ។
យថាបិ សេលោ ហិមវា  ឱសធោ[2] សព្វបាណិនំ
នាគានំ អសុរានញ្ច  ទេវានំ អាលយោ ភវេ ។
តថេវ ត្វំ មហាវីរ  ឱសធោ វិយ បាណិនំ
តេវិជ្ជា ឆឡភិញ្ញា ច  ឥទ្ធិយា បារមី គតា ។
អនុសិដ្ឋា មហាវីរ  តយា ការុណិកេន តេ
រមន្តិ ធម្មរតិយា  វសន្តិ តវ សាសនេ ។

១ ម. ភិក្ខុសង្ឃបរិវុតោ ។ ២ ម. ឱសធោ ។





បពិត្រព្រះសក្យបុត្ត ព្រះអង្គរីកហើយដោយវិមុត្តិ ពួកសាវ័កទាំងនោះ រមែងមិនប្រព្រឹត្តកន្លងនូវសាសនាឡើយ ដូចផ្កាឈូករីកដោយទឹក ។ ស្តេចសាលព្រឹក្សមានផ្ការីកហើយ តែងផ្សាយនូវក្លិនដូចជាទិព្វ ស្តេចសាលព្រឹក្ស មានពួកសាល-ព្រឹក្សដទៃចោមរោម តែងល្អដោយនាមជាសាលព្រឹក្ស យ៉ាងណាមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គរីកហើយដោយពុទ្ធញាណ មានភិក្ខុសង្ឃចោមរោមហើយ រុងរឿងដូចជាស្តេចសាលព្រឹក្ស ក៏យ៉ាងនោះដែរ ។ មួយទៀត ភ្នំហិមពាន្ត ជាឱសថរបស់សត្វទាំងអស់ផង ជាទីនៅនៃពួកនាគ អសុរនិងពួកទេវតាផង យ៉ាងណាមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គដូចជាឱសថ នៃពួកសត្វដែលបានត្រៃវិជ្ជា បានឆឡភិញ្ញា ដល់ហើយនូវបារមីនៃឫទ្ធិផង ក៏យ៉ាងនោះដែរ ។ បពិត្រព្រះអង្គមានព្យាយាមធំ សត្វទាំងនោះដែលព្រះអង្គ មានព្រះហឫទ័យករុណា ទ្រង់ប្រដៅហើយ តែងរីករាយដោយការត្រេកអរធម៌ តែងនៅក្នុងសាសនានៃព្រះអង្គ ។

## តតិយំ សារីបុត្តត្ថេរគាថំ

មិគរាជា យថា សីហោ អភិនិក្ខម្ម អាសយា
ចតុទ្ទិសា វិលោកេត្វា តិក្ខត្តុំ អភិនាទតិ ។
សព្វេ មិគា ឧត្តសន្តិ មិគរាជស្ស គជ្ជតោ
តថា ហិ ជាតិមា សីហោ បសុំ តាសេតិ សព្វទា ។
គជ្ជតោ តេ មហាវីរ វសុធាយំ បកម្បតិ
ពោធនេយ្យា ពុជ្ឈន្តិ តសន្តិ មារកាយិកា ។
តសន្តិ តិត្ថិយា សព្វេ នទតោ តេ មហាមុនិ
កាកសេនាវ វិក្កន្តា មិគរញ្ញា យថា មិគា ។
យេ កេចិ គណិនោ លោកេ សត្ថារោតិ បវុច្ចរេ
បរម្បរាគតំ ធម្មំ ទេសេន្តិ បរិសាយ តេ ។
ន ហេវំ ត្វំ មហាវីរ ធម្មំ ទេសេសិ បាណិនំ
សាមំ សច្ចានិ ពុជ្ឈិត្វា កេវលំ ពោធិបក្ខិកំ ។



## សារីបុត្តត្ថេរគាថា ទី ៣

សីហៈជាមិគរាជ ចេញអំពីទីអាស្រ័យហើយ តែងក្រឡេកមើលទិសទាំង ៤ ទើបបន្លឺឡើង ៣ ដង ។ កាលមិគរាជបន្លឺឡើង ពួកម្រឹគទាំងអស់ តែងតក់ស្លុតយ៉ាងខ្លាំង ព្រោះតែស្ដេចម្រឹគនុ៎ះ ជាសត្វមានជាតិខ្ពស់ តែងធ្វើសត្វឲ្យតក់ស្លុតសព្វ ៗ កាល (យ៉ាងណាមិញ) ។ បពិត្រព្រះអង្គមានព្យាយាមធំ កាលព្រះអង្គមានបន្ទូល ផែនដីនេះកក្រើក ពួកសត្វដែលគួរត្រាស់ដឹង រមែងត្រាស់ដឹង ពួកមារតែងតក់ស្លុត ។ បពិត្រព្រះមហាមុនី កាលបើព្រះអង្គទ្រង់បន្លឺឡើង ពួកតិរ្ថិយទាំងអស់តែងតក់ស្លុត ដូចពួកក្អែកនិងខ្លែង ដែលភ្ញាក់ផ្អើល ឬដូចជាពួកម្រឹគដែលភ្ញាក់ផ្អើល ដោយសារស្ដេចម្រឹគ ។ ពួកមេគណៈណា ដែលគេហៅថា សាស្ដាក្នុងលោក មេគណៈទាំងនោះ តែងសម្ដែងប្រាប់បរិស័ទ នូវធម៌ដែលតមកតៗ គ្នា ។ បពិត្រព្រះអង្គ មានព្យាយាមធំ ឯព្រះអង្គមិនសម្ដែងធម៌ ដល់ពួកសត្វ ដូច្នោះទេ ព្រោះត្រាស់ដឹងនូវសច្ចធម៌ទាំងឡាយ ដោយព្រះអង្គឯង ព្រមទាំងត្រាស់ដឹង នូវពោធិបក្ខិយធម៌ទាំងអស់ ដោយព្រះអង្គឯង ។

អាសយានុសយំ ញត្វា ឥន្ទ្រិយានំ ពលាពលំ
ភព្វាភព្វេ វិទិត្វាន មហាមេឃោវ គជ្ជសិ ។
ចក្កវាឡបរិយន្តា និសិន្នា បរិសា ភវេ
នានាទិដ្ឋី វិចេន្តិ វិមតិច្ឆេទនាយ តំ ។
សព្វេសំ ចិត្តមញ្ញាយ ឱបម្មកុសលោ មុនិ
ឯកំ បញ្ហំ កថេន្តោវ វិមតឹ ឆិន្ទសិ បជំ ។
ឧបតិស្សសទិសេហេវ វសុធា បូរិតា ភវេ
សព្វេវ តេ បញ្ជលិកា កិត្តយុំ លោកនាយកំ ។
កប្បំ វា តេ កិត្តយន្តា នានាវណ្ណេហិ កិត្តយុំ
បរិមេតុំ ន សក្កេយ្យុំ(១) អប្បមេយ្យោ តថាគតោ ។
យថា សកេន ថាមេន កិត្តិតោ ហិ មយា ជិនោ
កប្បកោដីបិ កិត្តេន្តា ឯវមេវ បកិត្តយុំ ។

១ ម. ន បហេយ្យុំ ។



ព្រះអង្គទ្រង់ជ្រាប នូវអាសយានុសយៈ នូវឥន្ទ្រិយទាំងឡាយ នូវពលៈនិងមិនមែនពលៈ ទ្រង់ជ្រាបច្បាស់នូវពួកសត្វ ដែលមានភព្វនិងអភព្វ ហើយទ្រង់សម្តែងធម៌ ដូចមហាមេឃ (គ្រហឹមហើយ) ។ បរិស័ទអង្គុយ ត្រឹមចុងបំផុតនៃចក្រវាឡ មានទិដ្ឋិផ្សេងៗគ្នា តែងត្រិះរិះនូវធម៌នោះ ដើម្បីនឹងផ្តាច់បង់សេចក្តីសង្ស័យ ។ ព្រះមុនីទ្រង់ឈ្លាសវៃ ក្នុងឧបមា បានជ្រាបនូវចិត្ត របស់សត្វទាំងអស់ ទ្រង់សម្តែងតែបញ្ហាមួយ ក៏បានកាត់បង់ នូវសេចក្តីសង្ស័យ របស់ពួកសត្វបាន ។ ផែនដីដែលពេញដោយមនុស្ស ប្រកបដោយក-តាទិក្កិលេស មនុស្សទាំងអស់នោះ នាំគ្នាប្រណម្យអញ្ជលី សរសើរគុណព្រះនាយក ។ មួយទៀត មនុស្សទាំងនោះ កាលសរសើរគុណ គប្បីសរសើរដោយគុណផ្សេងៗ អស់មួយកប្ប ក៏មិនគប្បីសម្រេចនូវការកំណត់បានឡើយ (ព្រោះ) ព្រះតថាគត មានគុណគេមិនគប្បីកំណត់បាន ។ ព្រះជិនស្រីដ៏ប្រសើរ ដែលមនុស្សទាំងទៅសរសើរហើយ ដោយកម្លាំង របស់ខ្លួន យ៉ាងណា មនុស្សទាំងឡាយ កាលសរសើរ គប្បីសរសើរ យ៉ាងនេះឯង អស់កោដិនៃកប្ប ។

សចេ ហិ កោដិវេធកោ មនុស្សោ ក សុសិក្ខិតោ
ឧបេតុំ បរិកប្បេយ្យ វិឃាតុំ លភេយ្យ សោ ។
សាសនេ តេ បតិដ្ឋាយ សក្យបុត្ត មហាយស
បញ្ញាយ បារមី គន្ត្វា វិហរាមិ អនាសវោ ។
តិត្ថិយេ សម្បមទ្ទាមិ វត្តេមិ ជិនសាសនំ
ធម្មសេនាបតិ អជ្ជ សក្យបុត្តស្ស សាសនេ ។
អបរិមេយ្យេ កតំ កម្មំ ផលំ ទស្សេសិ មេ ឥធ
សុមុត្តោ(១) សរវេគោវ កិលេសេ ឈាបយី មម ។
យោ កោចិ មនុជោ ភារំ ធារេយ្យ មត្ថកេ សទា
ភារេន ទុក្ខិតោ អស្ស ភារេហិ ភរិតោ តថា ។
ឌយ្ហមានោ តិហគ្គីហិ ភវេសុ សំសរឹ អហំ
ភរិតោ ភវភារេន គិរឹ ឧច្ចារិតោ យថា ។

---
១ ម. សុរិតោ ។





ប្រសិនបើ បុគ្គលណាមួយ ទោះជាទេវតា ឬមនុស្សដែលសិក្សាល្អហើយ គប្បីកំណត់ដើម្បីនឹងកប់ (ឲ្យដាច់ទឹកក្នុងសមុទ្រ) បុគ្គលនោះ នឹងបាននូវសេចក្ដីលំបាក ។ បពិត្រព្រះសក្យបុត្ត មានយសធំ ខ្ញុំព្រះអង្គឋិតនៅហើយ ក្នុងសាសនារបស់ព្រះអង្គ ដល់នូវបញ្ញាបារមី ជាបុគ្គលមិនមានអាសវៈ ។ ថ្ងៃនេះ ខ្ញុំព្រះអង្គជាធម្មសេនាបតី ក្នុងសាសនារបស់ព្រះសក្យបុត្ត បានញាំញីពួកតិរ្ថិយ ញ៉ាំងសាសនានៃព្រះជិនស្រីឲ្យប្រព្រឹត្តទៅ ។ កំពើដែលខ្ញុំធ្វើហើយ អស់កប្បប្រមាណមិនបាន ឲ្យផលដល់ខ្ញុំ ក្នុងជាតិនេះ ខ្ញុំព្រះអង្គបានដុតស្រឡះហើយនូវកិលេស ដូចកម្លាំងសរ (ដែលផុតចាកធ្នូ) ចាំងបានដុតបំផ្លាញ នូវកិលេសអស់ហើយ ។ មនុស្សណាមួយ បានទាំទៅនូវភារៈលើក្បាល សព្វ ៗ កាល (មនុស្សនោះ) គឺដល់នូវសេចក្ដីទុក្ខដោយភារៈ ព្រោះភារៈ ជារបស់ធ្ងន់ ។ ឯខ្ញុំព្រះអង្គ ត្រូវភ្លើងកិលេសទាំង ៣ គឺ លោភៈ ទោសៈ មោហៈ ដុតកំដៅហើយ បានអន្ទោលទៅក្នុងភពទាំងឡាយ សឹងតែធ្ងន់ហើយ ដោយទម្ងន់ គឺភព ដូចជាគេដកយកភ្នំសិនេរុ (មកទូលលើក្បាល) ។

ឱរោបិតោ ច មេ ភារោ  កតំ ឧគ្ឃាដិតា មយា

ករណីយំ កតំ សព្វំ  សក្យបុត្តស្ស សាសនេ ។

យាវតា ពុទ្ធខេត្តម្ហិ  ឋបេត្វា សក្យបុង្គវំ

អហំ អគ្គោម្ហិ បញ្ញាយ  សទិសោ មេ ន វិជ្ជតិ ។

សមាធិម្ហិ សុកុសលោ  ឥទ្ធិយា បារមឹ គតោ

ឥច្ឆមានោ អហំ អជ្ជ  សហស្សំ អភិនិម្មិនេ ។

អនុបុព្វវិហារស្ស  វសីភូតោ មហាមុនិ

កថេសិ សាសនំ មយ្ហំ  និរោធោ សយនំ មម ។

ទិព្វចក្ខុ វិសុទ្ធំ មេ  សមាធិកុសលោ អហំ

សម្មប្បធានមនុយុត្តោ  ពោជ្ឈង្គភាវនារតោ ។

សាវកេន ហិ បត្តព្វំ  សព្វមេវ កតំ មម

លោកនាថំ ឋបេត្វាន  សទិសោ មេ ន វិជ្ជតិ ។



ភារៈនោះ ខ្ញុំព្រះអង្គ បានទំលាក់ចោលហើយ កពព័នឡាយ ខ្ញុំព្រះអង្គ ក៏បានទម្លាយចោលហើយ កិច្ចទាំងពួង ដែលគួរធ្វើក្នុងសាសនា របស់ព្រះសក្យបុត្ត ខ្ញុំព្រះអង្គបានធ្វើរួចហើយ ។ ពុទ្ធខេត្តមានកំណត់ត្រឹមណា វៀរលែងតែព្រះអង្គ ជាបុគ្គលប្រសើរក្នុងសក្យត្រកូលចេញ ខ្ញុំព្រះអង្គជាបុគ្គលប្រសើរ ដោយប្រាជ្ញា មិនមែនបុគ្គលណា ស្មើនឹងខ្ញុំព្រះអង្គពុំបាន ។ ខ្ញុំព្រះអង្គឈ្លាសវៃចំណាប់ ក្នុងសមាធិ ដល់នូវបារមីញាណ ដោយឫទ្ធិ ថ្ងៃនេះ (បើ) ខ្ញុំព្រះអង្គប្រាថ្នា (នឹងធ្វើឫទ្ធិ) ក៏និម្មិតរូបប្រមាណ ១ ពាន់រូបបាន ។ ព្រះមហាមុនីទ្រង់ស្ទាត់ស្ទាញ ក្នុងអនុបុព្វវិហារធម៌ បានសំដែងនូវសាសនធម៌ ដល់ខ្ញុំព្រះអង្គ ឯព្រះនិព្វាន ជាគ្រឿងដេកដេក ជាទីដេករបស់ខ្ញុំព្រះអង្គ ។ ទិព្វចក្ខុរបស់ខ្ញុំព្រះអង្គស្អាតហើយ ខ្ញុំព្រះអង្គជាបុគ្គលឈ្លាសវៃ ក្នុងសមាធិ បានប្រកបក្នុងសម្មប្បធាន ត្រេកអរក្នុងការចំរើន ពោជ្ឈង្គ ។ កិច្ចណា ដែលសាវកគួរដល់ កិច្ចទាំងអស់នោះ ខ្ញុំព្រះអង្គធ្វើស្រេចហើយ វៀរលែងតែព្រះលោកនាថចេញ មិនមែនបុគ្គលណា ស្មើនឹងខ្ញុំព្រះអង្គ ពុំបានឡើយ ។

សមាបត្តិម្ហិ កុសលោ ឈានវិមោក្ខានំ ខិប្បំ បដិលាភី
ពោជ្ឈង្គភាវនារតោ សាវកគុណបារមិំ គតោស្មិ ។
សាវកគុណផុស្សេន(១) ពុទ្ធិយា បុរិសុត្តមគារវា
សទ្ធាសទ្ធហិតំ(២) ចិត្តំ សទា សព្រហ្មចារិសុ ។
ឧទ្ធដទាឋោ(៣)សប្បោ ឆិន្នវិសាណោវ ឧសភោ
និក្ខិត្តមានទប្បោវ ឧបេមិ គរុគារវេន គណំ ។
យទិ រូបិនី ភវេយ្យ បញ្ញា មេ វសុបតីនំ សមេយ្យ(៤)
អនោមទស្សិស្ស ភគវតោ ផលមេតំ ញាណថវនាយ ។
បវត្តិតំ ធម្មចក្កំ សក្យបុត្តេន តាទិនា
អនុវត្តេមហំ សម្មា(៥) ញាណថវនាយិទំ ផលំ ។
មា មេ កទាចិ បាបិច្ឆោ កុសីតោ ហីនវីរិយោ
អប្បស្សុតោ អនាចារោ សមេតោ(៦) កត្ថចិ អហុ ។

១ ម. សាវកគុណបេតំ ផុស្សេន ។ ២ ម. យំ សទ្ធាសន្តហិតំ ។ ៣ ម. ឧទ្ធដវិសោ។ ៤ ម. បតីនសមេយ្យ ។ ៥ ម. អនុវត្តេសហំ សត្ថុំ ។ ៦ ម. សម្មតោ ។



ខ្ញុំព្រះអង្គ ជាបុគ្គលឈ្លាសវៃ ក្នុងសមាបត្តិ ជាអ្នកបាននូវឈាន និងវិមោក្ខ យ៉ាងរហ័ស ត្រេកអរក្នុងការចំរើននូវពោជ្ឈង្គ ដល់ហើយនូវបារមីញាណ នៃសាវកគុណ ។ ចិត្ត (របស់ខ្ញុំព្រះអង្គ) ដែលសង្រួមហើយល្អ ក្នុងពួកសព្រហ្មចារី សព្វ ៗ កាល ព្រោះសេចក្តីគោរព ចំពោះបុរសប្រសើរដោយប្រាជ្ញា ដោយការបាននូវសាវកគុណ ។ ខ្ញុំព្រះអង្គមានសេចក្តីមោក គឺមានះដាក់ចុះហើយ ដូចពស់មានចង្កូមដកចេញហើយ ក៏ដូចជាគោឧសភស្នែងបាក់ ខ្ញុំព្រះអង្គ ចូលមកកាន់ទីប្រជុំសង្ឃ ដោយសេចក្តីគោរពក្រៃពេក ។ ឯបញ្ញា របស់ខ្ញុំព្រះអង្គ ប្រសិនបើមានរូប គប្បីស្មើនឹងស្តេចផែនដីគ្រប់ នេះជាផល នៃការសរសើរនូវញាណ របស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមអនោម-ទស្សី ។ ធម្មចក្រដែលព្រះសក្យបុត្ត ជាតាទិបុគ្គល ទ្រង់ឲ្យប្រព្រឹត្តទៅហើយ ខ្ញុំព្រះអង្គឲ្យប្រព្រឹត្តទៅតាម ដោយប្រពៃ នេះជាផលនៃការសរសើរនូវញាណ ។ (មួយទៀត) បុគ្គល អ្នកមានសេចក្តីប្រាថ្នាលាមក ជាបុគ្គលខ្ជិល មានព្យាយាមថោកថយ មិនចេះដឹង ប្រព្រឹត្តអនាចារ កុំឲ្យមក

ពហុស្សុតោ ច មេធាវី សីលេសុ សុសមាហិតោ

ចេតោសមថានុយុត្តោ អបិ ពុទ្ធំ តិដ្ឋតុ ។

និក្ខេ វណាមិ គន្ធំ តេ(១) យាវត្តក សមាគតា

អបរិជ្ជា ហោធ សត្តូនំ ញាណំ ធត្វា សទា អហុ(២)។

យេនាហំ បឋមំ ទិស្វា វិរជោ វិមលោ អហុ (៣)

សោ មេ អាចរិយោ ធីរោ អស្សជិ នាម សាវកោ ។

តស្សាហំ សាសនេ អជ្ជ ធម្មសេនាបតី អហុ(៣)

សព្វត្ថ បារមឹ បត្តោ វិហរាមិ អនាសវោ ។

យោ មេ អាចរិយោ អាសិ អស្សជិ នាម សាវកោ

យស្សំ ទិសាយំ វសតិ ឧស្សីសម្ហិ ករោមហំ ។

---

១ ម. កន្ទុតេ ។ ២ ម. ញាណបេឌា ឈានធាតុ សទា ។ ៣ ម. អហុំ ។



ជួបប្រទះនឹងព្រះអង្គ ក្នុងទីណាមួយបានឡើយ ។ បុគ្គល ជាអ្នកចេះដឹងច្រើន អ្នកមានប្រាជ្ញា អ្នកមានចិត្តតាំងមាំ ក្នុងសីល និងអ្នកប្រកបរឿយៗ នូវចេតោសមថៈ សូមចូល មកតាំងលំនៅលើក្បាល (របស់ខ្ញុំ) ។ ព្រោះហេតុនោះ ខ្ញុំ សូមពោលនឹងលោកទាំងឡាយ សូមអ្នកដឹងច្រើន (មាន) ដល់លោកទាំងឡាយ ទាំងអស់ ដែលបានមកជួបជុំ ក្នុង ទីនេះ សូមលោកទាំងឡាយមានប្រាជ្ញាតិច សព្វកាល ជា គាំឲ្យមាន សព្វៗ កាលចុះ ។ ខ្ញុំបានឃើញនូវអាចារ្យអង្គ ណា ជាដំបូង ហើយបានប្រាសចាកធូលី ប្រាសចាកមន្ទិល អាចារ្យខ្ញុំនោះ ជាអ្នកប្រាជ្ញ ជាសាវ័ក ឈ្មោះអស្សជិ ។ ខ្ញុំ ជាអ្នកស្តាប់ពាក្យនៃព្រះអស្សជិអង្គនោះ បានជាធម្មសេនាបតី បានដល់នូវបារមី ក្នុងទីទាំងពួងហើយ ជាអ្នកមិនមានអា-សវៈ ។ ព្រះសាវ័ក ឈ្មោះអស្សជិ ជាអាចារ្យរបស់ខ្ញុំ គង់ ក្នុងទិសណា ខ្ញុំធ្វើទីក្បាលដំណេក ទៅក្នុងទិសនោះ ។

មម កម្មំ សរិត្វាន គោតមោ សក្យបុង្គវោ

ភិក្ខុសង្ឃេ និសីទិត្វា អគ្គដ្ឋានេ ឋបេសិ មំ[១] ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សារីបុត្តោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សារីបុត្តត្ថេរស្ស អបទានំ សមត្តំ ។

## បាឡិ មហាមោគ្គល្លានត្ថេរាបទានំ

(២) អនោមទស្សី ភគវា លោកជេដ្ឋោ នរាសភោ

វិហាសិ ហិមវន្តម្ហិ ទេវសង្ឃបុរក្ខតោ ។

វរុណោ នាម នាមេន នាគរាជា អហំ តទា

កាមរូបី វិកុព្វាមិ មហោទធិនិវាសហំ[២] ។

---

១ ម. ឥតោ បរំ កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា ពន្ធំ ឆេត្វា នាគោវ វិហរាមិ អនាសវោ ។ ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ឥមេ គាថា អត្ថិ ។

២ ម. មហោទធិនិវាសយំ ។



ព្រះគោតម ជាបុគ្គលប្រសើរក្នុងសក្យត្រកូល ទ្រង់ជ្រាបឃើញនូវអំពើរបស់ខ្ញុំ ទ្រង់គង់ក្នុងកណ្តាលភិក្ខុសង្ឃ ហើយតាំងខ្ញុំទុកនូវក្នុងទីដ៏ប្រសើរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសារីបុត្តត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សារីបុត្តត្ថេរាបទាន ។

## មហាមោគ្គល្លានត្ថេរាបទាន ទី ២

(២) ព្រះមានព្រះភាគព្រះនាមអនោមទស្សី ជាច្បងក្នុងលោក ជាឧសភៈ មានពួកទេវតាចោមរោម ទ្រង់គង់នៅក្នុងព្រៃហិមពាន្ត ។ គ្រានោះ ខ្ញុំកើតជាស្តេចនាគ ឈ្មោះវរុណៈ នៅក្នុងមហាសមុទ្រ ចេះនិម្មិតប្រែបានតាមសេចក្តីប្រាថ្នា ។

អត្ថិយកណិ(១) ហិត្វា តុរិយំ បដ្ឋបេសហំ

សមុទ្ទំ បរិភេត្វា ភវេសុំ អដ្ឋក តទា ។

វិជ្ជមានេសុ តុរិយេសុ ទេវតុរិយានិ(២) វជ្ជយុំ

ឧភិន្នំ សទ្ទំ សុត្វាន ពុទ្ធោបិ សម្បពុជ្ឈថ ។

និមន្តយិត្វា សម្ពុទ្ធំ សកំ ភវនមុបាគមឹ

អាសនំ បញ្ញាបេត្វាន កាលមារោចយឹ អហំ ។

ខីណាសវសហស្សេហិ បរិវុតោ(៣) លោកនាយកោ

ឱភាសេន្តោ ទិសា សព្វា ភវនំ មេ ឧបាគមិ ។

ឧបវិដ្ឋំ មហាវីរំ ទេវទេវំ នរាសភំ

ភិក្ខុសង្ឃំ សន្តប្បេសឹ អន្នបានេនហំ តទា ។

១ ឱ. សង្គណិយំ ឥតិ ។ ២ ឱ. ទេវតូរិយំ ។ ៣ បរិវុតោ ។



វេលានោះ ខ្ញុំបានលះបង់នូវពួកនាគជាបរិវារ ហើយបានផ្ដើមប្រគំតូរ្យតន្ត្រី ឯពួកស្រីអប្សរ (នាងនាគមាណវិកា) ក៏ដោយលេងប្រគំ ថ្វាយព្រះសម្ពុទ្ធដែរ ។ កាលមានតូរ្យតន្ត្រីរបស់ពួកនាគហើយ ពួកទេវតា ក៏ចាតុម្មហារាជិកា ក៏បានប្រគំ នូវតូរ្យតន្ត្រីទិព្វ ឯព្រះសម្ពុទ្ធទ្រង់ឮ ទ្រង់ជ្រាបច្បាស់នូវសម្លេង នៃតូរ្យតន្ត្រីទាំងពីរពួកនោះ ។ បន្ទាប់មក ខ្ញុំបាននិមន្តព្រះសម្ពុទ្ធ ហើយវិលត្រឡប់ចូលទៅកាន់ពិមានរបស់ខ្លួនវិញ បានក្រាលអាសនៈ រួចហើយទៅក្រាបបង្គំទូលភត្តកាល ។ ព្រះលោកនាយក មានពួកព្រះខី-ណាស្រព មួយពាន់ចោមរោម ទ្រង់ផ្សាយនូវពន្លឺរស្មី សព្វទិស ហើយស្ដេចចូលទៅ កាន់លំនៅរបស់ខ្ញុំ ។ វេលានោះ ខ្ញុំបានអង្គាសព្រះពុទ្ធមានព្យាយាមធំ ទ្រង់ជាទេវតាប្រសើរជាងទេវតា ជានរាសភៈ និងភិក្ខុសង្ឃដែលចូលទៅគង់លំនៅខ្ញុំ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។

## ចតុត្ថំ មហាមោគ្គល្លានត្ថេរាបទានំ

អនុមោទិ មហាវីរោ សយម្ភូ អគ្គបុគ្គលោ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ សោ សង្ឃំ អបូជេសិ ពុទ្ធញ្ច លោកនាយកំ
តេន ចិត្តប្បសាទេន ទេវលោកំ គមិស្សតិ ។
សត្តសត្តតិក្ខត្តុញ្ច ទេវរជ្ជំ ករិស្សតិ
បឋព្យា រជ្ជំ អដ្ឋសតំ វសុធំ អាវសិស្សតិ ។
បញ្ចបញ្ញាសក្ខត្តុំ ច ចក្កវត្តិ ករិស្សតិ
ភោគា អសង្ខិយា តស្ស ឧប្បជ្ជិស្សន្តិ តាវទេ ។
អបរិមេយ្យេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន សត្ថា លោកេ ភវិស្សតិ ។
និរយា សោ ចវិត្វាន មនុស្សត្តំ គមិស្សតិ
កោលិតោ នាម នាមេន ព្រហ្មពន្ធុ ភវិស្សតិ ។



## មហាមោគ្គល្លានត្ថេរាបទាន ទី ៤

ព្រះសយម្ភូ ជាអគ្គបុគ្គល មានព្យាយាមធំ លុះទ្រង់ធ្វើអនុមោទនារួចហើយ ទើបទ្រង់គង់ក្នុងកណ្ដាល នៃភិក្ខុសង្ឃ ហើយទ្រង់សំដែង នូវព្រះគាថាទាំងឡាយនេះថា បុគ្គលនេះ បានបូជាព្រះពុទ្ធ ជាលោកនាយកផង ព្រះសង្ឃផង ដោយចិត្តជ្រះថ្លានោះ នឹងបានទៅកើត ក្នុងទេវលោក ។ បុគ្គលនេះ នឹងសោយទេវរជ្ជសម្បត្តិ អស់ ៧៧ ដង នឹងគ្រប់គ្រងរាជ្យលើផែនដី អស់ ១០៨ ដង ។ នឹងបានជាស្ដេចចក្រពត្តិ អស់ ៥៥ ដង ឯទ្រព្យសម្បត្តិរាប់មិនអស់ នឹងកើតឡើង សម្រាប់ស្ដេចចក្រពត្តិនោះ ក្នុងកាលនោះ ។ ក្នុងកប្បរាប់មិនបាន អំពីកប្បនេះ នឹងមានព្រះពុទ្ធមួយអង្គ ព្រះនាមគោតម កើតក្នុងត្រកូលឱក្កាកៈ នឹងបានជាសាស្ដាក្នុងលោក ។ បុគ្គលនោះ នឹងឃ្លាតចេញអំពីនរក មកកើតជាមនុស្ស មានឈ្មោះថាកោលិត ជាជាតិព្រាហ្មណ៍ ។ លុះតាំង

សោ បច្ឆា បព្វជិត្វាន កុសលមូលេន ចោទិតោ
គោតមស្ស ភគវតោ ទុតិយោ ហេស្សតិ សាវកោ ។
អារទ្ធវិរិយោ បហិតត្តោ ឥទ្ធិយា បារមឹ គតោ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សត្យនាសវោ ។
បាបមិត្តោបនិស្សាយ កាមរាគវសំ គតោ
មាតរំ បិតរញ្ចាបិ ឃាតយឹ ទុដ្ឋមានសោ ។
យំ យំ យោនុបបជ្ជាមិ និរយំ អថ មានុសំ
បាបកម្មសមង្គិតិ(១) ភិន្នសីសោ មរាមហំ ។
ឥទំ បច្ឆិមកំ មយ្ហំ ចរិមោ វត្តតេ ភវោ
ឥធាបិ ឯទិសំ(២) មយ្ហំ មរណកាលេ ភវិស្សតិ ។
បវិវេកមនុយុត្តោ សមាធិភាវនារតោ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។

---
១ ម. បាបកម្មសមង្គិតា ។ ២ ម. ឯទិសោ ។



ក្រោយមក កោលិតមាណពនោះ ត្រូវកុសលមូលដាស់តឿន ក៏បានចេញបួស នឹងបានជាទុតិយសាវ័ក របស់ព្រះមានព្រះភាគ ព្រះនាមគោតម លោកផ្តើមសេចក្តីព្យាយាម មានចិត្តស្ងប់ចុះទៅកាន់ព្រះនិព្វាន លោកដល់នូវបារមីដោយឫទ្ធិ កំណត់ដឹងនូវអាសវធម៌ទាំងពួង ជាអ្នកមិនមានអា-សវធម៌ នឹងបរិនិព្វាន ។

ខ្ញុំលុះក្នុងអំណាចនៃកាមរាគ ព្រោះអាស្រ័យនឹងបាប-មិត្ត មានចិត្តប្រទូស្ត ក៏បានសម្លាប់មាតានិងបិតា ។ ខ្ញុំចូលទៅយកកំណើតណា ៗ ទោះបីជានរកក្តី ជាមនុស្សក្តី ស៊ីនបរិបូណ៌ដោយបាបកម្ម ស្លាប់តែងតែបែកក្បាល ។ ជាតិនេះជាបច្ឆិមជាតិរបស់ខ្ញុំ ភពជាគំរប់ក្រោយ ប្រព្រឹត្តទៅហើយ ក្នុងពេលនេះខ្ញុំនឹងត្រូវមរណកាល ដែលដូចនេះទៀត ។ ខ្ញុំប្រកបរឿយ ៗ ក្នុងវិវេក ត្រេកអរក្នុងការចម្រើនសមាធិ កំណត់ដឹងនូវអាសវធម៌ទាំងពួង ទាំងជាអ្នកមិនមានអាសវធម៌ ។

ចតុត្ថំ មហាមោគ្គល្លានត្ថេរាបទានំ

ធរណឹបិ សុគម្ភីរំ ពហលំ ទុប្បធំសិយំ
វាមង្គុដ្ឋេន ចាលេយ្យំ[១] ឥទ្ធិយា បារមឹ គតោ ។
អស្មិមានំ ន បស្សាមិ មានោ មយ្ហំ ន វិជ្ជតិ
សាមណេរេ ឧបាទាយ គរុចិត្តំ ករោមហំ ។
អបរិមេយ្យេ ឥតោ កប្បេ យំ កម្មំ អភិនីហរឹ[២]
តាហំ ភូមឹ អនុប្បត្តោ បត្តោម្ហិ អាសវក្ខយំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មហាមោគ្គល្លានោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មហាមោគ្គល្លានត្ថេរស្ស អបទានំ សមត្តំ ។

---
១ ម. ខោភេយ្យំ ។ ២ ម. អភិនីហរឹ ។



មហាមោគ្គល្លានត្ថេរាបទាន ទី ៤

ខ្ញុំបានដល់នូវបារមីនៃឫទ្ធិ ហើយញ៉ាំងព្រះធរណី ដ៏ជ្រៅ ទំនងក្រាស់ ដែលបុគ្គលមិនអាចឲ្យកម្រើកបាន ឲ្យកម្រើកបាន ដោយចុងម្រាមជើងឆ្វេង ។ ខ្ញុំមិនដែលឃើញអស្មិមានះ មានះរបស់ខ្ញុំ មិនដែលមានទេ ខ្ញុំធ្វើចិត្តគោរព ចំពោះសមណៈ តាំងពីសាមណេរទៅ ។ ក្នុងកប្បរាប់មិនបាន ហួសមកដល់កប្បនេះ ខ្ញុំបានបំពេញនូវបុញ្ញកម្មណា ។ ក៏បានសម្រេចនូវសាវកភូមិនោះ តាំងពីបានដល់នូវអាសវក្ខ័យ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាមោគ្គល្លានត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មហាមោគ្គល្លានត្ថេរាបទាន ។

# បញ្ចមំ មហាកស្សបត្ថេរាបទានំ

(៨) បទុមុត្តរស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
និព្វុតេ លោកនាថម្ហិ បូជំ កុព្វន្តិ សត្ថុនោ ។
ឧទគ្គចិត្តា ជនតា អាមោទិតបមោទិតា
តេសុ សំវេគជាតេសុ បីតិ មេ ឧទបជ្ជថ ។
ញាតិមិត្តេ សមានេត្វា ឥទំ វចនមព្រវឹ
បរិនិព្វុតោ មហាវីរោ ហន្ទ បូជំ ករោម សេ ។
សាធូតិ តេ បដិស្សុត្វា ភិយ្យោ ហាសំ ជនឹសុ មេ
ពុទ្ធស្មឹ លោកនាថម្ហិ កាហាម បុញ្ញសញ្ចយំ ។
អគ្ឃិយំ សុកតំ កត្វា សតហត្ថំ សមុគ្គតំ
ទិយឌ្ឍំ ហត្ថសតំបិ វិមានំ នភមុគ្គតំ ។





# មហាកស្សបត្ថេរាបទាន ទី ៥

(៨) កាលព្រះមានព្រះភាគ ទ្រង់ព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ជាទីពឹងនៃសត្វលោក ទ្រង់បរិនិព្វានទៅ ពួកជនទាំងឡាយធ្វើការបូជាព្រះសាស្តានោះ ។ ប្រជុំជនមានចិត្តខ្ពស់ មានចិត្តសប្បាយរីករាយ កាលញាតិនិងមិត្តនៃខ្ញុំទាំងនោះ កំពុងកើតសង្វេគ បីតិកើតឡើងដល់ខ្ញុំ ។ ខ្ញុំប្រជុំញាតិនិងមិត្តទាំងឡាយ ហើយពោលពាក្យនេះថា ព្រះលោកនាថ មានព្យាយាមធំ ទ្រង់បរិនិព្វានហើយ បើដូច្នោះ យើងនឹងធ្វើការបូជា ។ ញាតិនិងមិត្តទាំងនោះទទួលស្តាប់ថា ប្រពៃហើយ ក៏ញុំាងសេចក្តីរីករាយឲ្យកើតដល់ខ្ញុំដោយច្រើន ខ្ញុំបានធ្វើនូវការសន្សំបុណ្យក្នុងព្រះពុទ្ធជាទីពឹង នៃសត្វលោក នោះ ។ ខ្ញុំបានសង់វិមាន មានកំពស់ ១០០ ហត្ថ មានទំហំ ១៥០ ហត្ថ ខ្ពស់ទើសអាកាស ជាវិមានមានដំបូល ដែលគេធ្វើយ៉ាងល្អ ។

កត្វាន អគ្ឃិយំ(១) តត្ថ   កុសលបន្តីហិ(២) ចិត្តិតំ
សកំ ចិត្តំ បសាទេត្វា   ចេតិយំ បូជយុត្តមំ ។
អគ្គិក្ខន្ធោ ជលតិ   សាលរាជាវ ផុល្លិតោ(៣)
ឥន្ទលដ្ឋីវ អាកាសេ   ឱភាសតិ ចតុទ្ទិសា ។
តត្ថ ចិត្តំ បសាទេត្វា   កត្វាន កុសលំ ពហុំ
បុព្វកម្មំ សរិត្វាន   តិទសំ ឧបបជ្ជហំ ។
សហស្សយុត្តំ ហយវាហិំ   ទិព្វយានំ អធិដ្ឋិតោ
ឧព្វិទ្ធំ ភវនំ មយ្ហំ   សត្តភូមំ សមុគ្គតំ ។
កូដាគារសហស្សានិ   សព្វសោណ្ណមយា អហុ(៤)
ជលន្តិ សកតេជេន   ទិសា សព្វា បភាសយុំ ។
សន្តិ អញ្ញេបិ និយ្យូហា   លោហិតង្គមយា តទា
តេបិ ជោតន្តិ អាភាយ   សមន្តា ចតុរោ ទិសា ។
បុញ្ញកម្មាភិនិព្វត្តា   កូដាគារា សុនិម្មិតា
មណិមយាបិ ជោតន្តិ   ទិសោ ទស សមន្តតោ ។

១ ម. ហម្មិយំ ។ ២ ម. តាលបន្តីហិ ។ ៣ ម. អគ្គិក្ខន្ធោវ ជលិតោ កឹសុកោ ឥវ ផុល្លិតោ ។ ៤ ម. សព្វេ សោណ្ណមយា អហុំ ។





ខ្ញុំស្ថាបនាវិមានដ៏មានដំបូល វិចិត្រដោយគំនរកុសលជាជួរឡាយ ក្នុងទីនោះហើយ បានញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បានបូជានូវចេតិយដ៏ប្រសើរ ។ ឯចេតិយនោះរុងរឿង ដូចគំនរភ្លើង ឬដូចស្ដេចសាលព្រឹក្សមានផ្ការីក ភ្លឺស្វាងក្នុងទិសទាំង ៤ ដូចឥន្ទធនូក្នុងអាកាស ។ ខ្ញុំញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងចេតិយនោះ ហើយធ្វើកុសលដ៏ច្រើន ខ្ញុំបានទៅកើតក្នុងឋានតាវត្តិង្ស ព្រោះរឭកឃើញបុព្វកម្មនោះ ។ ខ្ញុំជិះយានទិព្វ ទឹមដោយសេះមួយពាន់ ឯវិមាន ៧ ជាន់ ដ៏ខ្ពស់ កើតឡើងសម្រាប់ខ្ញុំ ។ ផ្ទះមានកំពូលមួយពាន់ ជាវិការៈនៃមាសសុទ្ធ រុងរឿងជាទិព្វ ទិសទាំងពួង សឹងតែភ្លឺដោយតេជះរបស់ខ្លួន ។ ផ្ទះមានមុខដទៃទៀត ជាវិការៈនៃកែវក្រហម មានក្នុងកាលនោះ ផ្ទះទាំងនោះភ្លឺថ្លាល ដោយរស្មី ទៅកាន់ទិសទាំង ៤ ដោយជុំវិញ ។ ផ្ទះមានកំពូលទាំងឡាយ កើតឡើងដោយបុញ្ញកម្ម ដ៏តាក់តែងល្អ ជាវិការៈនៃកែវមណី តែងភ្លឺព្រាលទៅកាន់ទិសតូចទិសធំ ដោយជុំវិញ ។

តេសំ ឧជ្ជោតមានានំ ឱភាសោ វិបុលោ អហុ
សព្វេ ទេវេ អភិភោមិ បុញ្ញកម្មស្សិទំ ផលំ ។
សដ្ឋិកប្បសហស្សម្ហិ ឧព្វិទ្ធោ នាម ខត្តិយោ
ចាតុរន្តោ វិជិតាវី បថវឹ អាវសឹ អហំ ។
ឥមេ ច ភទ្ទកេ កប្បេ តិំសក្ខត្តុំ អហោសហំ
សកកម្មាភិរទ្ធោហំ ចក្កវត្តិ មហព្ពលោ ។
សត្តរតនសម្បន្នោ ចតុទ្ទីបម្ហិ ឥស្សរោ
ឥន្ទាចិ ការំ មយ្ហំ ឥន្ទលដ្ឋីវ ឧគ្គតំ ។
អាយាមតោ ចតុព្វីសា វិត្ថារេន ច ទ្វាទស
រម្មកំ(១) នាម នគរំ ទឡ្ហបាការតោរណំ ។
អាយាមតោ បញ្ចសតំ វិត្ថារេន តទឌ្ឍកំ
អាកិណ្ណំ ជនកាយេហិ តិទសានំ បុរំ វិយ ។

១ ម. រម្មណំ ។





ផ្នូកកំពូលទាំងនោះកាលភ្លឺឡើង ស្មើគ្នាហើយ ខ្ញុំគ្របសង្កត់នូវទេវតាទាំងពួង នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៦ ហ្មឺន អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិព្រះនាមឧព្វិទ្ធៈ មានសមុទ្រទាំង ៤ ជាព្រំដែន ជាស្តេចឈ្នះលើផែនដី គ្រប់គ្រងផែនដី ។ ក្នុងកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិមានកម្លាំងច្រើន អស់ ៣០ ដង ខ្ញុំបានត្រេកអរនូវកម្មរបស់ខ្លួន (ប្រព្រឹត្តរួចជាយកផលមី ១០) ។ ខ្ញុំបរិបូណ៌ដោយកែវទាំង ៧ ជាឥស្សរៈក្នុងទ្វីបទាំង ៤ ប្រាសាទរបស់ខ្ញុំ ខ្ពស់ត្រដែតដូចជាផ្លុកបន្ទោរ ក្នុងរដ្ឋកាលនៃស្តេចចក្រពត្តិនោះ ។ ទីក្រុងឈ្មោះរម្មកៈ មានបណ្តោយ ២៤ យោជន៍ ទទឹង ១២ យោជន៍ មានកំពែងនិងក្លោងទ្វារដ៏មាំ ។ ឯកំពែងនោះ មានបណ្តោយ ៥០០ យោជន៍ មានទទឹង ២៥០ យោជន៍ កុះករដោយពួកជនទាំងឡាយ ដូចជាបុរីនៃទេវតា ក្នុងឋានត្រៃត្រឹង្ស ។

បញ្ចប់ មហាកស្សបត្ថេរាបទានំ

យថា សូចិឃរេ សូចី   បក្ខិត្តា បណ្ណរសតិ

អញ្ញមញ្ញំ បឃដ្ដេន្តិ   អាកិណ្ណា ហោតិ សតតា ។

ឯវម បុរំ មយ្ហំ   ហត្ថស្សរថសង្កុលំ

មនុស្សេហិ គណាកិណ្ណំ   រម្មកំ នគរុត្តមំ ។

តត្ថ ភុត្វា បិវិត្វា ច   បុន ទេវត្តំ គតោ

ភវេ បច្ឆិមកេ មយ្ហំ   អហោសិ កុលសម្បទា ។

ព្រាហ្មញ្ញកុលសម្ភូតោ   មហារតនសញ្ចយោ

អសីតិកោដិយោ ហិត្វា   ហិរញ្ញស្ស បរិច្ចជិំ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មហាកស្សបោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

មហាកស្សបត្ថេរស្ស អបទានំ សមត្តំ ។



មហាកស្សបត្ថេរាបទាន ទី ៤

ម្ជុលមានចំនួន ៦៤ ដែលគេយកទៅច្រក ក្នុងបំពង់ម្ជុល ពេញណែន រមែងកកិតជិតជាប់គ្នា យ៉ាងណាមិញ ។ ទីក្រុងរបស់ខ្ញុំ កុះករដោយដំរី សេះ រថ ទីក្រុងនោះ ច្រើនដោយពួកមនុស្ស ជាក្រុងវិសេសគួរជាទីត្រេកអរ ក៏យ៉ាងនោះដែរ ។ ខ្ញុំបរិភោគ (ភោជន) ផង ផឹកទឹកផង ក្នុងបុរនោះ រួចហើយទៅកាន់អត្តភាពជាទេវតាទៀត ក្នុងបច្ឆិមភព ខ្ញុំបរិបូណ៌ដោយត្រកូលខ្ពង់ខ្ពស់ ។ ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ ជាអ្នកសម្បូណ៌ដោយរតនៈច្រើន បានលះបង់ហិរញ្ញៈចំនួន៨០ កោដិ ហើយចេញបួស ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាកស្សបត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មហាកស្សបត្ថេរាបទាន ។

## ឆដ្ឋំ អនុរុទ្ធត្ថេរាបទានំ

[៦] សុមេធំ ភគវន្តាហំ លោកជេដ្ឋំ នរាសភំ
វូបកដ្ឋំ វិហរន្តំ អទ្ទសំ លោកនាយកំ ។
ឧបគន្ត្វាន សម្ពុទ្ធំ សុមេធំ លោកនាយកំ
អញ្ជលឹ បគ្គហេត្វាន ពុទ្ធសេដ្ឋំ អយាចហំ ។
អនុកម្ប មហាវីរ លោកជេដ្ឋ នរាសភ
បទីបន្តេ បទស្សាមិ រុក្ខមូលម្ហិ ឈាយតោ ។
អធិវាសេសិ សោ ធីរោ សយម្ភូ វទតំ វរោ
ទុមេសុ វិនិវិជ្ឈិត្វា យន្តំ យោជេត្វាហត្តទា ។
សហស្សវដ្ដិទាទាសឹ ពុទ្ធស្ស លោកពន្ធុនោ
សត្តាហំ បជ្ជលិត្វាន ទីបា វូបសមឹសុ(១) ។

១ ម. ទីបា វូបសមឹសុ មេ ។



## អនុរុទ្ធត្ថេរាបទាន ទី ៦

[៦] ខ្ញុំបានឃើញព្រះមានព្រះភាគ ទ្រង់ព្រះនាមសុមេធៈ ជាច្បងក្នុងលោក ជានរាសភៈ ជាលោកនាយក ទ្រង់ចេញចាកគណៈ ហើយគង់នៅតែមួយអង្គឯង ។ ទើបខ្ញុំចូលទៅជិតព្រះសុមេធសម្ពុទ្ធ ជាលោកនាយក ហើយផ្គងអញ្ជលីអារាធនាព្រះសម្ពុទ្ធដ៏ប្រសើរថា បពិត្រព្រះអង្គ ទ្រង់មានព្យាយាមធំ ជាច្បងក្នុងលោក ជានរាសភៈ សូមព្រះអង្គអនុគ្រោះ ខ្ញុំព្រះអង្គសូមថ្វាយប្រទីប ដល់ព្រះអង្គដែលទ្រង់ចម្រើនឈាន ក្បែរគល់ឈើ ។ ព្រះសយម្ភូ ជាអ្នកប្រាជ្ញ ប្រសើរជាងពួកអ្នកប្រាជ្ញនោះ ទ្រង់បានទទួលហើយគង់នៅនោះ ខ្ញុំបានចម្លុះឈើទាំងឡាយ ដើម្បីប្រកបនូវប្រទីប ។ មិនតែប៉ុណ្ណោះ ខ្ញុំបានថ្វាយប្រទេះចង្កៀងមួយពាន់ ដល់ព្រះសម្ពុទ្ធជាលោកពន្ធុ ឯប្រទីបទាំងឡាយ ក៏ឆេះរុងរឿងឡើង អស់ ៧ ថ្ងៃ ហើយទើបរលត់ទៅវិញ ។

តេន ចិត្តប្បសាទេន   ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ   វិមានំ ឧបបជ្ជហំ ។

ឧបបន្នស្ស ទេវត្តំ   ព្យម្ហោ(១) អាសិ សុនិម្មិតោ

សមន្តតោ បជ្ជលតិ   ទីបទានស្សិទំ ផលំ ។

អដ្ឋវីសតិក្ខត្តុំ   ចក្កវត្តី អហោសហំ

ទិវារត្តិញ្ច បស្សាមិ   សមន្តា យោជនំ តទា ។

សមន្តា យោជនំ សត្តំ   វិភេទេមិ អហំ តទា

សព្វេ ទេវេ អភិភោមិ   ទីបទានស្សិទំ ផលំ ។

តឹសកប្បានិ ទេវិន្ទោ   ទេវរជ្ជមការយឹ

ន មំ កេចាតិមញ្ញន្តិ   ទីបទានស្សិទំ ផលំ ។

សហស្សលោកំ ញាណេន   បស្សាមិ សត្ថុសាសនេ

ទិព្វចក្ខុំ អនុប្បត្តោ   ទីបទានស្សិទំ ផលំ ។

១ ឱ. ព្យម្ហំ ។





លុះខ្ញុំលះបង់កាយ ជារបស់មនុស្សហើយ ទៅកើតក្នុងវិមាន (ឋានសួគ៌) ដោយចិត្តជ្រះថ្លានោះផង ដោយការតាំងចេតនានោះផង ។ កាលដែលខ្ញុំទៅកើតជាទេវតាហើយ មានប្រាសាទដែលបុញ្ញកម្ម តាក់តែងដោយល្អ ភ្លឺរុងរឿងដោយជុំវិញ នេះជាផលនៃការថ្វាយនូវប្រទីប ។ ខ្ញុំកើតជាស្ដេចចក្រពត្តិអស់ ២៨ ដង បានឃើញរូប ចម្ងាយ ១ យោជន៍ជុំវិញ ទាំងថ្ងៃទាំងយប់ក្នុងកាលនោះ ។ ខ្ញុំតែងធ្វើនូវទិសទាំងពួង ចម្ងាយ ១ យោជន៍ដោយជុំវិញ ឲ្យភ្លឺរុងរឿង ក្នុងកាលនោះ ខ្ញុំគ្របសង្កត់ទេវតាទាំងអស់ នេះជាផលនៃការថ្វាយប្រទីប ។ ខ្ញុំជាធំជាងទេវតា បានសោយរាជ្យក្នុងពួកទេវតាអស់ ៣០ កប្ប ក៏គ្មានពួកទេវតាណា មើលងាយខ្ញុំបានឡើយ នេះជាផលនៃការថ្វាយនូវប្រទីប ។ ខ្ញុំបានសម្រេចទិព្វចក្ខុ ក្នុងសាសនានៃព្រះសាស្ដា តែងឃើញលោកធាតុមួយពាន់ដោយញាណ នេះជាផលនៃការថ្វាយនូវប្រទីប ។

សុមេធោ នាម សម្ពុទ្ធោ   តីសកប្បសហស្សិតោ
តស្ស ទីបោ មយា ទិន្នោ   វិប្បសន្នេន ចេតសា ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អនុបុព្វោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អនុបុព្វត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ បុណ្ណមន្តានីបុត្តត្ថេរាបទានំ

[៧] អជ្ឈាយកោ មន្តធរោ   តិណ្ណំ វេទាន បារគូ
បុរក្ខតោ សសិស្សេហិ   ឧបគច្ឆិំ នរុត្តមំ ។
បទុមុត្តរោ លោកវិទូ   អាហុតីនំ បដិគ្គហោ
មម កម្មំ បកិត្តេសិ   សង្ខិត្តេន មហាមុនិ ។
តាហំ ធម្មំ សុណិត្វាន   អភិវាទេត្វាន សត្ថុនោ
អញ្ជលឹ បគ្គហេត្វាន   បក្កាមឹ ទក្ខិណាមុខោ ។



ព្រោះតែខ្ញុំបានថ្វាយប្រទីប ដោយចិត្តជ្រះថ្លា ដល់ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈ ទ្រង់កើតក្នុងកាល ៣០ ពាន់កប្បនោះ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអនុបុព្វត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អនុបុព្វត្ថេរាបទាន ។

## បុណ្ណមន្តានីបុត្តត្ថេរាបទាន ទី ៧

[៧] ខ្ញុំជាអ្នករៀនមន្ត ចេះចាំមន្ត សម្រេចត្រៃវេទ មានពួកសិស្សហែហមហើយ បានចូលទៅគាល់ព្រះសម្មា-សម្ពុទ្ធ ដ៏ប្រសើរជាងនរជន ។ ព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវសត្វលោក ព្រះអង្គជាអ្នកគួរទទួលគ្រឿងបូជា បានសំដែងនូវកម្មរបស់ខ្ញុំដោយសង្ខេប ។ ខ្ញុំបានស្តាប់ធម៌នោះហើយ ក៏ផ្គងអញ្ជលីថ្វាយបង្គំព្រះសាស្តា ហើយបែរមុខត្រឡប់ ទៅកាន់ទិសទក្សិណ ដើរចេញទៅ ។

សត្តមំ បុណ្ណមន្តានីបុត្តត្ថេរាបទានំ

សង្ខិត្តេន សុណិត្វាន  វិត្ថារេន អទេសយឹ
សព្វេ សិស្សា អត្តមនា  សុត្វាន មម ភាសតោ ។
សកំ ទិដ្ឋឹ វិនោទេត្វា  ពុទ្ធេ ចិត្តំ បសាទយុំ
សង្ខិត្តេនបិ ទេសេមិ  វិត្ថារេន តថេវហំ(១) ។
អភិធម្មនយញ្ញូហំ  កថាវត្ថុវិសុទ្ធិយា
សព្វេសំ វិញ្ញាបេត្វាន  វិហរាមិ អនាសវោ ។
ឥតោ បញ្ចសតេ កប្បេ  ចតុរោ សុប្បកាសកា
សត្តរតនសម្បន្នា  ចតុទ្ទីបម្ហិ ឥស្សរា ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បុណ្ណោ មន្តានីបុត្តោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុណ្ណស្ស មន្តានីបុត្តត្ថេរស្ស អបទានំ សមត្តំ ។

១ ម. ទេសេសឹ វិត្ថារេនបិ កាសយឹ ។



បុណ្ណមន្តានីបុត្តត្ថេរាបទាន ទី ៧

ខ្ញុំបានស្តាប់ដោយសង្ខេប តែតថាគតសម្តែងដោយពិស្តារបាន ពួកសិស្សទាំងអស់ បានស្តាប់ភាសិតដែលខ្ញុំសម្តែង ក៏មានចិត្តត្រេកអរគ្រប់ៗគ្នា ។ ពួកសិស្សទាំងនោះ លះបង់នូវទិដ្ឋិរបស់ខ្លួនហើយ ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ខ្ញុំសម្តែងដោយសង្ខេបក៏បាន ដោយពិស្តារយ៉ាងនោះក៏បាន ។ ខ្ញុំឈ្លាសវៃក្នុងន័យព្រះអភិធម្ម ឈ្លាសវៃក្នុងវិសុទ្ធិ ក្នុងកថាវត្ថុ ញុំាងជនជាបណ្ឌិតទាំងពួង ឲ្យត្រាស់ដឹង ទាំងជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៥០០ អំពីភទ្ទកប្បនេះទៅ ខ្ញុំកើតជាស្តេចចក្រពត្តិ ៤ ដង មានកេរ្តិ៍ឈ្មោះល្បីល្បាញខ្ពរទៅ បរិបូណ៌ដោយកែវទាំង ៧ ប្រការ ជាឥស្សរៈក្នុងទ្វីប ៤ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុណ្ណមន្តានីបុត្តត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុណ្ណមន្តានីបុត្តត្ថេរាបទាន ។

## អដ្ឋមំ ឧបាលិត្ថេរាបទានំ

(៨) នគរេ ហំសវតិយា សុជាតោ នាម ព្រាហ្មណោ
អសីតិកោដិនិចយោ បហូតធនធញ្ញវា ។
អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន បារគូ
លក្ខណេ ឥតិហាសេ ច សទ្ធម្មេ បារមឹ គតោ ។
បរិព្វាជា ឯកសិខា គោតមា ពុទ្ធសាវកា
ចរកា តាបសា ចេវ ចរន្តិ មហិយា តទា ។
តេបិ មំ បរិវារេន្តិ ព្រាហ្មណោ វិស្សុតោ ឥតិ
ពហុជ្ជនោ មំ បូជេតិ នាហំ បូជេមិ កិញ្ចិនំ ។
បូជារហំ ន បស្សាមិ មានត្ថទ្ធោ អហំ តទា
ពុទ្ធោតិ វចនំ នត្ថិ តាវ នុប្បជ្ជតេ ជិនោ ។





## ឧបាលិត្ថេរាបទាន ទី៨

(៨) ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះសុជាត ក្នុងក្រុងហង្សវតី ជាអ្នកសន្សំទុកទ្រព្យសម្បត្តិ ចំនួន៨០កោដិ មានទ្រព្យនិងស្រូវជាច្រើន ។ ខ្ញុំជាអ្នករៀនមន្ត ទ្រទ្រង់មន្ត សម្រេចត្រៃវេទ ដល់នូវត្រើយក្នុងធម៌របស់ខ្លួន គឺក្បួនទាយលក្ខណៈ និងក្បួនឈ្មោះឥតិហាសៈ ។ ក្នុងគ្រានោះ ពួកបរិព្វាជក អ្នកមានផ្នួងសក់មួយ ពួកពុទ្ធសាវ័ករបស់ព្រះគោតម និងពួកតាបសអ្នកប្រព្រឹត្តតបៈ តែងត្រាច់ទៅលើផែនដី ។ ពួកជននោះ តែងហែហមខ្ញុំ ពួកជនជាច្រើនតែងបូជាខ្ញុំ ដោយសំគាល់ថាជាព្រាហ្មណ៍ មានកិត្តិស័ព្ទល្បីល្បាញ ខ្ញុំមិនបូជាជនណាមួយ ។ វេលានោះ ខ្ញុំជាមនុស្សរឹងត្អឹង ដោយមានះ មិនឃើញបុគ្គលគួរបូជា ពាក្យថាព្រះពុទ្ធ ក៏មិនដែលមាន ព្រោះព្រះជិនស្រី ទ្រង់មិនទាន់កើតឡើងនៅឡើយ ។

អដ្ឋមំ ទាលិគ្គោបទានំ

អជ្ឈាយេន អហោរត្តិំ   បទុមុត្តរនាយកោ(១)
សត្តាហំ តំ វិនោទេត្វា   លោកេ ឧប្បជ្ជិ ចក្ខុមា ។
វិត្ថារិតេ ពហុ ជញ្ញេ   បុថុភូតេ ច សាសនេ
បកាសេសិ តទា ពុទ្ធោ   ចតុរោ ហិ សច្ចានិ ។
បិតុ អត្ថាយ សោ ពុទ្ធោ   ធម្មំ ទេសេសិ ចក្ខុមា
តេន កាលេន បរិសា   សមន្តា យោជនំ តទា ។
សម្មតោ មនុជានំ យោ   សុនន្ទោ នាម តាបសោ
យាវតា ពុទ្ធបរិសា   បុប្ផច្ឆាទយិ តទា ។
ចតុសច្ចំ បកាសេន្តេ   សេដ្ឋេ(២) ច បុប្ផមណ្ឌបេ
កោដិសតសហស្សានំ   ធម្មាភិសមយោ អហុ ។
សត្តរត្តិន្ទិវំ ពុទ្ធោ   វស្សិត្វា ធម្មវុដ្ឋិយោ
អដ្ឋមេ ទិវសេ បត្តេ   សុនន្ទំ ព្យាករី ជិនោ ។

---

១ ម. បទុមុត្តនាយកោ ។ ២ ម. ហេដ្ឋា ។



ទាលិគ្គោបទាន ទី ៤

ល៉ុំរកខ្ញុំថ្ងៃនិងយប់ទៅ ព្រះពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុ កំចាត់បង់នូវងងឹតទាំងពួង ទ្រង់កើតឡើងក្នុងលោក ។ កាលបើពួកជន ជាអ្នកប្រាជ្ញ មានចំនួនច្រើនផ្សាយទៅផង សាសនាក៏ក្រាស់ក្រែលផង គ្រានោះ ព្រះសម្ពុទ្ធស្ដេចចូលទៅកាន់ក្រុងហង្សវតី ។ ព្រះពុទ្ធមានបញ្ញាចក្ខុនោះ ទ្រង់សម្ដែងធម៌ដើម្បីប្រយោជន៍ ដល់ព្រះបិតាក្នុងវេលានោះ ពួកបរិស័ទប្រមាណមួយយោជន៍ ដោយជុំវិញ (មកគាល់ព្រះអង្គ) តាមកាលដ៏គួរនោះ ។ គ្រានោះ តាបសឈ្មោះសុនន្ទៈ ដែលពួកមនុស្សគប់រកនាំ បានបាំងពួកបរិស័ទទាំងអស់ ដោយផ្កាទាំងឡាយ ។ កាលព្រះសម្ពុទ្ធ ទ្រង់ប្រកាសសច្ចៈទាំង ៤ ក្នុងមណ្ឌប ដ៏ប្រសើរ ពួកបរិស័ទមួយសែនកោដិ ក៏បានសម្រេចធម្មាភិសម័យ ។ ព្រះសម្ពុទ្ធ ទ្រង់បង្អុរភ្លៀង គឺព្រះធម៌ អស់ ៧ យប់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ ព្រះជិនស្រី ក៏ទ្រង់បានទំនាយ នូវតាបសឈ្មោះសុនន្ទៈថា

ទេវលោកេ មនុស្សេ វា សំសរន្តោ អយំ ភវេ
សព្វេសំ បវរោ ហុត្វា ភវេសុ សំសរិស្សតិ ។
កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន[១] សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
មន្តានិបុត្តោ បុណ្ណោតិ ហេស្សតិ សត្ថុ សាវកោ ។
ឯវំ កិត្តយិ សម្ពុទ្ធោ សុនន្ទំ តាបសំ តទា
ហាសយន្តោ ជនំ សព្វំ ទស្សយន្តោ សកំ ពលំ ។
កតញ្ជលី នមស្សន្តិ សុនន្ទំ តាបសំ តទា
ពុទ្ធេ ការំ ករិត្វាន សោធេសិ គតិមត្តនោ ។
តត្ថ មេ អហុ សង្កប្បោ សុត្វាន មុនិនោ វចំ
អហំ ការំ ករិស្សាមិ យថា បស្សាមិ គោតមំ ។

១ ម. គោត្តេន ។



សុនន្ទតាបសនេះ កាលអន្ទោលទៅក្នុងភពគឺទេវលោក ឬ មនុស្សលោក នឹងបានជាអ្នកប្រសើរជាងទេវតា ជាងជន មនុស្សទាំងអស់ នឹងអន្ទោលទៅក្នុងភពទាំងឡាយ ។ លុះដល់កប្បមួយសែនកប្ប នឹងមានព្រះសម្ពុទ្ធ ព្រះនាមគោតម កើតឡើងក្នុងត្រកូលឱក្កាកៈ នឹងបានជាសាស្តាក្នុងលោក ។ សុនន្ទតាបសនេះ នឹងបានជាទាយាទក្នុងធម៌ ជាឱរស ជាធម្មនិម្មិត ជាសាវ័ក ឈ្មោះបុណ្ណៈ ជាបុត្រនៃនាងមន្តានី របស់ព្រះសាស្តានោះ ។ លុះព្រះសម្ពុទ្ធ បានព្យាករសុនន្ទតាបសយ៉ាងនេះហើយ បានញ៉ាំងជនទាំងពួងឲ្យរីករាយ ទ្រង់សម្តែងនូវកម្លាំង របស់ព្រះអង្គ ។ វេលានោះ ពួកបរិស័ទបានប្រណម្យអញ្ជលីនមស្ការចំពោះសុនន្ទតាបស សុនន្ទតាបសក៏ធ្វើសក្ការបូជាចំពោះព្រះសម្ពុទ្ធ ជម្រះហើយនូវគតិរបស់ខ្លួនឲ្យស្អាត ។ ខ្ញុំបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះមុនី (ព្រះនាមបទុមុត្តរៈ) ក៏មានបំណងក្នុងវេលានោះថា អាត្មាអញនឹងបានឃើញព្រះគោតមយ៉ាងណា នឹងធ្វើសក្ការបូជាយ៉ាងនោះ ។

### អដ្ឋមំ គាថាសំភ្លេងទាន

ឯវាហំ ចិន្តយិត្វាន · កិរិយំ ចិន្តយឹ មមំ

ក្យាហំ កម្មំ អាចរាមិ បុញ្ញក្ខេត្តេ អនុត្តរេ ។

អយញ្ច បាឋិកោ ភិក្ខុ សព្វបាឋីច សាសនេ

វិនយេ អគ្គនិក្ខិត្តោ តំ ឋានំ បត្ថយឹ អហំ ។

ឥតិ មេ អមិតំ ភោគំ អក្ខោភំ សាគរូបមំ

តេន ភោគេន ពុទ្ធស្ស អារាមំ មាបយេ អហំ ។

សោភនំ នាម អារាមំ នគរស្ស បុរត្ថតោ

កិណិត្វា សតសហស្សេន សង្ឃារាមំ អមាបយឹ ។

កូដាគារេ ច បាសាទេ មណ្ឌបេ ហម្មិយេ គុហា

ចង្កមេ សុកតេ កត្វា សង្ឃារាមេ អមាបយឹ ។

ជន្តាឃរំ អគ្គិសាលំ អថោ ឧទកមាឡកំ

ន្ហានឃរំ មាបយិត្វា ភិក្ខុសង្ឃស្សទាសហំ ។



### គាថាសំភ្លេងទាន ទី ៨

លុះខ្ញុំគិតយ៉ាងនេះរួចហើយ ទើបគិតរកបុញ្ញកិរិយាក្រៅ ដែលខ្ញុំគួរធ្វើជា អាត្មាអញទើបប្រព្រឹត្តធ្វើអំពើហ្នឹង គឺបុញ្ញក្ខេត្តដ៏ប្រសើរ ។ ឯភិក្ខុជាអ្នកស្រុកអង្គនេះ ព្រះមានព្រះភាគបានតាំងជា ជាអ្នកប្រសើរខាងព្រះវិន័យ ជាភិក្ខុអ្នកស្រុកចាំងក្នុង គឺសាសនា ដូច្នេះ អាត្មាអញ ទើបត្រូវតែយកតំ-ណែងនោះ ។ ទ្រព្យរបស់អាត្មាអញនេះ ច្រើនណាស់ កប់មិនអស់ ចុះមានដូចសាគរ បុគ្គលមិនអាចនឹងឲ្យញាប់ញ័របានឡើយ ហេតុនេះ អាត្មាអញគួរសាងអារាមថ្វាយព្រះសង្ឃដោយទ្រព្យនោះ ។ ខ្ញុំបានសាងអារាមមួយ ឈ្មោះសោ-ភនៈ នៅខាងមុខទីក្រុង ឲ្យជាអារាមសំរាប់សង្ឃ អស់ចំនួនមួយសែនគហាបណៈ ។ ខ្ញុំបានសាងផ្ទះមានកំពូលផង ប្រាសាទវែងផង មណ្ឌបផង ប្រាសាទមានដំបូលរលីងផង គុហាផង ចង្ក្រមដ៏ល្អផង គឺអារាមរបស់សង្ឃ ។ មួយទៀត ខ្ញុំបានសាងរោងកំដៅកាយ រោងភ្លើង រោងទឹក បន្ទប់សំរាប់ស្រង់ទឹក ថ្វាយចំពោះព្រះភិក្ខុសង្ឃ ។

អាសន្ទិយោ ច បីឋកេ　　បរិភោគេ ច ភាជនេ
អាតបត្តញ្ច ភេសជ្ជំ　　សព្វមេតំ អទាសហំ ។
អាគន្តុំ បដ្ឋបេត្វាន　　ឋាតារំ ការយិំ ធជេ
ហ ដំ កោដិ វិហារេសុ　　សត្តធត្តាន តាធិធំ ។
អាភាសេ សតសហស្សេ　　សង្ឃារាមេ អមាបយិំ
វេបុល្លំ មាបយិត្វា　　សមុទ្ទំ ឧបជាមយិំ ។
ចិន្ទាបិតោ មយា កមោ　　សម្បជិច្ច ទុរំ អុធិ
និយ្យាទេស្វាមិ តំ ជីរ　　អធិវាសេហិ ចក្ខុម ។
បទុមុត្តរោ លោកវិទូ　　អាហុតីនំ បដិគ្គហោ
មម សង្កប្បមញ្ញាយ　　អធិវាសេសិ នាយកោ ។
អធិវាសនមញ្ញាយ　　សព្វញ្ញុស្ស មហេសិនោ
ភោជនំ បដិយាទេត្វា　　កាលមារោចយិំ អហំ ។



ខ្ញុំបានថ្វាយជើងម៉ា តាំង គ្រឿងប្រើប្រាស់ ភាជន៍ ភេសជ្ជៈ ទាំងអស់នុ៎ះ សម្រាប់អាកម ។ ខ្ញុំបានតាំងទុកបុគ្គលអ្នករក្សា ឲ្យគេធ្វើកំពែងយ៉ាងមាំ (ការពារ) កុំឲ្យមានសត្រូវណាមួយ មកបៀតបៀនព្រះអង្គ ទ្រង់ជាគតិបុគ្គល មានព្រះហឫទ័យស្ងប់ស្ងាប់ ។ ខ្ញុំបានឲ្យគេសាងអាវាស ជាអារាមសម្រាប់សង្ឃ អស់ចំនួនប្រាំមួយសែន លុះសាងអារាមមានសភាពល្អកល្អមហើយ ក៏បានបង្ហើនថ្វាយដល់ព្រះសម្ពុទ្ធជា បពិត្រព្រះមុនី អារាមខ្ញុំបានឲ្យគេសាងស្រេចហើយ សូមព្រះអង្គទទួលយក បពិត្រព្រះធីរៈ ខ្ញុំព្រះអង្គនឹងថ្វាយទាន ចំពោះព្រះអង្គ បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គទ្រង់ទទួលនិមន្ត ។ ព្រះលោកនាយក ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវសត្វលោក ទ្រង់គួរទទួលយក នូវគ្រឿងបូជា ទ្រង់ទទួលនិមន្តហើយ ព្រោះទ្រង់ជ្រាប នូវបំណងរបស់ខ្ញុំ ។ លុះខ្ញុំបានដឹងថា ព្រះអង្គទ្រង់ទទួលនិមន្តហើយ ទើបតាក់តែងនូវភោជនាហារ បម្រើថ្វាយដល់ព្រះសព្វញ្ញូ ទ្រង់ស្វែងរកគុណដ៏ធំ រួចហើយទើបក្រាបទូលភត្តកាល ។

អារោចិតម្ហិ កាលម្ហិ    បទុមុត្តរនាយកោ
ខីណាសវសហស្សេហិ    អារាមំ មេ ឧបាគមិ ។
និសិន្នំ កាលមញ្ញាយ    អន្នបានេន តប្បយិំ
ភុត្តាវិំ កាលមញ្ញាយ    ឥទំ វចនមព្រវិ ។
កីតោ សតសហស្សេន    តត្តកេនេវ ការិតោ
សោភនោ នាម អារាមោ    សម្បដិច្ឆ មហាមុនិ ។
ឥមិនារាមទានេន    ចេតនាបណិធីហិ ច
ភវេ និព្វត្តមានោហំ    លភាមិ មម បត្ថិតំ ។
បដិគ្គហេត្វា សម្ពុទ្ធោ    សង្ឃារាមំ សុមាបិតំ
ភិក្ខុសង្ឃេ និសីទិត្វា    ឥទំ វចនមព្រវិ ។
យោ សោ ពុទ្ធស្ស បាទាសិ    សង្ឃារាមំ សុមាបិតំ





លុះខ្ញុំក្រាបទូលនូវភត្តកាលរួចហើយ ទើបព្រះលោកនាយក ព្រះនាមបទុមុត្តរៈ ស្ដេចមកកាន់អារាមរបស់ខ្ញុំ (មួយអន្លើ) ដោយព្រះខីណាស្រព ប្រមាណមួយពាន់អង្គ ។ ខ្ញុំដឹងនូវវេលាដែលព្រះអង្គ ទ្រង់គង់សិប់ហើយ ក៏បានញុំាងព្រះអង្គឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក លុះខ្ញុំដឹងនូវវេលាដែលព្រះអង្គសោយស្រេចហើយ ទើបក្រាបបង្គំទូលនូវពាក្យនេះថា បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គបានជាវដី អស់តម្លៃមួយសែនកហាបណៈ បានឲ្យគេសាងអារាម ឈ្មោះសោភនៈ ដោយតម្លៃកហាបណៈប៉ុណ្ណោះដែរ សូមព្រះអង្គទ្រង់ទទួល ។ ដោយការថ្វាយអារាមនេះផង ដោយការតម្កល់ចេតនាទាំងនេះផង ខ្ញុំព្រះអង្គកាលទៅកើតក្នុងភព (ណា ៗ) សូមឲ្យបានសម្រេច តាមដែលខ្ញុំព្រះអង្គប្រាថ្នា ។

ព្រះសម្ពុទ្ធទ្រង់បានទទួលសង្ឃារាម ដែលខ្ញុំបានសាងល្អហើយ ព្រះអង្គគង់កណ្ដាលនៃជំនុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះថា បុគ្គលណា បានថ្វាយសង្ឃារាម ដែលខ្លួនបានសាងល្អហើយ ដល់ព្រះពុទ្ធ គថាគតនិង

តមហំ កាំក្ខយំសុភ្ជមិ    សុណាជ មម ការណា ។
ហត្ថី អស្សា រថា បត្តី    សេនា ច ចតុរង្គិនី
បរិវារេន្តិ មំ និច្ចំ    សង្ឃារាមស្សិទំ ផលំ ។
សដ្ឋី តុរិយសហស្សានិ(១)    ភេរិយោ សមលង្កតា
បរិវារេន្តិ មំ និច្ចំ    សង្ឃារាមស្សិទំ ផលំ ។
ចឡាសីតិសហស្សានិ    នារិយោ សមលង្កតា
វិចិត្តវត្ថាភរណា    អាមុត្តមណិកុណ្ឌលា ។
អឡារបម្ហា(២) ហសុលា    សុសញ្ញា តនុមជ្ឈិមា
បរិវារេន្តិ មំ និច្ចំ    សង្ឃារាមស្សិទំ ផលំ ។
តីសកប្បសហស្សានិ    ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ ទេវិន្ទោ    ទេវរជ្ជំ ករិស្សតិ ។
ទេវកេជន បត្តំ    សព្វំ បដិលភិស្សតិ
អនូនភោគោ ហុត្វាន    ទេវរជ្ជំ ករិស្សតិ ។

---

១ ម. តូរិយសហស្សានិ ។ ២ ម. អាឡារបម្ហា ។



ព្យាករបុគ្គលនោះ អ្នកចាំទីឡាយ ខ្ញុំស្តាប់នូវផលកុសលមួន៍ ខ្ញុំ ។ សេនាមានអង្គ ៤ គឺ ដំរី សេះ រថ ពលថ្មើរជើង ហែហម ដោយបុគ្គលនេះជានិច្ច នេះជាផលនៃសង្ឃារាម ។ តូរ្យតន្ត្រី ៦០ ពាន់ និងស្គរប្រដាប់ល្អហើយ ហែហមដោយបុគ្គលនេះ ជានិច្ច នេះជាផលនៃសង្ឃារាម ។ ពួកនារី ចំនួន ៨៤ ពាន់ ស្អិតស្អាងល្អហើយ សើងស្លៀកសំពត់ និងគ្រឿងអាភរណៈ វិចិត្រ ពាក់កណ្ឌលជាវិការៈនៃកែវមណី ។ (នារីទាំងនោះ) មានមុខស្រស់ក្រាយ មានសរីរៈល្អ មានចង្កេះរៀវ ហែហម ដោយបុគ្គលនេះជានិច្ច នេះជាផលនៃសង្ឃារាម ។ បុគ្គល នេះ នឹងត្រេកអរក្នុងទេវលោក អស់ ៣០ ពាន់កប្ប បាន ជាធំជាងទេវតា សោយទេវរជ្ជ អស់ចំនួនមួយពាន់ដង ។ នឹងបានសម្បត្តិទាំងពួង ដែលទៅជាបរិបូណ៌ ជាអ្នកមាន ភោគៈមិនខ្វះខាត ហើយសោយរាជ្យក្នុងមនុស្សលោក ។

សហស្សក្ខត្តុំ ចក្កវត្តិ   រាជា រជ្ជំ ករិស្សតិ
បទេសរជ្ជំ វិបុលំ   គណនាតោ អសង្ខិយំ ។
កប្បសតសហស្សម្ហិ   ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន   សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ   ឱរសោ ធម្មនិម្មិតោ
ឧបាលិ នាម នាមេន   ហេស្សតិ សត្ថុសាវកោ ។
វិនយេ បារមឹ បត្វា   ឋានាឋានេ ច កោវិទោ
ជិនសាសនំ ធារយន្តោ   វិហរិស្សតិនាសវោ ។
សព្វមេតំ អភិញ្ញាយ   គោតមោ សក្យបុង្គវោ
ភិក្ខុសង្ឃេ និសីទិត្វា   ឯតគ្គេ ឋបេស្សតិ ។
អបរិមេយ្យំ ឧបាទាយ   បត្ថេមិ តវ សាសនំ
សោ មេ អត្ថោ អនុប្បត្តោ   សព្វសំយោជនក្ខយោ ។



នឹងបានជាស្តេចចក្រពត្តិក្នុងផែនដី អស់មួយពាន់ដង នឹងបានជាស្តេចផែនដី ដ៏ស្តុកស្តម្ភ គណនារាប់មិនបាន ។ លុះផុតមួយសែនកប្បទៀត ព្រះគោតមបរមគ្រូ កើតក្នុងត្រកូលឱក្កាកៈ នឹងបានជាសាស្តា ក្នុងលោក ។ បុគ្គលនេះនឹងបានជាទាយាទ ជាឱរស ក្នុងធម៌ ជាធម្មនិម្មិត មាននាមជាឧបាលិ នឹងបានជាសាវ័ក នៃព្រះសាស្តានោះ ។ នឹងដល់នូវត្រើយ ក្នុងព្រះវិន័យផង ឈ្លាសវៃក្នុងហេតុនិងមិនមែនហេតុផង ទ្រទ្រង់នូវសាសនា របស់ព្រះជិនស្រី តាំងជាបុគ្គលមិនមានអាសវៈ ។ ព្រះគោតមជាបុគ្គលប្រសើរក្នុងសក្យត្រកូល ទ្រង់ជ្រាបច្បាស់ហេតុនុះ សព្វគ្រប់ហើយ ទ្រង់គង់ក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយនឹងតាំងទុកឧបាលិនុះ ក្នុងឯតទគ្គៈ ។

ខ្ញុំប្រាថ្នានូវសាសនា គឺពាក្យប្រៀនប្រដៅ របស់ព្រះអង្គ តាំងអំពីកប្បរាប់មិនបាន ប្រយោជន៍ គឺការអស់ទៅនៃសញ្ញោជនៈទាំងពួងនោះ ខ្ញុំបានសម្រេចហើយ ។

យថា ស្វណាវុតោ ពោសោ  ភជនេណ្ហាម ឥដ្ឋិតោ
សុលេ សាតំ អវិន្ទន្តោ  បរិមុត្តឹ វ ឥច្ឆតិ ។
ឥមេវាហំ មហាវីរ  ភវនេណ្ហាម ឥដ្ឋិតោ
កាមស្សណាវុតោ សន្តោ  បិពាសាវេទនដ្ឋិតោ ។
ភវេ សាតំ ន វិន្ទាមិ  ឌយ្ហន្តោ តីហិ អគ្គិហិ
បរិមុត្តឹ គវេសាមិ  យថា ន ភជនណ្ហាតោ ។
យថា វិសាភតោ បុរិសោ  វិសេន បរិបីឡិតោ
អគទំ សោ គវេសេយ្យ  វិសឃាតាយុបាយនំ ។
គវេសមានោ បស្សេយ្យ  អគទំ វិសឃាតកំ
តំ បិវិត្វា សុខី អស្ស  វិសម្ហា បរិមុត្តិយា ។
ឥមេវាហំ មហាវីរ  យថា វិសហតោ នរោ
សម្បីឡិតោ អវិជ្ជាយ  សទ្ធម្មាគទមេសហំ(១) ។

១ ម. សទ្ធម្មាគទមេសយិំ ។



បុរសជាប់គន្លឹះដែកអណ្ដាត ត្រូវកង់ចំណងត្រូវមរហើយ មិនបានស្រួលគន្លឹះដែកអណ្ដាត ព្រោះជាប់ចំណងរឿយៗ ដូចម្ដេចមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គត្រូវកា-ជាតិគកត្រូវមរហើយ ជាប់នៅហើយ គន្លឹះដែកអណ្ដាតតិកម្ម ជាប់នៅហើយដោយចំណងគឺវេទនា គឺសេចក្ដីស្រេកឃ្លាន ។ មិនបានស្រួលគន្លឹះគត ក្ដៅក្រហាយដោយភ្លើងទាំង ៣ ស្វែងរកនូវឧបាយ ដើម្បីនឹងរួចស្រឡះ ដូចបុរសដែលត្រូវជាប់ដើម្បីរួច ចាកចំណងយ៉ាងនោះ ។ មួយទៀត បុរសអ្នកត្រៀកត្រា ត្រូវពិសបៀតបៀនហើយ គេក៏ស្វែងរកនូវឱសថ ដោយប្រាថ្នាដើម្បីបន្សាបនូវពិស ។ កាលស្វែងរក ក៏បានឃើញនូវឱសថ ដែលជាគ្រឿងបន្សាបនូវពិស ក៏ផឹកនូវឱសថនោះ ហើយក៏បានសេចក្ដីសុខ ព្រោះរួចផុតអំពីពិស យ៉ាងណាមិញ ។ បពិត្រព្រះអង្គមានព្យា-យាមធំ ខ្ញុំព្រះអង្គ ក៏ដូចជាជនអ្នកលង់នៅក្នុងពិស ត្រូវអវិជ្ជាបៀតបៀនហើយ បានស្វែងរកឱសថគឺព្រះសទ្ធម្ម ។

ជម្ពាកតិំ ករេសន្តោ    អន្ធក្កិំ សក្យសាសនំ
អក្ខសន្ទោសជាតន្តិ(១)    សព្វសល្យារំ ជោឧជំ ។
ជន្ទោសជំ ចិត្តាឧ    វិសំ សព្វំ សមូហនិ
អជកបរំ សីតិការំ    ធញ្ញានំ បស្សយំ អហំ ។
យថា ភូតគន្ធិតោ ហោសោ    ភូតក្កាហេឧ បិណ្ឌិតោ
ភូតវេជ្ជំ ករេសយ្យ    ភូតស្មា បរិមុត្តិយា ។
ករេសមានោ បស្សេយ្យ    ភូតវិជ្ជាសុ កោវិទំ
តស្ស សោ វិហញ្ញេ ភូតំ    សមូលញ្ច វិនាសយេ ។
ឧដេភយំ មហាវីរ    តមក្កាហេឧ បិណ្ឌិតោ
ញាណាលោកំ ករេសាមិ    តមតោ បរិមុត្តិយា ។
អជ្ជទ្ទសំ សក្យមុនិំ    កិលេសតមសោធនំ
សោ មេ តមំ វិនោទេសិ    ភូតវេជ្ជោវ ភូតកំ ។

១ ម. អន្ធំ សញ្ញោសតាន់ឆំ ។





កាលខ្ញុំស្វែងរកទស្សនធម៌ កំប្រុងនឹងចូលសាសនា របស់ព្រះសក្យមុនីសម្ពុទ្ធ ជាទស្សនីយៈ ដ៏ប្រសើរបំផុត ជាទីសម្រាប់ជាធ្លាប់នឹងនូវសេចក្តីខ្លួន ។ ខ្ញុំព្រះអង្គ បាននឹករកទស្សនធម៌ ហើយដកខ្លួនកំសត់ខ្លួនចេញ កំបានឃើញព្រះជិនពុទ្ធ ជាគុណដែលមានចាស់ស្លាប់ មានសេចក្តីក្រអាក់កំយ៉ាងនោះដែរ ។ បុរសត្រូវខ្មោចសង្កត់សង្កិនហើយ ត្រូវគ្រោះថ្នាក់ពីខ្មោចបៀតបៀនហើយ គប្បីស្វែងរកពេទ្យ សម្រាប់ចាប់ខ្មោច ដើម្បីឲ្យរួចផុតអំពីខ្មោច ។ បុរសនោះ កំពុងតែស្វែងរក កំបានឃើញបុគ្គលអ្នកឈ្លាសវៃ ក្នុងវិជ្ជាចាប់ខ្មោច បុគ្គលនោះ កំបានបំបាត់ខ្មោច ព្រមទាំងធ្វើឫសគល់ឲ្យវិនាស អំពីបុរសនោះចេញ យ៉ាងណាមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គត្រូវគ្រោះថ្នាក់ពីងងឹតបៀតបៀនហើយ កំទៅស្វែងរកពន្លឺពីញាណ ដើម្បីឲ្យផុតអំពីងងឹត កំបានប្រទះឃើញព្រះសក្យមុនី ទ្រង់ជម្រះងងឹតគឺកិលេសរួចហើយ ព្រះអង្គទ្រង់កំចាត់ងងឹត របស់ខ្ញុំព្រះអង្គដូចជាពេទ្យចាប់ខ្មោច បានបណ្តេញបង់នូវខ្មោចចេញ ។

សំសារសោតំ សញ្ឆិន្ទិ   តណ្ហាសោតំ ឆិកវយឹ
ករី ទុក្ខក្ខយំ សព្វំ   ភូតវេជ្ជោ ម្ហលោ ។
គរុឡោ យថា ឱបតតិ   បន្នគំ ភក្ខមត្តនោ
សមន្តា យោជនសតំ   វិក្ខោភតិ មហាសរំ ។
បន្នគំ សោ គហេត្វាន   អធោសីសំ វិហេឋយំ
អាទាយ សោ បក្កមតិ   យេន កាមំ វិហង្គមោ ។
តថេវាហំ មហាវីរ   យថាបិ គរុឡោ ពលី
អសង្ខតំ គវេសន្តោ   ទោសេ វិក្ខាលយឹ អហំ ។
ទិដ្ឋោ អហំ ធម្មវរំ   សន្តិបទំ អនុត្តរំ
អាទាយ វិហរាមេតំ   គរុឡោ បន្នគំ យថា ។
អាសាវតី នាម លតា   ជាតា ចិត្តលតាវនេ
តស្សា វស្សសហស្សេន   ឯកំ និព្វត្តតេ ផលំ ។



ខ្ញុំព្រះអង្គបានផ្តាច់បង់ នូវខ្សែសង្សារ ហាមឃាត់នូវខ្សែ តណ្ហា ធ្វើនូវការធ្វើទីបំផុតទុក្ខទាំងអស់ ប្រៀបដូចពេទ្យគាប់ខ្មោច (ពៀតពៀនខ្មោច) ឲ្យអស់ពួសពិស ក៏យ៉ាងនោះដែរ ។ សត្វគ្រុឌ ចាប់យកពួកនាគ ជាចំណីរបស់ខ្លួន ធ្វើមហាស្រះ ទំហំ ១០០ យោជន៍ដោយជុំវិញ ឲ្យកំរើកញាប់ញ័រ ។ លុះគ្រុឌនោះ ចាប់យកនាគ ធ្វើឲ្យមានក្បាលចុះក្រោម ឲ្យបាន សេចក្តីលំបាក ហើយនាំយកទៅកាន់ទី តាមសេចក្តីប្រាថ្នា របស់ខ្លួន យ៉ាងណាមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គ មានកម្លាំងខ្លាំងដូចគ្រុឌ ខ្ញុំព្រះអង្គកំពុងស្វែងរក អសង្ខតធម៌ គឺព្រះនិព្វាន ហើយបានលាងទោសទាំងឡាយចេញ អស់ហើយ ។ ខ្ញុំព្រះអង្គ បានឃើញព្រះធម៌ប្រសើរ ជា ចំណែកនៃសេចក្តីស្ងប់រម្ងាប់ មិនមានគុណជាតដទៃប្រសើរ លើស ហើយកាន់យកនូវធម៌នោះ ដូចគ្រុឌចាប់យកនាគ ក៏យ៉ាងនោះដែរ ។ វល្លិ៍ឈ្មោះអាសាវតី កើតក្នុងចិត្តលតាវ័ន កន្លងទៅមួយពាន់ឆ្នាំ វល្លិ៍នោះក៏កើតផ្លែមួយឡើង ។

តំ ទេវា បយិរុបាសន្តិ | តាវ ទូរផលំ សតំ
ទេវានំ សា បិយា ឯវំ | អាសាវតី លតុត្តមា ។
សតសហស្សំ ឧបាទាយ | តាហំ បរិចរេ មុនិំ
សាយំ បាតំ នមស្សាមិ | ទេវា អាសាវតឹ យថា ។
អវញ្ឈា បារិចរិយា | អមោឃា ច នមស្សនា
ទូរាគតំបិ មំ សន្តំ | ខណោ មំ(១) ន វិរាធយិ ។
បដិសន្ធឹ ន បស្សាមិ | វិចិនន្តោ ភវេ អហំ
និរូបធិ វិប្បមុត្តោ | ឧបសន្តោ ចរាមហំ ។
យថាបិ បទុមំ នាម | សុរិយរំសេន បុប្ផតិ
តថេវាហំ មហាវីរ | ពុទ្ធរំសេន បុប្ផិតោ ។
យថា ពលាកយោនិម្ហិ | ន វិជ្ជតិ បុមា(២) សទា
មេឃេសុ គជ្ជមានេសុ | គព្ភំ គណ្ហន្តិ តា សទា ។

---

១ ម. យំ ។ ២ ម. បុមេ ។





ពួកទេវតា (គឺពួកទេវតាក្នុងឋានត្រៃត្រិង្ស) តែងតែចូលទៅអង្គុយជិតវល្លិនោះ ដែលមានផ្លែយូរៗម្តង តាមពិត វល្លិឈ្មោះអាសាវតីនោះ មានផ្លែដ៏ឧត្តម ជាទីពេញចិត្តរបស់ពួកទេវតាយ៉ាងនេះ ។ ចំណែកខាងខ្ញុំព្រះអង្គ ខំបម្រើព្រះមុនីអង្គនោះ កប់សែនកប្ប (ប៉ុណ្ណោះ) តែងនមស្ការ កាលព្រឹកល្ងាច ដូចជាពួកទេវតា តែងចូលទៅអង្គុយជិតវល្លិអាសាវតី ។ ការបម្រើ (របស់ខ្ញុំព្រះអង្គ) មិនឥតអំពើ ទាំងការនមស្ការ ក៏មិនឥតប្រយោជន៍ៈ ពុទ្ធុប្បាទក្ខណៈ ក៏មិនបានប្រព្រឹត្តកន្លង ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។ ឥឡូវនេះ ខ្ញុំព្រះអង្គត្រិះរិះទៅមិនឃើញបដិសន្ធិ គឺកំណើតទៀតទេ ខ្ញុំព្រះអង្គមិនមានឧបធិកិលេស រួចស្រឡះចាកសង្សារ មានចិត្តស្ងប់រម្ងាប់ ។ ធម្មតាផ្កាឈូក តែងរីកដោយសាររស្មីនព្រះអាទិត្យ យ៉ាងណាមិញ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គបានរីកដោយសាររស្មីព្រះពុទ្ធ ក៏យ៉ាងនោះដែរ ។ កំណើតក្រុកស មិនមានឈ្មោលសព្វៗកាលទេ កាលបើមេឃគ្រហឹម (ផ្គរលាន់) ក្រុកទាំងនោះ ក៏កាន់យកគភ៌សព្វៗកាល ។

ចិរំបិ កត្តិំ ធារេន្តិ  យាវ មេឃោ ន(១) គជ្ជតិ
ការតោ បរិមុច្ចន្តិ  យថា មេឃោ បវស្សតិ ។
បទុមុត្តរពុទ្ធស្ស  ធម្មមេឃេន គជ្ជតោ
សទ្ទេន ធម្មមេឃស្ស  ធម្មកិត្តិំ អគណ្ហហំ ។
សតសហស្សំ ឥតោ កប្បេ  បុញ្ញកិត្តិំ ធរេមហំ
នប្បមុញ្ចាមិ ការតោ  ធម្មមេឃោ ន គជ្ជតិ ។
យទា ពុទ្ធោ សក្យមុនិ  រម្មេ កាបិលវត្ថវេ(២)
គជ្ជសិ ធម្មមេឃេន  ការតោ បរិមុច្ចហំ ។
សុញ្ញតំ អនិមិត្តញ្ច  [illegible] ច
ចតុរោ ច ផលេ សព្វេ  ធម្មំ វិជដំ តិបិហំ(៣) ។

ទុតិយភាណវារំ ។

---

១ ឱ. ម. វុដ្ឋិ ។ ២ ឱ. កបិលវត្ថវេ ។ ៣ ឱ. ធម្មំ វិជេសិ អហំ ។



ក្នុងជាតិនោះ ទ្រទ្រង់កិត្តិអស់កាលដ៏យូរ ដរាបណាលោកមេឃ
លាន់គម្រាម ដល់តែមេឃបង្អុរភ្លៀង ទើបក្នុងជាតិនោះ
រួចផុតចាកការៈ យ៉ាងណាមិញ ។ កាលព្រះពុទ្ធ ព្រះ
នាមបទុមុត្តរៈ ទ្រង់គម្រាមដោយមេឃគឺធម៌ ខ្ញុំព្រះអង្គបាន
កាន់យកនូវកិត្តិធម៌ ដោយសម្លេង នៃមេឃគឺធម៌ ។ ខ្ញុំ
ព្រះអង្គទ្រទ្រង់ នូវកិត្តិបុណ្យ អស់សែនកប្ប មេឃគឺធម៌
មិនគម្រាម (ដរាបណា) ខ្ញុំក៏មិនបានរួចចាកការៈគុក (ដរាប
នោះ) ។ បពិត្រព្រះសក្យមុនី ពេលណា ព្រះអង្គទ្រង់
គម្រាមដោយមេឃគឺធម៌ ក្នុងក្រុងកបិលព័ស្តុ ដែលជាទី
ត្រេកអរ ខ្ញុំព្រះអង្គក៏បានរួចចាកការៈគឺគុក យ៉ាងនោះដែរ ។
ខ្ញុំព្រះអង្គ (បានចំរើនឲ្យជាក់ច្បាស់) នូវសុញ្ញតវិមោក្ខផង
អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង ត្រាស់ដឹងនូវធម៌
ទាំងពួង គឺផលទាំង ៤ ផង ចម្រាយនូវធម៌ គឺបណ្ដាញ
នោះផង ។

ចប់ ទុតិយភាណវារៈ ។

### អត្ថបទ បាលីស្លោកកាន់

អបរិមេយ្យុបាទាយ បត្ថេមិ តវ សាសនំ

សោ មេ អត្ថោ អនុប្បត្តោ សន្តិបទំ អនុត្តរំ ។

វិនយេ បារមឹ បត្តោ យថាបិ បាឋិកោ ឥសី

ន មេ សមសមោ អត្ថិ ធារេមិ សាសនំ អហំ ។

វិនយេ ខន្ធកេ ចាបិ តិកច្ឆេទេ ច បញ្ចមេ

ឯត្ថ មេ វិមតិ នត្ថិ អក្ខរេ ព្យញ្ជនេបិ វា ។

និគ្គហេ បដិកម្មេ ច ឋានាឋានេ ច កោវិទោ

ឱសារណេ វុដ្ឋាបនេ សព្វត្ថ បារមឹ គតោ ។

វិនយេ ខន្ធកេ ចាបិ និក្ខិបិត្វា បទំ អហំ

ឧភតោ វិនិវេត្វា(១) រសតោ ឱសរេយ្យហំ ។

---

១ ម. វិនិវេឋេត្វា ។



### បាលីស្លោកកន ទី ៤

ខ្ញុំព្រះអង្គ ព្រោះជាខ្ញុំសាសនារបស់ព្រះអង្គ រាប់ពុំប្រមាណមិនបាន ប្រយោជន៍គឺចំណែកនៃសេចក្ដីស្ងប់ដ៏ប្រសើរបំផុត ខ្ញុំព្រះអង្គបានសម្រេចហើយ ។ ខ្ញុំព្រះអង្គដល់នូវត្រើយក្នុងព្រះវិន័យ ដូចភិក្ខុអ្នកស្វែងរកឧត្តមគុណ អ្នកស្ងប់ (ក្នុងផែនដីសាសនាព្រះពុទ្ធ ព្រះនាមបទុមុត្តរៈនោះដែរ) ភិក្ខុជាអ្នកមានគុណស្មើ នឹងខ្ញុំព្រះអង្គមិនមានឡើយ ខ្ញុំព្រះអង្គទ្រទ្រង់សាសនា ។ សេចក្ដីសង្ស័យរបស់ខ្ញុំព្រះអង្គ ក្នុងវិន័យនូវផង ក្នុងខន្ធកវិន័យផង ក្នុងតិកច្ឆេទៈផង ក្នុងបញ្ចកៈផង សូម្បីតែអក្ខរៈមួយ ឬព្យញ្ជនៈមួយមិនមានឡើយ ។ ខ្ញុំព្រះដល់នូវត្រើយក្នុងព្រះវិន័យទាំងពួង ក្នុងនិគ្គហៈការសង្កត់សង្កិនភិក្ខុបាបផង ក្នុងបដិកម្ម គឺការសម្ដែងអាបត្តិផង ក្នុងហេតុគួរនិងមិនគួរផង ក្នុងឱសារណកម្ម គឺការហៅភិក្ខុចូលកាន់ទីប្រជុំសង្ឃ ក្នុងការញ៉ាំងភិក្ខុឲ្យចេញចាកអាបត្តិផង ។ ខ្ញុំព្រះអង្គបានរៀបចំទុកដាក់នូវចំណែក ក្នុងវិន័យផង ក្នុងខន្ធកៈផង ក្នុងឧភតោវិភង្គផង ហើយគប្បីឲ្យប្រជុំចុះ ដោយកិច្ចបាន

និរុត្តិយា ច កុសលោ អត្ថធម្មេ ច កោវិទោ
អញ្ញាតំ មយា នត្ថិ ឯកគ្គោ សត្ថុ សាសនេ ។
រូបទក្ខោ អហំ អជ្ជ សក្យបុត្តស្ស សាសនេ
កង្ខំ សព្វំ វិនោទេមិ ឆិន្ទាមិ សព្វសំសយំ ។
បទំ អនុបទញ្ចាបិ(១) អក្ខរញ្ចាបិ ព្យញ្ជនំ
និទានេ បរិយោសានេ សព្វត្ថ កោវិទោ អហំ ។
យថាបិ រាជា ពលវា និហន្ត្វា(២) បរន្តបេ
វិជិនិត្វាន សង្គាមំ នគរំ តត្ថ មាបយេ ។
បាការំ បរិក្ខញ្ចាបិ ឯសិកំ ទ្វារកោដ្ឋកំ
អដ្ដាលកេ ច វិវិធេ ការយេ នគរេ ពហូ ។

១ អនុបទំ ញាណមិតិ អដ្ឋកថាយំ ទិស្សតិ ។ ២ ម. និគ្គហិត្វា ។



ខ្ញុំព្រះអង្គ ជាអ្នកឈ្លាសវៃ ក្នុងវេយ្យាករណ៍ ឈ្លាសវៃក្នុងហេតុជាប្រយោជន៍ និងហេតុមិនជាប្រយោជន៍ សភាពដែលខ្ញុំព្រះអង្គ មិនបានដឹង (នោះ) មិនមានឡើយ ខ្ញុំព្រះអង្គជាអ្នកប្រសប់ក្នុងសាសនារបស់ព្រះសាស្តា ។ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គជាបុគ្គលយល់រូប ក្នុងសាសនានៃព្រះពុទ្ធជាសក្យបុត្ត ហើយបន្ទោបង់នូវកង្ខាទាំងពួង កាត់បង់នូវសង្ស័យទាំងអស់បាន ។ ខ្ញុំព្រះអង្គ (ដឹងច្បាស់) នូវបទផង អនុបទផង អក្ខរៈផង ព្យញ្ជនៈផង ឈ្លាសវៃក្នុងហេតុសព្វអន្លើ គឺហេតុជាដំបូង (ខាងដើម) និងហេតុជាទីបំផុត (នៃសិក្ខាបទ) ។ ព្រះរាជាមានកម្លាំងច្បាំងសង្កត់សង្កិន នូវពួកស្តេចជាសត្រូវ លុះច្បាំងឈ្នះសង្គ្រាមហើយ ទើបសាងទីក្រុង ក្នុងទីដែលច្បាំងឈ្នះហើយនោះ ។ ទ្រង់ឲ្យជាងធ្វើកំពែង ស្នាមភ្លោះ សសរគោល ក្លោងទ្វារនិងប៉មទាំងឡាយផ្សេង ៗ ជាច្រើន ក្នុងនគរ ។

សិង្ឃាដកំ ចតុក្កញ្ច(១) សុវិភត្តន្តរាបណំ

ការាបេយ្យ សកំ រដ្ឋំ អត្ថានត្ថំ វិចិន្តយំ ។

និគ្ឃាតត្ថំ អមិត្តានំ និគ្គហនិគ្គហំ ជានិតុំ

ពលកាយស្ស រក្ខាយ សេនាមច្ចំ ឋបេតិ សោ ។

អារក្ខត្ថាយ កណ្ហស្ស និធានកុសលំ នរំ

មា មេ កណ្ហំ វិនស្សតិ កណ្ហារក្ខំ ឋបេតិ សោ ។

សមត្ថោ(២) ហោតិ សោ រញ្ញោ វុទ្ធិ យស្ស ច ឥច្ឆតិ

តស្សាធិករណំ ទេតិ មិត្តស្ស បដិបជ្ជតិ ។

ឧប្បាទេសុ និមិត្តេសុ លក្ខណេសុ ច កោវិទំ

អជ្ឈាយកំ មន្តធរំ បោរោហិច្ចេ ឋបេតិ សោ ។

១ ម. ចតុក្កំ ។ ២ ម. សមត្ថោ ។



ទ្រង់ឲ្យធ្វើនូវផ្លូវបែកជាបីផ្លូវ ផ្លូវបែកជាបួនផ្លូវ កន្លែងផ្សារទាំងឡាយ ដែលចាត់ចែងល្អ ក្រុមតាំងសភាសម្រាប់វិនិច្ឆ័យនូវសេចក្តីចម្រើន និងសេចក្តីមិនចម្រើន ក្នុងដែននោះ ។ ព្រះរាជាអង្គនោះ ទ្រង់តាំងសេនាមាត្យ ដើម្បីឲ្យសង្គ្រោះនូវពួកសេនា ឲ្យស្គាល់ទោសនិងមិនមែនទោស ដើម្បីរក្សានូវពួកពល ។ ព្រះរាជាអង្គនោះ ទ្រង់តាំងបុរសអ្នករក្សាខ្លួនកណ្ហៈ ជាអ្នកឈ្លាសវៃក្នុងការទុកដាក់ ដើម្បីប្រយោជន៍រក្សានូវកណ្ហៈ ដោយព្រះរាជបំណងថា កុំឲ្យកណ្ហៈរបស់គាត់អញវិនាសទៅបានឡើយ ។ បុរសនោះជាអ្នកមានចិត្តស្មោះត្រង់ចំពោះព្រះរាជា ព្រោះព្រះរាជា ប្រាថ្នាការចម្រើន ដល់បុរសណា ទ្រង់ក៏ព្រះរាជទាននូវឥស្សរៈ ក្នុងការវិនិច្ឆ័យអធិករណ៍ដល់បុរសនោះ ដើម្បីប្រតិបត្តិ កុំឲ្យបែកមិត្ត ។ ព្រះរាជានោះ ទ្រង់តាំងបុរសអ្នកឆ្លាត ក្នុងឧប្បាតហេតុទាំងឡាយផង ក្នុងនិមិត្តទាំងឡាយផង ក្នុងលក្ខណៈទាំងឡាយផង ជាអ្នកបានរៀនមន្ត ចេះចាំមន្ត ក្នុងឋានៈជាបុរោហិត ។

ឯតេហង្គេហិ សម្បន្នោ ខត្តិយោតិ បវុច្ចតិ
សទា រក្ខន្តិ រាជានំ ចក្កវត្តី ទុក្ខិតំ ។
តថេវ ត្វំ មហាវីរ ហតាមិត្តោ ខត្តិយោ
សទេវកស្ស លោកស្ស ធម្មរាជាតិ វុច្ចតិ ។
តិត្ថិយេ និហនិត្វាន មារញ្ចាបិ សសេនកំ
តមន្ធការំ វិធមេត្វា ធម្មនគរំ អមាបយិ ។
សីលំ បាការកំ តត្ថ ញាណន្តេ ទ្វារកោដ្ឋកំ
សទ្ធា តេ ឯសិកា ធីរ ទ្វារបាលោ ច សំវរោ ។
សតិបដ្ឋានមដ្ដាលំ បញ្ញា តេ ចច្ចរំ មុនេ
ឥទ្ធិបាទញ្ច សិង្ឃាដំ ធម្មវីថិ សុមាបិតំ (១) ។
សុត្តន្តំ អភិធម្មញ្ច វិនយញ្ចាបិ កេវលំ
នវង្គំ ពុទ្ធវចនំ ឯសា ធម្មសភា តវ ។

១ ឧ. សុមាបិតា ។



ព្រះរាជាបរិបូណ៌ ដោយអង្គទាំងឡាយនុ៎ះហើយ ទើបហៅថា ក្សត្រិយ៍ បុរសទាំងនោះតែងរក្សាព្រះរាជានោះ សព្វៗ កាល ដូចសត្វចក្រពាក ក្រោះព្រមញាតិ ដែលដល់សេចក្តីទុក្ខ ។ បពិត្រព្រះអង្គ មានព្យាយាមធំ អ្នកដទៃតែងហៅព្រះអង្គថា ធម្មរាជរបស់សត្វលោក ព្រមទាំងទេវលោក ដូចក្សត្រិយ៍ ដែលកំចាត់សត្រូវហើយ ដូច្នោះដែរ ។ ព្រះធម្មរាជនោះទ្រង់ញាំញីនូវពួកតិរ្ថិយទាំងឡាយផង នូវមារព្រមទាំងសេនាផង ទ្រង់កំចាយនូវសេចក្តីងងឹតនោះ រួចហើយកសាងធម្មនគរ ។ បពិត្រព្រះអង្គមានបញ្ញាជាគ្រឿងទ្រទ្រង់ ឯក្នុងធម្មនគរនោះ មានសីលជាកំពែង មានញាណរបស់ព្រះអង្គ ជាក្លោងទ្វារ មានសទ្ធារបស់ព្រះអង្គ ជាសសរខឿន មានការសង្រួម ជានាយទ្វារ ។ បពិត្រព្រះមុនី សតិប្បដ្ឋាន ជាប៉ម បញ្ញារបស់ព្រះអង្គ ជាផ្លូវបែក ឥទ្ធិបាទ ជាផ្លូវក្រវែល តែង ថ្នល់គឺពោធិបក្ខិយធម៌ទាំង៣៧ ព្រះអង្គទ្រង់និម្មិតទុក ល្អហើយ ។ ព្រះសូត្រ ព្រះអភិធម្ម និងព្រះវិន័យ ពុទ្ធ-វចនៈមានអង្គ ៩ ទាំងអស់នុ៎ះ ជាធម្មសភារបស់ព្រះអង្គ ។

សុញ្ញតំ អនិមិត្តញ្ច | វិហារញ្ចប្បណីហិតំ
អនេជោ ច និរោធោ ច | វសា ធម្មញ្ញុជី តេ ។
បញ្ញាយ អគ្គោ ធិក្កិត្តោ | បដិភាណេ ច កោវិទោ
សារីបុត្តោតិ នាមេន | ធម្មសេនាបតី តេ ។
ឥទ្ធិបាទកុសលោ | ឥទ្ធិយា ចារមី គតោ
កោលិតោ នាម នាមេន | ហោរកហិទ្ធោ តេ មុនេ ។
បោរាណកវំសធរោ | ឧត្តតេជោ ទុកសទោ
ធុតកធិគុណេ អគ្គោ | អគ្គកស្សោ តេ មុនេ ។
ពហុស្សុតោ ធម្មធរោ | សព្វបាឋី ច សាសនេ
អានន្ទោ នាម នាមេន | ធម្មារក្ខោ តេ មុនេ ។
ឯតេ សតេ អតិក្កម្ម | មហេសី គគក មម
វិនយំ មេ ជានាសិ | វិនយេ វិញ្ញុនេសិតំ ។





សុញ្ញតវិហារ អនិមិត្តវិហារ អប្បណិហិតវិហារ ការមិនមាន
តណ្ហា ជាគ្រឿងញាប់ញ័រ និងការរំលត់ទុក្ខ នេះជាធម្មកុដិ
របស់ព្រះអង្គ ។ ព្រះថេរៈជាបុគ្គលប្រសើរខាងប្រាជ្ញា ដែល
ព្រះអង្គតាំងទុកហើយ ជាអ្នកឆ្លើយក្នុងប្រាជ្ញា មានឈ្មោះ
ជាសារីបុត្ត ជាធម្មសេនាបតីរបស់ព្រះអង្គ ។ បពិត្រព្រះមុនី
ព្រះថេរៈដែលឈ្មោះថា កន្លែងឫទ្ធិបាទញាណ តំប្រាជ្ញាដែល
ដឹងនូវទុក្ខនិងបរិសុទ្ធិរបស់សត្វ ដល់នូវត្រើយនៃឫទ្ធិ មាន
ឈ្មោះថាកោលិត ជាប្រុកចាំគរបស់ព្រះអង្គ ។ បពិត្រព្រះមុនី
ព្រះថេរៈឈ្មោះកស្សប អ្នកទ្រទ្រង់វង្សបុរាណ មានតេជះ
ដ៏ខ្ពង់ខ្ពស់ ដែលគេគ្របសង្កត់បានដោយក្រ ប្រសើរក្នុង
គុណ មានការកំចាត់បង់នូវទោសជាដើម គឺទ្រទ្រង់ធុតង្គទាំង
១៣ ជាអ្នកសម្រាប់កាត់ក្តីរបស់ព្រះអង្គ ។ បពិត្រព្រះមុនី
ព្រះថេរៈជាពហុស្សុត អ្នកទ្រទ្រង់ធម៌ ចេះចាំព្រះវចនៈទាំង
អស់ក្នុងសាសនា មានឈ្មោះថាអានន្ទ ជាអ្នករក្សាធម៌របស់
ព្រះអង្គ ។ ព្រះមានព្រះភាគរបស់ខ្ញុំ ជាអ្នកស្វែងរកគុណដ៏ធំ
ទ្រង់ប្រមានការពិច័យ គឺវិន័យ ដែលវិញ្ញូជនកំណត់ទុកហើយ
សម្តែងហើយ ដល់ខ្ញុំព្រះអង្គ រំលងព្រះថេរៈទាំងអស់នុះ ។

យោ គោចិ វិនយេ បញ្ហំ  បុច្ឆតិ ពុទ្ធសាវកោ
តត្ថ មេ ចិន្តនា នត្ថិ  តញ្ញេវត្ថំ កថេមហំ ។
យាវតា ពុទ្ធខេត្តម្ហិ  ឋបេត្វា តំ មហាមុនិំ
វិនយេ មាទិសោ នត្ថិ  កុតោ ភិយ្យោ ភវិស្សតិ ។
ភិក្ខុសង្ឃេ និសីទិត្វា  ឯវំ គជ្ជតិ(១) គោតមោ
ឧបាលិស្ស សមោ នត្ថិ  វិនយេ ខន្ធកេសុ ច ។
យាវតា ពុទ្ធភណិតំ  នវង្គំ សត្ថុសាសនំ
វិនយោគធិតំ សព្វំ  វិនយមូលបស្សិនោ ។
មម កម្មំ សរិត្វាន  គោតមោ សក្យបុង្គវោ
ភិក្ខុសង្ឃេ និសីទិត្វា  ឯតទគ្គេ ឋបេសិ មំ ។
សតសហស្សំ ឧបាទាយ  ឥមំ ឋានំ អបត្ថយឹ
សោ មេ អត្ថោ អនុប្បត្តោ  វិនយេ បារមឹ គតោ ។

---
១ ម. គជ្ជសិ ។



ពុទ្ធសាវកណាមួយ សួរបញ្ហាក្នុងវិន័យ (នឹងខ្ញុំព្រះអង្គ) ខ្ញុំព្រះអង្គមិនបានគិត ក្នុងបញ្ហានោះទេ ខ្ញុំព្រះអង្គប្រាប់សេចក្តីនោះតែម្តង ។ ពុទ្ធក្ខេត្តកំណត់ត្រឹមណា វៀរលែងតែព្រះមហាមុនីចេញ មិនមានភិក្ខុណា នឹងស្មើហាយខ្ញុំព្រះអង្គក្នុងវិន័យ តើនឹងមានភិក្ខុប្រសើរ លើសខ្ញុំព្រះអង្គ ពីណា ។ ព្រះគោតមទ្រង់គង់ ក្នុងកណ្តាលជំនុំភិក្ខុសង្ឃ ហើយទ្រង់ប្រកាស យ៉ាងនេះថា ភិក្ខុណាមួយ ជាអ្នកស្មើហាយឧបាលិ ក្នុងវិន័យនិងខន្ធកៈ មិនមានឡើយ ។ សត្ថុសាសនា មានអង្គ ៩ ដែលព្រះពុទ្ធសម្តែងហើយ ទាំងអម្បាលមាណ ខ្ញុំព្រះអង្គជាអ្នកឃើញឫសគល់ របស់វិន័យ (គាត់បង់) នូវសេចក្តីជាប់ចំពាក់ទាំងពួង ដែលព្រះអង្គសម្តែងហើយ ក្នុងវិន័យ ។ ព្រះគោតមជាឧត្តមប្រសើរ ក្នុងសក្យត្រកូល ទ្រង់រលឹកឃើញនូវអំពើរបស់ខ្ញុំ ហើយគង់ក្នុងភិក្ខុសង្ឃ ទ្រង់តម្កល់ខ្ញុំក្នុងទីជាឯតទគ្គៈ ។ ខ្ញុំបានប្រាថ្នាយកនូវតំណែងនេះ កប់សែនកប្ប មកហើយ ឥឡូវនេះ ប្រយោជន៍នោះ ខ្ញុំបានសម្រេចហើយ ខ្ញុំបានដល់នូវត្រើយ ក្នុងព្រះវិន័យហើយ ។

សក្យានំ នន្ទិជននោ(១) កប្បកោ អាសហំ បុរេ
វិជហិត្វាន តំ ជាតិំ បុត្តោ ជាតោ មហេសិនោ ។
ឥតោ ទុតិយកេ កប្បេ អញ្ជសោ នាម ខត្តិយោ
អនន្តតេជោ អមិតយសោ ភូមិបាលោ មហទ្ធនោ ។
តស្ស រញ្ញោ អហំ បុត្តោ ចន្ទនោ នាម ខត្តិយោ
ជាតិមទេន បត្ថទ្ធោ យសោភោគមទេន ច ។
នាគសតសហស្សានិ សព្វាលង្ការភូសិតា
តិធា បភិន្នា មាតង្គា បរិវារេន្តិ មំ សទា ។
សពលេហិ បរេតោហំ ឧយ្យានំ គន្តុកាមកោ
អារុយ្ហ សិរិកំ នាគំ នគរា និក្ខមឹ តទា ។
ចរណេន ច សម្បន្នោ គុត្តទ្វារោ សុសំវុតោ
ទេវលោ នាម សម្ពុទ្ធោ អាគច្ឆិ បុរតោ មមំ(២) ។

១ ឱ. នន្ទិជននោ ។ ២ ឱ. មម ។





កាលពីដើម ខ្ញុំជាជាងកាត់សក់ ជាអ្នកបណ្ដុះសេចក្ដីត្រេកអរ ដល់ពួកសក្យៈ លះបង់កំណើតនោះហើយ ទើបមកជាបុត្រ របស់ព្រះមហេសីសម្ពុទ្ធវិញ ។ ក្នុងកប្បទី ២ រាប់អំពីកប្បនេះទៅ មានក្សត្រិយ៍ឈ្មោះ អញ្ជសៈ មានតេជះរកទីបំផុតគ្មាន មានយសរាប់មិនបាន ជាម្ចាស់ផែនដី មានទ្រព្យច្រើន ។ ខ្ញុំជាព្រះរាជបុត្ររបស់ព្រះរាជានោះ ជាក្សត្រិយ៍ឈ្មោះចន្ទនៈ ជាអ្នករឹងត្អឹង ដោយស្រវឹងព្រោះជាតិផង ដោយស្រវឹងព្រោះយសស័ក្តិនិងភោគៈផង ។ មានពួកដំរីមាតង្គៈចំនួន ១ សែន សុទ្ធតែចុះប្រេង ដោយហេតុ ៣ ប្រការ(១) ដំរីប្រដាប់ដោយគ្រឿងអលង្ការគ្រប់គ្រាន់ ហែហមខ្ញុំ សព្វៗកាល ។ វេលានោះ ខ្ញុំមានពួកពលរបស់ខ្លួនហែហមហើយ ប្រាថ្នាទៅកាន់ឧទ្យាន ទើបឡើងជិះដំរីឈ្មោះសិរិកៈ ចេញអំពីនគរទៅ ។ ស្រាប់តែមានព្រះសម្ពុទ្ធ ព្រះនាមទេវលៈ ទ្រង់បរិបូណ៌ដោយចរណៈ មានទ្វារគ្រប់គ្រង សង្រួមល្អ បាននិមន្តមកចំពោះមុខខ្ញុំ ។

១ ដំរីចុះប្រេងបែកអាចមកចេញប្រេង ៣ កន្លែង គឺបែកត្រង់ក្លៀក ១ បែកត្រង់ត្រចៀក ១ បែកស្លាប់ភ្លុក (កន្សោមសាច់ត្រង់គល់ភ្លុក) ១ (អដ្ឋកថា) ។

បេសេត្វា សិវិកំ តាតំ ពុទ្ធំ អាសាទយី តទា
តតោ សញ្ជាតកោបោហំ ជាតោ ទុគ្គតោ បថិ ។
ជាតំ វណ្ណមទំ និស្វា ពុទ្ធេ កោបំ អកាសហំ
វិហេឋយិត្វា សត្ថុំ ឧយ្យានំ អគមាសហំ ។
សាតំ តត្ថ ន វិន្ទាមិ សិរោ បជ្ជលិតោ យថា
បរិឡាហេន ឌយ្ហាមិ មច្ឆោវ ពលិសាទកោ ។
សសាគរន្តា បឋវី អាទិត្តា វិយ ហោតិ មេ
បិតុ សន្តិកុបាគម្ម ឥទំ វចនមព្រវឹ ។
អាសីវិសំវ កុបិតំ អគ្គិក្ខន្ធំវ អាគតំ
មត្តំវ កុញ្ជរំ ទន្តិំ យំ សយម្ភុំ អាសាទយី ។
អាសាទិតោ មយា ពុទ្ធោ ឃោរោ ឧគ្គតបោ ជិនោ
បុរា សព្វេ វិនស្សាម ខមាបេស្សាម តំ មុនិំ ។

១០៦



ក្នុងកាលនោះ ខ្ញុំបានបញ្ជូនឈ្មោះសិវិកៈ ទៅឲ្យបៀតបៀនព្រះសម្ពុទ្ធ លំដាប់នោះ ដោយកើតក្រោធទើបមិនលើកលែង ។ លុះខ្ញុំឃើញដំរីមានចក្ខុទាំង កំហឹងក្រោធនឹងព្រះពុទ្ធជាម្ចាស់ បៀតបៀនព្រះសម្ពុទ្ធហើយ ក៏ទៅកាន់ឧទ្យាន ។ ខ្ញុំមិនបាននូវសេចក្តីសុខស្រួល ក្នុងឧទ្យាននោះ ក្បាល (របស់ខ្ញុំ) ហាក់ដូចជាឆេះ ខ្ញុំក្តៅក្រហាយ ដោយសេចក្តីក្រហល់ក្រហាយ ដូចត្រីជាប់សន្ទូច ។ ផែនដីដែលមានសាគរជាទីបំផុត ហាក់ដូចជាឆេះដល់ខ្ញុំ ទើបខ្ញុំចូលទៅកាន់សំណាក់នៃព្រះបិតា ហើយក្រាបបង្គំទូលថា យើងខ្ញុំបៀតបៀនព្រះពុទ្ធសយម្ភូណា ដូចបុគ្គលបៀតបៀនអាសិរពិស ដែលកំពុងក្រោធ ឬដូចបុគ្គលបៀតបៀនគំនរភ្លើង ដែលឆេះកាលមក ឬក៏ដូចបុគ្គលបៀតបៀនដំរីមានភ្លុក ដែលចុះប្រេង ។ ព្រះពុទ្ធជាម្ចាស់អង្គនោះ មានតបៈដ៏ខ្ពង់ខ្ពស់ ក្លៀវក្លា ជាព្រះជិនស្រី យើងខ្ញុំបៀតបៀនហើយ យើងខ្ញុំទាំងអស់គ្នានឹងវិនាស យើងខ្ញុំនឹងញ៉ាំងព្រះសយម្ភូ ជាមុនីអង្គនោះ ឲ្យអត់ទោស ។

## អដ្ឋមំ មហាលិច្ឆោមជាតកំ

ដោ ទេ តំ និជ្ឈាបេស្សាម   អត្តនត្ថំ សមាហិតំ
ទិរេន សន្តមេ ជិតសេ   រដ្ឋេ ម្ពេ វិជមិស្សតិ ។
សុមេទលោ កោសិយោ ច   សិក្ខាភ ជាមិ សត្តកោ
អាសានយិត្វា ឥសយោ   ឧក្កតា តេ សសេនកា(១) ។
យថា កាយបត្តិ ឥសយោ   សញ្ញតា ព្រហ្មចារិនោ
សានេកាំ វិចាសេត្តំ   សសាកាំ សបត្តាំ ។
តិយោជនសហស្សម្ហិ   ឬរិសេ សន្និចាគយំ
អក្វយំ នេសនត្ថាយ   សាយម្ភុំ ឧបសត្តមំ(២) ។
អល្យវត្វា អល្យសិក   សព្វេ បញ្ញលីកតា
ពុទ្ធស្ស ការេ និបតិត្វា   ឥធំ វចនមព្រវុំ(៣) ។
ទមស្ស តំ បហារ   អភិយាចតិ តំ ជនោ
បរិឡាហំ វិចារេណ   កាច(៤) រដ្ឋំ វិចាសយ ។

១ ម. សារម្ពិកា ។ ២ ម. ឧបសង្គមុំ ។ ៣ ម. វែនមព្រវុំ ។ ៤ ម. តោ ។



## មហាលិច្ឆោមជាតក ទី ៨

ប្រសិនបើយើងខ្ញុំ មិនមិនបានញ៉ាំងព្រះពុទ្ធ ដែលមានខ្លួនដ្ឋានហើយ មានព្រះហឫទ័យខ្ជាប់ខ្ជួនតោះ ឱ្យអត់ទោសទេ ដែនរបស់យើងខ្ញុំ មុខជាវិនាស ដោយពាក្យផ្តេសផ្តាសមិនខាន ។ ឥស្សរជន ៤ ព្រះអង្គ ព្រះនាមសុមេទលៈ១ កោសិយៈ១ សិក្ខរៈ១ សត្តកៈ១ ជាមួយនឹងពួកសេនានោះ បានបៀត-បៀនអស់ចាំងឡាយ ហើយដល់ខ្ទាសេចក្តីវិនាស ។ ពួកឥសីអ្នកសង្រួម ប្រព្រឹត្តព្រហ្មចរិយធម៌ ក្រោមទីនគរកាលណា ដែលនឹងធ្វើសត្វលោក ព្រមទាំងទេវលោក ទាំងសមុទ្រ និងភ្នំឲ្យវិនាសទៅបាន ។ ខ្ញុំបានប្រជុំពួកបុរស ក្នុងទីបា-កាន់យោជន៍ បានចូលទៅគាល់ព្រះសយម្ភូ ដើម្បីនឹងសូមទោស ។ ពួកបុរសទាំងនួន ស្លៀកសំពត់ទទឹក មានក្បាលទទឹក ធ្វើក្រពុំប្រណមដៃ ក្រាបទៀបព្រះពុទ្ធ ហើយទូលថា បពិត្រព្រះអង្គមានព្យាយាមធំ សូមព្រះអង្គអត់ទោស (ព្រោះ) ជនសូមទោសនឹងព្រះអង្គ សូមព្រះអង្គរម្ងាប់ក្រវល់ក្រវាយ សូមព្រះអង្គកុំធ្វើដែន (របស់យើងខ្ញុំ) ឲ្យវិនាសឡើយ ។

សទេវមានុសា សព្វេ សមាគតា សរក្ខសា

អយោមយេន កូដេន សិរំ ភិន្ទេយ្យ មេ សទា ។

ទុខេកោ អគ្គិ ច សណ្ឋាតិ វីជិ លោលេ ច រូហតិ

អគ្គេ ឥមំ ច សណ្ឋាតិ កោលោ ពុទ្ធេ ច ជាយតិ ។

យថា ច ភូមិ អចលា អប្បមេយ្យោ ច សាគរោ

អនន្តកោ ច អាកាសោ ឯវំ ពុទ្ធា អចិន្តិយា ។

អត្តទន្តា មហាវីរ[1] ទមិតា ច តបស្សិនោ

ទន្តានំ ទមិតានំ ច គមនំ តេ[2] ន វិជ្ជតិ ។

ឥធំ ឋានំ សម្មុឡ្ហោ បរិញ្ញាហំ វិពោធយំ

មហាជនស្ស បុរតោ ឥតិ អត្ថគតី គតា ។

តេន កម្មេនហំ វីរ ហិត្វា អជ្ឈាគតោ

សមតិក្កម្ម តំ ជាតិំ បាវិសី អភយំ បុរំ ។

---

១ ម. សព្វញ្ញូ មហាមុនិ ។ ២ ម. តំ ។



(ប្រសិនបើ ព្រះអង្គមិនអនុគ្រោះទេ) ក្លាយជាសត្វទាំងអស់ ព្រមទាំងទេវតានិងមនុស្ស ទាំងពួកយក្ខ ទាំងពួករាក្សស គេ គឺយកញញួរដែក មកទម្លាយកម្ទេចក្បាលរបស់ខ្ញុំ សព្វ ៗ កាល ។ (ព្រះសមុទ្រទ្រង់ត្រាស់ថា) ភ្លើងមិនឆេះនៅក្នុងទឹក ពូជមិនដុះលើថ្ម វត្ថុមិនប៉ះនៅក្នុងសង្ឃ សេចក្តីក្រោធមិនកើតក្នុងព្រះពុទ្ធ ។ ផែនដីមិនកម្រើក សមុទ្រសាគរប្រមាណមិនបាន អាកាសគេទីបំផុតគ្មាន យ៉ាងណាមិញ ព្រះពុទ្ធទាំងឡាយ មានព្រះហឫទ័យមិនជួយញាប់ញ័រ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធទាំងឡាយមានព្យាយាមធំ មានខ្លួនទូន្មានទ្រង់អត់ធន់ មានតបះ ក្តីបុគ្គលអ្នកអំណត់អត់ធន់ មិនមានការល្អះក្នុងគតិ ។ ព្រះបរមគ្រូសម្តេច ទ្រង់ពោលដូច្នេះហើយ ទើបម្ចាប់ក្រសាលក្រោយរបស់ខ្ញុំ ហើយហោះទៅតាមអាកាស ក្នុងទីចំពោះមុខមហាជន ក្នុងកាលនោះ ។ បពិត្រព្រះអង្គមានព្យាយាម ព្រោះតែអំពើនោះហើយ ខ្ញុំម្ចាស់ព្រះអង្គ ចូលទៅកាន់គតិជាអ្នករក្សាតបៈ លះកន្លងជាតិនោះចេញហើយ ក៏បានចូលទៅ កាន់អភយបុរី គឺព្រះនិព្វាន ។

## អដ្ឋមំ ខោសលិស្សាបទានំ

គតាបំ មំ មហាវីរ ឌយ្ហមានំ សុសណ្ឋិតំ
បរិឡាហំ វិនោទេសិ សយម្ភុំ ច ធាមាបយឹ ។
អជ្ជាបិ មំ មហាវីរ ឌយ្ហមានំ តិហគ្គិភិ
និព្វាបេសិ តយោ អគ្គី សីតិភាវញ្ច បាបយឹ ។
យេសំ សោតាវធានត្ថិ សុណាថ មម ភាសតោ
អត្ថំ តុម្ហំ បវក្ខាមិ យថា ទិដ្ឋំ បទំ មម ។
សយម្ភុំ តំ វិមានេត្វា សន្តចិត្តំ សមាហិតំ
តេន កម្មេនហំ អជ្ជ ជាតោម្ហិ ជិនឱរសោ ។
មា វោ ខណំ វិរាធេថ ខណាតីតា ហិ សោចរេ
សទត្ថេ វាយមេយ្យាថ ខណោ វោ បដិបាទិតោ ។



## ខោសលិស្សាបទាន ទី ៨

បពិត្រព្រះអង្គមានព្យាយាមធំ វេលានោះ ព្រះពុទ្ធបានញ៉ាំងខ្ញុំព្រះអង្គ ដែលកំពុងក្តៅក្រហាយ ទៅមិនដាច់ពេក ឲ្យមានភ្លើងក្រៅក្រាយចេញ ខ្ញុំព្រះអង្គបានញ៉ាំងព្រះសយម្ភូឲ្យឆ្អែតចាស ។ បពិត្រព្រះអង្គមានព្យាយាមធំ ក៏ក្នុងថ្ងៃនេះ ព្រះអង្គបានញ៉ាំងខ្ញុំព្រះអង្គ ដែលកំពុងក្តៅក្រហាយ ដោយភ្លើងទាំង ៣ ឲ្យរលត់ផង ញ៉ាំងភ្លើងទាំង ៣ ឲ្យរលត់ផង ដូច្នេះ ខ្ញុំព្រះអង្គបានផលដ៏ត្រជាក់ហើយ ។ លោកទាំងឡាយណា មានការត្រចៀកដល់ឡោសេកប្រសាទ លោកទាំងនោះ ចូរស្តាប់ខ្ញុំ ខ្ញុំនឹងប្រាប់ប្រយោជន៍ដល់អ្នក ដូចជាបំណងដែលខ្ញុំបានឃើញ ។ ខ្ញុំបានមើលឃើញព្រះសយម្ភូនោះ ដែលមានព្រះហឫទ័យស្ងប់ល្អ មានព្រះហឫទ័យភ្លឺរុងរឿង ដោយកម្មនោះហើយ បានជាក្នុងថ្ងៃនេះ ខ្ញុំមកកើតក្នុងកំណើតជាតថាគត ។ អ្នកទាំងឡាយកុំឲ្យខណៈឃ្លាតទៅចេញ ព្រោះបុគ្គលដែលខណៈកន្លងហើយ រមែងសោកសៅ អ្នកទាំងឡាយ គប្បីព្យាយាម ក្នុងប្រយោជន៍របស់ខ្លួន (ព្រោះ) ខណៈត្រូវបានផល់អ្នកទាំងឡាយហើយ ។

ឯកគ្គានញ្ច វនំ　ឯកគ្គានំ វិវេចនំ

វិសំ ហលាហលំ ឯកេ　ឯកគ្គានញ្ច ទិសចំ ។

វនំ បដិបន្នានំ　ផលដ្ឋានំ វិវេចនំ

ទិសចំ ផលលាភីនំ　បុញ្ញក្ខេត្តំ គវេសិនំ ។

សាសនេន វិរុទ្ធានំ　វិសំ ហលាហលំ យថា

អាសីវិសោ ទុដ្ឋវិសោ　ឯកំ(១) ឃាតេតិ តំ នរំ ។

សកឹ បីតំ ហលាហលំ　ទុបរុទ្ធតិ ជីវិតំ

សាសនេន វិរុជ្ឈិត្វា　កប្បកោដិម្ហិ ឌយ្ហតិ ។

ខន្តិយា អវិហឹសាយ　មេត្តចិត្តវតាយ ច

សទេវកំ សោ តារេតិ　តស្មា តេ អវិរោធិយា(២) ។

លាភាលាភេ ន សជ្ជន្តិ　សម្មានេ វិមានេ

បឋវីសទិសា ពុទ្ធា　តស្មា តេ ន វិរោធិយា ។

---

១ ឱ. ឯ ។ ២ ម. អវិរោធិយា ។



ផលក្នុងត្រពាំងចាំក្នុង ផលក្នុងត្រពាំងចាំបញ្ចោះ ផលក្នុងត្រពាំងចាំពិសដែលខ្លាំង ផលក្នុងត្រពាំងទុំឥតថ ។ ចាំក្នុងសម្រាប់ពួកបុគ្គលអ្នកប្រតិបត្តិ (ខ្ជីមត្ត) ចាំបញ្ចោះសម្រាប់ពួកបុគ្គលអ្នកបំពេញកិច្ចដែល ទុំសម្រាប់ពួកបុគ្គលអ្នកបានខ្ញុំដែលជាអ្នកស្វែងរកបុញ្ញក្ខេត្ត ។ ពិសដែលខ្លាំង សម្រាប់បុគ្គលអ្នកប្រតិបត្តិខុសចាកសាសនា ការពិតពិសដែលមានពិសកាចនៃធផុតទោះទោះនៃខ្មួយជន ។ ពិសនិងខ្លាំងដែលបុគ្គលផឹកហើយទៀតទៀនតែមានតែមួយជន ឯបុគ្គលអ្នកប្រតិបត្តិខុសចាកសាសនា តែងទៅក្រោយ សសំពៅខ្មែរកបួ ។ ទៅកើតទុកចាតលោក ព្រមទាំងទេវលោក ដោយការអត់ធន់ ១ ដោយការមិនបៀតបៀន ១ ដោយមានចិត្តមេត្តា ១ ហេតុនោះ បុគ្គលមិនគប្បីឲ្យផ្ទាំផ្ទងនឹងព្រះពុទ្ធទាំងនោះ ។ ព្រះពុទ្ធទាំង-ឡាយ មានព្រះហឫទ័យស្មើដោយផែនដី មិនជាប់ចំពាក់ក្នុងលាភនិងអលាភ ក្នុងការសរសើរ ក្នុងការមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឲ្យផ្ទាំផ្ទងនឹងព្រះពុទ្ធទាំងនោះ ។

### អដ្ឋមំ ឧបាលិត្ថេរាបទានំ

នេវ ទេវទត្តេ ច វធកេ  ចោរេ អង្គុលិមាលកេ
ធនបាលេ រាហុលេ ច  សព្វេសំ សមកោ មុនិ ។
ឃាតេសំ បដិឃំ នត្ថិ  រាគោមេសំ ន វិជ្ជតិ
សព្វេសំ សមកោ ពុទ្ធោ  វធកស្សោរសស្ស ច ។
បន្ថេ ទិស្វាន កាសាវំ  ឆឌ្ឌិតំ មីឡ្ហមក្ខិតំ
សិរសា អញ្ជលី កត្វា  វន្ទិតព្វំ ឥសិទ្ធជំ ។
អតីតា ច យេ ពុទ្ធា  វត្តមានា អនាគតា
ធជេនានេន សុជ្ឈន្តិ  តស្មា ឯតេ នមស្សិយា ។
សត្ថុកប្បំ សុវិនយំ  ធារេមិ ហទយេនហំ
នមស្សមានោ វិនយំ  វិហរិស្សាមិ សព្វទា ។
វិនយោ អាសយោ មយ្ហំ  វិនយោ ឋានចង្កមំ
កប្បេមិ វិនយេ វាសំ  វិនយោ មម គោចរោ ។



### ឧបាលិត្ថេរាបទាន ទី ៨

ព្រះមុនីមានព្រះហឫទ័យស្មើចំពោះសត្វទាំងពួង គឺទេវទត្ត ខ្មាន់ធ្នូ ចោរអង្គុលិមាល រាហុល និងដំរីធនបាល ។ ព្រះពុទ្ធមិនមានសេចក្ដីស្អប់ដល់ជនទាំងនុះ មិនមានសេចក្ដីស្រឡាញ់ដល់ជនទាំងនុះទេ មានព្រះហឫទ័យស្មើ ចំពោះជនទាំងអស់ គឺ ចំពោះខ្មាន់ធ្នូ និងចំពោះរាហុល ។ បុគ្គលបើឃើញសំពត់កាសាវៈ ជាទង់ជ័យរបស់ព្រះពុទ្ធ ដែលប្រឡាក់ដោយលាមក ដែលគេបោលហើយនឹងធូលី គប្បីធ្វើអញ្ជលីថ្វាយបង្គំ ដោយក្បាល ។ ព្រះសម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយក្ដី កំពុងប្រព្រឹត្តទៅក្ដី កំពុងមានមកក្ដី តែងបរិសុទ្ធ ដោយទង់ជ័យនេះ ព្រោះហេតុនោះ ព្រះសម្ពុទ្ធទាំងនុះ បុគ្គលគប្បីនមស្ការ ។ ខ្ញុំចាំវិន័យដោយប្រពៃ គួរតាមគន្លងស្រេច របស់ព្រះសាស្តា ដោយហឫទ័យ ខ្ញុំនឹងនមស្ការវិន័យនោះ សព្វៗកាល ។ វិន័យជាទីអាស្រ័យ វិន័យជាទីឈរ ទាំងជាទីចង្ក្រមរបស់ខ្ញុំ ខ្ញុំនឹងធ្វើការនៅ ក្នុងវិន័យ វិន័យជាទីគោចរ របស់ខ្ញុំ ។

វិនយេ បារមិប្បត្តោ សមថេ ចាបិ កោវិទោ

ឧបាលិ តំ មហាវីរ បាទេ វន្ទតិ សត្ថុនោ ។

សោ អហំ វិចរិស្សាមិ គាមាគាមំ បុរាបុរំ

នមស្សមានោ សម្ពុទ្ធំ ធម្មស្ស ច សុធម្មតំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

សព្វាសវា បរិក្ខីណា នត្ថិទានិ បុនព្ភវោ ។

ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ។

ឥត្ថំ សុទំ អាយស្មា ឧបាលិ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧបាលិត្ថេរស្ស អបទានំ សមត្តំ ។



បពិត្រព្រះអង្គមានព្យាយាមធំ ឧបាលិដល់នូវត្រើយក្នុងវិន័យផង ឈ្លាសវៃក្នុងសមថៈផង តែងថ្វាយបង្គំនូវព្រះបាទារបស់ព្រះសាស្តា ។ ខ្ញុំព្រះអង្គនោះនឹងត្រាច់ទៅ អំពីស្រុកមួយ ទៅកាន់ស្រុកមួយ អំពីបុរីមួយ ទៅកាន់បុរីមួយ ហើយ នមស្ការនូវព្រះសម្ពុទ្ធផង នូវភាពនៃធម៌ ជាធម៌ដ៏ល្អផង ។ ខ្ញុំព្រះអង្គដុតកិលេសទាំងឡាយហើយ ដកចោលនូវភពទាំងអស់ហើយ អាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះភពថ្មី មិនមានទេ ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់របស់ព្រះពុទ្ធដ៏ប្រសើរ (នេះ) ជាដំណើរមកដោយល្អ វិជ្ជាទាំង ៣ ខ្ញុំព្រះអង្គបានសម្រេចហើយ សាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំព្រះអង្គក៏បានប្រតិបត្តិហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបាលិត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧបាលិត្ថេរាបទាន ។

## នវមំ អញ្ញាកោណ្ឌញ្ញត្ថេរាបទានំ

(៤) បទុមុត្តរសម្ពុទ្ធំ លោកជេដ្ឋំ វិនាយកំ
ពុទ្ធភូមឹ អនុប្បត្តំ បឋមំ អទ្ទសំ អហំ ។
យាវតា ពោធិយា មូលេ យក្ខា សព្វេ សមាគតា
សម្ពុទ្ធំ បរិវារេត្វា វន្ទន្តិ បញ្ជលីកតា ។
សព្វេ ទេវា តុដ្ឋមនា អាកាសេ សញ្ចរន្តិ តេ
ពុទ្ធោ អយំ អនុប្បត្តោ អន្ធការតមោនុទោ ។
តេសំ ហាសបរេតានំ មហានាទោ អវត្តថ
កិលេសេ ឈាបយិស្សាម សម្មាសម្ពុទ្ធសាសនេ ។
ទេវានំ គិរមញ្ញាយ វាចាយ សមុទីរិតំ(១)
ហដ្ឋោ ហដ្ឋេន ចិត្តេន អាទិភិក្ខមទាសហំ ។
មម សង្កប្បមញ្ញាយ សត្ថា លោកេ អនុត្តរោ
ទេវសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។

១ ម. ភិក្ខុសមុទីរិតំ ។



## អញ្ញាកោណ្ឌញ្ញត្ថេរាបទាន ទី ៩

(៤) ខ្ញុំបានឃើញជាដំបូង នូវព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជាច្បងក្នុងលោក ជាអ្នកដឹកនាំសត្វលោក ទ្រង់ដល់នូវពុទ្ធភូមិ ។ ពួកយក្សទាំងអស់មកជួបជុំគ្នា ហែមកោមធ្វើអញ្ជលីថ្វាយបង្គំព្រះសម្ពុទ្ធ ទៀបគល់នៃពោធិព្រឹក្ស ។ ពួកទេវតាទាំងអស់នោះ មានចិត្តត្រេកអរ សញ្ចរទៅក្នុងអាកាស (ពោលថា) ព្រះពុទ្ធអង្គនេះ ទ្រង់បានដល់ហើយលំដាប់ ទ្រង់កំចាត់បង់នូវងងឹត ដែលជាតមោធ្វើឲ្យខ្វាក់ ។ ពួកទេវតាទាំងអស់នោះ មានសេចក្តីរីករាយប្រព្រឹត្តទៅខាងមុខ សំឡេងកងរំពងដ៏ខ្លាំងប្រព្រឹត្តទៅថា យើងទាំងឡាយនឹងដុតបំផ្លាញនូវពួកកិលេស ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ លុះខ្ញុំដឹងពាក្យរបស់ទេវតាទាំងឡាយ ដែលពោលដោយវាចា ហើយក៏ត្រេកអរ បានថ្វាយចង្ហាន់ជាដំបូង ដោយចិត្តដែលត្រេកអរ ។ ព្រះសាស្តា ព្រះអង្គប្រសើរក្នុងលោក ទ្រង់ជ្រាបបំណងរបស់ខ្ញុំ ទ្រង់គង់ក្នុងកណ្តាលនៃពួកទេវតាហើយ ហើយត្រាស់គាថាទាំងនេះថា

សត្តាហំ អភិនិក្ខម្ម ពោធឹ អជ្ឈគមំ អហំ
ឥទំ មេ បឋមំ ភត្តំ ព្រហ្មចារិស្ស យាបនំ ។
តុសិតាហិ ឥធាគន្ត្វា យោ មេ ភិក្ខំ ឧបានយិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
តិំសមត្តេ កប្បសហស្សេ ទេវរជ្ជំ ការិស្សតិ
សព្វេ ទេវេ អភិភោត្វា តិទិវំ អាវសិស្សតិ ។
ទេវលោកា ចវិត្វាន មនុស្សត្តំ គមិស្សតិ
សហស្សធា ចក្កវត្តី តត្ថ រជ្ជំ ការិស្សតិ ។
កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន សត្ថា លោកេ ភវិស្សតិ ។
តិទសា សោ ចវិត្វាន មនុស្សត្តំ គមិស្សតិ
អគារា បព្វជិត្វាន ឆព្វស្សានិ វសិស្សតិ ។
តតោ សត្តមកេ វស្សេ ពុទ្ធោ សច្ចំ កថេស្សតិ
កោណ្ឌញ្ញោ នាម នាមេន បឋមំ សច្ឆិកាហិតិ ។



តថាគតចេញទៅទ្រង់ព្រះផ្នួស អស់៧ថ្ងៃ ក៏បានដល់នូវពោធិញ្ញាណ ភត្តជាដំបូងរបស់តថាគតនេះ ញុំាងព្រហ្មចារីបុគ្គលឲ្យប្រព្រឹត្តទៅបាន ។ បុគ្គលណា ចុះចាកឋានតុសិត មកកើតក្នុងមនុស្សលោកនេះ ហើយថ្វាយចង្ហាន់ដល់តថាគត តថាគតនឹងសម្តែងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនេះនឹងបានសោយរាជ្យ ជាស្តេចនៃទេវតា អស់ ៣០ ពាន់កប្ប នឹងគ្របសង្កត់ទេវតាទាំងអស់ ហើយនៅគ្រប់គ្រងទេវលោក ។ លុះច្យុតចាកទេវលោក មកកាន់អត្តភាពជាមនុស្ស នឹងបានជាស្តេចចក្រពត្តិ សោយរាជ្យ ក្នុងមនុស្សលោកនោះ អស់មួយពាន់ដង ។ ក្នុងទីមួយសែនកប្ប ព្រះសាស្តា ព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងបានត្រាស់ដឹងក្នុងលោក ។ កុលបុត្រនោះ ច្យុតចាកទេវលោកមកកាន់អត្តភាពជាមនុស្ស នឹងចេញចាកផ្ទះទៅបួស នៅអស់ ៦ ឆ្នាំ ។ លំដាប់អំពីនោះមក ព្រះពុទ្ធនឹងទ្រង់សម្តែងនូវអរិយសច្ច ក្នុងឆ្នាំជាគំរប់ ៧ កុលបុត្រ មានឈ្មោះថា កោណ្ឌញ្ញៈ នឹងបានធ្វើឲ្យជាក់ច្បាស់នូវធម៌ ជាដំបូង ។

ឆិត្វាន្តាបុបព្វឹ   បធានំ សុកតំ មយា
កិលេសេ ឈាបនត្វាយ   បត្វឹ អចការំយិ ។
អធិគន្តាន សព្វញ្ញូ   ពុទ្ធោ លោកេ សទេវកេ
គមិណា មេ មហាវីរោ   អមតភេរិមាហនិ ។
សោណាជិ បត្តោ អមតំ   សន្តំ បទមនុត្តរំ(១)
សព្វាសវេ បរិញ្ញាយ   វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អញ្ញាកោណ្ឌញ្ញោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អញ្ញាកោណ្ឌញ្ញត្ថេរស្ស អបទានំ សមត្តំ ។

១ ម. សន្តិបទមនុត្តរំ ។





ខ្ញុំបួសតាមព្រះពោធិសត្វ ដែលចេញទៅទ្រង់ព្រះផ្នួស ហើយបានធ្វើសេចក្តីព្យាយាមដោយប្រពៃ ខ្ញុំចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ផុតបំបាត់ នូវកិលេសទាំងឡាយ ។ ព្រះសព្វញ្ញុ លុះបានត្រាស់ដឹង ក្នុងលោក ព្រមទាំងទេវលោកហើយ ទ្រង់យកសន្ទះនៃនូវស្គរ គឺអមតនិព្វាន ក្នុងព្រៃដល់ខ្ញុំ ។ ឥឡូវនេះ ខ្ញុំនោះបានដល់នូវអមតនិព្វាន ជាសន្តិបទដ៏ប្រសើរ ជាអ្នកមិនមានអាសវៈ ព្រោះកំណត់ដឹងនូវអាសវៈទាំងពួង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អញ្ញាកោណ្ឌញ្ញត្ថេរាបទាន ។

## ទសមំ បិណ្ឌោលភារទ្វាជត្ថេរាបទានំ

[១០] បទុមុត្តរោ នាម ជិនោ   សយម្ភូ អគ្គបុគ្គលោ
បុរតោ ហិមវន្តស្ស   ចិត្តកូដេ វសី តទា ។
អភីតរូបោ តត្ថាសឹ   មិគរាជា ចតុក្កមោ
យស្ស សទ្ទំ សុណិត្វាន   វិក្ខម្ភន្តិ ពហូ ជនា ។
សុផុល្លំ បទុមំ គយ្ហ   ឧបគច្ឆឹ នរាសភំ
វុដ្ឋិតស្ស សមាធិម្ហា   ពុទ្ធស្ស អភិរោបយឹ ។
ចាតុទ្ទិសំ នមស្សិត្វា   ពុទ្ធសេដ្ឋំ នរុត្តមំ
សកំ ចិត្តំ បសាទេត្វា   សីហនាទំ នទឹ តទា ។
បទុមុត្តរោ លោកវិទូ   អាហុតីនំ បដិគ្គហោ
សកាសនេ និសីទិត្វា   ឥមា គាថា អភាសថ ។





## បិណ្ឌោលភារទ្វាជត្ថេរាបទាន ទី ១០

[១០] កាលនោះ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ជាព្រះសយម្ភូ ជាអគ្គបុគ្គល ស្តេចគង់នៅភ្នំចិត្តកូដ ដែលនៅពីខាងមុខនៃព្រៃហិមពាន្ត ។ ខ្ញុំកើតជាស្តេចម្រឹគ (រាជសីហ៍) មានជើង ៤ មានសភាពមិនរបះខ្លាច បាននៅភ្នំចិត្តកូដនោះ ដែលពួកជនជាច្រើន បានឮសម្លេងនោះហើយ រមែងតក់ស្លុត ។ ខ្ញុំកាន់ផ្កាឈូកដែលរីកល្អ ចូលទៅគាល់ព្រះសម្ពុទ្ធ ព្រះអង្គប្រសើរជាងនរៈ ហើយបង្អោនចូលទៅបូជា ចំពោះព្រះសម្ពុទ្ធ ដែលក្រោកចេញអំពីសមាធិ ។ គ្រានោះ ខ្ញុំនមស្ការព្រះសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គខ្ពង់ខ្ពស់ជាងនរៈ ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយបន្លឺឡើងនូវសីហនាទ ក្នុងទិសទាំង ៤ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជា ទ្រង់គង់លើអាសនៈរបស់ព្រះអង្គ ហើយត្រាស់គាថាទាំងឡាយនេះ ។

ទសមំ បិណ្ឌបាតិកត្ថេរាបទានំ

ពុទ្ធស្ស តិរមេញ្ញាយ    សព្វេ ទេវា សមាគតា
អាគតោ វេធតិ សេដ្ឋោ    ធម្មំ សោស្សាម តំ មយំ ។
តេសំ ហាសបរេតានំ    បុរតោ លោកនាយកោ
មម សទ្ទំ ឧគាច្ឆសិ    ទីឃទស្សី មហាមុនិ ។
យេនិទំ បទុមំ ទិន្នំ    សីហនាទោ ច នាទិតោ
តមហំ កិត្តយិស្សាមិ    សុណាថ មម ភាសតោ ។
ឥតោ អដ្ឋមកេ កប្បេ ចក្កវត្តិ ភវិស្សតិ
សត្តរតនសម្បន្នោ    ចតុទ្ទីបម្ហិ ឥស្សរោ ។
ការយិស្សតិ ឥស្សរំ    មហិយា ចតុសដ្ឋិយា
បទុមោ នាម នាមេន    ចក្កវត្តិ មហាពលោ(១) ។
កប្បសតសហស្សម្ហិ    ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន សត្ថា លោកេ ភវិស្សតិ ។

១ ម. មហព្ពលោ ។



បិណ្ឌបាតិកត្ថេរាបទាន ទី ១០

ពួកទេវតាទាំងអស់ បានដឹងនូវព្រះពុទ្ធដីកា របស់ព្រះសម្ពុទ្ធហើយក៏មកជួបជុំគ្នា (ដោយពាក្យថា) ព្រះសម្ពុទ្ធជាប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់ស្ដេចមកហើយ ពួកយើងនឹងស្ដាប់ធម៌នោះ ។ ព្រះលោកនាយក ជាអ្នកប្រាជ្ញដ៏ប្រសើរ ព្រះអង្គឃើញកាលវេលា ទ្រង់សម្ដែងសំឡេងរបស់ខ្ញុំ គង់ទីចំពោះមុខ នៃទេវតាទាំងឡាយនោះ ដែលមានសេចក្ដីរីករាយប្រព្រឹត្តទៅខាងមុខ ដូច្នេះថា

ផ្កាឈូកនេះ ដែលបុគ្គលណា ថ្វាយហើយក្ដី សីហនាទ ដែលបុគ្គលណា បន្លឺឡើងហើយក្ដី តថាគត នឹងសម្ដែងសរសើរ នូវបុគ្គលនោះ អ្នកទាំងឡាយចូរស្ដាប់តថាគតសម្ដែងចុះ ។ បុគ្គលនោះ នឹងបានជាស្ដេចចក្រពត្តិ ជាធំក្នុងទ្វីបទាំង ៤ បរិបូណ៌ដោយកែវ ៧ ប្រការ ក្នុងកប្បទី ៨ អំពីកប្បនេះ ។ ឯស្ដេចចក្រពត្តិ (នោះ) ទ្រង់ព្រះនាមបទុមៈ មានកម្លាំងច្រើន នឹងបានសោយរាជ្យ ជាធំលើផែនដី ប្រមាណ ៦៤ ។ កន្លងទៅមួយសែនកប្បទៀត ព្រះសាស្ដា ព្រះនាមគោតមៈ ទ្រង់កើតក្នុងឱក្កាកត្រកូល នឹងបានត្រាស់ដឹង ក្នុងលោក ។

បកាសិតេ បាវចនេ ព្រហ្មពន្ធុ ភវិស្សតិ
ព្រហ្មញ្ញា អភិនិក្ខម្ម បព្វជិស្សតិ តាវទេ ។
បធានំ បហិតត្តោ សោ ឧបសន្តោ និរូបធិ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិនាសវោ ។
វិជ្ជនេ(១) បន្តសេយ្យម្ហិ វាឡមិគសមាកុលេ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បិណ្ឌោលភារទ្វាជោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បិណ្ឌោលភារទ្វាជត្ថេរស្ស អបទានំ សមត្តំ ។

១ ម. វិជនេ ។



កាលសាសនា ដែលព្រះសាស្ដាព្រះនាមគោតម ទ្រង់ប្រកាសហើយ ស្ដេចចក្រពត្តិនោះ នឹងកើតជាព្រាហ្មណ៍ នឹងចេញចាកភាពព្រាហ្មណ៍ ហើយទៅបួសក្នុងខណៈនោះ ។ កុលបុត្រនោះ មានចិត្តបញ្ជូនទៅកាន់ព្យាយាម មានចិត្តស្ងប់ មិនមានឧបធិកិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ កុលបុត្រនោះ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ក្នុងសេនាសនៈដ៏ស្ងាត់ ដែលច្រាសចាកជន ដ៏កុះករដោយម្រឹគសាហាវ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិណ្ឌោលភារទ្វាជត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បិណ្ឌោលភារទ្វាជត្ថេរាបទាន ។

## ឯកាទសមំ ឧត្តរិយត្ថេរាបទានំ

[១១] នទិកា ភាគីរសី នាម ហិមវន្តា បភាវិតា
កុតិត្ថេ នាវិកោ អាសិំ ឱរិមេ ច តរេ អហំ ។
បទុមុត្តរនាយកោ សម្ពុទ្ធោ ទិបទុត្តមោ
វសីសតសហស្សេហិ គង្គាសោតំ តរិស្សតិ(១) ។
ពហូ នាវា សមានេត្វា វឌ្ឍកីហិ សុសង្ខតំ(២)
នាវាយ ឆទនំ កត្វា បដិមានិំ នរាសភំ ។
អាគន្ត្វាន ច សម្ពុទ្ធោ អារុយ្ហិ តំ នាវបញ្ចកំ(៣)
វារិមជ្ឈេ ឋិតោ សត្ថា ឥមា គាថា អភាសថ ។
យោ សោ តារេសិ សម្ពុទ្ធំ សង្ឃញ្ចាបិ អនាសវំ
តេន ចិត្តប្បសាទេន ទេវលោកេ រមិស្សតិ ។
និព្វត្តិស្សតិ តេ ព្យម្ហំ សុកតំ នាវសណ្ឋិតំ
អាកាសេ បុប្ផឆទនំ ធារយិស្សតិ សព្វទា ។

---

១ ម. គង្គាតីរមុបាគតោ ។ ២ ម. វឌ្ឍកេហិ សុសង្ខតំ ។ ៣ ម. អារុហិញ្ច នាវកំ ។

១១៧

## ឧត្តរិយត្ថេរាបទាន ទី ១១

[១១] មានស្ទឹងមួយ ឈ្មោះភាគីរសី ហូរចេញអំពីព្រៃហិមពាន្ត (ហិមវន្ត) ខ្ញុំកើតជានាយទូកក្នុងកំពង់មិនល្អ ជាកំពង់សម្រាប់ឆ្លងមកកាន់ត្រើយអាយ ។ ព្រះសម្ពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ ព្រះអង្គប្រសើរជាងសត្វជើងពីរ ចម្លងនឹងឆ្លងនូវខ្សែទឹកគង្គាស្ទឹង ជាមួយនឹងភិក្ខុសង្ឃមួយសែនអង្គ ។ ខ្ញុំបាននាំប្រមូលទូកជាច្រើនមក ហើយធ្វើដំបូលទូក ដែលពួកជាងឈើ តាក់តែងល្អហើយ ទៅទទួលព្រះនរាសភៈ ។ ព្រះសម្ពុទ្ធ ទ្រង់ស្តេចមកឡើងគង់លើទូក ព្រះសាស្តាទ្រង់ឋិតត្រង់កណ្តាលទឹកស្ទឹង ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បានចម្លងព្រះសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃ ជាអ្នកមិនមានអាសវៈ បុគ្គលនោះនឹងត្រេកអរក្នុងទេវលោក ដោយចិត្តជ្រះថ្លានោះឯង ។ វិមាន មានសណ្ឋានដូចទូក ដែលបុញ្ញកម្មធ្វើល្អហើយ នឹងកើតដល់អ្នក វិមាននោះ នឹងទ្រទ្រង់នូវដំបូល ជាវិការៈនៃផ្កាក្នុងអាកាស សព្វ ៗ កាល ។

អដ្ឋបញ្ញាសកប្បម្ហិ   តារណោ នាម[១] ខត្តិយោ
ចាតុរន្តោ វិជិតាវី   ចក្កវត្តី ភវិស្សតិ ។
សត្តបញ្ញាសកប្បម្ហិ   ចម្មកោ នាម[២] ខត្តិយោ
ឧគ្គច្ឆន្តោវ សុរិយោ   ជោតិស្សតិ មហាពលោ[៣] ។
កប្បសតសហស្សម្ហិ   ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន   សត្ថា លោកេ ភវិស្សតិ ។
តិទសា[៤] ចវិត្វាន   មនុស្សត្តំ គមិស្សតិ
រេវតោ នាម នាមេន   ព្រហ្មពន្ធុ ភវិស្សតិ ។
អគារា និក្ខមិត្វាន   សុក្កមូលេន ចោទិតោ
គោតមស្ស ភគវតោ   សាសនេ បព្វជិស្សតិ ។
សោ បច្ឆា បព្វជិត្វាន   យុត្តយោគោ វិបស្សកោ
សព្វាសវេ បរិញ្ញាយ   និព្វាយិស្សត្យនាសវោ ។

១ ម. តារកោ នាម ។ ២ ម. ចម្បកោ នាម ។ ៣ ម. មហព្ពលោ ។ ៤ ម. តិទសា សោ ។



ក្នុងកប្បទី ៥៨ បុគ្គលនោះ នឹងបានជាស្តេចចក្រពត្តិព្រះនាមតារណៈ (ជាអ្នកស្រុះស្រួលផែនដី) មានសមុទ្រទាំង ៤ ជាទីបំផុត ទ្រង់ឈ្នះសង្គ្រាម ។ ក្នុងកប្បទី ៥៧ នឹងបានជាស្តេចព្រះនាមចម្មកៈ មានកម្លាំងច្រើន រុងរឿង ដូចព្រះអាទិត្យកំពុងរះ ។ ក្នុងកប្បទីមួយសែន ព្រះសាស្តា ព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ ស្តេចចម្មកៈ (នោះ) ច្យុតចាកទេវលោក មកកាន់អត្តភាពជាមនុស្ស នឹងកើតជាព្រាហ្មណ៍ ឈ្មោះរេវតៈ ។ រេវតកុមារនោះ ត្រូវកុសលមូលដាស់តឿន នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា នៃព្រះមានព្រះភាគ ព្រះនាមគោតម ។ រេវតភិក្ខុនោះ លុះបួសរួចហើយ ក្នុងកាលជាខាងក្រោយ ប្រកបសេចក្តីព្យាយាម ចំរើនវិបស្សនា កំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

វិរិយំ មេ ធុរធោរយ្ហំ យោគក្ខេមាធិវាហនំ
ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ(១) ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ខទិរវនិយោ រេវតត្ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ខទិរវនិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. ឥតោ បរំ សតសហស្សេ កតំ កម្មំ ផលំ ទស្សេសិ មេ ឥធ
សុមុត្តោ សរវេគោវ កិលេសេ ឈាបយី មម
ភវោ មំ វេទិរត់ ទិស្វា លោកគ្គមុនិ
វេទភិសិ ភិក្ខុ ឧត្តំ បញ្ញាបសិ មហាមតី
ឥមេ គាថា ទិស្សន្តិ ។





សេចក្តីព្យាយាមរបស់ខ្ញុំ នួរដើម្បីនាំមកនូវធុរៈ ជាទីនាំមកនូវធម៌ជាគ្រឿង ផុតចាកយោគៈ ខ្ញុំទ្រទ្រង់នូវកាយ មានក្នុងទីបំផុត គឺបច្ឆិមជាតិ ក្នុងសាសនា នៃព្រះសម្ពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះខទិរវនិយរេវតត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ខទិរវនិយត្ថេរាបទាន ។

## ទ្វាទសមំ អានន្ទត្ថេរាបទានំ

[១៦] អារាមទ្វារា និក្ខម្ម បទុមុត្តរោ មហាមុនិ
វស្សេន្តោ អមតវុដ្ឋឹ និព្វាបេសិ មហាជនំ ។
សតសហស្សា តេ ធីរា ឆឡភិញ្ញា មហិទ្ធិកា
បរិវារេន្តិ សម្ពុទ្ធំ ឆាយាវ អនុបាយិនី ។
ហត្ថិក្ខន្ធគតោ អាសឹ សេតច្ឆត្តំ វរុត្តមំ
សុចារុពុំ(១) ទិស្វាន បីតិ មេ ឧទបជ្ជថ ។
ឱរុយ្ហ ហត្ថិក្ខន្ធម្ហា ឧបគច្ឆិំ នរាសភំ
រតនាមយំ ឆត្តំ មេ ពុទ្ធសេដ្ឋស្ស ធារយឹ ។
មម សង្កប្បមញ្ញាយ បទុមុត្តរោ មហាឥសិ
តំ កថំ ឋបយិត្វាន ឥមា គាថា អភាសថ ។
យោ សោ ឆត្តំ អធារយិ សោណ្ណាលង្ការភូសិតំ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

១ ម. សុចារុរូបំ ។





## អានន្ទត្ថេរាបទាន ទី ១២

[១៦] ព្រះមហាមុនី ព្រះនាមបទុមុត្តរៈ កាលស្ដេចចេញអំពីទ្វារអារាម ហើយបង្អុរភ្លៀងគឺអមតៈ ញុំាងមហាជនឲ្យរលត់ទុក្ខ ។ ពួកអ្នកប្រាជ្ញ មួយសែននាក់ បានអភិញ្ញា ៦ ជាអ្នកមានឫទ្ធិធំ តែងហែហមព្រះសម្ពុទ្ធ ដូចស្រមោលអន្ទោលតាមប្រាណ ។ (សំដៅចំពោះ) ខ្ញុំជិះលើកដំរី បានឃើញស្វេតច្ឆត្រ ដ៏ឧត្តមប្រសើរ មានសភាពសមរម្យហើយ ស្រស់ស្រួល ខ្ញុំក៏មានបីតិកើតឡើង ។ ខ្ញុំចុះអំពីកដំរី ចូលទៅគាល់ព្រះនរាសភសម្ពុទ្ធ ខ្ញុំយកឆត្ររបស់ខ្ញុំ ជាវិការៈនៃកែវ បាំងថ្វាយព្រះសម្ពុទ្ធដ៏ប្រសើរ ។ ព្រះបទុមុត្តរៈ ព្រះអង្គស្វែងរកគុណដ៏ធំ ទ្រង់ជ្រាបបំណងរបស់ខ្ញុំ ហើយទ្រង់បញ្ឈប់កថានោះ ទើបត្រាស់គាថាទាំងឡាយនេះថា

កុលបុត្រណា បានបាំងឆត្រ ដ៏ស្អិតស្អាង ដោយគ្រឿងអលង្ការជាវិការៈនៃមាស តថាគតនឹងសំដែងនូវកុលបុត្រនោះ អ្នកទាំងឡាយ ចូរស្ដាប់តថាគតសំដែងចុះ ។

ឥតោ គន្ត្វា អយំ បោសោ  តុសិតំ អាវសិស្សតិ
អនុភោស្សតិ សម្បត្តិំ  អច្ឆរាហិ បុរក្ខតោ ។
ចតុត្តិំសតិក្ខត្តុំ ច  ទេវរជ្ជំ ករិស្សតិ
ឃកដ្ឋតោ(១) អដ្ឋសតំ  វសុធំ អាវសិស្សតិ ។
អដ្ឋបញ្ញាសក្ខត្តុំ ច  ចក្កវត្តិ ករិស្សតិ
បទេសរជ្ជំ វិបុលំ  មហិយា ការយិស្សតិ ។
កប្បសតសហស្សម្ហិ  ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន  សត្ថា លោកេ ភវិស្សតិ ។
សក្យានំ កុលគោត្តស្ស  ញាតិពន្ធុ ភវិស្សតិ
អានន្ទោ នាម នាមេន  ឧបដ្ឋាកោ មហេសិនោ ។
អាតាបី និបកោ ធាមិ  ពាហុសច្ចេសុ កោវិទោ
និវាតវុត្តិ អត្ថទ្ធោ  សព្វបាឋី ករិស្សតិ ។

១ ម. កណ្ឌិតោ ។





បុរសនេះ នឹងទៅអំពីលោកនេះហើយ នឹងគ្រប់គ្រងឋានតុសិត សោយទិព្វសម្បត្តិ មានពួកស្រីអប្សរហែហម ។ មិនតែប៉ុណ្ណោះ បុរសនេះ នឹងបានសោយរាជ្យ ជាស្តេចនៃទេវតា អស់ ៣៤ ដង នឹងបានជាធំជាងពួកនរៈ គ្រប់គ្រងផែនដី ៨ រយដង ។ នឹងបានជាស្តេចចក្រពត្តិ អស់ ៥៨ ដង (ប្រកាំតោះ) នឹងបានសោយប្រទេសរាជ្យ ដ៏ធំទូលាយលើផែនដី ។ តទៅនេះមួយសែនកប្បទៀត ព្រះសាស្ដាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងបានត្រាស់ដឹងក្នុងលោក ។ បុរសនេះ នឹងបានជាព្រះញាតិផៅពង្ស នៃព្រះពុទ្ធជាម្ចាស់ក្នុងត្រកូលរបស់ពួកសក្យៈ មាននាមថាអានន្ទ ជាឧបដ្ឋាករបស់ព្រះពុទ្ធ ទ្រង់ស្វែងរកគុណធំ ។ នឹងជាអ្នកមានព្យាយាម មានប្រាជ្ញាចាស់ ក្លៀវក្លាក្នុងសភាពជាពហុស្សុត ប្រព្រឹត្តខ្លួនរាបទាប មិនរឹងត្អឹង ទ្រទ្រង់នូវពុទ្ធវចនៈ ទាំងអស់ ។

បធានំ បហិតត្តោ សោ ឧបសន្តោ និរូបធិ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សត្យនាសវោ ។
សត្តិ អារញ្ញកា នាគា កុញ្ជរា សដ្ឋិហាយនា
តិធប្បភិន្នា មាតង្គា ឦសាទន្តា ឧរូឡ្ហវា ។
អនេកសតសហស្សា បណ្ឌិតាបិ មហាមុនិ
សព្វេ តេ ពុទ្ធនាគស្ស ន ហោន្តិ បរិក្ខិតា(១) ។
អាទិយាមេ នមស្សាមិ មជ្ឈិមេ អថ បច្ឆិមេ
បសន្នចិត្តោ សុមនោ ពុទ្ធសេដ្ឋំ ឧបដ្ឋហិំ ។
អាតាបី និបកោ ចាហំ សម្បជានោ បតិស្សតោ
សោតាបត្តិផលំ បត្តោ សេខភូមីសុ កោវិទោ ។
កប្បតោ សតសហស្សេ យំ កម្មមភិនីហរិំ
តាហំ ភូមិំ អនុប្បត្តោ ឋិតា សទ្ធា មហព្ពលា(២) ។

១ ម. បរិក្ខិត្តា តេ ។ ២ ម. ឋិតា សទ្ធម្មមាចលា ។



កាលខ្ញុំនោះ តំកល់នូវព្យាយាម មានចិត្តបញ្ជូនទៅកាន់សមាធិ មានចិត្តស្ងប់ មិនមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ហត្ថីនាគមានខ្លះទាំងឡាយ មានអាយុ ៦០ រថបយ កញ្ចុំង ទៅកន្លែង ចុះប្រេងដោយអាការ ៣ ប្រការ មានភ្លុកដូចបង្គោល មានភ្លៅធំមាំមួន ។ ហត្ថីនាគទាំងអស់នោះ មានច្រើនសែន ជាសត្វបណ្ឌិត មានឫទ្ធិច្រើន ក៏មិនហ៊ាន មើលងាយព្រះពុទ្ធនាគ ។ ខ្ញុំនឹងនមស្ការព្រះពុទ្ធនាគ ក្នុង-បឋមយាម មជ្ឈិមយាម និងបច្ឆិមយាម ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បម្រើព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំមានព្យាយាម មានប្រាជ្ញាចាស់ មានសតិនិងសម្បជញ្ញៈ ដល់នូវសោតាបត្តិផល ឈ្លាសវៃក្នុងសេក្ខភូមិទាំងឡាយ ។ ព្រោះហេតុដែលខ្ញុំ បានសន្សំតំកើតជាកុសល ក្នុងកប្បទីមួយសែន អំពីកប្បនេះ ទើបខ្ញុំបានដល់ នូវមហាភក្ខុម៉ោនោះ ហើយជំនឿ (របស់ខ្ញុំ) ក៏តាំងនៅស៊ប់ស្ងួន ជាជំនឿមានផលច្រើន ។

ពុទ្ធវគ្គ អានន្ទត្ថេរាបទានំ

ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អានន្ទោ ថេរោ ឥមា គា-
ថាយោ អភាសិត្ថាតិ ។

អានន្ទត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

ពុទ្ធោ បច្ចេកសម្ពុទ្ធោ សារីបុត្តោ ច កោលិតោ
កស្សបោ អនុរុទ្ធោ ច បុណ្ណត្ថេរោ ឧបាលិ ច
កោណ្ឌញ្ញោ ចាបិ បិណ្ឌោលោ រេវតានន្ទបណ្ឌិតោ(១)
ឆ សតានិ ច បញ្ញាស(២) គាថាយោ សព្វបិណ្ឌិតា ។

អបទានេ ពុទ្ធវគ្គោ បឋមោ ។

១ ម. អញ្ញាសិកោណ្ឌញ្ញោ បិណ្ឌោលោ រេវតានន្ទបណ្ឌិតោ ។ ២ ម. បញ្ញាស ។



អានន្ទត្ថេរាបទាន ទី ១០

ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ ជាដំណើរមកប្រពៃហើយ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអានន្ទត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អានន្ទត្ថេរាបទាន ។

## ឧទ្ទាន

រឿងព្រះពុទ្ធ ១ ព្រះបច្ចេកសម្ពុទ្ធ ១ ព្រះសារីបុត្ត ១ កោលិតគឺព្រះមោគ្គល្លាន ១ ព្រះកស្សប ១ ព្រះអនុរុទ្ធ ១ ព្រះបុណ្ណត្ថេរ ១ ព្រះឧបាលិ ១ ព្រះកោណ្ឌញ្ញៈ ១ ព្រះបិណ្ឌោលភារទ្វាជៈ ១ ព្រះរេវតៈ ១ ព្រះអានន្ទជាបណ្ឌិត ១ ឯគាថា ៦៥០ សុទ្ធតែជាគាថាពេញលេញទាំងអស់ ។

ចប់ អបទាន ពុទ្ធវគ្គ ទី ១ ។

## ទុតិយោ សីហាសនិយវគ្គោ

## បឋមំ សីហាសនទាយកត្ថេរាបទានំ

(១៣) និព្វុតេ លោកនាថម្ហិ សិទ្ធត្ថេ ទិបទុត្តមេ
វិត្ថារិតេ បាវចនេ ពាហុជញ្ញម្ហិ សាសនេ ។
បសន្នចិត្តោ សុមនោ សីហាសនមកាសហំ
សីហាសនំ ករិត្វាន បាទបីឋមកាសហំ ។
សីហាសនេ ច វស្សន្តេ ឃរំ តត្ថ អកាសហំ
តេន ចិត្តប្បសាទេន តុសិតំ ឧបបជ្ជហំ ។
អាយាមេន ចតុព្វីសា(១) យោជនាសិំសុ តាវទេ
វិមានំ សុកតំ មយ្ហំ វិត្ថារេន ចតុទ្ទស ។
សត្ត កញ្ញាសហស្សានិ បរិវារេន្តិ មំ សទា
សោណ្ណមយញ្ច បល្លង្កំ ព្យម្ហំ អាសិ សុនិម្មិតំ ។

---
១ ម. ចតុព្វីស ។

## សីហាសនិយវគ្គ ទី ២

## សីហាសនទាយកត្ថេរាបទាន ទី ១

(១៣) កាលព្រះលោកនាថព្រះនាមសិទ្ធត្ថៈ ព្រះអង្គប្រសើរជាងសត្វជើងពីរ ទ្រង់បរិនិព្វានហើយ កាលពាក្យជាប្រធានគឺសាសនា ផ្សាយទៅហើយក្នុងជនច្រើន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានកសាងសីហាសនៈ លុះកសាងសីហាសនៈរួចហើយ ខ្ញុំធ្វើកំណល់ព្រះបាទទៀត ។ កាលបើភ្លៀងបង្អុរលើសីហាសនៈ ខ្ញុំក៏ធ្វើរោងលើសីហាសនៈនោះ ដោយចិត្តជ្រះថ្លានោះ ខ្ញុំបានទៅកើតក្នុងឋានតុសិត ។ វេលានោះ វិមានមានបណ្ដោយ ២៤ យោជន៍ ទទឹង ១៤ យោជន៍ ដែលបុណ្យកម្ម តាក់តែងឡើងសម្រាប់ខ្ញុំ ។ ក្នុងវិមាននោះ មានកញ្ញា ៧ ពាន់ ហែហមខ្ញុំ សព្វៗកាល មានតាំងបល្ល័ង្កជាវិការៈនៃមាស ដែលបុណ្យកម្មនិម្មិតល្អហើយ ។

ហត្ថិយានំ អស្សយានំ　　រថយានំ ឧបដ្ឋិតំ
បាសាទា សិវិកា ចេវ　　និព្វត្តន្តិ យទិច្ឆកំ ។
មណិមយា ច បល្លង្កា　　អញ្ញេ សារមយា ពហូ
និព្វត្តន្តិ មមំ សព្វេ　　សីហាសនស្សិទំ ផលំ ។
សោវណ្ណមយា រូបិមយា　　ផលិកា វេឡុរិយាមយា
បាទុកា អភិរុយ្ហាមិ　　បាទបីឋស្សិទំ ផលំ ។
ចតុន្នវុតេ ឥតោ កប្បេ　　យំ កម្មមករី តទា
ទុគ្គតឹ នាភិជានាមិ　　បុញ្ញកម្មស្សិទំ ផលំ ។
តេសត្តតិ ឥតោ កប្បេ　　ឥន្ទនាមា តយោ ជនា
ទ្វេសត្តតិ ឥតោ កប្បេ　　តយោ សុមននាមកា ។
សមសត្តតិតោ កប្បេ　　តយោ វរុណនាមកា
សត្តរតនសម្បន្នា　　ចតុទ្ទីបម្ហិ ឥស្សរា ។



យានដំរី យានសេះ និងយានរថទិព្វ កើតឡើងសម្រាប់ខ្ញុំ ប្រាសាទនិងសិវិកា (អង្រឹង) កើតតាមសេចក្តីប្រាថ្នា ។ បល្ល័ង្កជាវិការៈនៃកែវមណី បល្ល័ង្កដទៃទៀតជាច្រើន ជាវិការៈនៃឈើ បល្ល័ង្កទាំងអស់នោះ កើតឡើងសម្រាប់ខ្ញុំ នេះជាផលនៃសីហាសនៈ ។ ខ្ញុំតែងពាក់ស្បែកជើង ជាវិការៈនៃមាស ជាវិការៈនៃប្រាក់ ជាវិការៈនៃកែវផលិក និងជាវិការៈនៃកែវពិទូរ្យ នេះជាផលនៃកំរាលព្រះបាទ ។ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកប្បទី ៩៤ អំពីភទ្ទកប្បនេះ ក្នុងកាលនោះ ខ្ញុំមិនស្គាល់ទុគ្គតិឡើយ នេះជាផលនៃបុញ្ញកម្មនោះ ។ ក្នុងកប្បទី ៧៣ អំពីភទ្ទកប្បនេះ ខ្ញុំបានកើតជាជនឈ្មោះឥន្ទៈ ៣ ដង ក្នុងកប្បទី ៧២ អំពីភទ្ទកប្បនេះ ខ្ញុំបានកើតជាជន ឈ្មោះសុមនៈ ៣ ដង ក្នុងកប្បទី ៧០ អំពីភទ្ទកប្បនេះ ខ្ញុំបានកើតជាជន ឈ្មោះវរុណៈ ៣ ដង ដែលជាស្តេចធំ ក្នុងទ្វីបទាំង ៤ បរិបូណ៌ដោយកែវ ៧ ប្រការ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សីហាសនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សីហាសនទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ ឯកត្ថម្ភិកត្ថេរាបទានំ

[១៤] សិទ្ធត្ថស្ស ភគវតោ មហាបូគគណោ(១) អហុ
សរណំ គតា ច តេ ពុទ្ធំ សទ្ទហន្តិ តថាគតំ ។
សព្វេ សង្គម្ម មន្តេត្វា មាឡំ កុព្វន្តិ សត្ថុនោ
ឯកត្ថម្ភំ អលភន្តា វិចិនន្តិ ព្រហាវនេ ។
តេហំ(២) អរញ្ញេ ទិស្វាន ឧបគម្ម គណំ តទា
អញ្ជលឹ បគ្គហេត្វាន បរិបុច្ឆឹ គណំ អហំ ។
តេ មេ បុដ្ឋា វិយាកំសុ សីលវន្តា ឧបាសកា
មាឡំ មយំ កត្តុកាមា ឯកត្ថម្ភោ ន លព្ភតិ ។

---

១ ម. មហាបូគគណោ ។ ២ ម. តេសំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសីហាសនទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សីហាសនទាយកត្ថេរាបទាន ។

## ឯកត្ថម្ភិកត្ថេរាបទាន ទី២

[១៤] ពួកគណៈធំ របស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ពួកជនទាំងនោះ បានដល់នូវព្រះពុទ្ធជាទីពឹង ហើយជឿព្រះតថាគត ។ ពួកជនទាំងអស់ ជួបជុំប្រឹក្សាគ្នា ហើយធ្វើរោង ថ្វាយព្រះសាស្ដា តែនៅខ្វះសសរ១ ក៏នាំគ្នាដើរស្វែងរកក្នុងព្រៃធំ ។ កាលនោះ ខ្ញុំឃើញជនទាំងនោះ ក្នុងព្រៃហើយ ចូលទៅជិតជនទាំងនោះ ក៏ផ្គងអញ្ជលីសាកសួរពួកនោះ ។ ពួកឧបាសក អ្នកមានសីលទាំងនោះ ដែលខ្ញុំសួរហើយ ក៏ប្រាប់ថា ពួកយើងប្រាថ្នានឹងធ្វើរោង តែនៅខ្វះសសរ១ ។

## ទុតិយំ ឯកច្ឆត្តិយាបទានំ

ឯកច្ឆត្តំ មយា ទេវ    អហំ ឧសភម្ហិ សត្ថុនោ
អភយាស្សព្ភមហំ ជន្តុំ    អមេយ្យស្សុញ្ញា ភត្តុនោ ។
តេ ទេ ជន្តុំ ចវេត្ថិស្ស    បសង្ឃា ឧទ្ធមានសា
តទា បដិនិវត្តិត្វា    សេតមិស្ស សតិំ សរំ ។
អបរំ កតេ បុតកណា    ជន្តុំ អឍាសហំ តទា(១)
ហេដ្ឋា ហោដ្ឋេន ចិត្តេន    ឋបេមិ ឧស្សបេសហំ ។
តេន ចិត្តប្បសាទេន    វិមានំ ឧបបជ្ជហំ
ឧត្តិត្តិ ករំ មយ្យំ    សត្តត្តមំ សមុត្តិតំ ។
វេជ្ជមានាស្ស ពេវស្ស    បវិចារេមហំ សទា
បញ្ចបញ្ញាសកប្បម្ហិ    រាជា អាសឹ យសោធរោ ។
តត្ថាបិ ករំ មយ្យំ    សត្តត្តមំ សមុត្តិតំ
ទ្វេជានាវិស្សេ តិ    ឯកច្ឆត្តំ មនោរមំ ។

---
១ ម. អហោសហត្ថា ។



## ឯកច្ឆត្តិយៈអបទាន ទី ២

ខ្ញុំឃើញ អ្នកតាំងទ្វាយខ្លះវ្រែសសារទ ដែលនាំមកនូវខ្លះ ខ្ញុំនឹងខ្ញុំយកលកោរព្រះសាស្តា ខ្ញុំនឹងតាំងសសារមក សូមពួកទេវតា-សកតាំងនោះ កុំមានសេចក្តីខ្វល់ខ្វាយឡើយ ។ ពួកទេវតា-សកតាំងនោះ មានចិត្តជ្រះថ្លាត្រេកអរហើយ តាំងសសាររបស់ខ្ញុំទៅ លុះត្រឡប់អំពីទីនោះវិញ ក៏មកកាន់ផ្ទះរៀងខ្លួន ។ គង់កាលនោះ កាលពួកគណៈ ដែលទើបចំរើនទៅ បំពានចំពោះយូរ ប៉ុន្មាន ខ្ញុំបានខ្វាយសសារ ខ្ញុំមានចិត្តត្រេកអរហើយ បាន លើកសសារ ជាដំបូង ។ ដោយចិត្តជ្រះថ្លានោះ ខ្ញុំចូលទៅកាន់វិមាន មានកំពស់ ៧ ជាន់ដែលផុះឡើងសម្រាប់ខ្ញុំ ។ គង់កប្បទី ៥៥ ខ្ញុំកើតជាស្តេច ឈ្មោះយសោធរៈ កាលបើស្តេច ដែលគេកុងប្រែរ ខ្ញុំក៏ឡើងបម្រើ សព្វៗកាល ។ លំនៅរបស់ខ្ញុំក្នុងទីនោះ មានកំពស់ ៧ ជាន់ ប្រកបដោយផ្ទះមានកំពូលដ៏ប្រសើរ មានសសរតែមួយ ជាទីគាប់ចិត្ត ។

ឯកាវីសតិកប្បម្ហិ  ឧទេនោ នាម ខត្តិយោ
តត្រាបិ ភវនំ មយ្ហំ  សត្តភូមំ សមុណ្ណតំ(១) ។
យំ យំ យោនុបបជ្ជាមិ  ទេវត្តំ អថ មានុសំ
អនុភោមិ សព្វមេតំ(២)  ឯកត្ថម្ភស្សិទំ ផលំ ។
ចតុន្នវុតេ ឥតោ កប្បេ  យំ ថម្ភមទទិំ តទា
ទុគ្គតិំ នាភិជានាមិ  ឯកត្ថម្ភស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកត្ថម្ភិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកត្ថម្ភិកត្ថេរស្ស អបទានំ សមត្តំ ។

១ ឱ. សមុគ្គតំ ។ ២ ឱ. សុខំ សព្វំ ។



ក្នុងកប្បទី ២១ ខ្ញុំកើតជាក្សត្រិយ៍ឈ្មោះឧទេនៈ លំនៅរបស់ខ្ញុំក្នុងទីនោះ មានជាន់៧ ដែលគេតាក់តែងល្អហើយ ។ ខ្ញុំកើតក្នុងកំណើតណា ៗ ទោះជាទេវតា ឬជាមនុស្ស ខ្ញុំក៏ទទួលសេចក្តីសុខគ្រប់ប្រការ នេះជាផលនៃសសរមួយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសសរ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសសរមួយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ តាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកត្ថម្ភិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកត្ថម្ភិកត្ថេរាបទាន ។

## តតិយំ ខេមត្ថេរាបទានំ

(១៨) បទុមុត្តរស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ

វត្ថំ ខោមំ មយា ទិន្នំ សយម្ភុស្ស មហេសិនោ ។

តម្មេ ពុទ្ធោ វិយាកាសិ ជលជុត្តមនាយកោ(១)

ឥមិនា វត្ថទានេន ហេមវណ្ណោ ភវិស្សសិ ។

ទ្វេ សម្បត្តី អនុភោត្វា សុក្កមូលេន(២) ចោទិតោ

គោតមស្ស ភគវតោ ទាយាទោ ត្វំ ភវិស្សសិ ។

ភវិត្វា សុខសីលោ កាមេសុ អនបាយុតោ

ពុទ្ធេន ចោទិតោ សន្តោ តទា(៣) ត្វំ បព្ពជិស្សសិ ។

បព្ពជិត្វាន ត្វំ តត្ថ កុសលមូលេន ចោទិតោ

សព្ពាសវេ បរិញ្ញាយ និព្វាយិស្សសិនាសវោ ។

១ ម. ជលជុត្តមនាមកោ ។ ២ ម. កុសលមូលេហិ ។ ៣ ម. តតោ ។



## ខេមត្ថេរាបទាន ទី៣

(១៨) ខ្ញុំបានថ្វាយសំពត់សម្បកឈើ ចំពោះព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ជាចំបងក្នុងលោក ទ្រង់ប្រកបដោយតាទិគុណ ជាព្រះសយម្ភូ ទ្រង់ស្វែងរកនូវគុណធំ ។ ព្រះពុទ្ធជានាយក ព្រះនាមជលជុត្តមៈ(១) ទ្រង់ព្យាករនូវផលនោះប្រាប់ខ្ញុំថា

អ្នកនឹងមានពណ៌សម្បុរដូចមាស ដោយការថ្វាយសំពត់នេះ ។ អ្នកនឹងបានទទួលសម្បត្តិទាំងពីរប្រការ ត្រូវកុសលមូលដាស់តឿនហើយ នឹងបានជាម្ចាស់នៃព្រះមានព្រះភាគព្រះនាមគោតម ។ អ្នកនឹងមានសេចក្តីត្រេកអរដោយកាមគុណ មានសេចក្តីសុខជាប្រក្រតី មានសេចក្តីជាប់ចំពាក់ដោយចំណងក្នុងកាមទាំងឡាយ តែលុះព្រះពុទ្ធទ្រង់ដាស់តឿន នឹងប្រែជាបួសស៊ប់ ហើយចេញបួសក្នុងកាលនោះ ។ អ្នកលុះបួសហើយ ត្រូវកុសលមូលដាស់តឿន នឹងកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វានក្នុងទីនោះ ។

១ ជាពាក្យនិយាយប្តូរឈ្មោះ បទុមុត្តរៈ ព្រោះ ជលជុត្តមៈ ប្រែថា ជលជាតិដ៏ឧត្តម, បទុមុត្តរៈ ប្រែថា ឈូកដ៏ឧត្តម ។

សតកប្បសហស្សម្ហិ　ចតុរោ ចេលនាមកា
សដ្ឋិកប្បសហស្សម្ហិ　ឧបចេលា ចតុជ្ជនា ។
បញ្ចកប្បសហស្សម្ហិ　ចេលាវ ចតុរោ ជនា
សត្តរតនសម្បន្នា　ចតុទីបម្ហិ ឥស្សរា ។
បដិសម្ភិទា ចតស្សោ　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧទេនោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទេនត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ បុប្ផបត្តត្ថេរាបទានំ

[១៦] បទុមុត្តរោ នាម ជិនោ　អាហុតីនំ បដិគ្គហោ
គណម្ហា វូបកដ្ឋោ សោ　ហិមវន្តេ វសី តទា ។



ក្នុងកប្បទីមួយសែន អាត្មាអញបានជាក្សត្រ ព្រះនាមចេលៈ ៤ អង្គ ក្នុងកប្បទី ៦០ ពាន់ នឹងបានកើតជាជន ឈ្មោះឧបចេលៈ ៤ អង្គ ។ ក្នុងកប្បទី ៥ ពាន់ នឹងបានជាជន ឈ្មោះចេលៈ ៤ អង្គទៀត ជាធំក្នុងទ្វីបទាំង ៤ បរិបូណ៌ដោយកែវ ៧ ប្រការ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទេនត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧទេនត្ថេរាបទាន ។

## បុប្ផបត្តត្ថេរាបទាន ទី ៤

[១៦] កាលនោះ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ទទួលគ្រឿងបូជា គេចចេញចាកគណៈ ទៅគង់នៅព្រៃហិមពាន្ត ។

អហញ្ច ហិមវន្តម្ហិ វសាមិ អស្សមេ តទា
អចិរាគតំ មហាវីរំ ឧបេសឹ លោកនាយកំ ។
បុប្ផច្ឆត្តំ គហេត្វាន ឧបគច្ឆឹ នរាសភំ
សមាធឹ សមាបជ្ជន្តំ អន្តរាយមកាសហំ ។
ឧភោ ហត្ថេហិ បគ្គយ្ហ បុប្ផច្ឆត្តំ អទាសហំ
បដិគ្គហេសិ ភគវា បទុមុត្តរោ មហាមុនិ ។
សព្វេ ទេវា អត្តមនា ហិមវន្តំ ឧបេន្តិ តេ
សាធុការំ បវត្តេសុំ អនុមោទិស្សតិ ចក្ខុមា ។
ឥទំ វត្វាន តេ ទេវា ឧបគញ្ឆុំ នរុត្តមំ
អាកាសេ ធារយន្តស្ស[១] បទុមំ ឆត្តមុត្តមំ ។
សតបត្តច្ឆត្តំ បគ្គយ្ហ អទាសិ តាបសោ មម
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

១ ម. ធារយន្តេ ។





គ្រានោះ ខ្ញុំនៅក្នុងអាស្រម នាព្រៃហិមពាន្ត បានចូលទៅគាល់ព្រះលោកនាយក ព្រះអង្គមានព្យាយាមធំ ដែលទ្រង់ទើបស្ដេចមកដល់ថ្មីៗ ។ ខ្ញុំកាន់ឆ័ត្រជាវិការៈនៃផ្កា ហើយចូលទៅគាល់ព្រះនរាសភៈ ដែលកំពុងចូលសមាធិ ហើយបានធ្វើឲ្យខូចសមាធិព្រះអង្គ ។ ខ្ញុំផ្គងដៃទាំងពីរហើយថ្វាយឆ័ត្រផ្កា ព្រះមានព្រះភាគ ជាមហាមុនី ព្រះនាមបទុមុត្តរៈ ទ្រង់បានទទួល ។ ពួកទេវតាទាំងអស់ មានចិត្តរីករាយចូលទៅកាន់ព្រៃហិមពាន្ត ពួកទេវតាទាំងនោះ បានញុំាងសាធុការឲ្យប្រព្រឹត្តទៅ (ហើយពោលថា) ព្រះពុទ្ធមានបញ្ញាចក្ខុ នឹងត្រេកអរអនុមោទនា ។ ទេវតាទាំងនោះ លុះពោលពាក្យនេះហើយ ក៏ចូលទៅគាល់ព្រះសម្ពុទ្ធ ដ៏ប្រសើរជាងនរៈ ដែលកំពុងទ្រទ្រង់ឆ័ត្រជាឈូកដ៏ឧត្តម របស់ខ្ញុំ ក្នុងអាកាស ។

(ព្រះបទុមុត្តរៈត្រាស់ថា) តាបសបានលើកឆ័ត្រប្រអប់ដោយស្រទាប់ ៧ ថ្វាយតថាគត តថាគតនឹងសំដែងសរសើរតាបសនោះ អ្នកទាំងឡាយ ចូរស្ដាប់តថាគតសំដែងចុះ ។

បញ្ចវីសតិកប្បានិ ទេវរជ្ជំ ករិស្សតិ
ចតុត្តឹសតិក្ខត្តុញ្ច ចក្កវត្តី ករិស្សតិ ។
យំ យំ យោនឹ សំសរតិ ទេវត្តំ អថ មានុសំ
អព្ភោកាសេ បតិដ្ឋន្តំ បទុមំ ធារយិស្សតិ ។
កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន សត្ថា លោកេ ភវិស្សតិ ។
បកាសិតេ បាវចនេ មនុស្សត្តំ លភិស្សតិ
មនោមយម្ហិ កាយម្ហិ ឧត្តមោ សោ ភវិស្សតិ ។
ទ្វេ ភាតរោ ភវិស្សន្តិ ឧភោបិ បន្ថកវ្ហយា
អនុភោត្វា ឧត្តមត្ថំ ជោតយិស្សន្តិ សាសនំ ។
សោ អដ្ឋារសវស្សោហំ[១] បព្វជឹ អនគារិយំ
វិសេសាហំ ន វិន្ទាមិ សក្យបុត្តស្ស សាសនេ ។
ទន្ធា មយ្ហំ គតិ អាសិ បរិភូតោ បុរេ អហំ[២]

១ ម. អដ្ឋារសញ្ច វស្សោហំ ។ ២ ម. អហុ ។



តាបសនេះ នឹងសោយទេវរាជ្យ អស់ ២៥ កប្ប មួយទៀត នឹងបានជាស្ដេចចក្រពត្តិ អស់ ៣៤ ដង ។ តាបសនេះបើអន្ទោលទៅកាន់កំណើតណា ៗ ទោះជាទេវតា ឬជាមនុស្សក្ដី ឈូកនឹងបាំងនូវតាបសនោះ ដែលកំពុងឋិតនៅក្នុងទីវាល ។ កន្លងទៅមួយសែនកប្ប ព្រះបរមសាស្ដា ព្រះនាមគោតម ទ្រង់កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ លុះដល់សាសនា ដែលព្រះពុទ្ធព្រះនាមគោតម ទ្រង់ប្រកាសហើយ តាបសនោះ នឹងបាននូវអត្តភាពជាមនុស្ស ជាអ្នកប្រសើរ ក្នុងកាយដ៏សម្រេចដោយចិត្ត ។ មានបងប្អូនពីរនាក់ ឈ្មោះបន្ថកៈដូចគ្នា ទាំងពីរនាក់ នឹងបានទទួលនូវប្រយោជន៍ដ៏ឧត្តម ហើយធ្វើពុទ្ធសាសនាឲ្យរុងរឿង ។

ខ្ញុំមានអាយុ ១៨ ឆ្នាំ បានចូលទៅកាន់ផ្នួស តែខ្ញុំមិនសម្រេចគុណវិសេស ក្នុងសាសនាព្រះពុទ្ធ ជាសក្យបុត្រទេ ។ គតិរបស់ខ្ញុំយឺត (ព្រោះ) ខ្ញុំបានមើលងាយគេ ក្នុងកាលមុន

## ចតុត្ថំ ចុល្លបន្ថកត្ថេរាបទានំ

ភាតា ច មំ បណាមេសិ គច្ឆ ទានិ សកំ ឃរំ ។
សោហំ បណាមិតោ សន្តោ សង្ឃារាមស្ស កោដ្ឋកេ
ទុម្មនោ តត្ថ អដ្ឋាសិ សាមញ្ញស្មឹ អបេក្ខវា ។
អថេត្ថ សត្ថា អាគច្ឆិ(១) សីសំ មយ្ហំ បរាមសិ
ពាហាយ មំ គហេត្វាន សង្ឃារាមំ បវេសយិ ។
អនុកម្បាយ មេ សត្ថា អទាសិ បាទបុញ្ឆនិ(២)
ឯវំ សុទ្ធំ អធិដ្ឋេហិ ឯកមន្តំ អធិដ្ឋិតំ ។
ហត្ថេហិ តមហំ គយ្ហ សរឹ កោកនទំ អហំ
តត្ថ ចិត្តំ វិមុច្ចិ មេ អរហត្តំ អបាបុណឹ ។
មនោមយេសុ កាយេសុ សព្វត្ថ បារមឹ គតោ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។

១ ម. ភគវា តត្ថ អាគច្ឆិ ។ ២ ម. មេ បាទបុញ្ឆនំ ។



## ចុល្លបន្ថកត្ថេរាបទានទី ៤

ឯភិក្ខុជាបង ក៏បណ្តេញខ្ញុំថា លោកចូរទៅកាន់ផ្ទះ របស់ខ្លួនឥឡូវនេះចុះ ។ ខ្ញុំនោះ ដែលត្រូវបងបណ្តេញចេញហើយ ក៏តូចចិត្ត បានទៅឈរនៅអែបក្រនៀកទ្វារនៃអារាម របស់សង្ឃនោះ ដោយមានសេចក្តីអាឡោះអាល័យ ក្នុងសមណភេទឡើយ ។ គ្រានោះ ព្រះសាស្តាស្តេចមកដល់ទីនោះហើយ អង្អែលសីសៈរបស់ខ្ញុំ ចាប់ខ្ញុំត្រង់ដើមដៃ ហើយនាំចូលទៅកាន់អារាម នៃសង្ឃវិញ ។ ព្រះសាស្តាបានប្រទានសំពត់ជូតជើងដល់ខ្ញុំ ហើយទ្រង់ត្រាស់ដោយសេចក្តីអនុគ្រោះថា អ្នកចូរអធិដ្ឋានសំពត់ដ៏ស្អាត យ៉ាងនេះចុះ សំពត់នេះគេដាក់អធិដ្ឋានហើយ ក្នុងទីដ៏សមគួរ ។ ខ្ញុំក៏បានចាប់យកសំពត់នោះ ដោយដៃទាំងពីរ ហើយនឹកនូវកម្មដ្ឋាន មានផ្កាឈូកក្រហមជាអារម្មណ៍ ចិត្តរបស់ខ្ញុំក៏រួចស្រឡះ (ចាកកិលេស) ក្នុងទីនោះ ខ្ញុំបានដល់អរហត្តផលហើយ ។ ខ្ញុំបានដល់នូវបារមីញាណ ក្នុងទីទាំងពួង ក្នុងកាយដែលសម្រេចដោយចិត្ត ហើយកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា ចុល្លបន្ថកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ចុល្លបន្ថកត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ បិលិន្ទវច្ឆត្ថេរាបទានំ

[១៧] និព្វុតេ លោកនាថម្ហិ សុមេធេ អគ្គបុគ្គលេ
បសន្នចិត្តោ សុមនោ ថូបបូជំ អកាសហំ ។
យេ ច ខីណាសវា តត្ថ ឆឡភិញ្ញា មហិទ្ធិកា
តេសំ សមានេត្វា សង្ឃភត្តំ អកាសហំ ។
សុមេធស្ស ភគវតោ ឧបដ្ឋាកោ តទា អហុ
សុមេធោ នាម នាមេន អនុមោទិត្ថ សោ តទា ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចុល្លបន្ថកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចុល្លបន្ថកត្ថេរាបទាន ។

## បិលិន្ទវច្ឆត្ថេរាបទាន ទី ៥

[១៧] កាលព្រះលោកនាថ ព្រះនាមសុមេធៈ ទ្រង់ជាអគ្គបុគ្គល ទ្រង់បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើនូវការបូជាព្រះស្តូប ។ ព្រះខីណាស្រពទាំងឡាយណា ដែលបានអភិញ្ញា ៦ មានឫទ្ធិច្រើន នៅក្នុងទីនោះ ខ្ញុំក៏បានប្រជុំព្រះខីណាស្រពទាំងនោះ ក្នុងទីនោះ ហើយបានធ្វើសង្ឃភត្ត ។ កាលនោះ ព្រះថេរៈ ឈ្មោះសុមេធៈ ជាឧបដ្ឋាក របស់ព្រះមានព្រះភាគ ព្រះនាមសុមេធៈ ព្រះថេរៈនោះ បានធ្វើអនុមោទនា ក្នុងកាលនោះ ។

### បញ្ចមំ បិលិន្ទវច្ឆត្ថេរាបទានំ

តេន ចិត្តប្បសាទេន វិមានំ ឧបបជ្ជហំ
ចតុរាសីតិសហស្សានិ អច្ឆរាយោ អហេសុ[1] មេ ។
មមេវ អនុវត្តន្តិ សព្វកាមេហិ តា សទា
អញ្ញេ ទេវេ អភិភោមិ បុញ្ញកម្មស្សិទំ ផលំ ។
បញ្ចវីសតិកប្បម្ហិ វរុណោ នាម ខត្តិយោ
វិសុទ្ធភោជនោ អាសិំ ចក្កវត្តិ អហំ តទា ។
ន តេ ពីជំ បវប្បន្តិ នបិ នីយន្តិ នង្គលា
អកដ្ឋបាកិមំ សាលឹ បរិភុញ្ជន្តិ មានុសា ។
តត្ថ រជ្ជំ ករិត្វាន ទេវត្តំ បុន គច្ឆហំ
តទាបិ ឯទិសា មយ្ហំ និព្វត្តា ភោគសម្បទា ។
ន មំ មិត្តា អមិត្តា វា ហឹសន្តិ សព្វបាណិនោ
សព្វេសំបិ បិយោ ហោមិ បុញ្ញកម្មស្សិទំ ផលំ ។
តឹសកប្បសហស្សម្ហិ យំ ទានមទទិំ តទា
ទុគ្គតិំ នាភិជានាមិ គន្ធាលេបស្សិទំ ផលំ ។

---
១ ម. រមឹសុ ។



### បិលិន្ទវច្ឆត្ថេរាបទាន ទី ៥

ដោយចិត្តជ្រះថ្លានោះ ខ្ញុំបានចូលទៅកាន់វិមាន ដែលមានស្រីអប្សរ ៨៤ ពាន់ កើតឡើងសម្រាប់ខ្ញុំ ។ ពួកស្រីអប្សរនោះ ប្រព្រឹត្តតាមចិត្តខ្ញុំ ដោយកាមទាំងពួង សព្វៗ កាល ខ្ញុំគ្របសង្កត់នូវពួកទេវតាដទៃ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ២៥ កាលនោះ ខ្ញុំបានជាស្តេចចក្រពត្តិ ឈ្មោះវរុណៈ មានភោជនដ៏បរិសុទ្ធ ។ មនុស្សទាំងឡាយនោះ មិនបាច់សាបព្រោះពូជ មិនបាច់ភ្ជួរដោយនង្គ័ល តែងបរិភោគស្រូវសាលីដែលដុះក្នុងទីមិនបាច់ភ្ជួរ ។ ខ្ញុំសោយរាជ្យ ក្នុងអត្តភាពជាមនុស្សនោះហើយ ក៏បានទៅកាន់អត្តភាពជាទេវតាម្តងទៀត ការបរិបូណ៌ដោយភោគៈបែបនេះ ក៏កើតឡើងសម្រាប់ខ្ញុំ ក្នុងកាលនោះ ។ សត្វទាំងអស់ ទោះបីជាមិត្តក្តី មិនមែនជាមិត្តក្តី មិនដែលបៀតបៀនខ្ញុំ ខ្ញុំមែនជាទីស្រឡាញ់នៃសត្វទាំងពួង នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៣០ ពាន់ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃគ្រឿងក្រអូប និងគ្រឿងលាប ។

ឥមម្ហិ ភទ្ទកេ កប្បេ ឯកោ អាសឹ ជនាធិបោ
មហានុភាវោ រាជិសិ ចក្កវត្តិ មហព្វលោ ។
សោហំ បញ្ចសុ សីលេសុ ឋបេត្វា ជនតំ ពហុំ
បាបេត្វា សុគតឹយេវ ទេវតានំ បិយោ អហុំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បិលិន្ទវច្ឆោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បិលិន្ទវច្ឆត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ រាហុលត្ថេរាបទានំ

[១៨] បទុមុត្តរស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
សត្តភូមម្ហិ បាសាទេ អាទាសំ សន្ថរឹ អហំ ។



ក្នុងភទ្ទកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិមួយអង្គ ជាធំជាងជន មានអានុភាពច្រើន ជារាជឥសី មានកម្លាំងច្រើន ។ ខ្ញុំបានតាំងនៅក្នុងសីល ៥ ហើយញុំាងពួកជនច្រើនឲ្យដល់នូវសុគតិ ខ្ញុំជាទីស្រឡាញ់ នៃទេវតាទាំងឡាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិលិន្ទវច្ឆត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បិលិន្ទវច្ឆត្ថេរាបទាន ។

## រាហុលត្ថេរាបទាន ទី៦

(១៨) ខ្ញុំបានក្រាលកញ្ចក់ ក្នុងប្រាសាទ ៧ ជាន់ ថ្វាយព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ត្រង់

ទីឃាសាសហស្សេហិ   បរិកិណ្ណោ មហាមុនិ
ឧបាគមិ តទ្ធកុដី   និមនិត្វោ ឆកសរោ ។
វិកេតយិ(១) តទ្ធកុដី   ទេវទេហ ឆកសរោ
ភិក្ខុសង្ឃេ ឋិតោ សត្ថា   ឥមា គាថា អភាសថ ។
យោ ឆាយំ ជោតិតា សេយ្យា   អាតាសេក សុសណ្ឋេតោ
តមហំ កិត្តយិស្សាមិ   សុណាថ មម ភាសតោ ។
សោណ្ណមយា រូបិយមយា   អថោ វេឡុរិយាមយា
និព្វត្តិស្សន្តិ បាសាទា   យេ កេចិ មនសោ បិយា ។
ចតុស្សដ្ឋិក្ខត្តុំ ទេវិន្ទោ   ទេវរជ្ជំ ករិស្សតិ
សហស្សក្ខត្តុំ ចក្កវត្តិ   ករិស្សតិ អឧន្តក ។
ឯកាវីសតិកប្បម្ហិ   វិមលោ នាម ខត្តិយោ

១ ម. វិកេចន្តិ ។



ប្រកបដោយគុណ ។ ព្រះមហាមុនិ ជាធំជាងសត្វលើផែនដី ព្រះអង្គប្រសើរជាងជនៈ មានភិក្ខុព្រះទីណាស្រព មួយពាន់អង្គចោមរោម ស្តេចចូលទៅកាន់គន្ធកុដិ ។ ព្រះសាស្តា ជាទេវតាប្រសើរជាងទេវតា ព្រះអង្គប្រសើរជាងជនៈ ទ្រង់ញ៉ាំងគន្ធកុដិឲ្យរុងរឿង ឋិតនៅក្នុងកណ្តាលភិក្ខុសង្ឃ ហើយសម្តែង នូវគាថាទាំងឡាយនេះថា

ទីសេយ្យាសន៍នេះ ដែលបុគ្គលណា ធ្វើឲ្យរុងរឿង ហើយ ផ្ទុកកញ្ចក់ដែលគេក្រាលដោយល្អល្អៈ តថាគតនឹងសម្តែងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ ប្រាសាទណាមួយ ជាទីស្រឡាញ់ពេញចិត្ត ប្រាសាទទាំងនោះ សុទ្ធតែជាវិការៈនៃមាស ទាំងជាវិការៈនៃកែវពិទូរ្យ នឹងកើតឡើង សម្រាប់បុគ្គលនេះ ។ បុគ្គលនោះនឹងសោយរាជ្យ ជាធំជាងទេវតា អស់ ៦៤ ដង ក្នុងជាតិជាលំដាប់មក នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង ក្នុងកប្បទី ២១ នឹងបានជាស្តេចចក្រពត្តិ ព្រះនាមវិមលៈ ។

ចាតុរន្តោ វិជិតាវី ចក្កវត្តិ ភវិស្សតិ ។
ចក្កំ វេឡុរិយំ នាម វជ្ជកាហិ សុមាបិតំ
អាយាមតោ តីណិ សតំ ចតុរស្សសមាយុតំ ។
សុទស្សនោ នាម បាសាទោ វិស្សុកម្មេន មាបិតោ
កូដាគារវរូបេតោ សត្តរតនភូសិតោ ។
ទសសទ្ទា វិវិត្តំ វិជ្ជាធរសមាកុលំ
សុទស្សនំ ចក្កំ នេរាជំ ភវិស្សតិ ។
បក និក្ខដ្ឋិតេ តស្ស ឧក្កដ្ឋេត្វ ស្សរិយ(១)
វិភជិស្សតិ តំ ចិទ្ធំ សមន្តា អដ្ឋយោជនំ ។
កាមស្សកសហស្សម្ហិ ទិណ្ណាកាកុលសម្ភវេ
ភោគមោ នាម កោរព្ពោ សត្តា លោភោ ភវិស្សតិ ។
តុសិតា ចវិត្វាន សុញ្ញម្ហលេខ ពោធិតោ
គោតមស្ស ភគវតោ អគ្គោជោ សោ ភវិស្សតិ ។

១ ម. ស្សរិយោ ។



ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ជាស្តេចឈ្មោះសុរុចិ ។ ទីក្រុង (របស់ព្រះបាទវិមលៈនោះ) ឈ្មោះវេឡុរិយ ដែលគេស្ថាបនាដោយវជ្ជ មានបណ្ដោយ ៣០០ យោជន៍ ប្រកបដោយជ្រុង ៤ ។ ប្រាសាទឈ្មោះសុទស្សនៈ ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ ស្អិតស្អាងដោយកែវ ៧ ប្រការ ដែលវិស្សុកម្មទេវបុត្រសាងថ្វាយ ។ ទីក្រុងនោះ ស្ងប់ស្ងាត់ មានសម្លេងទាំង ១០ មិនដែលទាស់ដោយពួកវិជ្ជាធរ ដូចជាទីក្រុងឈ្មោះសុទស្សនៈ របស់ទេវតាទាំងឡាយដែរ ។ កាលព្រះអាទិត្យរះឡើង កន្លែងរបស់ក្រុងនោះ នឹងរុងរឿងជាទង្វ ដោយជុំវិញ អស់ចម្ងាយ ៨ យោជន៍ ។ ក្នុងកប្បទីមួយសែន ព្រះសាស្តា ព្រះនាមគោតម កើតក្នុងឧក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ កុលបុត្រនោះ នឹងច្យុតចាកឋានតុសិតនោះមកវិញ ត្រកូលសម្បូណ៌ដោយទ្រព្យ បានមកកើតជាព្រះរាជឱរស របស់ព្រះមានព្រះភាគ ព្រះនាមគោតម ។

ឆដ្ឋំ រាហុលត្ថេរាបទានំ

សចេ វសេយ្យ អគារំ ចក្កវត្តិ ភវេយ្យ សោ
អដ្ឋានមេតំ យំ តាទិ អគារេ រតិមជ្ឈគា ។
និក្ខមិត្វា អគារម្ហា បព្វជិស្សតិ សុព្វតោ
រាហុលោ នាម នាមេន អរហា សោ ភវិស្សតិ ។
កិកីវ អណ្ឌំ រក្ខេយ្យ ចាមរីវ វាលធឹ
និបកោ សីលសម្បន្នោ មមំ រក្ខិ(១) មហាមុនិ ។
តស្សាហំ ធម្មមញ្ញាយ វិហាសិំ សាសនេ រតោ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា រាហុលោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

រាហុលត្ថេរស្ស អបទានំ សមត្តំ ។

---
១ ម. ឆាំ រក្ខិ ។



រាហុលត្ថេរាបទាន ទី ៦

កុលបុត្រនោះ ប្រសិនបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ តែមិនមានហេតុ ដែលឲ្យកុលបុត្រជាតាទិបុគ្គលនុ៎ះ បានដល់នូវសេចក្តីត្រេកអរក្នុងផ្ទះឡើយ កុលបុត្រនោះនឹងចេញចាកផ្ទះទៅបួស ជាអ្នកមានវត្តល្អ នឹងបានជាព្រះអរហន្ត ឈ្មោះរាហុល ។

ព្រះមហាមុនី ព្រះអង្គមានប្រាជ្ញាចាស់ បរិបូណ៌ដោយសីល ទ្រង់រក្សាខ្ញុំ ថែទាំខ្ញុំ ដូចជាមេបក្សីក្រួចរក្សាស៊ុត ពុំនោះសោត ដូចជាមេចាមរី រក្សារោម ។ ខ្ញុំបានដឹងធម៌ របស់ព្រះតថាគតសម្ពុទ្ធនោះ ត្រេកអរក្នុងសាសនា ហើយកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះរាហុលត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ រាហុលត្ថេរាបទាន ។

## សត្តមំ ឧបសេនវង្គន្តបុត្តត្ថេរាបទានំ

[១៩] បទុមុត្តរំ ភគវន្តំ លោកជេដ្ឋំ នរាសភំ
បព្ភារម្ហិ និសិន្នំ តំ(១) ឧបគញ្ឆិំ(២) នរុត្តមំ ។
កណិការំ បុប្ផិតំ ទិស្វា វណ្ដេ(៣) ឆេត្វាន តំ អហំ
អលង្ករិត្វា ឆត្តម្ហិ ពុទ្ធស្ស អភិរោបយិំ ។
បិណ្ឌបាតញ្ច បាទាសិំ បរមន្នំ សុភោជនំ
ពុទ្ធេន នវមេ តត្ថ សមណា អដ្ឋ ភោជិតា ។
អនុមោទិ មហាវីរោ សយម្ភូ អគ្គបុគ្គលោ
ឥមិនា ឆត្តទានេន បរមន្នបវេច្ឆនា
តេន ចិត្តប្បសាទេន សម្បត្តិំ អនុភោស្សសិ
តិំសក្ខត្តុំ ច ទេវិន្ទោ ទេវរជ្ជំ ករិស្សតិ ។
ឯកវីសតិក្ខត្តុំ ច ចក្កវត្តិ ភវិស្សតិ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។

---

១ ម. និសីទន្តំ ។ ២ ឱ. ឧបគច្ឆិំ ។ ៣ ម. វិណ្ដេ ។



## ឧបសេនវង្គន្តបុត្តត្ថេរាបទាន ទី ៧

[១៩] ខ្ញុំចូលទៅគាល់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ព្រះអង្គជាច្បងក្នុងលោក អង់អាចជាងនរៈ ប្រសើរជាងនរៈ ដែលទ្រង់គង់នៅក្នុងជ្រលងភ្នំ ។ គ្រានោះ ខ្ញុំបានឃើញផ្កាកណិការរីក ក៏កាច់ផ្កានោះត្រង់ទង យកមកធ្វើប្រដាប់លើឆ័ត្រ ហើយនាំយកចូលទៅថ្វាយព្រះសម្ពុទ្ធ ។ ខ្ញុំបានថ្វាយបិណ្ឌបាត ជាភោជនដ៏ល្អឧត្តម . ញុំាងសមណៈ ៨ អង្គ គំរប់ ៩ នឹងព្រះសម្ពុទ្ធ ឲ្យឆ្អែតស្កប់ស្កល់ក្នុងទីនោះ ។ ព្រះសយម្ភូមានព្យាយាមធំ ព្រះអង្គប្រសើរ ទ្រង់អនុមោទនាថា ដោយការថ្វាយឆ័ត្រ និងការថ្វាយបិណ្ឌដ៏ប្រសើរនេះផង

ដោយចិត្តជ្រះថ្លានោះ បុគ្គលនេះ នឹងបានទទួលសម្បត្តិ គឺនឹងបានគ្រប់គ្រងទេវរាជ្យ ជាធំជាងទេវតាអស់ ៣០ ដង ។ នឹងបានជាស្ដេចចក្រពត្តិ អស់ ២១ ដង នឹងបានគ្រប់គ្រងប្រទេសរាជ្យដ៏ធំទូលាយ រាប់មិនអស់ដោយគណនា ។

យំ វទន្តិ សុមេធោតិ  ភូរិបញ្ញំ សុមេធសំ
កប្បតោ សតសហស្សេ  ឱក្កាកកុលសម្ភវោ ។
គោតមោ នាម គោត្តេន  សោ ពុទ្ធោ ភវិស្សតិ
សាសនេ ទិព្វមានម្ហិ  មនុស្សត្តំ គមិស្សតិ ។
ឧបោសថោតិ នាមេន  ហេស្សតិ សត្ថុសាវកោ
ករំ វត្តតេ មយ្ហំ  តស្ស សុត្វា សម្មុខា
ធារេមិ អន្តិមំ ទេហំ  ជេត្វា មារំ សវាហនំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧបោសថោ វុត្តបុត្តា ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧបោសថត្ថេរបុព្វកម្មស្ស អបទានំ សមត្តំ ។

តតិយភាណវារំ និដ្ឋិតំ ។





ព្រះសម្ពុទ្ធដ៏ទ្រង់យស ទ្រង់ត្រាស់ហៅបណ្ឌិតណា ជាអ្នកមានប្រាជ្ញាដូចផែនដី មានប្រាជ្ញាល្អ ជាអ្នកមានប្រាជ្ញាល្អ បណ្ឌិតនោះ នឹងកើតក្នុងឧក្កាកត្រកូល ក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ បណ្ឌិតនុ៎ះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម កាលបើសាសនានៃព្រះគោតម រុងរឿង បុគ្គល (អ្នកច្យុយ ផ្កា) នោះ នឹងទៅកាន់អត្តភាពជាមនុស្ស ឈ្មោះឧបោសថៈ នឹងបានជាសាវ័ក របស់ព្រះសាស្តាព្រះនាមគោតមនោះ ។

គុណវិសេស ជាទីបំផុត របស់ខ្ញុំ កំពុងប្រព្រឹត្តទៅ គតជាទីអស់ ខ្ញុំបានផុតភពហើយ ខ្ញុំបានឈ្នះមារ ព្រមទាំងសេនារបស់មារ ហើយទ្រទ្រង់នូវកាយជាទីបំផុត ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបោសថត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧបោសថត្ថេរបុព្វកម្មអបទាន ។

ចប់ ភាណវារៈ ទី ៣ ។

## អដ្ឋមំ រដ្ឋបាលត្ថេរាបទានំ

(៦០) បទុមុត្តរស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
វរនាគោ មយា ទិន្នោ ឦសាទន្តោ ឧរូឡ្ហវា ។
សេតច្ឆត្តោបសោភិតោ សកច្ឆណោ[១] សហត្ថិបោ
អគ្ឃាបេត្វាន តំ សព្វំ សង្ឃារាមំ អការយឹ ។
ចតុបញ្ញាសសហស្សានិ បាសាទេ ការយឹ អហំ
មហោឃទានំ ករិត្វាន និយ្យាទេសឹ មហេសិនោ ។
អនុមោទិ មហាវីរោ សយម្ភូ អគ្គបុគ្គលោ
សព្វេ ជនេ ហាសយន្តោ ទេសេសិ អមតំ បទំ ។
តំ មេ ពុទ្ធោ វិយាកាសិ ជលជុត្តមនាយកោ[២]
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
ចតុបញ្ញាសសហស្សានិ បាសាទេ ការយិ អយំ
កថយិស្សាមិ វិបាកំ សុណាថ មម ភាសតោ ។

១ ម. សាវត្ថិតោ ។ ២ ម. ជលជុត្តមនាមកោ ។





## រដ្ឋបាលត្ថេរាបទាន ទី៨

(៦០) ខ្ញុំបានថ្វាយដំរីដ៏ប្រសើរ មានភ្លុកដ៏ដូចងនង្គ័ល មានភ្លៅដ៏ធំមូល ដល់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ។ ដំរីនោះ មានស្វេតច្ឆត្រសម្រាប់ប្រដាប់ មានកប្បសម្រាប់ព្យាបាល មានហ្មត់សម្រាប់ព្យា ខ្ញុំកាត់ថ្លៃរបស់ទាំងអស់នោះ (លក់បំណាយ) ធ្វើអារាមរបស់សង្ឃ ។ ខ្ញុំបានធ្វើប្រាសាទ អស់ប្រាក់ ៥៤ ពាន់ ធ្វើទានដូចជាទឹកជំនន់ធំ ហើយប្រគល់ថ្វាយព្រះមហេសី ។ ព្រះសយម្ភូ មានព្យាយាមធំ ជាបុគ្គលប្រសើរ ទ្រង់អនុមោទនា ញ៉ាំងជនទាំងពួងឲ្យរីករាយ សម្តែងនូវអមតនិព្វាន ។ ព្រះពុទ្ធ ជានាយក ព្រះនាមបទុមុត្តរៈ គង់ក្នុងភិក្ខុសង្ឃ ទ្រង់ព្យាករទានរបស់ខ្ញុំនោះ ហើយសម្តែងគាថាទាំងឡាយនេះថា

កុលបុត្តនេះ បានធ្វើប្រាសាទ អស់ប្រាក់ ៥៤ ពាន់ (ក្នុងកាលណោះ) តថាគតនឹងសម្តែង នូវផលនៃទាន (របស់កុលបុត្តនុ៎ះ) អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។

អដ្ឋមំ វន្ទិតាសណ្ឋេកទានំ

អដ្ឋារសសហស្សានិ  ក្ខុជាតាក អាសិស្សរេ
ព្រហ្មត្ថុមម្ហំ និព្វត្តា  សព្វសោណ្ណមយា ចតេ ។
បញ្ញាសក្ខត្តុំ ទេវិន្ទោ  ទេវរជ្ជំ ការេស្សតិ
អដ្ឋ បញ្ញាសក្ខត្តុំ ច  ចក្កវត្តិ ភវិស្សតិ ។
កប្បសតសហស្សម្ហិ  ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន  សត្ថា លោកេ ភវិស្សតិ ។
ទេវលោកា ចវិត្វាន  សុក្កមូលេន ចោទិតោ
ឌីតេ កុលេ មហាភោគេ  និព្វត្តិស្សតិ តាវទេ ។
សោ បច្ឆា បព្វជិត្វាន  សុក្កមូលេន ចោទិតោ
វជ្ជីបាលោតិ នាមេន  ហេស្សតិ សត្ថុ សាវកោ ។
បធានំ បហិតត្តោ សោ  ឧបសន្តោ និរូបធិ
សព្វាសវេ បរិញ្ញាយ  និព្វាយិស្សត្យនាសវោ ។
ឧដ្ឋាយ អភិនិក្ខម្ម  ជហិត្វា ភោគសម្បទា
ខេឡបិណ្ឌោវ ភោគម្ហិ  បេមំ មយ្ហំ ន វិជ្ជតិ ។



វន្ទិតាសណ្ឋេកទាន ទី ៨

ផ្ទះមានកំពូលចំនួន ១៨ កាន់ នឹងកើតឡើងសម្រាប់កុលបុត្តនេះ ផ្ទះមានកំពូលទាំងនោះ សុទ្ធតែជាវិការៈនៃមាសទាំងអស់ កើតឡើងក្នុងវិមាននោះដ៏ឧត្តម ។ កុលបុត្តនេះ នឹងបានសោយទេវរជ្ជ ជាធំជាងទេវតា អស់ ៥០ ដង នឹងបានជាស្តេចចក្រពត្តិ អស់ ៥៨ ដង ។ ក្នុងកប្បទីមួយសែន ព្រះសាស្តា ព្រះនាមគោតម កើតក្នុងត្រកូលឱក្កាករាជ នឹងត្រាស់ដឹងក្នុងលោក ។ ខណៈនោះ កុលបុត្តនេះ នឹងច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន នឹងកើតក្នុងត្រកូលស្តុកស្តម្ភ មានភោគៈច្រើន ។ កុលបុត្តនោះឈ្មោះវជ្ជីបាល លុះកាលជាខាងក្រោយមក ក៏ចេញបួស ត្រូវកុសលមូលដាស់តឿន នឹងបានជាសាវ័ក នៃព្រះសាស្តា ព្រះនាមគោតមនោះ ។ កុលបុត្តនោះឯង មានចិត្តបញ្ជូនទៅកាន់ព្យាយាម ជាអ្នកមានចិត្តស្ងប់ មិនមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំក្រោកទៅសាងផ្នួស លះបង់ភោគសម្បត្តិ ខ្ញុំមិនមានសេចក្តីស្រឡាញ់ភោគសម្បត្តិ ទុកដូចជាដុំទឹកមាត់ ។

ភិយំ មេ ធុរធោរយ្ហំ  យោគក្ខេមាធិវាហនំ
ធារេមិ អន្តិមំ ទេហំ  សម្មាសម្ពុទ្ធសាសនេ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វច្ឆបាលោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វច្ឆបាលត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ សោបាកត្ថេរាបទានំ

[៦១] បព្ភារំ សោធយន្តស្ស  ឋាវរេ(១) បព្វតុត្តមេ
សិទ្ធត្ថោ នាម ភគវា  អាគច្ឆិ មម សន្តិកំ ។
ពុទ្ធំ ឧបគតំ ទិស្វា  លោកជេដ្ឋស្ស តាទិនោ
សន្ថរំ បញ្ញបេត្វាន(២)  បុប្ផាសនមទាសហំ ។

១ ម. វិបិនេ ។ ២ ម. សន្ថរិត្វាន ។



សេចក្តីព្យាយាមរបស់ខ្ញុំ នាំទៅនូវធុរៈ ជាទីនាំមកនូវធម៌ដ៏ក្សេមចាកយោគៈ ឥឡូវនេះ ខ្ញុំទ្រទ្រង់នូវកាយ ដែលជាទីបំផុតក្នុងសាសនា របស់ព្រះសម្មាសម្ពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវច្ឆបាលត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វច្ឆបាលត្ថេរាបទាន ។

## សោបាកត្ថេរាបទាន ទី៩

[៦១] កាលខ្ញុំកំពុងតែសំអាតញកដ៏ភ្នំ ជិតភ្នំប្រសើរ ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ទ្រង់ស្តេចមកកាន់សំ-ណាក់ខ្ញុំ ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធស្តេចមកដល់ ក៏ក្រាលកម្រាល ហើយបូជាអាសនៈជាវិការៈនៃផ្កា ចំពោះព្រះសម្ពុទ្ធ ជាលោកជេដ្ឋ ព្រះអង្គមិនញាប់ញ័រ ដោយលោកធម៌ ។

បុញ្ញាសនេ និសីទិត្វា    សិក្ខាត្វា លោកធាតុយោ
មមញ្ច កតិបញ្ញាយ    អជ្ឈត្តំ ឧទាហរិ ។
អជ្ជា វត សរន្តាក    ឧបាទាយ ជន្មិនោ
ឧបេន្តិត្វា និព្វុត្តិ    តេសំ រូបសមោ សុខោ ។
វត្វំ វត្វាន សព្វញ្ញូ    លោកជេដ្ឋោ នរាសភោ
នភេ អព្ភុគ្គមិ ធីរោ    ហំសរាជាវ អម្ពរេ ។
សកំ ទិដ្ឋី ជហិត្វាន    ភាវយានិច្ចសញ្ញហំ
ឯកាហំ ភាវយិត្វាន    តត្ថ កាលកតោ អហំ ។
ទ្វេ សម្បត្តី អនុភោត្វា    សុក្កមូលេន ចោទិតោ
បច្ឆិមេ ភវសម្បត្តេ    សាធាការយោនុបាគមិ(១) ។
អគារា អភិនិក្ខម្ម    បព្វជឹ អនគារិយំ
ជាតិយា សត្តវស្សោហំ    អរហត្តំ អបាបុណឹ ។

១ ប. បច្ឆិមេ ភវសម្បត្តេ សធាកយោនុបាគមិ ។



ព្រះលោកនាយកព្រះអង្គសម្ពុទ្ធ គង់លើបុប្ផាសនៈ ហើយ
ប្រោសតំបែសខ្ញុំ ទើបទ្រង់សម្ដែងនូវអនិច្ចតាធម៌ថា សង្ខារ
ទាំងឡាយ មិនទៀងតាក់ពិត មានការកើតឡើង និងការ
សូន្យទៅវិញជាធម្មតា លុះកើតឡើងហើយ រមែងរលត់ទៅ
វិញ ការរម្ងាប់នូវសង្ខារទាំងឡាយនោះបាន ទើបនាំមកនូវ
សេចក្ដីសុខ ។ ព្រះសព្វញ្ញូ ព្រះអង្គជាធំជាងគេនៃលោក
ជានរាសភៈ ជាអ្នកប្រាជ្ញ លុះទ្រង់សម្ដែងអនិច្ចតាធម៌នេះរួច
ហើយ ទើបស្ដេចហោះឡើងទៅក្នុងអាកាស ដូចស្ដេចហង្ស
ការហើរទៅក្នុងអាកាស ។ ខ្ញុំបានលះបង់នូវទិដ្ឋិរបស់ខ្លួន
ហើយចម្រើននូវអនិច្ចសញ្ញា ខ្ញុំក៏បានចម្រើន អស់ ១ ថ្ងៃ
ហើយធ្វើមរណកាល ក្នុងទីនោះ ។ ខ្ញុំសោយសម្បត្តិទាំងពីរ
ត្រូវកុសលមូលដាស់តឿន ក៏បានដល់នូវបច្ឆិមភព ខ្ញុំចូល
ទៅកាន់កំណើត ប្រកបដោយផល ។ ខ្ញុំមានអាយុ ៧ ឆ្នាំ
ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផនួស បានដល់អរហត្តផល ។

អារទ្ធវីរិយោ បហិតត្តោ សីលេសុ សុសមាហិតោ
តោសេត្វាន មហានាគំ អលត្ថំ ឧបសម្បទំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ បុប្ផទានស្សិទំ ផលំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ សញ្ញំ ភាវយឹ តទា
តំ សញ្ញំ ភាវយន្តស្ស បត្តោ មេ អាសវក្ខយោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សោបាកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សោបាកត្ថេរស្ស អបទានំ សមត្តំ ។



ខ្ញុំមានព្យាយាមតឹងរ៉ឹងណាស់ មានចិត្តបញ្ជូនទៅកាន់សមាធិ មានចិត្តតំកល់ខ្ជាប់ល្អក្នុងសីល ញុំាងព្រះពុទ្ធជាមហានាគឲ្យត្រេកអរត្រេកណា ហើយបានឧបសម្បទា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្កា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានចម្រើននូវអនិច្ចសញ្ញា ក្នុងកាលនោះ ការអស់អាសវៈក៏បានសម្រេចដល់ខ្ញុំ ដែលចម្រើនសញ្ញានោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោបាកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សោបាកត្ថេរាបទាន ។

## ទសមំ សុមង្គលត្ថេរាបទានំ

[៦៦] អាហុតឹ យិដ្ឋុកាមោហំ បដិយាទេត្វាន ភោជនំ
ព្រាហ្មណេ បដិមានេន្តោ វិសាលេ មាឡកេ ឋិតោ ។

អថទ្ទសាសឹ សម្ពុទ្ធំ បិយទស្សឹ មហាយសំ
សព្វលោកំ វិនេតារំ សយម្ភុំ អគ្គបុគ្គលំ ។

ភគវន្តំ ជុតិមន្តំ សាវកេហិ បុរក្ខតំ
អាទិច្ចមិវ រោចន្តំ រថិយំ បដិបន្នកំ ។

អញ្ជលឹ បគ្គហេត្វាន សកំ ចិត្តំ បសាទយឹ
មនសា និមន្តេសឹ អាគច្ឆតុ មហាមុនិ ។

មម សង្កប្បមញ្ញាយ សត្ថា លោកេ អនុត្តរោ
ខីណាសវសហស្សេហិ មម ទ្វារំ ឧបាគមិ ។

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
បាសាទំ អភិរុហិត្វា សីហាសនេ និសីទតុ ។



## សុមង្គលត្ថេរាបទាន ទី ១០

[៦៦] ខ្ញុំមានប្រាថ្នានឹងបូជាភ្លើងបូជា កំពុងតាក់តែងភោជនទទួលពួកព្រាហ្មណ៍ ឈរចាំនៅក្នុងរោងធំ ។ គ្រានោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធព្រះនាមបិយទស្សី ព្រះអង្គមានយសធំ ទ្រង់ទូន្មានសត្វលោកទាំងពួង ព្រះអង្គជាព្រះសយម្ភូ ជាបុគ្គលដ៏ប្រសើរ ។ ព្រះអង្គមានជោគ មានរស្មីរុងរឿង មានពួកសាវ័កហែហម កំពុងស្តេចទៅកាន់ផ្លូវ រុងរឿងដូចជាព្រះអាទិត្យ ។ ខ្ញុំផ្គងអញ្ជលីហើយធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បាននិមន្តព្រះអង្គដោយចិត្តថា សូមព្រះមហាមុនី ស្តេចនិមន្តមក ។ ព្រះសាស្តាប្រសើរក្នុងលោក ទ្រង់ជ្រាបបំណងរបស់ខ្ញុំ ហើយស្តេចចូលទៅកាន់ទ្វារផ្ទះរបស់ខ្ញុំ (ជាមួយ) នឹងព្រះខីណាស្រពមួយពាន់អង្គ ។ (ខ្ញុំក្រាបទូលថា) បពិត្របុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្របុរសដ៏ឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ សូមព្រះអង្គស្តេចឡើងកាន់ប្រាសាទរបស់ខ្ញុំ ហើយគង់លើអាសនៈដ៏ប្រសើរ ។

ទន្តោ ទន្តុបរិកេ   តិណ្ណោ តារយតំ វរេ
ហំសានំ អភិរូហិត្វា   និសីទិ បវេសនេ ។
យំ មេ អត្ថិ សកេ គេហេ   អាមិសំ បច្ចុបដ្ឋិតំ
តាហំ ពុទ្ធស្ស អាទាសិំ   បសន្នោ សេហិ បាណិភិ ។
បសន្នចិត្តោ សុមនោ   វេទជាតោ កតញ្ជលី
ពុទ្ធសេដ្ឋំ នមស្សាមិ   អហោ ពុទ្ធស្សុឡារតា ។
អដ្ឋន្នំ បយិរុបាសតំ(១)   ភុញ្ជុំ ខិណាសវា ពហូ
តុយ្ហេវេសោ អានុភាវោ   សរណាគតំ ឧបេមហំ ។
បិយទស្សី ច ភគវា   លោកជេដ្ឋោ នរាសភោ
ភិក្ខុសង្ឃេ និសីទិត្វា   ឥមា គាថា អភាសថ ។
យោ សោ សង្ឃំ អភោជេសិ   ឧជុភូតំ សមាហិតំ
តថាគតញ្ច សម្ពុទ្ធំ   សុណាថ មម ភាសតោ ។

---
១ ម. បយិរុបាសំ ។



ព្រះសម្ពុទ្ធ ព្រះនាមបិយទស្សី ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ ព្រះអង្គមានពួកព្រះខីណាស្រពជាបរិវារ ដែលមានឥន្ទ្រិយទូន្មានហើយដែរ ព្រះអង្គឆ្លងផុតសង្សារ ប្រសើរជាងពួកជនអ្នកឆ្លង ទ្រង់ចូលទៅកាន់ប្រាសាទ ហើយគង់លើអាសនៈដ៏ប្រសើរ ។ អាមិសៈណា ដែលខ្ញុំតាក់តែងបំរុងទុកក្នុងផ្ទះរបស់ខ្លួន ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយអាមិសៈនោះ ចំពោះព្រះពុទ្ធដោយដៃទាំងពីររបស់ខ្លួន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តល្អ មានសេចក្តីត្រេកអរ ធ្វើអញ្ជលីនមស្ការនូវព្រះពុទ្ធដ៏ប្រសើរថា ឱ ព្រះពុទ្ធមានអានុភាពថ្លៃថ្លា ។ បណ្តាភិក្ខុ ៨ អង្គដែលចូលមកគាល់ទីនោះ មានព្រះខីណាស្រពច្រើនអង្គនេះ ជាអានុភាពរបស់ព្រះអង្គ ខ្ញុំសូមដល់នូវព្រះអង្គជាទីពឹង ។ ព្រះមានព្រះភាគ ព្រះនាមបិយទស្សី ជាច្បងក្នុងលោក ជានរាសភៈ គង់ក្នុងភិក្ខុសង្ឃ ហើយសំដែងគាថាទាំងនេះថា

កុលបុត្តណា បានឲ្យភិក្ខុសង្ឃ ជាអ្នកមានចិត្តត្រង់ មានចិត្តនឹងធឹង ព្រមទាំងតថាគត ជាព្រះសម្ពុទ្ធ ឲ្យឆាន់ស្កប់ស្កល់ អ្នកទាំងឡាយ ចូរស្តាប់តថាគតសំដែងចុះ ។

ទសមំ សុមង្គលត្ថេរាបទានំ

សត្តសីតិក្ខត្តុំ សោ   ទេវរជ្ជំ ករិស្សតិ
សកកម្មាភិរត្តោ សោ   ទេវលោកេ រមិស្សតិ ។
ទស ច អដ្ឋក្ខត្តុំ សោ   ចក្កវត្តិ ករិស្សតិ
បទេស្យរជ្ជំ បញ្ចសតំ   វសុធំ អាវសិស្សតិ ។
អរញ្ញំ វនមោគ្គយ្ហ(១)   កាននំ ព្យគ្ឃសេវិតំ
បធានំ បទហិត្វាន   កិលេសេ ឈាបយិតា មហេ ។
អដ្ឋារសេ កប្បសតេ   យំ ទានមទទិំ តទា
ទុគ្គតឹ នាភិជានាមិ   ភត្តទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា សុមង្គលោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

សុមង្គលត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. អរញ្ញ វនមោគ្គយ្ហ ។

សុមង្គលត្ថេរាបទាន ទី ១០

កុលបុត្រនោះ នឹងសោយទេវរាជ្យ អស់ ៦៧ ដង កុលបុត្រនោះត្រេកអរក្នុងកុសលកម្ម របស់ខ្លួនហើយ នឹងរីករាយក្នុងទេវលោក ។ កុលបុត្រនោះ នឹងបានជាស្តេចចក្រពត្តិ ១៨ ដង នឹងបានសោយប្រទេសរាជ្យ គ្រប់គ្រងផែនដី អស់ ៥០០ ដង ។

ខ្ញុំចូលទៅកាន់ព្រៃធំ ជាអរញ្ញនៃ ដែលពួកខ្លាអាស្រ័យនៅ ក៏តាំងព្យាយាមដុតបំផ្លាញ នូវពួកកិលេស ។ ក្នុងកប្បទី ១១៨ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យភត្ត ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមង្គលត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមង្គលត្ថេរាបទាន ។

## ឧទ្ទានំ

សីហាសនី ឯកត្ថម្ភី នន្ទោ ច ចុល្លបន្ថកោ
បិលិន្ទរាហុលោ ចេវ វង្គន្តោ រដ្ឋបាលកោ ។
សោបាកោ មង្គលោ ចេវ ទសេវ ទុតិយេ វគ្គេ
សតញ្ច សត្តតឹសា ច គាថា ចេត្ថ បកាសិតា ។

សីហាសនិយវគ្គោ ទុតិយោ ។

---





## ឧទ្ទាន

រឿងព្រះសីហាសនទាយកត្ថេរ ១ ព្រះឯកត្ថម្ភិកត្ថេរ ១ ព្រះនន្ទត្ថេរ ១ ព្រះចុល្លបន្ថកត្ថេរ ១ ព្រះបិលិន្ទវច្ឆត្ថេរ ១ ព្រះរាហុលត្ថេរ ១ ព្រះឧបសេនវង្គន្តបុត្តត្ថេរ ១ ព្រះរដ្ឋបាលត្ថេរ ១ ព្រះសោបាកត្ថេរ ១ ព្រះសុមង្គលត្ថេរ ១ ត្រូវជា ១០ រឿង ជាវគ្គទីពីរ គាថាដែលលោកសំដែងហើយ ក្នុងវគ្គនោះ មាន ១៣៧ គាថា ។

ចប់ សីហាសនិយវគ្គ ទី ២ ។

## តតិយោ សុភូតិវគ្គោ

### បឋមំ សុភូតិត្ថេរាបទានំ

(៤៣) ហិមវន្តស្ស អវិទូរេ  និសភោ នាម បព្វតោ
អស្សមោ សុកតោ មយ្ហំ  បណ្ណសាលា សុមាបិតា ។
កោសិយោ នាម នាមេន  ជដិលោ ឧគ្គតាបនោ
ឯកាកិយោ អទុតិយោ  វសាមិ និសភេ តទា ។
ផលមូលញ្ច បណ្ណញ្ច  ន ភុញ្ជាមិ អហំ តទា
បវត្តញ្ច សុបាតាហំ  ឧបជីវាមិ តាវទេ ។
នាហំ កោបេមិ អាជីវំ  ចជមានោបិ ជីវិតំ
អារាធេមិ សកំ ចិត្តំ  វិវជ្ជេមិ អនេសនំ ។
រូបសំហិតំ ចិត្តំ  យទា ឧប្បជ្ជតេ មម
សយំវ បច្ចវេក្ខាមិ  ឯកគ្គោ តំ ទមេមហំ ។
រជ្ជសិ រជនីយេ ច  ទោសនីយេ ច ទុស្សសេ
មុយ្ហសេ មោហនីយេ ច  និក្ខមស្សុ វនា តុវំ ។

## សុភូតិវគ្គ ទី ៣

### សុភូតិត្ថេរាបទាន ទី ១

(៤៣) មានភ្នំមួយឈ្មោះនិសភៈ នៅជិតព្រៃហិមពាន្ត អាស្រមរបស់ខ្ញុំ ទាំងបណ្ណសាលារបស់ខ្ញុំ គេសង់ល្អហើយ ស្រួលត្រង់នោះ ។ ក្នុងកាលនោះ ខ្ញុំជាជដិល ឈ្មោះកោសិយៈ មានតបៈដ៏ខ្ពង់ខ្ពស់ ប្រព្រឹត្តតែម្នាក់ឯង ឥតមានបុគ្គលជាទីពីរ អាស្រ័យនៅភ្នំនិសភៈ ។ ខ្ញុំមិនបរិភោគផ្លែឈើ មើមឈើ និងស្លឹកឈើទេ ខ្ញុំចិញ្ចឹមជីវិតដោយផ្លែឈើជ្រុះឯង ក្នុងវេលាព្រឹក ។ ខ្ញុំស៊ូលះបង់ជីវិត មិនញុំាងអាជីវៈឲ្យកម្រើក ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យរីករាយ វៀរចាកនូវអនេសនៈ ។ ចិត្តរបស់ខ្ញុំប្រកបដោយរាគៈ កើតឡើងក្នុងកាលណា ខ្ញុំពិចារណាដោយខ្លួនឯង ខ្ញុំតែម្នាក់ឯងទូន្មាននូវចិត្តនោះ ក្នុងកាលនោះថា អ្នកឯងនៅតែត្រេកអរក្នុងអារម្មណ៍ ដែលគួរត្រេកអរ ប្រទូស្តក្នុងអារម្មណ៍ដែលគួរប្រទូស្តផង វង្វេងក្នុងអារម្មណ៍ដែលគួរវង្វេងផង អ្នកចូរចៀសចេញចាកព្រៃទៅ ។

វិសុទ្ធានំ អយំ វាសោ និម្មលានំ តបស្សិនំ
មា ខោ វិសុទ្ធំ ទូសេសិ និក្ខមស្សុ វនា តុវំ ។
រកតារិកោ(១) កទិត្វាន យថា យុត្តិ(២) លភិស្សសិ
ឧក្កោចិ មា វិភាវេសិ និក្ខមស្សុ វនា តុវំ ។
ជភលាតំ យថា កដ្ឋំ ន ក្វចិ កិច្ចការតំ
នេវ គាមេ អរញ្ញេ វា ន ហិ តំ កដ្ឋសម្មតំ ។
ឯភលាតូបមោ ត្វំសិ ន គិហី នបិ សញ្ញតោ
ឧភតោ មុត្តកោ អជ្ជ និក្ខមស្សុ វនា តុវំ ។
សិយា នុ ខោ តវ(៣) ឯតំ កោ បជានាតិ(៤) តេ ឥទំ
សីឃំ(៥) ធុរំ វហិសិ មេ កោសជ្ជពហុលាយ ច ។
ជិគុច្ឆិស្សន្តិ តំ វិញ្ញូ អសុចិំ នាគរិកោ យថា
អាកឌ្ឍិត្វាន ឥសយោ ចោទយិស្សន្តិ តំ សទា ។

១ ម. ឧត្តរិកោ ។ ២ ម. យុត្តំ ។ ៣ ម. តុវំ ។ ៤ ម. បជានាតិ ។ ៥ ម. សក្កា ។



ប្រទេសនេះ ជាលំនៅរបស់ពួកបុគ្គលជាអ្នកស្អាត ដែលមិនមានមន្ទិល មានតបធម៌ អ្នកកុំប្រទូស្តទីស្អាតនេះឡើយ អ្នកចូរចៀសចេញចាកព្រៃទៅ ។ បើអ្នកជាគ្រហស្ថ ទីទ ទាននូវស្បៀង ក្នុងកាលណា អ្នកកុំធ្វើនូវកំហឹងនោះឲ្យកាត់តង់ឡើយ (ក្នុងកាលនោះ) អ្នកចូរចៀសចេញចាកព្រៃទៅ ។ ខេសដែលគេដុតសាកសពហើយ ជារបស់ធ្វើកិច្ចមិនបានក្នុងទីណាមួយ គឺមិនបានការក្នុងស្រុកក្នុងព្រៃ ព្រោះថាខេសនោះ គេមិនសន្មតថាជាខេសឡើយ យ៉ាងណាមិញ ។ អ្នកឯងទុកដូចជាខេស ដែលគេដុតសាកសព គឺមិនមែនជាគ្រហស្ថ មិនមែនជាបព្វជិតសង្រួមទេ ជាមនុស្សដុតបាកទោកំណើត ក្នុងថ្ងៃនេះ អ្នកចូរចៀសចេញចាកព្រៃទៅ ។ ក្រែងអ្នកនឹងបានតស់កើតឡើង ព្រោះអ្នកណានឹងដឹង នូវការកើតរបស់អ្នកនេះ អ្នកនឹងនាំទៅនូវទុក្ខៈ ជាកកាកនៃយើង ដែលជាអ្នកច្រើនដោយសេចក្ដីខ្ជិលច្រអូស យ៉ាងឆាប់ ។ អ្នកប្រាជ្ញទាំងឡាយ នឹងរង្គៀសអ្នក ដូចអ្នកក្រុងរង្គៀសមនុស្សមិនស្អាត ឥសីទាំងឡាយ នឹងកោះហៅអ្នកមកដោយ សព្វ ៗ កាល ។

### បឋម សុភាសិតឆ្លាប់កាច់

តំ វិញ្ញូ បរិទេវន្តំ សអតិញ្ញាត្តសាសនំ
សំកសំ អលគគ្គោ ហិ កាជំ ទីវិហិសី តុរី ។
តិធប្បភិន្នំ មាតង្គំ កុញ្ជរំ សដ្ឋិហាយនំ
ពលីនាគោ ឧបគន្ត្វា យូថា នីហរតេ គជំ ។
យូថា វិនិស្សតោ សន្តោ សុខំ សាតំ ន វិន្ទតិ
ទុក្ខិតោ វិមនោ ហោតិ បជ្ឈាយន្តោ បវេធតិ ។
តថេវ ជដិលា តំបិ នីហរិស្សន្តិ ទុម្មតិ
តេហិ ត្វំ និស្សតោ សន្តោ សុខំ សាតំ ន លច្ឆសិ ។
ទិវា វា យទិ វា រត្តឹ សោកសល្លសមប្បិតោ
ឌយ្ហសិ បរិឡាហេន គជោ យូថាវ និស្សតោ ។



### សុភាសិតឆ្លោងពាន ទី ១

អ្នកប្រាជ្ញតាំងខ្លួន នឹងតិះដៀលអ្នកជា ជាមនុស្សប្រព្រឹត្ត កន្លងសាសនា អ្នកកាលមិនបានទៅរៀនជាមួយ (នឹងប្រាជ្ញតាំងខ្លួន) តើដឹងរស់នៅដូចម្ដេច ។ ដីរីមានកម្លាំងខ្លួន ទៅជិតដីរីប្រសើរ មានអាយុ ៦០ ទើបថយកម្លាំង ចុះប្រែង ដោយចំណែក ៣ ហើយបណ្ដេញដីរី (ខ្ញុំ) ពាកហ្វូន ។ ដីរីខ្ញុំ កាលក្រោយដីរីមានកម្លាំង បណ្ដេញចេញពាកហ្វូនហើយ រមែងស្ងប់ស្ងៀម មិនបានសុខស្រួលទេ ជាសត្វដល់នូវសេចក្ដីទុក្ខ ទូលចិត្ត សព្វប់សញ្ញាំងញាប់ញ័រ យ៉ាងណា ។ ពួកដឹលនឹងបណ្ដេញអ្នកឯង ដែលមានគំនិតអាក្រក់ចេញ អ្នកឯងត្រូវពួកដឹលតាំងនោះ បណ្ដេញចេញហើយ រមែងស្ងប់ស្ងៀម មិនបានសុខស្រួលទេ គឺយ៉ាងនោះឯង ។ អ្នកឯងគំកុងគោកោញ៉ាដោយសេះ គឺសេចក្ដីសោក ទេះកេលកល ព្រោះសេចក្ដីក្ដៅក្រហាយ ចាំងថ្ងៃចាំងយប់ ដូចជាដីរីចុះប្រែង ដែលត្រូវដីរីមានកម្លាំងបណ្ដេញពាកហ្វូន ។

ជាតរូបំ យថា កូដំ    នេវ ឈាយតិ កត្ថចិ
ឯវំ សីលវិហីនោ ត្វំ    ន ឈាយិស្សសិ កត្ថចិ ។
អគារកំ សមាចេបំ    កិច្ឆំ ជីវិហិសី តុវំ
មត្តិកំ បេត្តិកញ្ចាបិ    នត្ថិ តេ និហិតំ ធនំ ។
សកំ កម្មំ ករិត្វាន    កត្តេ សេធំ ចនោទយំ
ឯវំ ជីវិហិសី គេហេ    សាធុ តេ តំ ភវិស្សតិ ។
ឯតាហំ តត្ថ ភរេមិ    សត្ថាលេសកតំ មនំ
នានាជម្មកជំ កត្វា    ហាលា ចត្តំ ឆភាយី ។
ឯវំ មេ វិហរន្តស្ស    អប្បមាទវិហារិនោ
តិំសវស្សសហស្សានិ    ចរេ(១) មេ អតិក្កមុំ ។
អប្បមាទេន មំ ទិស្វា(២)    ឧត្តមត្ថំ គវេសកំ
បទុមុត្តរសម្ពុទ្ធោ    អាគញ្ឆិ មម សន្តិកំ ។

---
១ ម. វិចរេ ។ ២ ម. អប្បមាទរតំ ទិស្វា ។



ជាតរូបក្លែងក្លាយ តែងមិនភ្លឺក្នុងទីណាមួយ យ៉ាងណា អ្នកឯងជាបុគ្គលសាបសូន្យចាកសីល នឹងតែងមិនភ្លឺ ក្នុងទីណាមួយ យ៉ាងនោះដែរ ។ អ្នកឯងកាលបើនៅគ្រប់គ្រងផ្ទះ នឹងរស់នៅដោយលំបាក ព្រោះទ្រព្យជារបស់នៃមាតាក្តី ជារបស់នៃបិតាក្តី ដែលអ្នកបម្រុងទុក មិនមានទេ ។ អ្នកឯងលុះតែធ្វើការងាររបស់ខ្លួន ហើយញុំាងកក្តីខុសឲ្យហួរចេញ ទើបនឹងរស់នៅក្នុងផ្ទះបាន ហេតុនេះ ខ្ញុំសូមអង្វរ អ្នកកុំគាប់ចិត្តនឹងការងារនោះឡើយ ។ ខ្ញុំយកនូវចិត្ត ដែលសង់នូវសេចក្តីសៅហ្មង ក្នុងទីនោះ យ៉ាងនេះហើយ ខ្ញុំធ្វើនូវមនុស្សជាផ្សែង ។ ហើយឃាត់ចិត្តចាកអំពើអាក្រក់ ។ កាលបើខ្ញុំនៅ ដោយសេចក្តីមិនប្រមាទ យ៉ាងនេះ ៣០ ពាន់ឆ្នាំរបស់ខ្ញុំ កន្លងហើយក្នុងទីនោះ ។ ព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ឃើញខ្ញុំ ជាអ្នកស្វែងរកនូវប្រយោជន៍ដ៏ឧត្តម ដោយសេចក្តីមិនប្រមាទ ហើយស្តេចមកកាន់សំណាក់នៃខ្ញុំ ។

កម្ពុស្សកាវណ្ណកោ អប្បមេយ្យោ អនូបមោ

រូបោភាសតិ សោ ពុទ្ធោ អាកាសេ ចន្ទិមា យថា ។

សុផុល្លោ សាលរាជាវ វិជ្ជុវព្ភឃនុត្តរេ

ញាណោភាសតិ សោ ពុទ្ធោ អាកាសេ ចន្ទិមា យថា ។

សីហរាជាវសម្ភីតោ គជរាជាវ ទប្បិតោ(១)

អភីតោ(២) ព្យគ្ឃរាជាវ អាកាសេ ចន្ទិមា យថា ។

សន្តិចិត្តសុវណ្ណាភោ ទធិវត្តាវ សង្ឃកោ

មណិ បភា ជោតិរសោ អាកាសេ ចន្ទិមា យថា ។

វិសុទ្ធកេលាសសង្កាសោ បុណ្ណមាយេវ ចន្ទិមា

មជ្ឈន្តិកេវ សុរិយោ អាកាសេ ចន្ទិមា យថា ។

ទិស្វា ជនក(៣) ចន្ទិមន្តិ បីតិ ចិត្តេសហំ ជនា

ទេវោ នុ ខោ អយំ សត្ថា ឧទាហុ មនុជោ អយំ ។

---

១ ម. ទម្មិតោ ។ ២ ម. ឈាសិតោ ។ ៣ ម. ទិស្វាន កំ ។



កាលនោះ ព្រះពុទ្ធមានពន្លឺដូចជាសម្បុរនៃផ្លែខ្នាច់ និងប្រមាណមិនបាន មិនមានគ្រឿងប្រៀប មិនមានរូបដទៃប្រាកដស្មើដោយព្រះរូប (របស់ព្រះអង្គ) ទ្រង់ចង្ក្រមឰដ៏អាកាស ។ កាលនោះ ព្រះពុទ្ធមិនមានអ្វីប្រាកដស្មើដោយញាណ ទ្រង់ចង្ក្រមឰដ៏អាកាស ដូចជាសាលព្រឹក្ស ដែលមានផ្ការីកល្អ ពុំនោះសោត ដូចផ្លេកបន្ទោរ ក្នុងចន្លោះនៃដុំពពក ។ កាលនោះ ព្រះពុទ្ធទ្រង់ចង្ក្រមឰដ៏អាកាស ដូចជាស្តេចសីហៈមិនមានសេចក្តីព្រឺព្រួច ឬដូចស្តេចដំរី ដែលគេហាត់បានហើយ ពុំនោះសោត ដូចស្តេចខ្លា ដែលមិនមានសេចក្តីភ្ញាក់ ។ គ្រានោះ ព្រះសម្ពុទ្ធមានរស្មីដូចមាសក្តោរ ឈ្មោះសិង្គី ឬដូចរងើកភ្លើងទៀនសន្សើម ពុំនោះសោត ដូចកែវមណី មានរស្មីរុងរឿង ទ្រង់ចង្ក្រមឰដ៏អាកាស ។ គ្រានោះ ព្រះសម្ពុទ្ធដូចភ្នំកៃលាស ដ៏បរិសុទ្ធ ឬដូចព្រះចន្ទ្រនៅពេញបូណ៌មី ពុំនោះសោត ដូចព្រះអាទិត្យកើតទៅក្នុងវេលាកណ្តាល (ថ្ងៃត្រង់) ទ្រង់ចង្ក្រមឰដ៏អាកាស ។ គ្រានោះ ជនឃើញព្រះសម្ពុទ្ធ ដែលកំពុងចង្ក្រមឰដ៏អាកាស ក៏គិតយ៉ាងនេះថា សត្ថានេះ ជាទេវតា ឬថា សត្ថានេះ ជាមនុស្ស ។

ឥមេ សុតោ វេធិន្នោ ក | បហាយក មនិសោ ឥតោ
អម្ពំ មត្ថុបន្តំ អត្ថិ | អយំ សត្ថា ភវិស្សតិ ។
ឯកាហំ ចិន្តយិត្វាន | សកំ ចិត្តំ បសាទយឹ
នានាបុប្ផញ្ច គន្ធញ្ច | សន្និធាបេសហំ តទា ។
បុប្ផាសនំ បញ្ញាបេត្វា | សាធុចិត្តំ មនោរមំ
នរសារថិនំ អគ្គំ | ឥទំ វចនមព្រវឹ ។
ឥធ មេ អាសនំ វីរ | បញ្ញត្តំ តវនុច្ឆវំ[១]
ហាសយន្តោ មម ចិត្តំ | និសីទ កុសុមាសនេ ។
និសីទិ តត្ថ ភគវា | អសម្ភីតោ[២] កេសរី
សត្តរត្តិន្ទិវំ ពុទ្ធោ | បវរេ កុសុមាសនេ ។
នមស្សមានោ អដ្ឋាសឹ | សត្តរត្តិន្ទិវំ អហំ
វុដ្ឋហិត្វា សមាធិម្ហា | សត្ថា លោកេ អនុត្តរោ ។
មម កម្មំ បកិត្តេន្តោ | ឥទំ វចនមព្រវិ
ភាវេហិ ពុទ្ធានុស្សតឹ | ភាវនានំ អនុត្តរំ ។

១ ម. តវានុច្ឆវំ ។ ២ ម. អសម្ភីតោវ ។



នៅបែបនោះហើយផែនដី ខ្ញុំមិនឃើញ មិនឃើញ ចំនង ជាមនុស្សណាតែមួយ សត្វនេះប្រហែលជាសាស្តា ។ ខ្ញុំលុះគិតយ៉ាងនេះហើយ ក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា គ្រានោះខ្ញុំប្រមូលផ្កាផ្សេងៗ និងគ្រឿងក្រអូប ។ ខ្ញុំក្រាលបុប្ផាសនៈដ៏វិចិត្រល្អ ដែលជាទីពេញចិត្ត ហើយពោលពាក្យនេះទៅកាន់ព្រះមានព្រះភាគ ជាសារថី នៃនរជនដ៏ប្រសើរជា បពិត្រព្រះអង្គមានព្យាយាម អាសនៈដែលខ្ញុំព្រះអង្គក្រាលហើយនេះ សមគួរដល់ព្រះអង្គ សូមព្រះអង្គញុំាងចិត្តខ្ញុំព្រះអង្គឲ្យរីករាយ ហើយគង់លើអាសនៈជាវិការៈនៃផ្កា ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈ ជាវិការៈនៃផ្កាដ៏ប្រសើរនោះ អស់ ៧ យប់ ៧ ថ្ងៃ ដូចជាកេសរសីហ៍ ឥតតក់ស្លុតឡើយ ខ្ញុំបានឈរនមស្ការ អស់ ៧ យប់ ៧ ថ្ងៃ ។

ព្រះសាស្តា ព្រះអង្គប្រសើរក្នុងលោក ទ្រង់ចេញចាកសមាធិ កាលនឹងទ្រង់សម្តែង នូវអំពើរបស់ខ្ញុំ ទ្រង់ត្រាស់នូវពាក្យនេះថា អ្នកចូរចំរើននូវពុទ្ធានុស្សតិ ដែលជាគុណជាតិដ៏ប្រសើរ ជាងការចំរើននូវអនុស្សតិទាំងឡាយដទៃ ។

## ហេមំ សុជាតត្ថេរាបទានំ

ឥមំ សតិ ការយិត្វា ឆាយិស្សតិ(១) មាលិសំ
តិំសកប្បសហស្សានិ ទេវលោកេ រមិស្សសិ ។
អសីតិក្ខត្តុំ ទេវិន្ទោ ទេវរជ្ជំ ករិស្សសិ
សហស្សក្ខត្តុំ ចក្កវត្តិ រាជា រដ្ឋេ ករិស្សសិ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
អនុភោស្សសិ តំ សព្វំ បុញ្ញកម្មស្សិទំ ផលំ ។
ភវាភវេ សំសរន្តោ មហាភោគំ លភិស្សសិ
ភោគេហិ ឩនតា នត្ថិ បុញ្ញកម្មស្សិទំ ផលំ ។
កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន សត្ថា លោកេ ភវិស្សតិ ។
អសីតិកោដី ឆឌ្ឌេត្វា ទាសកម្មករេ ពហូ
គោតមស្ស ភគវតោ សាសនេ បព្វជិស្សសិ ។
អារាធយិត្វាន សម្ពុទ្ធំ គោតមំ សក្យបុង្គវំ
សុជាតោ នាម នាមេន ហេស្សសិ សត្ថុសាវកោ ។

---
១ ម. ឆាយិស្សតិ ។



## សុជាតត្ថេរាបទាន ទី ១

ព្រោះអំណាចច្រើន នូវកុសលនោះហើយ ខ្ញុំបានញ៉ាំងចិត្ត ឱ្យពេញ ខ្ញុំរីករាយក្នុងទេវលោក អស់ ៣០ ពាន់កប្ប ។ អញនឹងបានសោយទេវរាជ្យ ជាធំជាងទេវតា អស់ ៨០ ដង ខ្ញុំបានជាស្ដេចចក្រពត្តិ ក្នុងផែនដីមួយពាន់ដង ។ ខ្ញុំបានជាស្ដេចក្នុងប្រទេសដ៏ធំទូលាយ ដោយនូវសម្បត្តិទាំង អស់នោះ រាប់បានមួយអសង្ខេយ្យកប្ប នេះជាផលនៃបុញ្ញ- កម្ម ។ អញកាលបើអន្ទោលទៅ ក្នុងភពតូចភពធំ ខ្ញុំបាននូវភោគៈដ៏ច្រើន ការខ្វះខាតដោយភោគៈទាំង- ឡាយរបស់អញ មិនមានឡើយ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទីមួយសែនកប្ប ព្រះសាស្ដា ព្រះនាមគោតម កើតក្នុងត្រកូលឱក្កាកៈ ទ្រង់ជាធំដ៏ខ្ពង់ខ្ពស់ក្នុងលោក ។ អញ ខ្ញុំលះបង់ ទ្រព្យ ៨០ កោដិ ទាំងពួកទាសកម្មករ ច្រើន ហើយបួសក្នុងសាសនា របស់ព្រះមានព្រះភាគ ព្រះនាមគោតមនោះ ។ អញមានឈ្មោះជាសុជាត ខ្ញុំញ៉ាំង ព្រះសម្ពុទ្ធ ព្រះនាមគោតម ទ្រង់ប្រសើរជាងពួកសក្យៈឱ្យ ត្រេកអរ ហើយខ្ញុំបានជាសាវ័កនៃព្រះសាស្ដា ។

ភិក្ខុសង្ឃេ និសីទិត្វា ទក្ខិណេយ្យគុណម្ហិ តំ
តថារណវិហារេ ច ទ្វីសុ អគ្គេ(១) បវេសយិ ។
ឥតិ វត្វាន សម្ពុទ្ធោ ជលជុត្តមនាយកោ(២)
នភំ អព្ភុគ្គមិ វីរោ ហំសរាជាវ អម្ពរេ ។
សាសិតោ លោកនាថេន នមស្សិត្វា តថាគតំ
សទា ភាវេសិំ(៣) មុទិតោ ពុទ្ធានុស្សតិមុត្តមំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតិំសំ អគញ្ឆហំ ។
អសីតិក្ខត្តុំ ទេវិន្ទោ ទេវរជ្ជំ អការយិំ
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ អហោសហំ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ

១ ម. អគ្គេ ។ ២ ម. ជលជុត្តមនាមកោ ។ ៣ ម. ភាវេមិ ។



ព្រះតថាគតសម្ពុទ្ធ ទ្រង់គង់ក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយ ទ្រង់តាំងអ្នក ជាភិក្ខុប្រសើរ ក្នុងឋានៈជាទីពីរ គឺក្នុងពួក នៃទក្ខិណេយ្យបុគ្គល ១ ក្នុងការនៅមិនមានកិលេស (ដោយ ធម្មទេសនា) ១ ។

ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ជានាយក ព្រះនាមបទុមុត្តរៈ លុះត្រាស់នូវពាក្យនេះហើយ ទ្រង់ហោះឡើងកាន់អាកាស ដូចស្តេចហង្ស ហើយនៅឰដ៏អាកាស ។ ខ្ញុំដែលព្រះលោក- នាថ ទ្រង់ប្រៀនប្រដៅហើយ ក៏មានចិត្តរីករាយនមស្ការព្រះ តថាគត ហើយចម្រើននូវពុទ្ធានុស្សតិដ៏ឧត្តម សព្វ ៗ កាល ។ ខ្ញុំលះបង់នូវកាយ ជារបស់មនុស្សហើយ បានទៅកើតក្នុង តាវត្តិង្សទេវលោក ដោយសារកុសលកម្ម ដែលខ្ញុំធ្វើល្អ ហើយនោះផង ដោយការតាំងចិត្តទុកនោះផង ។ ខ្ញុំបាន សោយទេវរជ្ជសម្បត្តិក្នុងទេវលោក អស់ ៨០ ដង បានជាស្តេច ចក្រពត្តិ អស់មួយពាន់ដង ។ ខ្ញុំសោយរាជ្យក្នុងប្រទេស ដ៏ធំទូលាយ ជាសម្បត្តិដ៏ច្រើន រាប់បានមួយអសង្ខេយ្យជាតិ

អនុភោមិ សុសម្បត្តឹ ពុទ្ធានុស្សតិយា ផលំ ។
ភវាភវេ សំសរន្តោ មហាភោគំ លភាមហំ
ភោគេ មេ ឩនតា នត្ថិ ពុទ្ធានុស្សតិយា ផលំ ។
សតសហស្សិតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធានុស្សតិយា ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សុភូតិ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុភូតិត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ ឧបវាណត្ថេរាបទានំ

[៦៦] បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
ជលិត្វា អគ្គិក្ខន្ធោវ សម្ពុទ្ធោ បរិនិព្វុតោ ។





នេះជាផលនៃពុទ្ធានុស្សតិ ។ ខ្ញុំកាលអន្ទោលទៅ ក្នុងភពតូចនិងភពធំ តែងបានភោគៈដ៏ច្រើន ការខ្វះខាតដោយភោគៈរបស់ខ្ញុំ មិនមានឡើយ នេះជាផលនៃពុទ្ធានុស្សតិ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធានុស្សតិ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុភូតិត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុភូតិត្ថេរាបទាន ។

## ឧបវាណត្ថេរាបទាន ទី ២

[៦៦] ព្រះជិនស្រីសព្វញ្ញូ ព្រះនាមបទុមុត្តរៈ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។

មហាជនា សមាគម្ម    បូជយិត្វា តថាគតំ
ចិតំ កត្វាន សុកតំ    សរីរំ អភិរោបយុំ ។
សរីរកិច្ចំ កត្វាន    ធាតុំ តត្ថ សមានយុំ
សទេវមនុស្សា សព្វេ    ពុទ្ធថូបំ អកំសុ តេ ។
បឋមា កញ្ចនមយា    ទុតិយា ច(១) មណីមយា
តតិយា រូបិយមយា    ចតុត្ថា ផលិកាមយា ។
តត្ថ បញ្ចមិយា ភូមិ    លោហិតង្គមយា អហុ
ឆដ្ឋា មសារគល្លស្ស    សព្វរតនមយូបរិ ។
ជង្ឃា មណិមយា អាសិ    វេទិកា រតនាមយា
សព្វសោវណ្ណមយោ ថូបោ    ឧទ្ធំ យោជនមុគ្គតោ ។
ទេវា តត្ថ សមាគន្ត្វា    ឯកតោ មន្តយុំ តទា
មយម្បិ ថូបំ ករិស្សាម(២)    លោកនាថស្ស តាទិនោ ។
ធាតុ អាវេណិកា នត្ថិ    សរីរំ ឯកបិណ្ឌិតំ
ឥមម្ហិ ពុទ្ធថូបម្ហិ    ករិស្សាម កញ្ចុកំ មយំ ។

---

១. ម. ទុតិយាសិ ។ ២. ម. កស្សាម ។



មហាជនមកជួបជុំគ្នា បូជាព្រះតថាគត ធ្វើជើងថ្ករដ៏ល្អ ហើយលើកតំកល់ព្រះសរីរៈ ។ ពួកមហាជនទាំងនោះ ព្រមទាំងទេវតានិងមនុស្ស លុះធ្វើព្រះសរីរកិច្ចរួចហើយ ប្រមូលព្រះធាតុត្រង់កន្លែងជើងថ្ករនោះ មកធ្វើព្រះពុទ្ធស្តូប ។ ជាន់ទី ១ ធ្វើដោយមាស ជាន់ទី ២ ធ្វើដោយកែវមណី ជាន់ទី ៣ ធ្វើដោយប្រាក់ ជាន់ទី ៤ ធ្វើដោយកែវផលិក ។ ជាន់ទី ៥ នៃព្រះស្តូបនោះ ធ្វើដោយកែវទទឹម ជាន់ទី ៦ ធ្វើដោយកែវមរកត ខាងលើធ្វើដោយរតនៈគ្រប់យ៉ាង ។ ប្រឡាយខ្នាប់ (នៃព្រះស្តូប) ធ្វើដោយកែវមណី បង្កាន់ដៃធ្វើដោយកែវ ព្រះស្តូប ធ្វើដោយមាសសុទ្ធទាំងអស់ គិតកំពស់ឡើងទៅលើមួយយោជន៍ ។ កាលនោះ ទេវតាមកជួបជុំគ្នា ត្រង់កន្លែងនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកយើងនឹងធ្វើព្រះស្តូប ថ្វាយព្រះលោកនាថ ជាតាទិបុគ្គល ។ ព្រះធាតុឥតមានចែកចេញពីគ្នា ព្រះសរីរធាតុនៅជាដុំមួយ (បើដូច្នោះ) ពួកយើង នឹងធ្វើព្រះស្តូប គ្រោបលើព្រះពុទ្ធស្តូបនេះ ។

ទេវា សត្តរតនេហិ　　អញ្ញំ វឌ្ឍេសុ យោជនំ
ថូបោ ទ្វិយោជនុព្វេធោ　　តិមិរំ ព្យបហន្តិ សោ ។
នាគា តត្ថ សមាគន្ត្វា　　ឯកតោ មន្តយុំ តទា
មនុស្សា ទេវទេវា ច　　ពុទ្ធថូបំ អកំសុ តេ ។
មា នោ បមត្តា អស្សុម្ហា　　អប្បមត្តា សទេវកា
មយម្បិ ថូបំ ការេស្សាម　　លោកនាថស្ស តាទិនោ ។
ឥន្ទនីលំ មហានីលំ　　អថោ ជោតិរសំ មណិំ
ឯកតោ សន្និបាតេត្វា　　ពុទ្ធថូបំ អការយុំ ។
សព្វំ មណិមយំ អាសិ　　តាវទេ ពុទ្ធចេតិយំ
តិយោជនសមុព្វិទ្ធំ　　អាលោកករណំ តទា ។
កុម្ភណ្ឌា ច សមាគន្ត្វា　　ឯកតោ មន្តយុំ តទា
មនុស្សា ទេវតា ច　　ពុទ្ធថូបំ អកំសុ តេ ។
មា នោ បមត្តា អស្សុម្ហា　　អប្បមត្តា សទេវកា
មយម្បិ ថូបំ ការេស្សាម　　លោកនាថស្ស តាទិនោ ។





ពួកទេវតាបានបន្ថែមកំពស់មួយយោជន៍ទៀត ដោយកែវទាំង ៧ ប្រការ ព្រះស្តូបនោះទៅជាមានកំពស់ ២ យោជន៍ តែងកំចាត់បង់នូវងងឹត សព្វ ៗ កាល ។ គ្រានោះ ពួកនាគមកជួបជុំគ្នា ត្រង់កន្លែងព្រះស្តូបនោះ ហើយប្រឹក្សាគ្នាមួយគ្នាថា ពួកមនុស្សនិងទេវតា បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ។ ពួកយើងកុំប្រហែសឡើយ ព្រោះមនុស្សនិងទេវ-តា មិនប្រហែស ដើម្បីនោះ ពួកយើងនឹងធ្វើព្រះស្តូប ថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។ ពួកនាគទាំងនោះប្រមូលកែវឥន្ទនីល កែវមហានីល ទាំងកែវមណី មានរស្មីរុងរឿង គង់ជាមួយគ្នា ហើយស្រោបព្រះពុទ្ធស្តូប ។ ព្រះពុទ្ធចេតិយទាំងមូល ប្រដាប់ដោយកែវមណី មានកំពស់ ៣ យោជន៍ តែងផ្សាយបញ្ចេញនូវពន្លឺ ក្នុងកាលនោះ ។ កាលនោះ ពួកគ្រុឌមកជួបជុំគ្នា ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្ស ទេវតានិងនាគទាំងឡាយ បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ។ ពួកយើងកុំប្រហែសឡើយ ព្រោះមនុស្សនិងទេវតាទាំងឡាយ មិនប្រហែស ដើម្បីនោះ ពួកយើងនឹងធ្វើព្រះស្តូប ថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។

សត្ថុ មណិមយំ ថូបំ　អការិំ តារ(១) កញ្ចុកំ
យោជនំ ឧច្ចំ វិត្ថស្សុំ　អាយតំ ពុទ្ធចេតិយំ ។
ចតុយោជនមុព្វេធោ　ពុទ្ធថូបោ វិរោចតិ
ឱភាសេតិ ទិសា សព្វា　សតរំសីវ ឧគ្គតោ ។
កុម្ភណ្ឌា ច សមាគន្ត្វា　ឯកតោ មន្តយុំ តទា
មនុស្សា ទេវា នាគា ច　ជាតា ច កិន្នរា តទា ។
បច្ចេកំ ពុទ្ធសេដ្ឋស្ស　អកំសុ ថូបមុត្តមំ
មា នោ បមត្តា អស្សុម្ហា　អប្បមត្តា សទេវកា ។
មយម្បិ ថូបំ កាស្សាម　លោកនាថស្ស តាទិនោ
វិសុំ ចេហំ ឆាទយិស្សាម　អាយតំ ពុទ្ធចេតិយំ
យោជនុច្ចំ វិត្ថស្សុំ　អាយតំ ពុទ្ធចេតិយំ
បញ្ចយោជនមុព្វេធោ　ថូបោ ឱភាសតី តទា ។

១ ម. តេន ។



ក្រុមទាំងនោះបាននាំធ្វើព្រះស្តូប ប្រដាប់ដោយកែវមណីសុទ្ធឲ្យជាគ្រឿងស្រោប មានទំហំប៉ុនគ្នា ពួកក្រុមទាំងនោះ បានធ្វើពុទ្ធចេតិយ ឲ្យមានកំពស់កើនមួយយោជន៍ទៀត ។ ព្រះពុទ្ធស្តូប នៅជាមានកំពស់ ៤ យោជន៍ រុងរឿងញ៉ាំងទិសទាំងអស់ឲ្យភ្លឺ ដូចព្រះអាទិត្យដែលរះឡើង ។ កាលនោះ ពួកកុម្ភណ្ឌមកជួបជុំគ្នា ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្សទេវតា នាគនិងគ្រុឌទាំងឡាយ បាននាំគ្នាធ្វើព្រះស្តូបដ៏ថ្លៃថ្លា ថ្វាយព្រះពុទ្ធដ៏ប្រសើរ ផ្សេងៗគ្នា ពួកយើងកុំធ្វេសប្រហែសឡើយ ព្រោះមនុស្សនិងទេវតាទាំងឡាយ មិនប្រហែស យើដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូប ថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ពួកយើងនឹងស្រោបពុទ្ធចេតិយ ដោយកែវទាំងឡាយតទៅទៀត ។ ពួកកុម្ភណ្ឌទាំងនោះ បានធ្វើពុទ្ធ-ចេតិយ ឲ្យកើនកំពស់មួយយោជន៍ទៅទៀត ព្រះស្តូបនៅជាមានកំពស់ ៥ យោជន៍ តែងរុងរឿងក្នុងកាលនោះ ។

យក្ខា ចក្ខុ សមាគន្ត្វា ឯកតោ មន្តយុំ តទា
មនុជា ទេវតា នាគា កុម្ភណ្ឌា គរុឡា តទា(១) ។
បច្ចេកំ ពុទ្ធសេដ្ឋស្ស អកំសុ ថូបមុត្តមំ
មា នោ បមត្តា អស្សុម្ហា អប្បមត្តា សទេវកា ។
មយំបិ ថូបំ កាហាម លោកនាថស្ស តាទិនោ
ផលិកា ធានយិស្សាម(២) អាយតំ ពុទ្ធចេតិយំ ។
យោជនុច្ចេបិ វិត្ថរំ អាយតំ ពុទ្ធចេតិយំ
ឆ យោជនានិ ឧព្វេធោ ថូបោ ឱភាសតី តទា ។
ខត្តិយា ច សមាគន្ត្វា ឯកតោ មន្តយុំ តទា
មនុជា ទេវតា នាគា គរុឡា កុម្ភណ្ឌកា ។
សព្វេ ការា ពុទ្ធថូបំ មយមេត្ថ អការកា
មយម្បិ ថូបំ កាហាម លោកនាថស្ស តាទិនោ ។

---

១ ម. មនុស្សា ទេវតា ច គរុឡា កុម្ភណ្ឌកានិ ចិន្តយុំ ។ ២ ម. ផលិកាហិ ការេស្សាម ។





លំដាប់នោះ ពួកយក្សមកជួបជុំគ្នា ប្រឹក្សានូវព្រះស្តូបនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្ស ទេវតា នាគ កុម្ភណ្ឌ និងគ្រុឌទាំងឡាយ បានធ្វើព្រះស្តូបដ៏ឧត្តម ថ្វាយព្រះពុទ្ធដ៏ប្រសើរ ផ្សេងៗ គ្នា ពួកយើងកុំធ្វេសប្រហែសឡើយ ព្រោះមនុស្សនិងទេវតាទាំងឡាយ មិនប្រហែស ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ពួកយើងនឹងស្រោបព្រះចេតិយ ដោយកែវផលិកតទៅទៀត ។ ពួកយក្សទាំងនោះ បានធ្វើព្រះចេតិយឲ្យកើតកំពស់មួយយោជន៍ទៅទៀត ព្រះស្តូបនៅជាធាតុកំពស់៦យោជន៍ ភ្លឺរុងរឿងក្នុងកាលនោះ ។ គ្រានោះ ពួកក្សត្រប្រជុំប្រឹក្សាគ្នាជាមួយនឹងពួកមនុស្ស ទេវតា នាគ គ្រុឌ កុម្ភណ្ឌ និងយក្សទាំងឡាយ ទាំងអស់គ្នាបានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ចំណែកពួកយើងមិនបានធ្វើព្រះស្តូប ក្នុងទីនោះឡើយ ដើម្បីហេតុនោះ ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។

វេទិយោ សត្តរតនា   យោជនំ ជម្ពា អគ្ឃំសុ តេ(១)
សព្វសោវណ្ណមយំ ថូបំ   គន្ធព្វា ការយុំ តទា ។
សត្តយោជនមុព្វេធោ   ថូបោ ឱភាសតេ តទា
រត្តិន្ទិវា ន ញាយន្តិ   អាលោកា ហោន្តិ សព្វទា ។
អភិភោន្តិ ន តស្សាភា   ចន្ទសូរា(២) សតារកា
សមន្តា យោជនសតេ   បទីបោ បន បជ្ជលិ ។
តេន កាលេន យេ កេចិ   ថូបំ បូជេន្តិ មានុសា
ន តេ ថូបំ អារុហន្តិ   អម្ពរេ ឧក្ខិបន្តិ តេ ។
ទេវេហិ ឋបិតោ យក្ខោ   អភិសម្មតនាមកោ
ធជំ វា បុប្ផទាមំ វា   អភិរោបេតិ ឧត្តរិ ។
ន តេ បស្សន្តិ តំ យក្ខំ   ទាមំ បស្សន្តិ គច្ឆតោ
ឯវំ(៣) បស្សិត្វា គច្ឆន្តា   សព្វេ គច្ឆន្តិ សុគ្គតឹ ។
វិរុទ្ធា យេ បាវចនេ   បសន្នា យេ ច សាសនេ
បាដិហីរំ ទដ្ឋុកាមា   ថូបំ បូជេន្តិ មានុសា ។

---

១ ម. ឆត្តមាលោបរិសុ ឥតិ ទិស្សតិ ។ ២ ម. ចន្ទ្រកា ។ ៣ ម. ឯវំ ។



ពួកគន្ធព្វទាំងនោះ បានធ្វើរាជវតិ ៧ ជាន់ ដែលជាទីកែវប្រពៃ ខ្ពស់ឡើងទៅ បានធ្វើព្រះស្តូបសុទ្ធតែជាវិការៈនៃមាសទាំងអស់ ក្នុងកាលនោះ ។ ព្រះស្តូបនោះមានកំពស់ ៧ យោជន៍ ភ្លឺរុងរឿង ក្នុងកាលនោះ គេមិនដឹងថាយប់ថ្ងៃ ព្រោះពន្លឺមានទៅ សព្វ ៗ កាល ។ ព្រះចន្ទព្រះអាទិត្យព្រមទាំងពួកផ្កាយ គ្របសង្កត់ពន្លឺព្រះស្តូបនោះមិនបាន ឯប្រទីបរុងរឿងតែក្នុងទីចម្ងាយ ១០០ យោជន៍ជុំវិញ ។ ក្នុងកាលនោះ មនុស្សទាំងឡាយណាមួយ បូជាព្រះស្តូប មនុស្សទាំងនោះ មិនឡើងកាន់ព្រះស្តូប មនុស្សទាំងនោះ តែងបោះទៅឯអាកាស ។ មានយក្សមួយ ឈ្មោះអភិសម្មតៈ ដែលពួកទេវតាតាំងទុកហើយ តែងទូលទង់ឬកម្រងផ្កា ឲ្យខ្ពស់ឡើង ។ មនុស្សទាំងនោះ មិនឃើញយក្សនោះទេ ឃើញតែកម្រងផ្កាដែលអណ្តែតទៅ លុះឃើញកម្រងផ្កាទាំងនោះ ហើយក៏ដើរទៅ ពួកមនុស្ស ទាំងអស់នោះឯង តែងទៅកាន់សុគតិ ។ ពួកមនុស្ស ទាំងអ្នកទុសក្នុងសាសនា ទាំងអ្នកជ្រះថ្លា ក្នុងសាសនា ដែលចង់ឃើញបាដិហារ តែងបូជាព្រះស្តូប ។

នគរេ ហំសវតិយា    អហោសឹ ភតកោ តទា
អាមោទិតំ ជនំ ទិស្វា    ឯវំ ចិន្តេសហំ តទា ។
ឧឡារោ ភគវា ហេសោ(១)    យស្ស ធាតុឃរេទិសំ
ឥមា ច ជនតា តុដ្ឋា    ការំ កុព្វំ ន តប្បរេ ។
អហំបិ ការំ កស្សាមិ    លោកនាថស្ស តាទិនោ
តស្ស ធម្មេសុ ទាយាទោ    ភវិស្សាមិ អនាគតេ ។
សុធោតំ រជកេនាហំ    ឧត្តរេយ្យបដំ មម
វេឡគ្គេ(២) អាលគ្គេត្វាន    ធជំ ឧក្ខិបិមម្ពរេ ។
អភិសម្មតកោ គយ្ហ    អម្ពរេ ហាសិ មេ ធជំ
វាតេរិតំ ធជំ ទិស្វា    ភិយ្យោ ហាសំ ជនេសហំ ។
តត្ថ ចិត្តំ បសាទេត្វា    សមណំ ឧបសង្កមឹ
តំ ភិក្ខុំ អភិវាទេត្វា    វិបាកំ បុច្ឆហំ ធជេ ។

១ ម. ឧឡារោ ភគវា នេសោ ។ ២ ម. វេឡគ្គេ ។



គ្រានោះ ខ្ញុំកើតជាអ្នកកំសត់នៅក្នុងក្រុងហង្សវតី បានឃើញជនរីករាយហើយ ក៏គិតយ៉ាងនេះក្នុងកាលនោះថា ព្រះស្តូប ដែលបញ្ចុះព្រះសរីរធាតុ ថ្កោលផុតនេះ របស់ព្រះមានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនុ៎ះ មានបុណ្យដ៏លើសលុប ពួកជននេះមានចិត្តត្រេកអរហើយ ធ្វើការបូជាអ្នកធ្វើនូវសក្ការៈ រមែងមិនក្តៅក្រហាយ ។ តាមអញនឹងធ្វើសក្ការៈ ថ្វាយព្រះលោកនាថ ជាតាទិបុគ្គលផង នឹងបានជាព្រះទាយាទក្នុងធម៌ របស់ព្រះលោកនាថអង្គនោះ ក្នុងកាលជាអនាគត ។ ខ្ញុំក៏លើកឡើងនូវសំពត់ របស់ជាងជ្រលក់ដែលហោកគក់ យ៉ាងស្អាត ព្យួរនឹងចុងឫស្សី ហើយលើកឡើងជាទង់ ក្នុងអាកាស ។ អភិសម្មតកយក្ស រែកយកទង់របស់ខ្ញុំ (បិតនៅ) ក្នុងអាកាស ខ្ញុំឃើញទង់ ដែលខ្យល់បក់រំភើបហើយ ក៏ញុំាងសេចក្តីរីករាយ ឲ្យកើតដោយក្រៃលែង ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ចំពោះទង់នោះហើយ ក៏ចូលទៅរកព្រះសមណៈ ថ្វាយបង្គំទូលសួរនូវផលទង់នឹងភិក្ខុនោះ ។

សោ មេ បាបេសិ អាណត្តិ បីតិសញ្ញាណំ មម
តស្ស ទេវស្ស ញាតកំ អនុកោសស្សិំ សព្វទា ។
ហត្ថី អស្សា រថា បត្តី សេនា ច ចតុរង្គិនី
បរិវារេស្សន្តិ មំ និច្ចំ ធជទានស្សិទំ ផលំ ។
សដ្ឋិ តុរិយសហស្សានិ ភេរិយោ សមលង្កតា
បរិវារេស្សន្តិ មំ និច្ចំ ធជទានស្សិទំ ផលំ ។
ឆឡាសីតិសហស្សានិ នារិយោ សមលង្កតា
វិចិត្តវត្ថាភរណា អាមុត្តមណិកុណ្ឌលា ។
អឡារបម្ហា(១) ហសុលា សុសញ្ញា តនុមជ្ឈិមា
បរិវារេស្សន្តិ មំ និច្ចំ ធជទានស្សិទំ ផលំ ។
តិំសកប្បសហស្សានិ ទេវលោកេ រមិស្សសិ
អសីតិក្ខត្តុំ ទេវិន្ទោ ទេវរជ្ជំ ករិស្សសិ ។
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សសិ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។

---

១ ម. អឡារបម្ហា ។



កុសលនោះសម្រេចផ្លូវកិរិយាកើតឡើង នៃសេចក្តីត្រេកអរ និងបីតិរបស់ខ្ញុំ ព្រោះខ្ញុំជា អ្នកនឹងបានទទួលផលរបស់ទង់នោះ សព្វៗកាល ។ សេនាមានអង្គ ៤ គឺ ដំរី សេះ រថ ពលថ្មើរជើង នឹងចោមរោមអ្នកអស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ តូរ្យតន្ត្រី ៦០ ពាន់និងស្គរដែលគេតាក់-តែងយ៉ាងល្អ នឹងចោមរោមអ្នក អស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ ពួកនារី ៨៦ ពាន់ មានខ្លួនតាក់តែងយ៉ាងល្អ មានសំពត់និងគ្រឿងអលង្ការវិចិត្រ ពាក់កែវមណីនិងកុណ្ឌល ។ ពួកនារីទាំងនោះ មានមុខញញឹម មានមុខស្រស់ស្រាយ មានត្របកភ្នែកវែង មានចង្កេះរៀវល្អ នឹងចោមរោមអ្នក អស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ អ្នកនឹងរីករាយ ក្នុងទេវលោក អស់ ៣០ ពាន់កប្ប នឹងបានសោយទេវរាជ្យ ជាធំជាងទេវតា អស់ ៨០ ដង ។ នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង នឹងសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។

កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន សត្ថា លោកេ ភវិស្សតិ ។
ទេវលោកា ចវិត្វាន សុក្កមូលេន ចោទិតោ
បុញ្ញកម្មេន សំយុត្តោ ព្រហ្មពន្ធុ ភវិស្សសិ ។
អសីតិកោដឹ ឆឌ្ឌេត្វា ទាសកម្មករេ ពហូ
គោតមស្ស ភគវតោ សាសនេ បព្វជិស្សសិ ។
អារាធយិត្វា សម្ពុទ្ធំ គោតមំ សក្យបុង្គវំ
ឧបវាណោតិ នាមេន ហេស្សសិ សត្ថុសាវកោ[១] ។
សតសហស្សេ កតំ កម្មំ ផលំ ទស្សេសិ មេ ឥធ
សុមុត្តោ សរវេគោវ កិលេសេ ឈាបយឹ មមំ ។
ចក្កវត្តិស្ស សន្តស្ស ចាតុទ្ទីបិស្សរស្ស មេ
តីណិ យោជនសមន្តា ឧស្សីយន្តិ ធជា សទា ។

១ ម. ឧទ្ទណាវកោ ។





កន្លងទៅមួយសែនកប្ប ព្រះសាស្ដាព្រះនាមគោតម ទ្រង់សម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ អ្នកនឹងច្យុតចាកទេវលោកមក ត្រូវកុសលមូលដាស់តឿន ប្រកបដោយបុញ្ញកម្ម នឹងកើតជាព្រាហ្មណ៍ ។ អ្នកនឹងលះបង់ទ្រព្យ ៨០ កោដិ នឹងទាសកម្មករជាច្រើន ហើយបួសក្នុងសាសនា របស់ព្រះមានព្រះភាគព្រះនាមគោតម ។ អ្នកនឹងមានឈ្មោះឧបវាណៈ ញុំាងព្រះសម្ពុទ្ធព្រះនាមគោតម ដ៏ប្រសើរជាងពួកសក្យៈ ឲ្យត្រេកត្រអាល ហើយនឹងបានជាសាវ័ក របស់ព្រះសាស្ដា ។

កុសលកម្មដែលខ្ញុំធ្វើហើយ ក្នុងកប្បមួយសែនកប្ប បានឲ្យផលដល់ខ្ញុំ ក្នុងជាតិនេះ ខ្ញុំផុតស្រឡះហើយ (ចាកអាសវធម៌) ដូចសរនៃព្រួញ (ដែលផុតស្រឡះចាកធ្នូ) ខ្ញុំដុតកំដៅញាំញីនូវកិលេសទាំងឡាយ របស់ខ្ញុំហើយ ។ កាលដែលខ្ញុំកើតជាស្ដេចចក្រពត្តិ ជាឥស្សរៈ ក្នុងទ្វីបទាំង ៤ ទង់ផុសឡើង ក្នុងទី ៣ យោជន៍ជុំវិញ សព្វ ៗ កាល ។

សតសហស្សេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ធជទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា ធជទាយកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ធជទាយកត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ តីណិសរណាគមនិយត្ថេរាបទានំ

២៨) នគរេ ពន្ធុមតិយា មាតុបដ្ឋាយកោ អហំ
អន្ធា មាតាបិតា មយ្ហំ តេ បោសេមិ អហំ តទា ។
រហោគតោ និសីទិត្វា ឯវំ ចិន្តេសហំ តទា
បោសេន្តោ មាតាបិតរោ បព្វជ្ជំ ន លភាមហំ ។
តមន្ធការបិហិតា(១) តិវិធគ្គីហិ ឌយ្ហរេ
ឯតាទិសេ ភវេ ជាតេ នត្ថិ កោចិ វិនាយកោ ។

១ ម. មហន្ធការបិហិតា ។





ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន ធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការថ្វាយទង់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធជទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធជទាយកត្ថេរាបទាន ។

## តីណិសរណាគមនិយត្ថេរាបទាន ទី ៣

(២៨) ខ្ញុំជាអ្នកបម្រើមាតាបិតាក្នុងក្រុងពន្ធុមតី មាតាបិតារបស់ខ្ញុំខ្វាក់ ខ្ញុំចិញ្ចឹមលោកទាំងនោះ ក្នុងកាលនោះ ។ កាលនោះ ខ្ញុំនៅក្នុងទីស្ងាត់អង្គុយគិតយ៉ាងនេះថា កាលអញការចិញ្ចឹមមាតាបិតា ក៏មិនបាននូវបព្វជ្ជា ។ បុគ្គលទាំងឡាយដែលត្រូវងងឹតធំបិទបាំងហើយ រមែងឆេះដោយភ្លើង ៣ យ៉ាង គ្មានអ្នកណាមួយ ជាអ្នកដឹកនាំ ក្នុងភពប្រាកដដូច្នោះទេ ។

### គាថា តីណិសរណាគមនិយត្ថេរាបទានំ

ពុទ្ធោ លោកេ សមុប្បន្នោ  ធិរេត្តិ(១) ជានិ សាសនំ
សត្ថា ឧទ្ទិតុំ អត្ថា  បុញ្ញកាមេន ជន្តុនា ។
ឧក្កដ្ឋ តីណិ សរណា  បរិបុណ្ណានិ គោចយិំ
តេន កម្មេន សុកតេន  បដិមុទានំ ទុក្ខតិំ ។
និសភោ នាម សមណោ  ពុទ្ធស្ស អគ្គសាវកោ
តំ អហំ ឧបគន្ត្វាន  សរណាគមនំ គហិំ ។
វស្សសតសហស្សានិ  អាយុំ វិជ្ជតិ តាវទេ
តាវតា សរណាគមនំ  បរិបុណ្ណំ អគោចយិំ ។
ចរិមេ វត្តមានម្ហិ  សរណំ តំ អនុស្សរិំ
តេន កម្មេន សុកតេន  តាវតឹសំ អគញ្ឆហំ ។
ទេវលោកគតោ សន្តោ  បុញ្ញកម្មសមាហិតោ
យំ យំ ទេសំ ឧបបជ្ជាមិ  អដ្ឋ ហេតូ លភាមហំ ។

១ ម. ទិព្វតិ ។



### តីណិសរណាគមនិយត្ថេរាបទាន ទី ៣

ផ្លូវនេះ ព្រះពុទ្ធត្រាស់ឡើងក្នុងលោកហើយ តែងញុំាងសាសនាឲ្យរុងរឿង សត្វអ្នកប្រាថ្នាបុណ្យ គាប់ចិត្តរឿងបាន ។ ខ្ញុំដល់នូវត្រៃសរណគមន៍ ហើយរក្សាពេញលេញ បានរួចផុតចេញពីទុគ្គតិ ដោយសារអំពើ ដែលខ្ញុំធ្វើដោយប្រពៃនោះ ។ មានសមណៈមួយអង្គ ឈ្មោះនិសភៈ ជាអគ្គសាវ័ក របស់ព្រះពុទ្ធ ខ្ញុំបានចូលទៅរកព្រះនិសភៈនោះ ហើយទទួលនូវសរណគមន៍ ។ កាលសម័យនោះ អាយុ (របស់សត្វ) មានប្រមាណមួយសែនឆ្នាំ ខ្ញុំបានរក្សាសរណគមន៍ឲ្យពេញលេញ អស់កាលប៉ុណ្ណោះដែរ ។ ក្នុងកាលជាទីបំផុតកំពុងប្រព្រឹត្តទៅ ខ្ញុំរលឹកឃើញ ។ នូវសរណគមន៍នោះ ខ្ញុំបានទៅកាន់ឋានតាវត្តិង្ស ដោយសារកុសលកម្ម ដែលខ្ញុំបានធ្វើល្អហើយនោះ ។ ខ្ញុំកាលទៅកើតក្នុងទេវលោក ដែលតម្កល់ខ្លួនដោយបុញ្ញកម្ម ទើបចូលទៅកាន់ប្រទេសណា ៗ រមែងបាន នូវហេតុ ៨ ប្រការ (ក្នុងប្រទេសនោះ ៗ) ។

និសាសុ ឧជ្ជលោ ហោមិ  តិក្ខបញ្ញោ ភវាមហំ
សព្វេ ទេវាតិវត្តិ  អមិតភោគំ លភាមហំ ។
សុវណ្ណវណ្ណោ សព្វត្ថ  បដិភាណោ(១) ភវាមហំ
មិត្តានំ អចលោ ហោមិ  យសោ អព្ភុគ្គតោ មម(២) ។
អសីតិក្ខត្តុំ ទេវិន្ទោ  ទេវរជ្ជមការយឹ
ទិព្វសុខំ អនុភវឹ  អច្ឆរាហិ បុរក្ខតោ ។
បញ្ចសត្តតិក្ខត្តុញ្ច  ចក្កវត្តី អហោសហំ
បទេសរជ្ជំ វិបុលំ  គណនាតោ អសង្ខិយំ ។
បច្ឆិមេ ភវសម្បត្តេ  បុញ្ញកម្មសមាហិតោ
បុរេ សាវត្ថិយំ ជាតោ  មហាសាលេ សុអឌ្ឍកេ ។
នគរា និក្ខមិត្វាន  ទារកេហិ បុរក្ខតោ
សាយំ ចិត្តាសមត្ថិហំ(៣)  សង្ឃារាមំ ឧបាគមឹ ។
តត្ថទ្ទសាសឹ(៤) សមណំ  វិប្បមុត្តំ និរូបធឹ
សោ មេ ធម្មមទេសេសិ  សរណញ្ច អទាសិ មេ ។

១ ម. បដិភានោ ។ ២ ម. អព្ភុគ្គតោ មមំ ។ ៣ ម. ហេសវិត្វាសមត្តំ ។ ៤ ម. តត្ថទ្ទ-សាហំ ។



នឹងទៅកើតជាខ្ញុំ ក៏មិនសម្លាប់ឡើយ ១ ខ្ញុំជាអ្នកមានប្រាជ្ញា មោះមុត ១ គួរនៅកាត់តែអស់ រៀងនិប្រព្រឹត្តទៅ (តាមខ្ញុំ) ១ ខ្ញុំកើតបាននូវភោគៈ រាប់ចំនួនពុំមិនបាន ១ ។ ខ្ញុំមានសម្បុរដូចមាស ក្នុងទីតាំងក្នុង ១ មានបញ្ញាវាងវៃ ១ មិនរេរ្រើកចាកមិត្រភក្តិឡើយ ១ យសរបស់ខ្ញុំខ្ពង់ខ្ពស់ ១ ។ ខ្ញុំបានធ្វើជាធំនៃទេវតា សោយទេវរាជ្យ មានពួកស្រីអប្សរចោមរោម សោយសេចក្តីសុខដ៏ជាទិព្វ អស់ ៨០ ដង ។ បានជាស្តេចចក្រពត្តិ អស់ ៧៥ ដង សោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។ លុះដល់បច្ឆិមភព ខ្ញុំប្រកបដោយបុណ្យកម្ម កើតក្នុងត្រកូលមហាសាល ដ៏ស្តុក-ស្តម្ភ ក្នុងក្រុងសាវត្ថី ។ ខ្ញុំចាប់ផ្តើមដោយល្បែង មានពួកទារកចោមរោម ចេញចាកទីក្រុងហើយ ចូលទៅកាន់អារាមរបស់សង្ឃ ក្នុងវេលាល្ងាច ។ ក្នុងអារាមនោះ ខ្ញុំឃើញសមណៈ លោកផុតស្រឡះចាកកិលេស មិនមានឧបធិ លោកបានសម្តែងធម៌ដល់ខ្ញុំ ទាំងបានឲ្យសរណគមន៍ដល់ខ្ញុំ ។

សោហំ សុត្វាន សរណំ   សរណំ មេ អនុស្សរឹ
ឯកាសនេ និសីទិត្វា   អរហត្តំ អបាបុណឹ ។
ជាតិយា សត្តវស្សេន(១)   អរហត្តំ អបាបុណឹ
ឧបសម្បាទយិ ពុទ្ធោ   គុណមញ្ញាយ ចក្ខុមា ។
អបរិមេយ្យេ ឥតោ កប្បេ   សរណានិ អគច្ឆហំ
តតោ មេ សុកតំ កម្មំ   ផលំ ទស្សេសិ មេ ឥធ ។
សុគោបិតំ មេ សរណំ   មានសំ សុប្បណិហិតំ
អនុភោត្វា យសំ សព្វំ   បត្តោម្ហិ អចលំ បទំ ។
យេសំ សោតាវធានត្ថិ   សុណាថ មម ភាសតោ
អហំ វោ កថយិស្សាមិ   សាមំ ទិដ្ឋំ បទំ មម ។
ពុទ្ធោ លោកេ សមុប្បន្នោ   វត្តតេ ជិនសាសនំ
អមតា វាទិតា ភេរី   សោកសល្លវិនោទនា ។

១ ម. សត្តមេ វស្សេ ។





ខ្ញុំបានស្តាប់សរណគមន៍ បានរលឹកឃើញ នូវសរណគមន៍របស់ខ្ញុំ ខ្ញុំអង្គុយលើអាសនៈមួយ ហើយបានដល់អរហត្ត ។ ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត បានដល់អរហត្ត ព្រះពុទ្ធមានចក្ខុ ជ្រាបនូវគុណ (របស់ខ្ញុំ) ហើយឲ្យឧបសម្បទាជាភិក្ខុដល់ខ្ញុំ ។ ខ្ញុំបានដល់នូវសរណគមន៍ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ឯអំពើដែលខ្ញុំបានធ្វើហើយប៉ុណ្ណោះ បានឲ្យផលដល់ខ្ញុំ ក្នុងលោកនេះ ។ សរណៈគមន៍ ខ្ញុំបានរក្សាល្អហើយ ចិត្តខ្ញុំបានតាំងទុកល្អហើយដែរ ខ្ញុំបានទទួលនូវយសទាំងពួង ហើយដល់នូវព្រះនិព្វាន ជាធម្មជាតមិនមានការញាប់ញ័រ ។ អ្នកទាំងឡាយណា មានការប្រុងប្រៀបស្តាប់ អ្នកទាំងឡាយនោះ ចូរស្តាប់ខ្ញុំពោលចុះ ខ្ញុំនឹងសម្តែងប្រាប់អ្នកទាំងឡាយ នូវអត្ថ ដែលខ្ញុំឃើញដោយខ្លួនឯង ។ ព្រះសម្ពុទ្ធត្រាស់ដឹងហើយ ក្នុងលោក សាសនាព្រះជិនស្រីកំពុងប្រព្រឹត្តទៅ ស្គរ គឺអមតធម៌ ជាគ្រឿងបន្ទោបង់ នូវសរគឺសោក ព្រះអង្គវាយហើយ ។

យថាសរោច ជាមេធ បុញ្ញក្ខេត្ត អនុត្តរេ
អជ្ឈការី ការេយ្យាថ បស្សយំសេយ្យថ និព្វុតិំ ។
បត្ថយា គីណំ សរណំ បញ្ចសីលានិ គោបយ
ពុទ្ធេ ចិត្តំ បសាទេត្វា ទុក្ខស្សន្តំ ករិស្សថ ។
យថាមមំ ការិត្វាន(១) សីលានិ បរិគោបយ
អចិរំ អរហត្តំ ភោ សព្វេ ភាគិណោស្សថ ។
តេវិជ្ជា ឥទ្ធិបត្តម្ហិ ចេតោបរិយកោវិទោ
សាវកោ តេ មហាវីរ ចរណេ វន្ទាមិ(២) សត្ថុនោ ។
អបរិមេយ្យេ ឥតោ កប្បេ សរណំ ពុទ្ធមគញ្ឆហំ(៣)
ទុគ្គតិំ នាភិជានាមិ សរណាគមនេ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡាភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. សម្មាធម្មំ ការិត្វាន ។ ២ ម. សរណេ វន្ទិ ។ ៣ ម. ពុទ្ធស្ស គច្ឆហំ ។



អ្នកទាំងឡាយគប្បីធ្វើនូវការគោរព ក្នុងបុញ្ញក្ខេត្តដ៏ប្រសើរ ក្នុងការមកកាន់ទីរបស់ខ្ញុំនុ៎ះ អ្នកទាំងឡាយនឹងឃើញ នូវការរំលត់ទុក្ខ ។ អ្នកទាំងឡាយចូរទទួលនូវត្រៃសរណគមន៍ រក្សាសីល ៥ ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ នឹងធ្វើទីបំផុតទុក្ខបាន ។ អ្នកទាំងឡាយ ចូរធ្វើនូវខ្ញុំឲ្យជាគ្រឿងប្រៀបធៀប ហើយរក្សាសីលទាំងឡាយ មិនយូរប៉ុន្មាន អ្នកទាំងឡាយគ្រប់គ្នានឹងបានដល់នូវព្រះអរហត្ត ។ ខ្ញុំជាអ្នកមានវិជ្ជា ៣ ជាអ្នកដល់នូវឫទ្ធិ ឈ្លាសវៃក្នុងការកំណត់ដឹងនូវចិត្ត បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំជាសាវ័ករបស់ព្រះអង្គ សូមថ្វាយបង្គំចំពោះព្រះបាទព្រះសាស្តា ។ ខ្ញុំព្រះអង្គបានដល់នូវព្រះពុទ្ធជាទីពឹង ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ (នេះ) ជាផលនៃការដល់នូវត្រៃសរណគមន៍ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា តិណសូលកច្ឆទនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណសូលកច្ឆទនិយត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ បញ្ចសីលសមាទានិយត្ថេរាបទានំ

[៦៦] នគរេ ចន្ទវតិយា ភតកោ(១) អាសហំ តទា
បរកម្មាយនេ យុត្តោ បព្វជ្ជំ ន លភាមហំ ។
មហន្ធការបិហិតា តិវិធគ្គីហិ ឌយ្ហរេ
កេន នុ ខោ ឧបាយេន វិសំយុត្តោ ភវេ អហំ ។
ទេយ្យធម្មោ ច មេ នត្ថិ វរាកោ ភតកោ អហំ(២)
យន្នូនាហំ បញ្ចសីលំ រក្ខេយ្យំ បរិបូរយំ ។
អនោមទស្សិស្ស មុនិនោ និសភោ នាម សាវកោ
តមហំ ឧបសង្កម្ម បញ្ចសិក្ខាបទគ្គហឹ ។

---
១ ម. ភតកោ ។ ២ ម. ភតកោ ទុក្ខិតោ អហន្តិ ទិស្សន្តិ ។





បានឮថា ព្រះតិណសូលកច្ឆទនិយត្ថេរ មានអាយុ បាន សម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណសូលកច្ឆទនិយត្ថេរាបទាន ។

## បញ្ចសីលសមាទានិយត្ថេរាបទាន ទី ៤

[៦៦] គ្រានោះ ខ្ញុំកើតជាបុរសអ្នកស៊ីឈ្នួល ក្នុងក្រុងចន្ទវតី ខ្ញុំរវល់តែនឹងការងាររបស់អ្នកដទៃ មិនបាននូវបព្វជ្ជា ។ ខ្ញុំគិតថា បុគ្គលទាំងឡាយ ដែលត្រូវងងឹតគ្របសង្កត់ហើយ រមែងឆេះដោយភ្លើង ៣ យ៉ាង អាត្មាអញគប្បីរួចចេញដោយឧបាយណាហ្ន៎ ។ អាត្មាអញជាមនុស្សកំព្រា ធ្វើការឈ្នួល ទាំងទេយ្យធម៌ របស់អាត្មាអញក៏មិនមាន បើដូច្នោះគួរតែអាត្មាអញរក្សាសីល ៥ ឲ្យពេញលេញ ។ មានព្រះថេរៈមួយអង្គឈ្មោះនិសភៈ ជាសាវ័ករបស់ព្រះមុនីព្រះនាមអនោមទស្សី ខ្ញុំក៏ចូលទៅរកព្រះថេរៈអង្គនោះ ហើយទទួលនូវសិក្ខាបទទាំង ៥ ។

វស្សសតសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា បញ្ចសីលានិ បរិបុណ្ណានិ គោបយឹ ។
មច្ចុកាលេ(១) ច សម្បត្តេ ទេវ អស្សាសយន្តិ មំ
រថោ សហស្សយុត្តោ តេ មារិសាយំ ឧបដ្ឋិតោ ។
វត្តតេ(២) ចរិម ចិត្តេ មម សីលំ អនុស្សរឹ
តេន កម្មេន សុកតេន តាវតឹសំ អគញ្ឆហំ ។
តឹសក្ខត្តុញ្ច ទេវិន្ទោ ទេវរជ្ជមការយឹ
ទិព្វសុខំ អនុភវឹ អច្ឆរាហិ បុរក្ខតា ។
បញ្ចសត្តតិក្ខត្តុញ្ច ចក្កវត្តី អហោសហំ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។
ទេវលោកា ចវិត្វាន សកកម្មាភិនន្ទិតា
បុរេ វេសាលិយំ ជាតា មហាសាលេ(៣) សុអឌ្ឍកេ ។
វស្សូបនាយិកេ កាលេ ទិប្បន្តេ ជិនសាសនេ
មាតា ច មេ បិតា ចេវ បញ្ចសិក្ខាបទញ្ចហុំ ។

១ ម. មច្ចុកាលម្ហិ ។ ២ ម. វត្តន្តេ ។ ៣ ម. មហាកុលេ ។



ក្នុងសម័យនោះ អាយុ (របស់សត្វ) មានប្រមាណមួយសែនឆ្នាំ ខ្ញុំរក្សាសីល ៥ ឲ្យបរិបូណ៌ អស់កាលប៉ុណ្ណោះដែរ ។ លុះមរណកាលមកដល់ព្រមហើយ ទេវតាទាំងឡាយលួងលោមខ្ញុំថា នែអ្នកនិទ្ទុក្ខ រថដែលទឹមដោយសេះមួយពាន់នេះ មកប្រាកដដល់អ្នកហើយ ។ កាលបើចិត្តជាគំរប់ក្រោយ កំពុងប្រព្រឹត្តទៅ ខ្ញុំបានរលឹកនូវសីលរបស់ខ្ញុំ ខ្ញុំបានទៅកាន់ឋានតាវត្តិង្ស ដោយសារអំពើដែលខ្ញុំធ្វើល្អហើយនោះ ។ ខ្ញុំបានជាធំជាងទេវតា ដោយទេវរាជ្យ មានពួកស្រីអប្សរហែហម ដោយសេចក្តីសុខដ៏ជាទិព្វ អស់៣០ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិ អស់ ៧៥ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។ ខ្ញុំច្យុតចាកទេវលោក ត្រេកអរដោយបុណ្យរបស់ខ្លួន ក៏មកកើតក្នុងត្រកូលមហាសាលដ៏ស្តុកស្តម្ភ ក្នុងក្រុងវេសាលី ។ កាលសាសនា របស់ព្រះជិនស្រីកំពុងរុងរឿង មាតានិងបិតា របស់ខ្ញុំ បានទទួលនូវសិក្ខាបទទាំង៥ ក្នុងកាលចូលវស្សា ។

### ចតុត្ថំ បញ្ចសីលសមាទានិយត្ថេរាបទានំ

អបរិមេយ្យេសុ សីលេសុ   វត្តន្តា ជិនសាសនេ
កប្បេសុ យទិ វត្តេយ្យុំ   វិហារោ សីទិសោ ករេ ។
សហ សុត្វានហំ សីលំ   មម សីលំ អនុស្សរឹ
បកាសនេ និសីទិត្វា   អរហត្តំ អបាបុណឹ ។
ជាតិយា បញ្ចវស្សេន   អរហត្តំ អបាបុណឹ
ឧបសម្បាទយី ពុទ្ធោ   គុណមញ្ញាយ ចក្ខុមា ។
បរិបុណ្ណានិ គោបេត្វា   បញ្ចសិក្ខាបទានហំ
អបរិមេយ្យេ ឥតោ កប្បេ   វិនិបាតំ ន គច្ឆហំ ។
សោហំ យសំ អនុភវឹ   តេសំ សីលាន វាហសា
កប្បកោដឹ បកិត្តេន្តោ   កិត្តយេ ឯកទេសតោ ។
បញ្ចសីលានិ គោបេត្វា   តយោ ហេតូ លភាមហំ
ទីឃាយុកោ មហាភោគោ   តិក្ខបញ្ញោ ភវាមហំ ។
បកិត្តេន្តោ[១] ច សព្វេសំ   អធិមត្តញ្ច បោរិសំ
ភវាភវេ សំសរិត្វា   ឯតេ ឋានេ លភាមហំ ។

---

១ ម. សំកិត្តេន្តោ ។



### បញ្ចសីលសមាទានិយត្ថេរាបទាន ទី ៤

ខ្ញុំបានទទួលសីលជាមួយ (នឹងតាត) ហើយបានរលឹកឃើញនូវសីលរបស់ខ្ញុំ ខ្ញុំអង្គុយលើអាសនៈមួយ ហើយបានដល់នូវអរហត្ត ។ ខ្ញុំមានអាយុ ៥ ឆ្នាំអំពីកំណើត បានដល់នូវអរហត្ត ព្រះពុទ្ធមានចក្ខុ ទ្រង់ជ្រាបនូវគុណ (របស់ខ្ញុំ) ហើយទ្រង់ឲ្យឧបសម្បទាដល់ខ្ញុំ ។ ខ្ញុំរក្សានូវសិក្ខាបទទាំង ៥ ពេញលេញ ខ្ញុំមិនដែលទៅកាន់កំណើត អសុរកាយ អស់កប្ប នឹងប្រមាណមិនបាន អំពីកប្បនេះ ។ ខ្ញុំនោះបានទទួលនូវយស ព្រោះហេតុនៃសីលទាំងនោះ ខ្ញុំកាលសម្តែងនូវកោដិនៃកប្ប គប្បីសម្តែងជាឯកទេស (មួយចំណែក) ។ ខ្ញុំរក្សាសីលទាំង ៥ ហើយបាននូវហេតុ ៣ គឺខ្ញុំជាអ្នកមានអាយុវែង ១ មានទ្រព្យច្រើន ១ មានប្រាជ្ញាមោះមុត ១ ។ មួយទៀត ខ្ញុំសម្តែងនូវភាពនៃខ្លួនជាបុរសដ៏ក្រៃលែង ជាងជនទាំងពួង អន្ទោលទៅកាន់ភពតូចនិងភពធំ ហើយតែងបាននូវឋានៈទាំងនុ៎ះ ។ សីលទាំងឡាយ របស់ព្រះជិនស្រី កាលប្រព្រឹត្តក្នុងសីល នឹងប្រមាណមិនបាន បើលោកនៅក្រែកអាក្តិកល តើនឹងបានផលដូចម្តេចទៅ ។

សុចិណ្ណំ មេ បញ្ចសីលំ   ភតកេន តបស្សិនា

តេន សីលេនហំ អជ្ជ   មោចយឹ សព្វពន្ធនា ។

អបរិមេយ្យេ ឥតោ កប្បេ   បញ្ចសីលានិ គោបយឹ

ទុគ្គតឹ នាភិជានាមិ   បញ្ចសីលានិទំ ផលំ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បញ្ចសីលសមាទានិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បញ្ចសីលសមាទានិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ អនុសំសាវកត្ថេរាបទានំ

(៦៧) សុវណ្ណវណ្ណំ សម្ពុទ្ធំ   គច្ឆន្តំ អន្តរាបណេ

កញ្ចនគ្ឃិយសង្កាសំ(១)   ទ្វត្តឹសវរលក្ខណំ ។

---

១ ម. កញ្ចនគ្ឃិយសង្កាសំ ។



សីល ៥ ដែលខ្ញុំជាអ្នកស៊ីឈ្នួលគេ មានព្យាយាម ប្រព្រឹត្តល្អហើយ ខ្ញុំបានរួចចាកចំណងទាំងពួង ក្នុងថ្ងៃនេះ ដោយសារសីលនោះ ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំរក្សាសីល ៥ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសីល៥ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចសីលសមាទានិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បញ្ចសីលសមាទានិយត្ថេរាបទាន ។

## អនុសំសាវកត្ថេរាបទាន ទី ៥

(៦៧) ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថៈ មានព្រះវណ្ណៈដូចមាស មានលក្ខណៈ ៣២ ដ៏ប្រសើរ ប្រាកដស្មើដោយដើមមាស ដែលកំពុងស្តេចទៅក្នុងចន្លោះនៃផ្សារ

បញ្ចមំ អន្នសំសាវកត្ថេរាបទានំ

សិទ្ធត្ថំ លោកបជ្ជោតំ អប្បមេយ្យំ អនោបមំ
អលត្ថំ បរមំ បីតឹ ទិស្វា ទន្តំ ជុតិន្ធរំ ។
សម្ពុទ្ធំ អភិវាទេត្វា ភោជយិត្វា មហាមុនឹ
មុនិ ការុណិកោ លោកេ អនុមោទិ មមំ តទា ។
តស្មឹ មហាការុណិកេ បរមស្សាសការកេ
ពុទ្ធេ ចិត្តំ បសាទេត្វា កប្បំ សគ្គម្ហិ មោទហំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ភិក្ខាទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អន្នសំសាវកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អន្នសំសាវកត្ថេរស្ស អបទានំ សមត្តំ ។



អន្នសំសាវកត្ថេរាបទាន ទី ៥

ព្រះអង្គជាប្រទីបបំភ្លឺសត្វលោក មានគុណដ៏ប្រមាណមិនបាន មិនមានបុគ្គលប្រៀបផ្ទឹម មានឥន្ទ្រិយទូន្មានហើយ ទ្រង់ទ្រទ្រង់នូវរស្មីដ៏រុងរឿង ហើយក៏បាននូវបីតិដ៏ឧត្តម ។ ខ្ញុំបានថ្វាយបង្គំព្រះសម្ពុទ្ធជាមហាមុនី ហើយនិមន្តព្រះអង្គឲ្យឆាន់ គ្រានោះ ព្រះមុនីប្រកបដោយសេចក្តីករុណា ចំពោះសត្វលោក ទ្រង់អនុមោទនាទានរបស់ខ្ញុំ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះសម្ពុទ្ធអង្គនោះ ព្រះអង្គប្រកបដោយមហាករុណា ទ្រង់ជាអ្នកញុំាងនូវសេចក្តីត្រេកអរដ៏ក្រៃលែង ហើយខ្ញុំត្រេកអរក្នុងឋានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយចង្ហាន់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអន្នសំសាវកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អន្នសំសាវកត្ថេរាបទាន ។

# ឆដ្ឋំ ធូបទាយកត្ថេរាបទានំ

(៤៨) សិទ្ធត្ថស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
កុដិធូបំ មយា ទិន្នំ វិប្បសន្នេន ចេតសា ។
យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុសំ
សព្វេសំបិ បិយោ ហោមិ ធូបទានស្សិទំ ផលំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ធូបមទទឹ តទា(១)
ទុគ្គតឹ នាភិជានាមិ ធូបទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា ធូបទាយកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ធូបទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. ធូបមទាសហំ ។



# ធូបទាយកត្ថេរាបទាន ទី ៦

(៤៨) ខ្ញុំមានចិត្តជ្រះថ្លាបានថ្វាយធូប សម្រាប់អប់កុដិ ចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំចាប់កំណើតណា ៗ ទោះជាទេវតាឬជាមនុស្ស ខ្ញុំរមែងជាទីស្រឡាញ់ របស់ជនទាំងពួង នេះជាផលនៃការថ្វាយធូប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយធូប ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយធូប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធូបទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធូបទាយកត្ថេរាបទាន ។

## សត្តមំ បុប្ផបូជកត្ថេរាបទានំ

(៤៨) វិបស្សិស្ស ភគវតោ ពោធិយា បាទបុត្តមេ
បុរាណំ បុប្ផំ ឆឌ្ឌេត្វា សុទ្ធំ បុប្ផានមាកិរឹ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមទាសហំ
ទុគ្គតិំ នាភិជានាមិ បុប្ផទានស្សិទំ ផលំ ។
តិបញ្ញាសេ ឥតោ កប្បេ រាជា អាសិំ ជនាភិភូ
មហាបុប្ផោ នាមេន ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុប្ផបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុប្ផបូជកត្ថេរស្ស អបទានំ សមត្តំ ។



## បុប្ផបូជកត្ថេរាបទាន ទី ៧

(៤៨) ខ្ញុំកើបផ្កាចាស់ចោល ហើយកាយកាយ នូវផ្កាថ្មីៗស្អាត ត្រង់ទៀបនៃពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ ក្នុងកប្បទី ៥៣ អំពីកប្បនេះ ខ្ញុំបានជាស្ដេចចក្រពត្តិ ជាធំជាងជន មានកម្លាំងច្រើន ព្រះនាមមហាបុប្ផៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផបូជកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុប្ផបូជកត្ថេរាបទាន ។

## អដ្ឋមំ ឧត្តិយត្ថេរាបទានំ

[៣០] ចន្ទភាគានទីតីរេ សុំសុមារោ អហំ តទា
សគោចរបសុតាហំ(១) នទីតិត្ថំ អគញ្ឆហំ(២) ។
សិទ្ធត្ថោ តម្ហិ សមយេ សយម្ភូ អគ្គបុគ្គលោ
នទឹ តរិតុកាមោ សោ នទីតិត្ថំ ឧបាគមិ ។
ឧបាគតេ ច សម្ពុទ្ធេ អហំបិ តត្ថុបាគមឹ
ឧបគន្ត្វាន សម្ពុទ្ធំ ឥមំ វាចំ ឧទីរយឹ ។
អភិរុហ មហាវីរ តារេស្សាមិ(៣) អហំ តុវំ
បេត្តិកំ វិសយំ មយ្ហំ អនុកម្ប មហាមុនិ ។
មម ឧគ្គជ្ជំ សុត្វា អភិរុហិ មហាមុនិ
ហដ្ឋោ ហដ្ឋេន ចិត្តេន តារេសឹ លោកនាយកំ ។
នទិយា បារិមេ តីរេ សិទ្ធត្ថោ លោកនាយកោ
អស្សាសេសិ មមំ តត្ថ អមតំ បាបុណិស្សសិ ។

១ ម. សគោចរបសុតោហំ ។ ២ ម. អគច្ឆហំ ។ ៣ ម. តារិស្សាមិ ។



## ឧត្តិយត្ថេរាបទាន ទី ៨

[៣០] គ្រានោះ ខ្ញុំកើតជាក្រពើនៅតាមច្រាំងស្ទឹង ឈ្មោះចន្ទភាគា ខ្ញុំកំពុងខ្វល់ខ្វាយរកចំណីដើម្បីខ្លួន ហើយបានទៅកាន់កំពង់ស្ទឹង ។ សម័យនោះ ព្រះសយម្ភូព្រះនាមសិទ្ធត្ថៈ ជាបុគ្គលប្រសើរ ព្រះអង្គមានប្រាថ្នានឹងឆ្លងស្ទឹង ទ្រង់ស្តេចចូលទៅកាន់កំពង់ នៃស្ទឹងនោះ ។ កាលព្រះសម្ពុទ្ធស្តេចមកដល់ហើយ ខ្ញុំក៏ចូលមកដល់ត្រង់កំពង់នោះដែរ លុះចូលមកដល់ហើយ បានពោលវាចានេះនឹងព្រះសម្ពុទ្ធថា បពិត្រព្រះអង្គមានព្យាយាមធំ សូមព្រះអង្គឡើងកាន់ (ខ្នងរបស់ខ្ញុំ) ចុះ ខ្ញុំនឹងចំឡងព្រះអង្គ បពិត្រព្រះមហាមុនី សូមព្រះអង្គអនុគ្រោះនូវវិស័យជារបស់នៃបិតា ដល់ខ្ញុំផង ។ ព្រះមហាមុនីទ្រង់ព្រះសណ្តាប់ នូវសំរែករបស់ខ្ញុំហើយ ស្តេចឡើងកាន់ (ខ្នងរបស់ខ្ញុំ) ខ្ញុំមានចិត្តរីករាយស្រស់ស្រាយ ចំឡងព្រះលោកនាយក ។ ព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ ញុំាងខ្ញុំឲ្យស្រស់ស្រាយ ឯត្រើយខាងណាយ នៃស្ទឹងនោះថា អ្នកនឹងដល់នូវព្រះនិព្វានឈ្មោះអមតៈ ។

## អដ្ឋមំ ឧត្តិយត្ថេរាបទានំ

តម្ហា កាយា ចវិត្វាន ទេវលោកំ អគច្ឆហំ
ទិព្វំ សុខំ អនុភវឹ អច្ឆរាហិ បុរក្ខតោ ។
សត្តក្ខត្តុញ្ច ទេវិន្ទោ ទេវរជ្ជំ អការសហំ
តីណិក្ខត្តុំ ចក្កវត្តិ មហិយា ឥស្សរោ អហំ ។
វិវេកមនុយុត្តោហំ និបកោ ច សុសំវុតោ
ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។
ចតុន្នវុតេ ឥតោ កប្បេ តារេសឹ យំ ឧកសំ
ទុគ្គតឹ នាភិជានាមិ តរណាយ ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧត្តិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧត្តិយត្ថេរស្ស អបទានំ សមត្តំ ។



## ឧត្តិយត្ថេរាបទាន ទី ៨

ខ្ញុំច្យុតចាកកាយនោះ បានទៅកាន់ទេវលោក មានពួកស្រីអប្សរចោមរោម សោយសេចក្ដីសុខដ៏ជាទិព្វ ។ ខ្ញុំបានជាធំជាងទេវតា សោយទេវរជ្ជ អស់ ៧ ដង ខ្ញុំបានជាស្ដេចចក្រពត្តិ ជាធំលើផែនដី អស់ ៣ ដង ។ ខ្ញុំប្រកបរឿយ ៗ នូវវិវេក ជាអ្នកមានប្រាជ្ញាចាស់ សង្រួមល្អ ទ្រ-ទ្រង់នូវកាយជាទីបំផុត ក្នុងសាសនា របស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានចម្លងព្រះឧកសភៈ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការចម្លង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧត្តិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧត្តិយត្ថេរាបទាន ។

## នវមំ ឯកញ្ជលិកត្ថេរាបទានំ

(៣១) សុវណ្ណវណ្ណំ សម្ពុទ្ធំ គច្ឆន្តំ អន្តរាបណេ
វិបស្សឹ សត្ថវាហគ្គំ នរវីរំ វិនាយកំ ។
អទន្តទមនំ តាទឹ មហាវាទឹ មហាមតឹ
ទិស្វា បសន្នោ សុមនោ ឯកញ្ជលឹ អកាសហំ ។
ឯកនវុតេ ឥតោ កប្បេ យំ អញ្ជលិមករឹ តទា
ទុគ្គតឹ នាភិជានាមិ អញ្ជលិស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឯកញ្ជលិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកញ្ជលិកត្ថេរស្ស អបទានំ សមត្តំ ។



## ឯកញ្ជលិកត្ថេរាបទាន ទី៩

[៣១] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះនាមវិបស្សី មានព្រះវណ្ណៈដូចមាស ទ្រង់នាំនូវពួកដ៏ប្រសើរ ជានរៈដ៏ក្លៀវក្លា ជាអ្នកដឹកនាំនូវសត្វលោក យ៉ាងវិសេស កំពុងស្តេចទៅ ក្នុងចន្លោះផ្សារ ។ ខ្ញុំលុះឃើញព្រះសម្ពុទ្ធ ព្រះអង្គទូន្មាននូវបុគ្គលដែលមិនទាន់ទូន្មាន ជាតាទិបុគ្គល មានពាក្យដ៏ប្រសើរ មានប្រាជ្ញាច្រើន ហើយមានចិត្តជ្រះថ្លា សោមនស្ស បានធ្វើអញ្ជលិកម្មម្តង (ចំពោះព្រះសម្ពុទ្ធនោះ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើអញ្ជលិ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអញ្ជលិ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកញ្ជលិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកញ្ជលិកត្ថេរាបទាន ។

## ទសមំ ខោមទាយកត្ថេរាបទានំ

[៣៦] នគរេ ពន្ធុមតិយា អហោសិំ វាណិជោ តទា

តេនេវ ទារំ បោសេមិ រោបេមិ ពីជសម្បទំ ។

រថិយំ បដិបន្នស្ស វិបស្សិស្ស មហេសិនោ

ឯកំ ខោមំ មយា ទិន្នំ កុសលត្ថាយ សត្ថុនោ ។

ឯកនវុតេ ឥតោ កប្បេ យំ ខោមំ អទទឹ តទា

ទុគ្គតឹ នាភិជានាមិ ខោមទានស្សិទំ ផលំ ។

សត្តបញ្ញាសេ(១) ឥតោ កប្បេ ឯកោ សិន្ធុវសន្ទនោ

សត្តរតនសម្បន្នោ ចាតុទ្ទីបម្ហិ ឥស្សរោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ខោមទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ខោមទាយកត្ថេរស្ស អបទានំ ទសមំ ។

១ ម. សត្តរសេ ។



## ខោមទាយកត្ថេរាបទាន ទី ១០

[៣៦] ក្នុងកាលនោះ ខ្ញុំកើតជាអ្នកជំនួញ នៅក្នុងក្រុងឈ្មោះ ពន្ធុមតី ខ្ញុំចិញ្ចឹមភរិយាដោយរបរជំនួញនោះ ខ្ញុំបណ្ដុះសម្បត្តិពូជ ។ ខ្ញុំបានថ្វាយសំពត់សម្បកឈើ ១ ដើម្បីប្រយោជន៍ដល់កុសល ចំពោះព្រះសាស្ដា ព្រះនាមវិបស្សី ព្រះអង្គស្វែងរកនូវគុណធំ ដែលកំពុងស្ដេចទៅតាមថ្នល់ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់សម្បកឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់សម្បកឈើ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ១ អង្គ ឈ្មោះសិន្ធុវសន្ទនៈ ជាឥស្សរៈក្នុងទ្វីបទាំង ៤ ប្រកបដោយរតនៈទាំង ៧ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះខោមទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ខោមទាយកត្ថេរាបទាន ។

## ឧទ្ទានំ

សុភូតិ ឧបវាណោ(១) ច សរណោ សីលគាហកោ
អន្នសំសាវកោ ធូបោ(២) បុឡិនោ ឧត្តិយេន(៣) ច ។
អញ្ជលី ខោមទាយី ច ទសេវ តតិយេ គណេ
បញ្ចាសីតិសតំ(៤) វុត្តា គាថាយោ សព្វបិណ្ឌិតា ។

សុភូតិវគ្គោ តតិយោ ។

ចតុត្ថំ ភាណវារំ ។

---

១ ម. កត្ថចិ បោត្ថកេ ឧបវានោតិ ទិស្សតិ ។ ២ ម. ធូបំ ។ ៣ ម. ឧត្តិយេន ។
៤ ម. បញ្ចាសីតិសតា ។



## ឧទ្ទាន

រឿងព្រះសុភូតិ ១ ព្រះឧបវាណៈ ១ ព្រះតិសរណគម-និយៈ ១ ព្រះបញ្ចសីលសមាទានិយៈ ១ ព្រះអន្នសំសាវកៈ ១ ព្រះធូបទាយកៈ ១ ព្រះបុឡិនបូជកៈ ១ ព្រះឧត្តិយៈ ១ ព្រះឯកញ្ជលិកៈ ១ ព្រះខោមទាយកៈ ១ ត្រូវជា ១០ រឿង គាថាទាំងឡាយ (ដែលព្រះថេរៈទាំងនោះ) បានពោលហើយ ប្រមូលរួមទាំងអស់ ត្រូវជា ១៨៥ ក្នុងតតិយវគ្គ ។

ចប់ សុភូតិវគ្គ ទី ៣ ។

ចប់ ភាណវារៈ ទី ៤ ។

## បញ្ចមោ កុណ្ឌធានវគ្គោ

### បឋមំ កុណ្ឌធានត្ថេរាបទានំ

[៣៣] សត្តាហំ បដិសល្លីនំ សយម្ភុំ អគ្គបុគ្គលំ
បសន្នចិត្តោ សុមនោ ពុទ្ធសេដ្ឋំ ឧបដ្ឋហឹ ។
វុដ្ឋិតំ កាលមញ្ញាយ បទុមុត្តរំ មហាមុនឹ
មហន្តិំ(១) ផារុសិកណ្ណឹ គហេត្វា ឧបគច្ឆហំ ។
បដិគ្គហេសិ ភគវា សព្វញ្ញូ លោកនាយកោ
មម ចិត្តំ បសាទេន្តោ បរិភុញ្ជិ មហាមុនិ ។
បរិភុញ្ជិត្វាន សម្ពុទ្ធោ សត្ថវាហោ អនុត្តរោ
សកាសនេ និសីទិត្វា ឥមា គាថា អភាសថ ។
យេ ច សន្តិ សមីតារោ យក្ខា ឥមម្ហិ បព្វតេ
អរញ្ញេ ភូតគណា សព្វេ(២) សុណន្តុ វចនំ មម ។

១ ម. មហន្តិំ កទលីកណ្ណឹ ។ ២ ម. អរញ្ញេ ភូតភព្វានិ ។

## កុណ្ឌធានវគ្គទី ៥

### កុណ្ឌធានត្ថេរាបទាន ទី ១

[៣៣] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបម្រើព្រះសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គជាព្រះសយម្ភូ ជាអគ្គបុគ្គល ទ្រង់គេចចេញចាកពួក សម្ងំនៅក្នុងកុដិ អស់ ៧ ថ្ងៃ ។ ខ្ញុំដឹងនូវកាលដែលទ្រង់ចេញអំពីទីសម្ងំ ហើយខ្ញុំកាន់ចេកមួយស្និតធំ នាំចូលទៅថ្វាយព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ។ ព្រះមានព្រះភាគជាសព្វញ្ញូ ជាលោកនាយក ទ្រង់បានទទួល ព្រះមហាមុនី ញុំាងចិត្តរបស់ខ្ញុំឲ្យជ្រះថ្លា ទ្រង់សោយ (ចេកនោះ) ។ លុះព្រះសម្ពុទ្ធ ទ្រង់ជាអ្នកដឹកនាំពួក ជាបុគ្គលប្រសើរផុត ទ្រង់សោយរួចហើយគង់លើអាសនៈ របស់ព្រះអង្គ ហើយត្រាស់នូវគាថាទាំងឡាយនេះថា

ពួកយក្សណា ដែលមកជួបជុំ នៅភ្នំនេះ និងពួកភូតទាំងពួង ដែលនៅអាស្រ័យក្នុងព្រៃនេះ (ពួកយក្ស និងភូតទាំងនោះ) ចូរស្តាប់ពាក្យ របស់តថាគត ។

យោ សោ ពុទ្ធំ ឧបដ្ឋាសិ  មិគរាជំវ កេសរឹ

តមហំ កិត្តយិស្សាមិ  សុណាថ មម ភាសតោ ។

ឯកាទសញ្ចក្ខត្តុំ សោ  ទេវរជ្ជំ ករិស្សតិ

ចតុត្តឹសតិក្ខត្តុញ្ច  ចក្កវត្តី ភវិស្សតិ ។

កប្បសតសហស្សម្ហិ  ឱក្កាកកុលសម្ភវោ

គោតមោ នាម គោត្តេន  សត្ថា លោកេ ភវិស្សតិ ។

អក្កោសិត្វាន សមណេ  សីលវន្តេ អនាសវេ

បាបកម្មវិបាកេន  នាមធេយ្យំ លភិស្សតិ ។

តស្ស ធម្មេសុ ទាយាទោ  ឱរសោ ធម្មនិម្មិតោ

កុណ្ឌធានោតិ នាមេន  សាវកោ សោ ភវិស្សតិ ។

បវិវេកំ អនុយុត្តោ  ឈាយី ឈានរតោ អហំ

តោសយិត្វាន សត្ថារំ  វិហរាមិ អនាសវោ ។

សាវកេហិ បរិវុតោ  ភិក្ខុសង្ឃបុរក្ខតោ

ភិក្ខុសង្ឃេ និសីទិត្វា  សលាកំ គាហយី ជិនោ ។



កុលបុត្រណា បានបម្រើនូវព្រះពុទ្ធ ព្រះអង្គដូចជាកេសរៈ-រាជសីហ៍ ជាស្តេចនៃម្រឹគ តថាគតនឹងសម្តែងសរសើរនូវកុលបុត្រនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែង ៗ កុលបុត្រនោះ នឹងបានជាស្តេចនៃទេវតា អស់ ១១ ដង នឹងបានជាស្តេចចក្រពត្តិ អស់ ៣៤ ដង ៗ កន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្តា ព្រះនាមគោតម កើតក្នុងឱក្កាក-ត្រកូល ត្រាស់ដឹងក្នុងលោក ៗ កុលបុត្រនោះនឹងបាននូវនាម (ជាកុណ្ឌធាន) ដោយវិបាកនៃបាបកម្ម ព្រោះជេរនូវសមណៈទាំងឡាយ ជាអ្នកមានសីល មិនមានអាសវៈ ៗ កុលបុត្រដែលឈ្មោះកុណ្ឌធាននោះ នឹងបានជាទាយាទក្នុងធម៌ របស់ព្រះពុទ្ធព្រះនាមគោតមនោះ នឹងជាព្រះឱរស ជាធម្មនិម្មិត ក៏នឹងបានជាសាវ័ក របស់ព្រះពុទ្ធអង្គនោះ ៗ

ខ្ញុំតែងប្រកបរឿយ ៗ នូវវិវេក ជាអ្នកមានឈាន ត្រេកអរក្នុងឈាន ញុំាងព្រះសាស្តាឲ្យត្រេកអរ ជាអ្នកមិនមានអាសវៈ ៗ ព្រះជិនស្រី មានសាវ័កចោមរោម មានភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងកណ្តាលភិក្ខុសង្ឃ ហើយញុំាងភិក្ខុឲ្យកាន់យកស្លាក ៗ

## បាលី កុណ្ឌធានត្ថេរាបទានំ

ឯកាសិំ ជីវំ កត្វា    វន្ទិត្វា លោកនាយកំ
វនេតំ វរស្ស បុរតោ    បឋមំ អគ្គហេសហំ ។
តេន កម្មេន កតេន    ឆសសហស្សេកម្បកោ
ភិក្ខុសង្ឃេ និសីទិត្វា    អគ្គដ្ឋានេ ឋបេសិ មំ ។
វីរិយំ មេ ធុរធោរយ្ហំ    យោគក្ខេមាធិវាហនំ
ធារេមិ អន្តិមំ ទេហំ    សម្មាសម្ពុទ្ធសាសនេ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កុណ្ឌធានោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុណ្ឌធានត្ថេរស្ស អបទានំ សមត្តំ ។



## កុណ្ឌធានត្ថេរាបទាន ទី ៤

ខ្ញុំធ្វើនូវបីការនៀនស្មាម្កាន ហើយថ្វាយបង្គំព្រះលោកនាយក កាន់យកនូវស្លាកជាដំបូង ក្នុងទីចំពោះព្រះភក្ត្រព្រះសម្ពុទ្ធដ៏ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ។ ព្រះមានព្រះភាគ ញ៉ាំងលោកធាតុមួយម៉ឺនឲ្យញាប់ញ័រ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ដោយសារអំពើនោះ ។ សេចក្តីព្យាយាមរបស់ខ្ញុំ គួរដើម្បីនាំទៅនូវធុរៈ ជាទីនាំមកនូវធម៌ជាក្សេមចាកយោគៈ ខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្ពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុណ្ឌធានត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុណ្ឌធានត្ថេរាបទាន ។

## ទុតិយំ សាគតត្ថេរាបទានំ

[៣៦] សោភិតោ នាម នាមេន អហោសិំ ព្រាហ្មណោ តទា

បុរក្ខតោ សសិស្សេហិ អារាមំ អគមាសហំ ។

ភគវា តម្ហិ សមយេ ភិក្ខុសង្ឃបុរក្ខតោ

អារាមទ្វារា និក្ខម្ម អដ្ឋាសិ បុរិសុត្តមោ ។

តមទ្ទសាសឹ សម្ពុទ្ធំ ទន្តំ ទន្តបុរក្ខតំ

សកំ ចិត្តំ បសាទេត្វា សន្ថវឹ លោកនាយកំ ។

យេ កេចិ បាទបា សព្វេ មហិយា តេ វិរូហរេ

ពុទ្ធិមន្តោ តថា សត្តា រូហន្តិ ជិនសាសនេ ។

សត្ថវាហោសិ សប្បញ្ញោ មហេសី ពហុកេ ជនេ

វិបថា ឧទ្ធរិត្វាន បថំ អាចិក្ខសេ តុវំ ។



## សាគតត្ថេរាបទាន ទី ២

[៣៦] គ្រានោះ ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះសោភិតៈ មានពួកសិស្សចោមរោម ដើរទៅកាន់អារាម ។ សម័យនោះ ព្រះមានព្រះភាគ ជាបុរសឧត្តម មានពួកភិក្ខុចោមរោម ស្តេចចេញអំពីទ្វារអារាម ហើយឋិតនៅ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធអង្គនោះ ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ មានសាវ័កដែលមានឥន្ទ្រិយទូន្មានហើយដែរ ជាបរិវារ ខ្ញុំក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយពោលសរសើរព្រះលោកនាយកថា ពួកឈើទាំងអស់ណាមួយ ពួកឈើទាំងនោះរមែងដុះលូតលាស់លើផែនដី យ៉ាងណាមិញ សត្វទាំងឡាយជាអ្នកមានប្រាជ្ញា រែងចំរើនលូតលាស់ឡើង ក្នុងសាសនា របស់ព្រះជិនស្រី ក៏យ៉ាងនោះ ។ ព្រះអង្គជាអ្នកដឹកនាំពួក ជាសព្វញ្ញូ ស្វែងរកនូវគុណធំ សូមស្រោចស្រង់នូវពួកជនជាច្រើន អំពីផ្លូវខុស ហើយប្រាប់ផ្លូវត្រូវ ។

## ទុតិយំ សាគតត្ថេរបទានំ

ទន្តោ ទន្តបុរក្ខតោ   ឈាយី ឈានរតេហិ ច
អាតាបីបហិតត្តេហិ   ឧបសន្តេហិ តាទិភិ ។
អលង្កតោ បរិសតោ(១)   បុញ្ញញាណេហិ សោភសិ
បភា និទ្ធាវតេ តុយ្ហំ   សុរិយោ ឧទយតោ យថា ។
បសន្នចិត្តំ ទិស្វាន   មហេសី ឧទុម្ពរេ
ភិក្ខុសង្ឃេ ឋិតោ សត្ថា   ឥមា គាថា អភាសថ ។
យោ មេ ហាសំ ជនេត្វាន   ឥមំ ថោមេសិ ព្រាហ្មណោ
កប្បានំ សតសហស្សំ   ទេវលោកេ រមិស្សតិ ។
តុសិតាហិ(២) ចវិត្វាន   សុក្កមូលេន ចោទិតោ
គោតមស្ស ភគវតោ   សាសនេ បព្វជិស្សតិ ។

១ ម. បរិសាហិ ។ ២ ម. តុសិតតោ ។



ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ ព័ទ្ធដោយសាវ័ក ដែលមានឥន្ទ្រិយទូន្មានហើយ ហែហមរោម ព្រះអង្គមានឈាន មានពួកអ្នកត្រេកអរក្នុងឈាន អ្នកមានព្យាយាម និងអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន អ្នកមានចិត្តស្ងប់រម្ងាប់ អ្នកមិនញាប់ញ័រដោយលោកធម៌ ហែហមរោម ។ ព្រះអង្គប្រដាប់ហើយដោយពួកបរិស័ទ ទ្រង់ល្អដោយបុណ្យនិងញាណ រស្មីរបស់ព្រះអង្គផ្សាយចេញ ដូចព្រះអាទិត្យ ដែលរះទើបនឹងរះឡើង ។ ព្រះមហេសីជាសាស្តាព្រះនាមបទុមុត្តរៈ ទ្រង់ឋិតនៅកណ្តាលភិក្ខុសង្ឃ ឃើញខ្ញុំមានចិត្តជ្រះថ្លាហើយ ត្រាស់នូវគាថាទាំងឡាយនេះថា

ព្រាហ្មណ៍ណា ញុំាងសេចក្តីត្រេកអរឲ្យកើតឡើងហើយ បានសរសើរតថាគត ព្រាហ្មណ៍នោះនឹងត្រេកអរ ក្នុងទេវលោក អស់សែនកប្បទាំងឡាយ ។ ព្រាហ្មណ៍នោះលុះច្យុតចាកឋានតុសិតមក ត្រូវកុសលមូលដាស់តឿន នឹងបួសក្នុងសាសនា របស់ព្រះមានព្រះភាគ ព្រះនាមគោតម ។

តុដ្ឋហដ្ឋ លភិស្សតិ     បព្វជិត្វាន សាសនេ
សាគតោ នាម នាមេន     ហេស្សតិ សត្ថុ សាវកោ ។
បព្វជិត្វាន កាយេន     បាបកម្មំ វិវជ្ជយិំ
វចីទុច្ចរិតំ ហិត្វា     អាជីវំ បរិសោធយិំ ។
ឯវំ វិហរមានោហំ     តេជោធាតុសុ កោវិទោ
សព្វាសវេ បរិញ្ញាយ     វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ     វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា     កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សាគតោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សាគតត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ មហាកច្ចាយនត្ថេរាបទានំ

[៣៥] បទុមុត្តរនាថស្ស     បទុមំ នាម ចេតិយំ
សិលាសនំ(*) ការយិត្វាន     សុវណ្ណេនាភិលេបយិំ ។

* ម. សីហាសនំ ។



ព្រាហ្មណ៍នោះ បួសក្នុងសាសនាហើយ នឹងបាននូវសេចក្តីត្រេកអរក្រៃលែង មាននាមថាសាគតៈ នឹងបានជាសាវ័ករបស់ព្រះសាស្តានោះ ។

ខ្ញុំបួសហើយ ក៏វៀរចាកបាបកម្ម ដោយកាយ លះបង់នូវវចីទុច្ចរិត ជម្រះសំអាតនូវអាជីវៈឲ្យបរិសុទ្ធ ។ ខ្ញុំកាលនៅយ៉ាងនេះ ជាអ្នកឈ្លាសវៃក្នុងតេជោធាតុ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសាគតត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សាគតត្ថេរាបទាន ។

## មហាកច្ចាយនត្ថេរាបទាន ទី៣

[៣៥] ខ្ញុំបានធ្វើចេតិយឈ្មោះបទុមៈ ជាវិការៈនៃថ្ម ហើយលាបដោយមាស ថ្វាយព្រះលោកនាថ ព្រះនាមបទុមុត្តរៈ ។

រតនាមយឆត្តញ្ច បគ្គយ្ហ វាឡវីជនឹ
ពុទ្ធស្ស អភិរោបេសឹ លោកពន្ធុស្ស តាទិនោ ។
យាវតា ទេវតា ភុម្មា សព្វេ សន្និបតុំ តទា
រតនាសនឆត្តានំ វិបាកំ កថយិស្សតិ ។
តញ្ច សព្វំ សុណិស្សាម កថយន្តស្ស សត្ថុនោ
ភិយ្យោ ហាសំ ជនេយ្យាម សម្មាសម្ពុទ្ធសាសនេ ។
ហេមាសនេ និសីទិត្វា សយម្ភូ អគ្គបុគ្គលោ
ភិក្ខុសង្ឃបរិព្យូឡ្ហោ ឥមា គាថា អភាសថ ។
យេនិទំ អាសនំ ទិន្នំ សោវណ្ណំ រតនាមយំ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
តឹសកប្បានិ ទេវិន្ទោ ទេវរជ្ជំ ករិស្សតិ
សមន្តា យោជនសតំ អាភាយាភិភវិស្សតិ ។
មនុស្សលោកមាគន្ត្វា ចក្កវត្តិ ករិស្សតិ
បភស្សរោតិ នាមេន ឧគ្គតេជោ ភវិស្សតិ ។





ខ្ញុំលើកឆត្រជាវិការៈនៃកែវ និងផ្លិតរោមសត្វ ថ្វាយព្រះពុទ្ធ ជាផៅពន្ធុនៃលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ គ្រានោះ ពួកទេវតាទាំងអស់ ទាំងប៉ុន្មាន បានមកប្រជុំគ្នាថា ព្រះលោកនាថ នឹងសម្តែងផលនៃអាសនៈ និងឆត្រជាវិការៈនៃកែវ ។ ពួកយើងនឹងស្តាប់ នូវផលទាំងពួងនោះ កាលបើព្រះសាស្តាកំពុងសម្តែង ពួកយើងនឹងញ៉ាំងសេចក្តីរីករាយ ឲ្យកើតដោយក្រៃលែង ក្នុងសាសនា របស់ព្រះសម្មាសម្ពុទ្ធ ។ ព្រះសយម្ភូ ជាអគ្គបុគ្គល មានភិក្ខុសង្ឃចោមរោម ទ្រង់គង់លើអាសនៈមាសហើយ ត្រាស់នូវគាថាទាំងឡាយនេះថា

កុលបុត្រណា បានថ្វាយអាសនៈមាស ប្រដាប់ដោយកែវនេះ តថាគតនឹងសម្តែងសរសើរកុលបុត្រនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ កុលបុត្រនោះនឹងបានជាធំជាងទេវតា សោយទេវរជ្ជ អស់៣០កប្ប នឹងមានរស្មីគ្របសង្កត់ ១០០ យោជន៍ ដោយជុំវិញ ។ កុលបុត្រនោះ លុះត្រឡប់មកកាន់មនុស្សលោកវិញ នឹងបានជាស្តេចចក្រពត្តិ មាននាមថាបភស្សរៈ នឹងមានតេជះដ៏ខ្ពង់ខ្ពស់ ។

ទិវា វា យទិ វា រត្តិំ  សតរំសីវ ឧគ្គតោ
សមន្តា អដ្ឋរតនំ  ឧជ្ជោតិស្សតិ ចក្កិយោ ។
កប្បសតសហស្សម្ហិ  ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន  សត្ថា លោកេ ភវិស្សតិ ។
តុសិតាហិ ចវិត្វាន  សុក្កមូលេន ចោទិតោ
កប្បោ នាម នាមេន  ព្រហ្មពន្ធុ ភវិស្សតិ ។
សោ បច្ឆា បព្វជិត្វាន  ពុទ្ធោ ហេស្សត្យនាសវោ
គោតមោ លោកបជ្ជោតោ  អគ្គដ្ឋានេ ឋបេស្សតិ ។
សន្ទិដ្ឋំ បុដ្ឋំ បញ្ហំ  វិគ្គាហេន កថេស្សតិ
កថយន្តោ ច តំ បញ្ហំ  អជ្ឈាសយំ បូរេស្សតិ ។
អឌ្ឍកុលេ អភិជាតោ  ព្រាហ្មណោ មន្តបារគូ
ឱហាយ ធនធញ្ញានិ  បព្វជិំ អនគារិយំ ។
សន្ទិដ្ឋាបិ បុដ្ឋោ  វិគ្គាហេន កថេមហំ
អជ្ឈាសយំ តេសំ បូរេមិ[១]  តោសេមិ ទិបទុត្តមំ ។

១ ម. អញ្ញសិ តេសំ បូរមិ ។



ព្រះបាមេតស្សព្រោះនោះ នឹងរុងរឿង អស់ទី ៨ ហត្ថដោយជុំវិញ ចំណែកថ្ងៃចំណែកយប់ ដូចជាព្រះអាទិត្យរះឡើង ។ កន្ទួលទៅមួយសែនកប្ប នឹងមានព្រះសាស្តា ព្រះនាមគោតម កើតក្នុងក្នុងត្រកូល ព្រះអង្គនៃលោក ។ កុលបុត្រនោះ ព្រ[illegible] ក្រៅក្នុងស្រីមួលជាសរសៀង នឹងបានជាព្រាហ្មណ៍ មាននាមកប្បៈ ។ លុះកាលជាខាងក្រោយមក កប្បៈនោះចេញបួស នឹងបានជាអ្នកប្រាជ្ញ មិនមានអាសវៈ ព្រះគោតមជាប្រទីបនៃលោក ទ្រង់នឹងតាំង (កប្បៈនោះ) ក្នុងទីជាឯតទគ្គៈ ។ កប្បៈនោះ នឹងសម្រេចនូវប្រស្នាដែលគេសួរយ៉ាងស្រួល ដោយពិស្តារបាន មួយវិញទៀត កប្បៈនោះ កាលនឹងសម្រេចនូវប្រស្នានោះ កាចនឹងបំពេញអធ្យាស្រ័យ (របស់អ្នកសួរ) បាន ។ កុលបុត្រនោះ កើតក្នុងត្រកូលស្តុកស្តម្ភ ជាព្រាហ្មណ៍ដល់នូវត្រើយនៃមន្ត លះបង់ទ្រព្យនិងស្រូវ ចូលទៅកាន់ផ្នួស ។

កាលបើមានប្រស្នា ដែលជនទាំងឡាយសួរដោយបំប្រួញ នឹងសម្រេចដោយពិស្តារ បំពេញអធ្យាស្រ័យ នៃពួកជននោះ នាំញ៉ាំងព្រះសម្ពុទ្ធប្រសើរជាងសត្វជើងពីរ ឲ្យត្រេកអរ ។

តោសិតោ មេ មហាវីរ សយម្ភូ អគ្គបុគ្គលោ
ភិក្ខុសង្ឃេ និសីទិត្វា ឯតទគ្គេ ឋបេសិ មំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា មហាកច្ចាយនោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

មហាកច្ចាយនត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ កាឡុទាយិត្ថេរាបទានំ

[៣៦] បទុមុត្តរស្ស ពុទ្ធស្ស លោកជេដ្ឋស្ស តាទិនោ
អទ្ធានំ បដិបន្នស្ស ចរតោ ចារិកំ តទា ។
សុផុល្លំ បទុមំ គយ្ហ ឧប្បលំ មល្លិកញ្ចហំ
បរមន្នំ គហេត្វាន អទាសិំ សត្ថុនោ អហំ ។
បរិភុញ្ជិ[១] មហាវីរោ បរមន្នំ សុភោជនំ
តញ្ច បុប្ផំ គហេត្វាន ជនស្ស[២] សម្បទស្សយិ[៣] ។

១ កត្ថចិ បោត្ថកេ បរិភុញ្ជ ឥតិ ទិស្សតិ ។ ២ ម. ជិនស្ស ។ ៣ កត្ថចិ បោត្ថកេ សម្បទស្សយិត្ថ ទិស្សតិ ។





ព្រះសយម្ភូ ជាអគ្គបុគ្គល ព្រះអង្គមានព្យាយាមធំ ដែលខ្ញុំធ្វើឲ្យត្រេកអរហើយ ទ្រង់គង់ក្នុងកណ្តាលភិក្ខុសង្ឃ ហើយទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកច្ចាយនត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កច្ចាយនត្ថេរាបទាន ។

## កាឡុទាយិត្ថេរាបទាន ទី ៤

[៣៦] គ្រានោះ ព្រះបទុមុត្តរសម្ពុទ្ធ ព្រះអង្គជាច្បងក្នុងលោក មិនញាប់ញ័រដោយលោកធម៌ ស្តេចយាងតាមផ្លូវឆ្ងាយត្រាច់ទៅកាន់ចារិក ។ ខ្ញុំកាន់ផ្កាឈូក ផ្កាឧប្បល ផ្កាម្លិះ ដែលរីកស្គុះស្គាយ ទាំងយកចង្ហាន់ដ៏ថ្លៃថ្លា បង្អោនទៅថ្វាយព្រះសាស្តា ។ ព្រះសម្ពុទ្ធ ព្រះអង្គមានព្យាយាមធំ ទ្រង់ឆាន់ចង្ហាន់ដ៏ប្រសើរ ជាភោជនដ៏ល្អរួចហើយ ទ្រង់កាន់នូវផ្កាទាំងនោះ បង្ហាញដល់ប្រជុំជនថា

ឥដ្ឋំ កន្តយិតំ លោកេ   ជលជំ បុប្ផមុត្តមំ
សុកក្ការំ កតំ តេន   យំ(១) មេ បុប្ផំ អជាសិ សោ ។
យោ បុប្ផំ អភិរោបេសិ   បរមន្នញ្ជាសិ មេ
តមហំ កិត្តយិស្សាមិ   សុណាថ មម ភាសតោ ។
ទសមដ្ឋក្ខត្តុំ សោ   ទេវរជ្ជំ ករិស្សតិ
ឧប្បលំ បទុមញ្ចាបិ   មល្លិកញ្ច តទុត្តរិ ។
អស្ស បុញ្ញវិបាកេន   ទិព្វគន្ធសមាយុតំ
អាកាសេ ឆទនំ កត្វា   ធារយិស្សតិ តាវទេ ។
បញ្ចវីសតិក្ខត្តុញ្ច   ចក្កវត្តី ភវិស្សតិ
បថព្យា រជ្ជំ បញ្ចសតំ   វសុធំ អាវសិស្សតិ ។
កប្បសតសហស្សម្ហិ   ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន   សត្ថា លោកេ ភវិស្សតិ ។

---

១ កត្ថចិ បោត្ថកេ យោតិ ទិស្សតិ ។



បុរសនោះ បានថ្វាយផ្កាឈូកណា ដល់តថាគត ផ្កាឈូកនេះជាឧត្តម ជាទីស្រឡាញ់ ជាទីត្រេកអរ (របស់ជន) ក្នុងលោក អំពើដែលគេធ្វើបានដោយកម្រ បុរសនោះ ក៏បានធ្វើហើយ ។ បុរសណា បានបូជាផ្កាទាំងនេះថ្វាយចំពោះ ដ៏ប្រសើរ ដល់តថាគត តថាគតនឹងសម្តែងសរសើរបុរសនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ បុរសនោះនឹងបានសោយទេវរជ្ជ អស់ ១៨ ដង ផ្កាឧប្បល ផ្កាឈូក ផ្កាម្លិះ និងផ្កាដទៃក្រៅពីនោះ ដែលប្រកបដោយក្លិនដ៏ជាទិព្វ នឹងកើតឡើង ធ្វើឲ្យជាគ្រឿងប្រក់ក្នុងអាកាស ក្នុងខណៈនោះ ដោយផលនៃបុណ្យ របស់បុរសនោះ ។ បុរសនោះ នឹងបានជាស្តេចចក្រពត្តិ អស់ ២៥ ដង នឹងបានសោយរាជ្យលើផែនដី គ្រប់គ្រងផែនដី អស់ ៥០០ ដង ។ កន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្តា ព្រះនាមគោតម ទ្រង់កើតក្នុងឱក្កាកត្រកូល ត្រាស់ដឹងក្នុងលោក ។

### បត្ថុំ កាឡុទាយិត្ថេរាបទានំ

សព្ពកាមាភិរតោ សោ សុក្កមូលេន ចោទិតោ
សព្យាធិ ធន្ធជនោ(១) ញាតិពន្ធុ គវិស្សតិ ។
សោ ច បច្ឆា បព្វជិត្វា សុក្កមូលេន ចោទិតោ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សត្យនាសវោ ។
បដិសម្ភិទប្បត្តំ កតកិច្ចំ អនាសវំ
គោតមោ លោកពន្ធុ តំ ឯតទគ្គេ ឋបេស្សតិ ។
បធានំ បហិតត្តោ សោ ឧបសន្តោ និរូបធិ
ឧទាយិ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។
រាគោ ទោសោ ច មោហោ ច មានោ មក្ខោ ច ធំសិតោ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
តោសយិត្វាន សម្ពុទ្ធំ អាតាបី និបកោ អហំ
បសាទិតោ ច សម្ពុទ្ធោ ឯតទគ្គេ ឋបេសិ មំ ។

១ កត្ថចិ បោត្ថកេ ធន្ធជនោតិ ទិស្សតិ ។



### កាឡុទាយិត្ថេរាបទាន ទី ៤

បុរសនោះ មានកម្មរបស់ខ្លួនប្រាកដហើយ មានកុសលមូលចាស់ក្លៀវហើយ នឹងបានកើតជាព្រះញាតិផៅពង្ស ជាអ្នកញុំាងពួកសក្យៈឲ្យកើតសេចក្តីត្រេកអរ ។ លុះកាលជាខាងក្រោយមក បុរសនោះនឹងចេញបួស ត្រូវកុសលមូលចាស់ក្លៀវ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះគោតម ព្រះអង្គជាផៅពង្ស នៃសត្វ-លោក នឹងតាំងភិក្ខុនោះ ដែលដល់បដិសម្ភិទាហើយ មានសោឡសកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ ក្នុងទីជាឯតទគ្គៈ ។ ភិក្ខុនោះតាំងព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានចិត្តស្ងប់ស្ងាប់ មិនមានឧបធិ មាននាមជាឧទាយិ នឹងបានជាសាវ័ក របស់ព្រះសាស្តានោះ ។

ខ្ញុំកំចាត់បង់រាគៈ ទោសៈ មោហៈ មានៈ និងមក្ខៈ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ មួយវិញទៀត ខ្ញុំមានព្យាយាម មានប្រាជ្ញាចាស់ បានញុំាងព្រះសម្ពុទ្ធឲ្យត្រេកអរ ឯព្រះសម្ពុទ្ធ ដែលខ្ញុំបានធ្វើឲ្យជ្រះថ្លាហើយ ទ្រង់តាំងខ្ញុំ ក្នុងទីជាឯតទគ្គៈ ។

បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋមេ
ឆឡាភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ការុណាយំ ទេសកោ ឥមា
គាថាយោ អភាសិត្ថាតិ ។

កប្បាយនត្ថេរស្ស ជាតកំ សមត្តំ ។

## បញ្ចមំ មោឃរាជត្ថេរជាតកំ

(៣៧) អត្ថទស្សី តុ ភគវា សយម្ភូ អបរាជិតោ
ភិក្ខុសង្ឃបរិព្យូឡ្ហោ    រថិយំ បដិបជ្ជថ ។
សិស្សេហិ សម្បរិវុតោ    ឃរម្ហា អភិនិក្ខមឹ
និក្ខមិត្វានហំ តត្ថ    អទ្ទសំ លោកនាយកំ ។
អភិវាទេត្វាន សម្ពុទ្ធំ    សិរេ កត្វាន អញ្ជលឹ
សកំ ចិត្តំ បសាទេត្វា    សន្ថវឹ លោកនាយកំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ តាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកប្បាយនត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កប្បាយនត្ថេរជាតក ។

## មោឃរាជត្ថេរជាតក ទី ៥

(៣៧) កាលនោះ ព្រះមានព្រះភាគព្រះនាមអត្ថទស្សី ជាព្រះសយម្ភូ ឥតមានបុគ្គលផ្ចាញ់បាន មានភិក្ខុសង្ឃចោមរោម ស្តេចយាងទៅតាមថ្នល់ ។ ខ្ញុំមានពួកសិស្សចោមរោមចេញអំពីផ្ទះ លុះចេញទៅ ក៏បានឃើញព្រះលោកនាយក ក្នុងទីនោះ ។ ខ្ញុំធ្វើអញ្ជលីលើសិរ្សៈ ក្រាបបង្គំព្រះសម្ពុទ្ធ ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយពោលសរសើរព្រះលោកនាយកថា

បញ្ចមំ មោឃរាជត្ថេរាបទានំ

យាវតា រូបិនោ សត្តា អរូបី ច អសញ្ញិនោ
សព្វេ តេ តវ ញាណម្ហិ អន្តោ ហោន្តិ សមោគធា ។
សុខុមច្ឆិកេន ជាលេន ឧទកំ យោ បរិក្ខិបេ
យេ កេចិ ឧទកេ បាណា អន្តោជាលេ ភវន្តិ តេ ។
យេសញ្ច ចេតនា អត្ថិ រូបិនោ ច អរូបិនោ
សព្វេ តេ តវ ញាណម្ហិ អន្តោ ហោន្តិ សមោគធា ។
សមុទ្ធរសិមំ លោកំ អន្ធការសមាកុលំ
តវ ធម្មំ សុណិត្វាន កង្ខាសោតំ តរន្តិ តេ ។
អវិជ្ជានិវុតា លោកា អន្ធការេន ឱត្ថដា
តវ ញាណម្ហិ ជោតន្តេ អន្ធការា បធំសិតា ។
តុវំ ចក្ខុសិ សព្វេសំ សព្វតមវិនោទនោ
តវ ធម្មំ សុណិត្វាន និព្វាយិំសុ ពហុជ្ជនោ ។



មោឃរាជត្ថេរាបទាន ទី ៥

ពួកសត្វមានរូបក្តី ឥតរូបក្តី ឥតសញ្ញាក្តី ទាំងប៉ុន្មាន ពួកសត្វទាំងអស់នោះ តែងប្រជុំចុះខាងក្នុងញាណ របស់ព្រះអង្គ ។ បុគ្គលណា បិទបាំងទឹកដោយសំណាញ់ មានក្រឡាល្អិត ពួកសត្វណាមួយនៅក្នុងទឹក ពួកសត្វទាំងនោះ រមែងមាននៅខាងក្នុងសំណាញ់ (របស់បុគ្គលនោះ ដូចម្តេចមិញ) ។ សត្វទាំងឡាយណា ដែលមានចេតនា ទោះបីមានរូបក្តី ឥតរូបក្តី ពួកសត្វទាំងអស់នោះ រមែងប្រជុំចុះខាងក្នុងញាណ របស់ព្រះអង្គ (ដូច្នោះដែរ) ។ ព្រះអង្គស្រោចស្រង់សត្វលោកនេះ ដែលច្រឡូកច្រឡំដោយងងឹត សត្វទាំងនោះស្តាប់នូវធម៌ របស់ព្រះអង្គហើយ ទើបឆ្លងនូវខ្សែទឹក គឺសេចក្តីសង្ស័យបាន ។ សត្វលោក មានអវិជ្ជារួបរឹត មានងងឹតគ្របសង្កត់ហើយ ទើបក៏បាត់ងងឹតទាំងឡាយ ព្រោះញាណ របស់ព្រះអង្គដែលព្រោលឡើង ។ ព្រះអង្គមានចក្ខុ បន្ទោបង់នូវងងឹតធំ របស់សត្វទាំងពួង ជនជាច្រើន លុះស្តាប់ធម៌ របស់ព្រះអង្គហើយ ទើបបានសម្រេចព្រះនិព្វាន ។

បុតកំ(១) បូរយិត្វាន មធុំ ខុទ្ទំ អនេលកំ
ឧភោហត្ថេហិ បគ្គយ្ហ ឧបនេសិំ មហេសិនោ ។
បដិគ្គណ្ហិ មហាវីរោ សកហត្ថេន(២) មហាឥសិ
ភុញ្ជិត្វា តញ្ច សព្វញ្ញូ វេហាសំ អព្ភុគ្គមិ ។
អន្តលិក្ខេ ឋិតោ សត្ថា អត្ថទស្សី នរាសភោ
មម ចិត្តំ បសាទេន្តោ ឥមា គាថា អភាសថ ។
យេនិទំ ថវិតំ ញាណំ ពុទ្ធសេដ្ឋោ ច ថោមិតោ
តេន ចិត្តប្បសាទេន ទុគ្គតឹ សោ ន គច្ឆតិ ។
ចតុស្សដ្ឋិញ្ច(៣) ខត្តុំ សោ ទេវរជ្ជំ ករិស្សតិ
បទេសរជ្ជដ្ឋសតំ វសុធំ អាវសិស្សតិ ។
បញ្ចេវ សតក្ខត្តុញ្ច ចក្កវត្តី ករិស្សតិ
បទេសរជ្ជំ អសង្ខេយ្យំ មហិយា ការយិស្សតិ ។

១ ម. បុដកំ ។ ២ ម. សហត្ថេន ។ ៣ ម. ចតុស្សដ្ឋិ ។



ខ្ញុំញ៉ាំងកន្ត្រកឲ្យពេញ ដោយឃ្មុំផ្លិតដែលឥតមេ ហើយប្រគោយដៃទាំងពីរ បង្អោនចូលទៅថ្វាយព្រះមហេសី ។ ព្រះពុទ្ធជាមហាឥសី ព្រះអង្គមានព្យាយាមធំ ទ្រង់ទទួលដោយព្រះហស្តរបស់ព្រះអង្គ ព្រះសព្វញ្ញូ ទ្រង់សោយនូវឃ្មុំនោះរួចហើយ ស្តេចហោះឡើងកាន់អាកាសវេហាស៍ ។ ព្រះសាស្តា ព្រះនាមអត្ថទស្សី ជានរាសភៈ ឋិតនៅក្នុងអាកាស ទ្រង់ញ៉ាំងចិត្តរបស់ខ្ញុំឲ្យជ្រះថ្លា ហើយត្រាស់គាថាទាំងឡាយនេះថា

កុលបុត្រណា សរសើរញាណនេះផង សរសើរព្រះពុទ្ធដ៏ប្រសើរផង កុលបុត្រនោះ នឹងមិនទៅកាន់ទុគ្គតិ ដោយចិត្តដែលជ្រះថ្លានោះ ។ កុលបុត្រនោះ នឹងបានសោយទេវរាជ្យ អស់ ៦៤ ដង នឹងបានសោយប្រទេសរាជ្យ គ្រប់គ្រងផែនដី អស់ ៨០០ ដង នឹងបានជាស្តេចចក្រពត្តិ អស់ ៥០០ ដង ។ កុលបុត្រនោះ នឹងបានសោយប្រទេសរាជ្យ លើផែនដី អស់មួយអសង្ខេយ្យ

## បញ្ចមំ មោឃរាជត្ថេរាបទានំ

អជ្ឈាយិកោ មន្តធរោ តិណ្ណំ វេទាន បារគូ
គោតមស្ស ភគវតោ សាសនេ បព្វជិស្សតិ ។
គម្ភីរំ និបុណំ អត្ថំ ញាណេន វិជានិស្សតិ
មោឃរាជាតិ នាមេន ហេស្សតិ សត្ថុ សាវកោ ។
តីហិ វិជ្ជាហិ សម្បន្នោ កតកិច្ចោ អនាសវោ
គោតមោ សក្កមហេត្តា ឯតទគ្គេ ឋបេស្សតិ ។
ហិត្វា មានុសកំ យោគំ ឆេត្វាន ភវពន្ធនំ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា មោឃរាជោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មោឃរាជត្ថេរស្ស អបទានំ សមត្តំ ។



## មោឃរាជត្ថេរាបទាន ទី ៥

ជាអ្នកស្វាធ្យាយមន្ត ចាំទ្រមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ។ កុលបុត្រនោះនឹងបួសក្នុងសាសនា របស់ព្រះមានព្រះភាគ ព្រះនាមគោតម នឹងពិចារណានូវអត្ថដ៏ល្អិតជ្រាលជ្រៅ ដោយញាណបាន ។ កុលបុត្រនោះ មាននាមថាមោឃរាជ នឹងបានជាសាវ័ក របស់ព្រះសាស្តាអង្គនោះ ជាអ្នកបរិបូរ ដោយវិជ្ជា ៣ មានសោឡសកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ ។ ព្រះគោតម ជាអ្នកដឹកនាំពួកដ៏ប្រសើរ នឹងតាំងភិក្ខុនោះ ក្នុងទីជាឯតទគ្គៈ ។

ខ្ញុំលះបង់នូវយោគធម៌ ជារបស់នៃមនុស្ស កាត់ផ្តាច់នូវចំណងក្នុងភពហើយ កំណត់ដឹងនូវអាសវៈទាំងពួង ទាំងជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមោឃរាជត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មោឃរាជត្ថេរាបទាន ។

## ឆដ្ឋំ អធិមុត្តកត្ថេរាបទានំ

(៣៨) និព្វុតេ លោកនាថម្ហិ អត្ថទស្សិនរុត្តមេ(១)
និមន្តេត្វា(២) ភិក្ខុសង្ឃំ វិប្បសន្នេន ចេតសា ។
និមន្តេត្វា សង្ឃរតនំ(៣) ឧជុភូតំ សមាហិតំ
ឧច្ឆុនា មណ្ឌបំ កត្វា ភោជេសិំ សង្ឃមុត្តមំ ។
យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុសំ
សព្វេ សត្តេ អភិភោមិ បុញ្ញកម្មស្សិទំ ផលំ ។
អដ្ឋារសេ កប្បសតេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ឧច្ឆុទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អធិមុត្តកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អធិមុត្តកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. អត្ថទស្សីនរុត្តមេ ។ ២ ម. ឧបដ្ឋហឹ ។ ៣ ម. ភិក្ខុសង្ឃំ ។



## អធិមុត្តកត្ថេរាបទានទី៦

[៣៨] កាលព្រះលោកនាថ ព្រះនាមអត្ថទស្សី ព្រះអង្គប្រសើរជាងនរជនៈ បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា និមន្តភិក្ខុសង្ឃ លុះនិមន្តព្រះសង្ឃរតន ដែលមានសន្តានត្រង់ មានចិត្តតម្កល់មាំហើយ ខ្ញុំធ្វើមណ្ឌបដោយដើមអំពៅ បាននិមន្តព្រះសង្ឃដ៏ប្រសើរឲ្យឆាន់ ។ ខ្ញុំទៅកាន់កំណើតណាៗ ទោះជាទេវតា ឬជាមនុស្ស ខ្ញុំគ្របសង្កត់នូវពួកសត្វទាំងអស់ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ១.៨០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យអំពៅ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអធិមុត្តកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អធិមុត្តកត្ថេរាបទាន ។

## សត្តមំ លសុណទាយកត្ថេរាបទានំ

(៣៩) ហិមវន្តស្ស អវិទូរេ តាបសោ អាសហំ តទា
លសុណំ ឧបជីវាមិ លសុណំ មយ្ហ ភោជនំ ។
ខារិយោ បូរយិត្វាន សង្ឃារាមំ អគច្ឆហំ
ហដ្ឋោ ហដ្ឋេន ចិត្តេន សង្ឃស្ស លសុណំ អទំ ។
វិបស្សិស្ស នរគ្គស្ស សាសនេ និរតស្សហំ
សង្ឃស្ស លសុណំ ទត្វា កប្បំ សគ្គម្ហិ មោទហំ ។
ឯកនវុតេ ឥតោ កប្បេ លសុណំ យំ អទិំ តទា
ទុគ្គតឹ នាភិជានាមិ លសុណស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា លសុណទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

លសុណទាយកត្ថេរស្ស អបទានំ សមត្តំ ។



## លសុណទាយកត្ថេរាបទាន ទី ៧

(៣៩) គ្រានោះ ខ្ញុំកើតជាតាបស នៅជិតព្រៃហិមពាន្ត ចិញ្ចឹមជីវិត (ដោយស្រួយ) នឹងការដាំខ្ទឹម ខ្ទឹមជាភោជនរបស់ខ្ញុំ ។ ខ្ញុំបានកែខ្ទឹមពេញមួយអង្រែក ទៅកាន់អារាមរបស់សង្ឃ ខ្ញុំមានចិត្តរីករាយ បានប្រគេនខ្ទឹមដល់សង្ឃ ដោយចិត្តរីករាយ ។ ខ្ញុំបានប្រគេនខ្ទឹម ដល់ព្រះសង្ឃ ដែលមិនត្រេកអរនឹងកាម ក្នុងសាសនា នៃព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់ប្រសើរជាងពួកនរៈ ខ្ញុំរីករាយក្នុងឋានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានប្រគេនខ្ទឹម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃខ្ទឹមទាំងឡាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលសុណទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ លសុណទាយកត្ថេរាបទាន ។

## អដ្ឋមំ អាយាគទាយកត្ថេរាបទានំ

[៦០] និព្វុតេ លោកនាថម្ហិ សិខិម្ហិ វទតំ វរេ
ហដ្ឋោ ហដ្ឋេន ចិត្តេន អករឹ ថូបមុត្តមំ ។
វឌ្ឍកីហិ កថាបេត្វា មូលំ ទត្វានហំ តទា
ហដ្ឋោ ហដ្ឋេន ចិត្តេន អាយាគំ(១) ការយឹសហំ ។
អដ្ឋកប្បានិ ទេវេសុ អព្ភោកិណ្ណំ វសឹ អហំ
អវសេសេសុ កប្បេសុ វោកិណ្ណំ សំសរឹ អហំ ។
កាយេ វិសំ ន កមតិ សត្ថានិ ន ច ហន្តិ មេ
ឧទកេហំ ន មិយ្យាមិ អាយាគស្ស ឥទំ ផលំ ។
យទិច្ឆាមិ អហំ វស្សំ មហាមេឃោ បវស្សតិ
ទេវាបិ មេ វសំ ឯន្តិ បុញ្ញកម្មស្សិទំ ផលំ ។
សត្តរតនសម្បន្នា តិសក្ខត្តុំ អហោសហំ
ន មំ កេចាវជានន្តិ(២) បុញ្ញកម្មស្សិទំ ផលំ ។

១ ម. អាយាគំ ។ ២ ម. កេចិ វជានន្តិ ។



## អាយាគទាយកត្ថេរាបទាន ទី ៨

[៦០] កាលព្រះលោកនាថ ព្រះនាមសិខី ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ បរិនិព្វានហើយ ខ្ញុំរីករាយ បានធ្វើបង្គំព្រះស្តូបដ៏ប្រសើរ ដោយចិត្តរីករាយ ។ កាលនោះ ខ្ញុំបានឲ្យជាងឈើ និយាយកាត់ថ្លៃ ហើយឲ្យថ្លៃ ខ្ញុំរីករាយឲ្យជាងឈើធ្វើរានសំណាក់ ដោយចិត្តរីករាយ ។ ខ្ញុំនៅជាប់មិនដាច់ក្នុងទេវលោក អស់ ៨ កប្ប ខ្ញុំអន្ទោលទៅកក់កាយក្នុងកប្បដ៏សេស ។ ពិសមិនជ្រាបទៅក្នុងកាយ ទាំងគ្រឿងសស្ត្រាក៏មិនមុតខ្ញុំ ខ្ញុំមិនស្លាប់ក្នុងទឹក នេះជាផលនៃរានសំណាក់ ។ បើខ្ញុំប្រាថ្នាទឹកភ្លៀង មហាមេឃក៏បង្អុរភ្លៀងមក ទាំងពួកទេវតា ក៏លុះអំណាចរបស់ខ្ញុំ នេះជាផលនៃបុញ្ញកម្ម ។ ខ្ញុំបរិបូណ៌ដោយកែវ ៧ ប្រការ អស់ ៣០ ដង ពួកជនណាមួយ មិនមើលងាយខ្ញុំឡើយ នេះជាផលនៃបុញ្ញកម្ម ។

ឯកត្តឹសេ ឥតោ កប្បេ អាហារំ យំ អទាសយឹ
ទុគ្គតឹ នាភិជានាមិ អាហារស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា អាហារទាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

អាហារទាយកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ ធម្មបក្កិកត្ថេរាបទានំ

(៦១) សិទ្ធត្ថស្ស ភគវតោ សីហាសនស្ស សម្មុខា
ធម្មចក្កំ មយា ឋបិតំ សុកតំ វិញ្ញុវណ្ណិតំ ។
ចតុវណ្ណាយ សោភាមិ សយោគ្គពលវាហនោ
បរិវេន្តិ មំ និច្ចំ អនុយន្តា ពហូ ជនា ។
សដ្ឋិតុរិយសហស្សេហិ បរិវេមហិ សទា
បរិវេន សោភាមិ បុញ្ញកម្មស្សិទំ ផលំ ។



ក្នុងកប្បទី៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានឲ្យបាយធ្វើកើនសំណាក់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកើនសំណាក់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអាហារទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អាហារទាយកត្ថេរាបទាន ។

## ធម្មបក្កិកត្ថេរាបទាន ទី៩

[៦១] ធម្មចក្រដ៏វិចិត្រល្អ ដែលអ្នកប្រាជ្ញសរសើរហើយ ខ្ញុំបានតំកល់ទុកខាងមុខសីហាសនៈ របស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ។ ខ្ញុំមានយានទឹមដោយពលពាហនៈ ដែលរុងរឿង ដោយវណ្ណៈ ៤ យ៉ាង ពួកជនដ៏ច្រើន ដើរតាមហែហមខ្ញុំជានិច្ច ។ ខ្ញុំមានតូរ្យតន្ត្រី ៦០.០០០ ហែហម សព្វកាល ខ្ញុំរុងរឿងដោយបរិវារ នេះជាផលនៃបុញ្ញកម្ម ។

ចតុន្នវុតេ ឥតោ កប្បេ យំ ធម្មំ ថបយឹ អហំ
ទុគ្គតឹ នាភិជានាមិ ធម្មក្ខន្ធស្សិទំ ផលំ ។
ឥតោ បណ្ណរសេ កប្បេ អដ្ឋាសីសុ ជនាធិបា
សហស្សរាជា នាមេន ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ធម្មក្ខន្ធោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ធម្មក្ខន្ធត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ កប្បរុក្ខិយត្ថេរាបទានំ

[៦២] សិទ្ធត្ថស្ស ភគវតោ ថូបសេដ្ឋស្ស សម្មុខា
វិចិត្តទុស្សេ លគ្គេត្វា កប្បរុក្ខំ ឋបេសហំ ។



កន្លងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានតម្កល់ទុកនូវធម៌ កន្លងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃធម្មក្ខន្ធ ។ កន្លងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ៨ អង្គ ព្រះនាមសហស្សរាជដូចគ្នា ជាធំជាងជន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មក្ខន្ធត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធម្មក្ខន្ធត្ថេរាបទាន ។

## កប្បរុក្ខិយត្ថេរាបទាន ទី ១០

(៦២) ខ្ញុំបានដាំនូវដើមកប្បព្រឹក្សមួយដើម ព្រមទាំងព្យួរនូវសំពត់វិចិត្រទាំងឡាយ នៅទីមុខនៃព្រះស្តូប ដ៏ប្រសើរ របស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ។

ទសមំ កប្បរុក្ខិយត្ថេរាបទានំ

យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុសំ
សោភយន្តោ មម ទ្វារំ កប្បរុក្ខោ បតិដ្ឋតិ ។
អហញ្ច បរិសា ចេវ យេ កេចិ សមវស្សិតា(១)
តម្ហា ទុស្សំ គហេត្វាន និវាសេម មយំ សទា ។
ចតុន្នវុតេ ឥតោ កប្បេ យំ រុក្ខំ ឋបយឹ អហំ
ទុគ្គតឹ នាភិជានាមិ កប្បរុក្ខស្សិទំ ផលំ ។
ឥតោ ច សត្តមេ កប្បេ សុចេឡា អដ្ឋ ខត្តិយា
សត្តរតនសម្បន្នា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កប្បរុក្ខិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កប្បរុក្ខិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. មម ស្សិតា ។





ខ្ញុំទៅកាន់កំណើតណាៗ គឺជាទេវតា ឬជាមនុស្ស ដើមកប្បព្រឹក្សដ៏ល្អ ប្រតិស្ឋានទៀបមាត់ទ្វារផ្ទះនៃខ្ញុំ ។ យើងទាំងឡាយ គឺខ្ញុំផង បរិស័ទផង ពួកជននីមួយៗដែលមានទាំងស្រីតាមខ្ញុំផង តែងកាន់យកសំពត់ អំពីដើមកប្បព្រឹក្សនោះមកស្លៀកដណ្តប់ គ្រប់កាលនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ ដាំដើមឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដើមកប្បព្រឹក្ស ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រិយ៍ចក្រពត្តិ ៨ អង្គ ព្រះនាមសុចេលៈដូចគ្នា ប្រដាប់ប្រដាដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកប្បរុក្ខិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កប្បរុក្ខិយត្ថេរាបទាន ។

## ឧទ្ទានំ

កុណ្ឌសាគតកច្ចានា ឧទាយី រាជសញ្ញកោ[1]
អធិមុត្តោ លសុណទោ អាយាគី ធម្មចក្កិកោ
កប្បរុក្ខី ច ទសមោ គាថាទ្វយំ ទសសតំបិច ។

កុណ្ឌធានវគ្គោ ចតុត្ថោ ។

---

[1] ម. មោឃរាជកោ ។



## ឧទ្ទាន

កុណ្ឌធានត្ថេរ ១ សាគតត្ថេរ ១ កច្ចាយនត្ថេរ ១ កាឡុទាយិ-ត្ថេរ ១ មោឃរាជត្ថេរ ១ អធិមុត្តត្ថេរ ១ លសុណទាយក-ត្ថេរ ១ អាយាគទាយកត្ថេរ ១ ធម្មចក្កិកត្ថេរ ១ កប្បរុក្ខិយ-ត្ថេរ ១ ជាគំរប់ ១០ មានគាថា ១១៦ ។

ចប់ កុណ្ឌធានវគ្គ ទី៤ ។

## បញ្ចមោ ឧបាលិវគ្គោ

## បឋមំ ឧបាលិត្ថេរាបទានំ

(៤៣) ខីណាសវសហស្សេហិ បរិវុតោ លោកនាយកោ

វិវេកមនុយុត្តោ សោ គច្ឆតេ បដិសល្លិតុំ ។

អជិនេន និវត្ថោហំ តិទណ្ឌបរិធារណោ

ភិក្ខុសង្ឃបរិព្យូឡ្ហំ អទ្ទសំ លោកនាយកំ

ឯកំសំ អជិនំ កត្វា សិរេ កត្វាន អញ្ជលឹ

សម្ពុទ្ធំ អភិវាទេត្វា សន្ថវឹ លោកនាយកំ

យថាណ្ឌជា ច សំសេទា ឱបបាតី ជលាពុជា

កាកាទិបក្ខិនោ សព្វេ អន្តលិក្ខេ សទា ចរា ។

យេ កេចិ បាណភូតត្ថិ សញ្ញិនោ វា អសញ្ញិនោ

សព្វេ តេ តវ ញាណម្ហិ អន្តោ ហោន្តិ សមោគធា ។

## ឧបាលិវគ្គ ទី៥

## ឧបាលិត្ថេរាបទាន ទី១

(៤៣) ព្រះលោកនាយក ទ្រង់ព្រះនាមបទុមុត្តរៈ មានពួកព្រះខីណាស្រពមួយពាន់អង្គចោមរោម ទ្រង់ប្រកបរឿយ ៗ នូវវិវេក កំពុងតែចូលទៅ ដើម្បីពួនសម្ងំ ។ ខ្ញុំស្លៀកស្បែកខ្លាឃ្មុំ កាន់ឈើច្រត់ចំការ ៣ ជើងទៅ បានឃើញព្រះលោកនាយក ចោមរោមដោយភិក្ខុសង្ឃ ទើបខ្ញុំធ្វើស្បែកខ្លាឃ្មុំឆៀងស្មាម្ខាង រួចហើយធ្វើអញ្ជលីលើសិរ្សៈ ថ្វាយបង្គំព្រះសម្ពុទ្ធ សរសើរព្រះលោកនាយកថា សត្វទាំងឡាយដែលកើតអំពីពងក្តី ដែលកើតអំពីញើសក្តី ដែលជាឱបបាតិកៈក្តី ដែលកើតអំពីទឹកក្តី ពួកបក្សីទាំងអស់ មានក្អែកជាដើមក្តី និងត្រាច់ទៅក្នុងអាកាស សព្វ ៗ កាល យ៉ាងណាមិញ ។ ពួកសត្វណាមួយ ដែលមានសញ្ញាក្តី អសញ្ញាក្តី សត្វទាំងអស់នោះ សឹងប្រជុំចុះ ក្នុងខាងក្នុង នៃព្រះញាណរបស់ព្រះអង្គ ក៏យ៉ាងនោះដែរ ។

តទា ច បច្ចេកេយ្យេ យេ ភិនវន្តិ ឧត្តមេ

សព្ពេ តេ តវ សីលម្ហិ ការណាយេ ច យុជ្ជរេ ។

មោហន្ធការបក្ខន្ទោ អយំ លោកោ សទេវកោ

តវ ញាណម្ហិ ជោតន្តេ អន្ធការា វិធំសិតា ។

យថា អត្ថង្គតេ សុរិយេ ហោន្តិ សត្តា តមោគតា

ឯវំ ពុទ្ធេ អនុប្បន្នេ ហោតិ លោកោ តមោគតោ ។

យថោទយន្តោ អាទិច្ចោ វិនោទេតិ តមំ សទា

តថេវ ត្វំ ពុទ្ធសេដ្ឋ វិទ្ធំសេសិ តមំ សទា ។

បធានំ បហិតត្តោសិ ពុទ្ធោ លោកេ សទេវកេ

តវ កម្មាភិរទ្ធេន តោសេសិ ជនតំ ពហុំ ។

តំ សុត្វា(១) អនុមោទិត្វា បទុមុត្តរោ មហាមុនិ

នភេ អព្ភុគ្គមិ ធីរោ ហំសរាជាវ អម្ពរេ ។

---

១ ម. សុត្វា ។



មួយវិញទៀត កូនឈើក្តាំងខ្សោយណា លើកហើមពាន្លដី ឡើង កូនទាំងអស់នោះ មិនបានមួយចំណែក នឹងកូនសីល របស់ព្រះអង្គ ។ លោកនេះ ព្រមទាំងទេវលោក តែងស្រុះ ទៅកាន់ងងឹតគឺមោហៈ កាលបើញាណរបស់ព្រះអង្គ ព្រោល ឡើងហើយ ងងឹតក៏ត្រាត់ចេញទៅ ។ កាលបើព្រះអាទិត្យ អស្តង្គតហើយ ពួកសត្វក៏ដល់នូវសេចក្តីងងឹត យ៉ាងណា កាលព្រះពុទ្ធមិនទាន់បានត្រាស់ លោកក៏ដល់នូវសេចក្តីងងឹត យ៉ាងនោះដែរ ។ ព្រះអាទិត្យកាលរះឡើង តែងបន្ទោបង់នូវ ងងឹត សព្វកាល យ៉ាងណា បពិត្រព្រះពុទ្ធដ៏ប្រសើរ ព្រះ អង្គក៏កាត់បង់នូវងងឹត សព្វកាល យ៉ាងនោះដែរ ។ ព្រះអង្គ មានព្រះទ័យបញ្ជូនទៅកាន់ព្យាយាម បានជាព្រះពុទ្ធ ក្នុង លោក ព្រមទាំងទេវលោក ទ្រង់ញុំាងប្រជុំជនដ៏ច្រើនឲ្យ ត្រេកអរ ដោយការប្រារព្ធនូវអំពើរបស់ព្រះអង្គ ។ ព្រះបទុ- មុត្តរមហាមុនី ជាអ្នកប្រាជ្ញ បានទ្រង់ព្រះសណ្តាប់នូវពាក្យ នោះហើយ ក៏ទ្រង់អនុមោទនា ហោះឡើងទៅឰដ៏អាកាស ដូចជាស្តេចហង្ស ហើរទៅឰដ៏អាកាស ដូច្នោះដែរ ។

អត្តកក្ខាន សម្ពុទ្ធោ មហេសី បទុមុត្តរោ
អគ្គលិគ្គោ ឋិតោ សត្ថា ឥមា គាថា អភាសថ ។
យេនិទំ(១) ជីវិតំ ញាណំ ឧបមេហិ(២) សមាយុតំ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
អដ្ឋារសញ្ច ខត្តុំ សោ ទេវរជ្ជំ ករិស្សតិ
បថព្យា រជ្ជំ តិសតំ វសុធំ អាវសិស្សតិ ។
បញ្ចវីសតិខត្តុញ្ច ចក្កវត្តី ភវិស្សតិ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។
កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន សត្ថា លោកេ ភវិស្សតិ ។
តុសិតា ហិ ចវិត្វាន សុក្កមូលេន ចោទិតោ
ហីនោ ជាតិយា សន្តោ ឧបាលិ នាម ហេស្សតិ ។
សោ ច បច្ឆា បព្វជិត្វា វិរាជេត្វាន បាបកំ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សត្យនាសវោ ។

១ ម. យេនិទ ។ ២ ម. ឧបមេហិ ។



ព្រះសម្ពុទ្ធជាមហេសី ព្រះនាមបទុមុត្តរៈ ជាសាស្តា លុះទ្រង់ហោះឡើងហើយ ក៏ឋិតនៅក្នុងអាកាស ទើបសំដែងនូវគាថាទាំងនេះថា

បុគ្គលណា សរសើរញាណនេះ ប្រកបដោយឧបមាទាំងឡាយ តថាគតនឹងសំដែងសរសើរ នូវបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសំដែងចុះ ។ បុគ្គលនោះនឹងបានជាទេវរាជ អស់ ១៨ ដង នឹងសោយរាជ្យ លើផែនដីគ្រប់គ្រងផែនដី អស់ ៣០០ ដង ។ នឹងបានជាស្តេចចក្រពត្តិ ២៥ ដង (បានគ្រប់គ្រង) នូវប្រទេសរាជ្យ ដ៏ធំទូលាយ រាប់បានអសង្ខេយ្យជាតិ ។ ក្នុងទីបំផុតសែនកប្ប ព្រះសាស្តា ព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលក្សត្រិយ៍ឱក្កាកៈ នឹងទ្រង់កើតឡើង ក្នុងលោក ។ បុគ្គលនោះ ច្យុតចាកតុសិតទេវលោកមក ត្រូវកុសលមូលដាស់តឿន ទោះជាអ្នកថោកទាប ដោយជាតិ ឈ្មោះថាឧបាលិ ក៏ដោយ ។ តែលុះដល់កាលជាខាងក្រោយ ឧបាលិនោះ នឿយណាយនឹងអំពើបាប ក៏ចេញបួស កំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ពុទ្ធោ ច គោតមោ នាម សក្យបុត្តោ មហាយសោ
វិនយាធិគតំ តស្ស ឯតទគ្គេ ឋបេស្សតិ ។
សទ្ធាយហំ បព្វជិតោ កតកិច្ចោ អនាសវោ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
ភគវា ចានុកម្បី មំ វិនយេហំ វិសារទោ
សកកម្មាភិរតោ ច វិហរាមិ អនាសវោ ។
សំវុតោ បាតិមោក្ខម្ហិ ឥន្ទ្រិយេសុ ច បញ្ចសុ
ធារេមិ វិនយំ សព្វំ កេវលំ រតនាករំ ។
មមញ្ច គុណមញ្ញាយ សត្ថា លោកេ អនុត្តរោ
ភិក្ខុសង្ឃេ និសីទិត្វា ឯតទគ្គេ ឋបេសិ មំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។



ព្រះពុទ្ធព្រះនាមគោតម ជាសក្យបុត្ត ទ្រង់មានយសច្រើន ត្រាស់ដឹងហើយ ទ្រង់តាំងទុកលោកនោះ ដែលចេះដឹងនូវវិន័យ ក្នុងទីជាឯតទគ្គៈ ។

ខ្ញុំបួសដោយសទ្ធា មានសោឡសកិច្ចធ្វើស្រេចហើយ ជាអ្នកមិនមានអាសវៈ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកអស់អាសវៈ ។ ព្រះមានព្រះភាគ ទ្រង់អនុគ្រោះខ្ញុំ ខ្ញុំជាអ្នកក្លៀវក្លា ក្នុងវិន័យ ព្រោះពេញចិត្តក្នុងកម្មរបស់ខ្ញុំ ជាអ្នកមិនមានអាសវៈ ។ ខ្ញុំសង្រួម ក្នុងបាតិមោក្ខផង ក្នុងឥន្ទ្រិយទាំង៥ផង ទ្រទ្រង់នូវវិន័យទាំងអស់ ដែលជាទីកើតនៃរតនៈគ្រប់យ៉ាង ។ ព្រះសាស្តា ប្រសើរក្នុងលោក ទ្រង់ជ្រាបនូវគុណរបស់ខ្ញុំហើយ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំ ក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ឧបាលិ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧបាលិត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ សោណកោដិវីសត្ថេរាបទានំ

៤៤) អនោមទស្សិស្ស មុនិនោ លោកជេដ្ឋស្ស តាទិនោ
សុធាយ លេបនំ កត្វា ចង្កមំ ការយឹ អហំ ។
នានាវណ្ណេហិ បុប្ផេហិ ចង្កមំ សន្ថរឹ អហំ
អាកាសេ វិតានំ កត្វា ភោជយឹ ពុទ្ធមុត្តមំ ។
អញ្ជលឹ បគ្គហេត្វាន អភិវាទេត្វាន សុព្វតំ(១)
ទីឃសាលំ ភគវតោ និយ្យាទេសិំ មហាមុនា ។
មម សង្កប្បមញ្ញាយ សត្ថា លោកេ អនុត្តរោ
បដិគ្គហេសិ ភគវា អនុកម្បាយ ចក្ខុមា ។

១ ម. បុប្ផតំ ។



បានឮថា ព្រះឧបាលិត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧបាលិត្ថេរាបទាន ។

## សោណកោដិវីសត្ថេរាបទាន ទី ២

(៤៤) ខ្ញុំបានធ្វើទីចង្ក្រម ធ្វើនូវការលាបដោយកំបោរ ថ្វាយព្រះមុនី ព្រះនាមអនោមទស្សី ទ្រង់ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំក្រាលទីចង្ក្រម ដោយផ្កាមានពណ៌ផ្សេងៗ ធ្វើនូវពិតានក្នុងអាកាស និមន្តព្រះពុទ្ធដ៏ប្រសើរឲ្យឆាន់ភត្ត ។ គ្រានោះ ខ្ញុំផ្គងអញ្ជលី ថ្វាយបង្គំព្រះសម្ពុទ្ធ ទ្រង់មានវត្តដ៏ល្អ ហើយថ្វាយទីឃសាលា ចំពោះព្រះមានព្រះភាគ ។ ព្រះសាស្តា ទ្រង់ប្រសើរបំផុតក្នុងលោក ទ្រង់ជ្រាបនូវចំណង់របស់ខ្ញុំ ព្រះមានព្រះភាគ មានចក្ខុ ទ្រង់បានទទួល (សាលានោះ) ដោយអនុគ្រោះ ។

បដិគ្គហេត្វាន សម្ពុទ្ធោ ឧគ្គិរោយោ សទេវកេ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ សោ ហាសេន ចិត្តេន ទីឃសាលំ អទាសិ មេ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
ឥមស្ស មច្ចុកាលម្ហិ បុញ្ញកម្មសមង្គិនោ
សហស្សយុត្តស្សរថោ ឧបដ្ឋិស្សតិ តាវទេ ។
តេន យានេនយំ បោសោ ទេវលោកំ គមិស្សតិ
អនុមោទិស្សរេ ទេវា សម្បត្តេ កុសលេ ភវេ[១] ។
មហារហំ ព្យម្ហំ សេដ្ឋំ រតនមត្តិកលេបនំ
កូដាគារវរូបេតំ ព្យម្ហំ អជ្ឈាវសិស្សតិ ។
តិំសកប្បសហស្សានិ ទេវលោកេ រមិស្សតិ
បញ្ចវីសតិកប្បានិ ទេវរាជា ភវិស្សតិ ។
សត្តសត្តតិក្ខត្តុញ្ច ចក្កវត្តី ភវិស្សតិ
យសោធរសនាមា តេ សព្វេបិ ឯកនាមកា ។

---

១ ឱ. កុសលព្ភវេ ។



ព្រះសម្ពុទ្ធ ជាទក្ខិណេយ្យបុគ្គល ក្នុងលោក ព្រមទាំងទេវលោក លុះទទួលហើយ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយសំដែងនូវគាថាទាំងឡាយនេះថា

កុលបុត្រណា មានចិត្តរីករាយ បានថ្វាយទីឃសាលាចំពោះតថាគត តថាគតនឹងសំដែងសរសើរ នូវកុលបុត្រនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសំដែងចុះ ។ កុលបុត្រដែលប្រកបដោយបុញ្ញកម្មនេះ នឹងមានរថទឹមដោយសេះមួយពាន់ កើតឡើងប្រាកដ ក្នុងមរណកាល ។ បុរសនេះ នឹងទៅកាន់ទេវលោក ដោយយាននោះ ពួកទេវតារីករាយ ក្នុងភពជាកុសលដែលសម្រេចដល់បុរសនោះ ។ ទេវបុត្រនោះ នឹងនៅគ្រប់គ្រងវិមានដ៏ប្រសើរ ដែលមានថ្លៃច្រើន ណាបលាបដោយដីកែវ ជាវិមានប្រកបដោយកំពូលដ៏ប្រសើរ ។ ទេវបុត្រនោះ នឹងរីករាយក្នុងទេវលោក អស់ ៣០.០០០កប្ប នឹងបានជាទេវរាជ អស់ ២៥ កប្បទៀត ។ នឹងបានជាស្តេចចក្រពត្តិ អស់ ៧៧ដង ស្តេចចក្រពត្តិទាំងអស់នោះ មាននាមតែមួយ គឺនាមថាយសោធរៈ ។

## ទុតិយំ សោណកោឡិវិសត្ថេរាបទានំ

ទេ្វ សម្បត្តី អនុភោត្វា ចិនិត្វា បុញ្ញសញ្ចយំ
អជ្ជវីសតិកប្បម្ហិ ឧក្កាវត្តិ ករិស្សតិ ។
តត្ថាបិ ព្យម្ហំ វរំ វិស្សកម្មេន មាបិតំ
ទសសទ្ទាវិវិត្តំ បុរំ អជ្ឈាវសិស្សតិ ។
អបរិមេយ្យេ ឥតោ កប្បេ ភូមិបាលោ មហិទ្ធិកោ
ឱក្កាកោ នាម នាមេន រាជា រជ្ជំ ករិស្សតិ ។
សោឡសិត្ថីសហស្សានំ សព្វាសំ បវរា យា(១)
អភិជាតា ខត្តិយានី នវ បុត្តេ ជនិស្សតិ ។
នវ បុត្តេ ជនិត្វាន ខត្តិយានី មរិស្សតិ
តរុណី ច បិយា កញ្ញា មហេសិត្តំ ករិស្សតិ ។

១ ម. ឲ្យា ប សា ។



## សោណកោឡិវិសត្ថេរាបទាន ទី ២

លុះកុលបុត្តនោះ សោយសម្បត្តិទាំងពីរហើយ សន្សំនូវបុណ្យ នឹងបានជាស្តេចចក្រពត្តិ ក្នុងកប្បទី ២៨ ។ ស្តេចចក្រពត្តិនោះ នឹងនៅគ្រប់គ្រងប្រាសាទដ៏ប្រសើរ ដែលវិស្សុកម្មនិម្មិតថ្វាយ ក្នុងទីនោះ ជាបុរី មិនស្ងាត់ចាកសម្លេង ១០ ប្រការ(១) ។ ក្នុងកប្បច្រើន ប្រមាណមិនបាន អំពីកប្បនេះ កុលបុត្តនោះ នឹងបានជាស្តេចក្នុងដែន គ្រប់គ្រងផែនដី មានឫទ្ធិធំ មាននាមថាឱក្កាកៈ ។ អភិជាតខត្តិយានី (របស់ស្តេចនោះ) ដ៏ប្រសើរលើសជាងស្រីស្នំ ១៦ ពាន់ទាំងអស់ ព្រះនាងនឹងប្រសូត នូវព្រះរាជបុត្រ ៩ ព្រះអង្គ ។ នាងខត្តិយានី លុះប្រសូតបុត្រ ៩ ព្រះអង្គហើយ ក៏នឹងធ្វើកាលកិរិយាទៅ នឹងមាននាងកញ្ញា (ដទៃទៀត) ជាស្រីក្មេង ជាទីគាប់ព្រះទ័យ នឹងបានមកជាមហេសី ។

១ សម្លេងដំរី សម្លេងសេះ សម្លេងរថ សម្លេងស្គរ សម្លេងសម្ភោ សម្លេងពិណ សម្លេងច្រៀង សម្លេងស័ង្ខ សម្លេងមហោស្រព សម្លេងអញ្ជើញបរិភោគ ។ អដ្ឋកថា ។

ឱក្កាកំ តោសយិត្វាន វរំ កញ្ញា លភិស្សតិ
វរំ លទ្ធា ច សា កញ្ញា បុត្តេ បព្វាជយិស្សតិ ។
បព្វាជិតា ច តេ សព្វេ គមិស្សន្តិ នគុត្តមំ
ជាតិភេទភយា សព្វេ ភគិនីហិ វសិស្សរេ ។
ឯកា ច កញ្ញា ព្យាធីហិ ភវិស្សតិ បុរក្ខតា
មា នោ ជាតិ បភិជ្ជតិ និខណិស្សន្តិ ខត្តិយា ។
ខត្តិយោ នីហរិត្វាន តាយ សទ្ធិំ វសិស្សតិ
ភវិស្សតិ តទា ភេទោ ឱក្កាកកុលសម្ភវោ ។
តេសំ បជា ភវិស្សន្តិ កោលិយា នាម ជាតិយា
តត្ថ មានុសកំ ភោគំ អនុភោស្សន្តិនប្បកំ ។



នាងកញ្ញា ធ្វើក្សត្រឧក្កាកៈឲ្យត្រេកអរហើយ នឹងបានខ្ញើ
ពរ លុះនាងកញ្ញានោះ បានទទួលពរហើយ ក៏ញុំាងព្រះ
រាជាឲ្យបំបរបង់ ព្រះរាជបុត្រាដើមទាំងឡាយចោល ។ ព្រះ
រាជបុត្រទាំងអស់នោះ លុះព្រះបិតាបំបរបង់ហើយ ក៏នាំគ្នា
ទៅកាន់ហិមវន្ត ព្រះរាជបុត្រទាំងអស់ ខ្លាចបែកធ្លាយ
ជាតិ ក៏នៅរួមសង្វាសនឹងប្អូនស្រីទាំងឡាយរបស់ខ្លួន ។ ៦
នាងកញ្ញាម្នាក់ នឹងកើតព្យាធិពេញខ្លួន ក្សត្រទាំងឡាយនឹង
ជីក (រណ្ដៅឲ្យនៅ ដោយចំណងថា) ជាតិរបស់យើងកុំ
ធ្លាយឡើយ ។ មានក្សត្រ (ផ្សេងទៀត) មួយអង្គ នាំនាង
កញ្ញានោះ យកទៅនៅរួមសង្វាសជាមួយ ក្នុងការកើត
ត្រកូលក្សត្រឧក្កាកៈ នឹងបែកធ្លាយ ក្នុងកាលនោះ ។ ព្រះ
រាជវង្សទាំងឡាយ របស់ក្សត្រទាំងពីរអង្គនោះ នឹងបាន
ឈ្មោះថា កោលិយៈ (ក្សត្រទាំងពីរអង្គនោះ) នឹងសោយ
ភោគៈ ជារបស់មនុស្ស ប្រមាណមិនបាន ក្នុងទីនោះ ។

ទុតិយំ សោណកោឡិវិសត្ថេរាបទានំ

តម្ហា កាយា ចវិត្វាន ទេវលោកំ គមិស្សតិ
តត្រាបិ បវរំ ព្យម្ហំ លភិស្សតិ មនោរមំ ។
ទេវលោកា ចវិត្វាន សុក្កមូលេន ចោទិតោ
អាគន្ត្វាន មនុស្សត្តំ សោណោ នាម ភវិស្សតិ ។
អារទ្ធវីរិយោ បហិតត្តោ បទហំ សត្ថុ សាសនេ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សត្យនាសវោ ។
អនន្តទស្សី ភគវា គោតមោ សក្យបុង្គវោ
វិសេសញ្ញូ មហាវីរោ អគ្គដ្ឋានេ ឋបេស្សតិ ។

វុដ្ឋម្ហិ ទេវេ ចតុរង្គុលម្ហិ
តិណេ អនិលេរិតអង្គណម្ហិ
ឋត្វាន យោគស្ស បយុត្តតាទិនោ
តតោត្តរិំ បារមតា ន វិជ្ជតិ ។



សោណកោឡិវិសត្ថេរាបទានទី ២

លុះកុលបុត្តនោះ ច្យុតចាកកាយនោះ នឹងទៅកើតក្នុងទេវ-លោក នឹងបាននូវប្រាសាទ ដ៏ប្រសើរ ដែលជាទីគាប់ចិត្ត ក្នុងទេវលោកនោះ ។ លុះច្យុតចាកទេវលោក ត្រូវកុសល-មូលដាស់តឿន ហើយមកកាន់អត្តភាពជាមនុស្ស មាន នាមថាសោណៈ ។ សោណមានចិត្ត ប្រារព្ធព្យាយាម មាន ចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន តាំងនៅក្នុងសាសនា របស់ ព្រះសាស្តា កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមាន អាសវៈ នឹងបរិនិព្វាន ។ ព្រះអនន្តទស្សី មានព្រះភាគ ព្រះនាមគោតម ជាសក្យៈប្រសើរ ទ្រង់ជ្រាបវិសេស មាន ព្យាយាមធំ នឹងតាំង (សោណៈនោះ) ក្នុងឋានៈដ៏ប្រសើរ ។

កាលភ្លៀងធ្លាក់ លិចស្មៅអស់៤ធ្នាប់ នៅសល់
មួយធ្នាប់ ត្រូវខ្យល់បក់ទៀត (នៅតែប្រឹងដុះ)
ធៀបនឹងតាទិបុគ្គល អ្នកមានព្យាយាម មិន
មានអ្វីប្រសើរលើស ជាងស្មៅនោះទៀតទេ ។

ឧត្តមេ ទមថេ ទន្តោ ចិត្តំ មេ សុប្បណិហិតំ
ភារោ មេ ឱហិតោ សព្វោ និព្វុតោម្ហិ អនាសវោ ។
អង្គីរសោ មហានាគោ អភិជាតោវ កេសរី
ភិក្ខុសង្ឃេ និសីទិត្វា ឯតទគ្គេ ឋបេសិ មំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សោណោ កោឡិយវេស្សោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សោណកោឡិយវេស្សត្ថេរស្ស[១] អបទានំ សមត្តំ ។

## តតិយំ ភទ្ទិយកាឡិគោធាយបុត្តត្ថេរាបទានំ

(៤៨) បទុមុត្តរសម្ពុទ្ធំ មេត្តចិត្តំ មហាមុនឹ
ឧបេតិ ជនតា សព្វា សព្វលោកគ្គនាយកំ ។

១ ម. សោណកោឡិកណ្ណត្ថេរស្សាបទានំ ។



ខ្ញុំមានខ្លួនទូន្មានហើយ ក្នុងការទូន្មានដ៏ឧត្តម ចិត្តរបស់ខ្ញុំតាំងល្អហើយ ភារៈគឺខន្ធ ខ្ញុំដាក់ចុះហើយ ខ្ញុំជាអ្នកមិនមានអាសវៈ រលត់ទុក្ខហើយ ។ ព្រះមហានាគ ជាអង្គីរស មានជាតិដ៏ប្រសើរ ដូចជាកេសរសីហ៍ គង់ក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោណកោឡិយវេស្សត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សោណកោឡិយវេស្សត្ថេរាបទាន ។

## ភទ្ទិយកាឡិគោធាយបុត្តត្ថេរាបទាន ទី៣

(៤៨) ប្រជុំជនទាំងអស់ បានចូលទៅគាល់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់មានព្រះហឫទ័យប្រកបដោយមេត្តា ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់ជាអ្នកនាំសត្វលោកទាំងមូល ។

សត្តុកញ្ញ បកកញ្ញា(១) អាមិសម្បាទភោជនំ
ធនត្ថិ សត្តុនោ សាធុ បុញ្ញក្ខេត្តេ អនុត្តរេ ។
អហម្បិ ធនំ ធស្សាមិ ទេវទេវស្ស តាទិនោ
ពុទ្ធសេដ្ឋំ និមន្តេត្វា សង្ឃម្បិ ច អនុត្តរំ ។
ឧយ្យោជិតា មយា ទេវ និមន្តេសុំ តថាគតំ
កោសលំ ភិក្ខុសង្ឃញ្ច បុញ្ញក្ខេត្តំ អនុត្តរំ ។
សតសហស្សបល្លង្កំ សោវណ្ណំ គោណកត្ថតំ
តូលិកាបដលិកាយ ខោមកប្បាសិកេហិ ច ។
មហារហំ បញ្ញាបយឹ អាសនំ ពុទ្ធយុត្តកំ
បទុមុត្តរោ លោកវិទូ ទេវទេវោ នរាសភោ ។
ភិក្ខុសង្ឃបរិព្យូឡ្ហោ មម ទ្វារំ ឧបាគមិ
បច្ចុគ្គន្ត្វាន សម្ពុទ្ធំ លោកនាថំ យសស្សិនំ ។

---

១ ម. ភទ្ទកញ្ញ ។



ពួកជនទាំងពួង តែងនាំយកនូវសត្តុផង នំឈ្មោះបកកៈផង អាមិសៈ ទឹកដមនិងភោជនផង ដល់ព្រះសាស្ដា ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។ ឯខ្ញុំក៏និមន្តនាំនិមន្តព្រះពុទ្ធ ដ៏ប្រសើរផង ព្រះសង្ឃ ដ៏ប្រសើរផង ហើយនឹងឲ្យទាន ដល់ព្រះសម្ពុទ្ធ ជាទេវតាដ៏ក្រៃលែង ជាងទេវតា ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ពួកជនទាំងនុះ ដែលខ្ញុំបានទៅឲ្យនិមន្ត ក៏បាននិមន្តព្រះតថាគតផង ភិក្ខុសង្ឃទាំងអស់ ជាបុញ្ញក្ខេត្តដ៏ប្រសើរផង ។ ខ្ញុំបានក្រាលបល្ល័ង្ក មានថ្លៃមួយសែន ជាវិការៈនៃមាស ក្រាលឈ្មោះគោណកៈ ព្រមដោយក្រាលញាត់គ ក្រាលធ្វើដោយរោមសត្វ ជាដាច់ក្ដោមផង ក្រាលដែលធ្វើដោយសម្បកឈើ ក្រាលដែលត្បាញដោយអំបោះផង ។ ខ្ញុំក្រាលនូវអាសនៈ មានថ្លៃដ៏ប្រសើរគួរដល់ព្រះពុទ្ធ ឯព្រះបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ជាទេវតាប្រសើរជាងទេវតា ជានរាសភៈ ទ្រង់ចោមរោមដោយភិក្ខុសង្ឃ ស្ដេចចូលមកកាន់ទ្វារផ្ទះរបស់ខ្ញុំ ខ្ញុំក្រោកទទួលព្រះសម្ពុទ្ធ ជាលោកនាថ ដ៏ទ្រង់យស ។

បសន្នចិត្តោ សុមនោ អភិនាមយិំ សង្ឃំ
ភិក្ខូនំ សតសហស្សំ ពុទ្ធញ្ច លោកនាយកំ ។
បសន្នចិត្តោ សុមនោ បរមន្នេន តប្បយិំ
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ ។
ភិក្ខុសង្ឃេ ឋិតោ សត្ថា ឥមា គាថា អភាសថ
យេនិទំ អាសនំ ទិន្នំ សោវណ្ណំ គោណកត្ថតំ ។
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ
ចតុសត្តតិក្ខត្តុំ សោ ទេវរជ្ជំ ករិស្សតិ ។
អនុភោស្សតិ សម្បត្តិំ អច្ឆរាហិ បុរក្ខតោ
បទេសរជ្ជំ សហស្សំ វសុធំ អាវសិស្សតិ ។
ឯកបញ្ញាសក្ខត្តុញ្ច ចក្កវត្តី ករិស្សតិ ។
សព្វាសុ ភវយោនីសុ ឧច្ចាកុលី ភវិស្សតិ ។



ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ញុំាងភិក្ខុសង្ឃមួយសែនអង្គ ទាំងព្រះពុទ្ធជាលោកនាយក ឲ្យចូលមកកាន់ផ្ទះរបស់ខ្លួន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ (ញុំាងព្រះសម្ពុទ្ធនិងភិក្ខុសង្ឃ) ឲ្យឆ្អែតស្កប់ស្កល់ ដោយភោជនដ៏ឧត្តម ព្រះបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយត្រាស់នូវគាថាទាំងនេះថា

បុគ្គលណា ឲ្យអាសនៈ ជាវិការៈនៃមាស ក្រាលដោយកម្រាលគោណកៈនេះ តថាគតនឹងសម្តែងសរសើរនូវបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនោះ នឹងសោយទេវរជ្ជសម្បត្តិ អស់ ៧៤ ដង នឹងសោយទិព្វសម្បត្តិ មានពួកស្រីអប្សរហែហមកោម នឹងបានគ្រប់គ្រងផែនដី បានជាស្តេចក្នុងប្រទេស មួយពាន់ដង ។ នឹងកើតជាស្តេចចក្រពត្តិ អស់ ៥១ ដង នឹងបានជាអ្នកមានត្រកូលខ្ពស់ ក្នុងកំណើតដែលមានក្នុងភពទាំងពួង ។

តតិយំ ភទ្ទិយកាឡិគោធាយបុត្តត្ថេរាបទានំ

សោ ច បច្ឆា បព្វជិត្វា សុក្កមូលេន ចោទិតោ
ភទ្ទិយោ នាម នាមេន ហេស្សតិ សត្ថុ សាវកោ ។
វិវេកមនុយុត្តោម្ហិ បន្តសេននិសេវហំ(១)
ផលំ ចាធិគតំ សព្វំ(២) ចត្តក្លេសោម្ហិ អជ្ជហំ ។
មម សព្វំ អភិញ្ញាយ សព្វញ្ញូ លោកនាយកោ
ភិក្ខុសង្ឃេ និសីទិត្វា ឯតទគ្គេ ឋបេសិ មំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភទ្ទិយោ កាឡិគោធាយ-
បុត្តោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភទ្ទិយស្ស កាឡិគោធាយបុត្តត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. បន្តសេនាសនំ ។ ២ ម. ផលញ្ចាធិគតំ សព្វំ ។



ភទ្ទិយកាឡិគោធាយបុត្តត្ថេរាបទាន ទី ៣

លុះកាលជាខាងក្រោយ កុលបុត្តនោះ ត្រូវកុសលមូលដាស់តឿន ក៏ចេញបួស តាមនាមជាភទ្ទិយៈ នឹងបានជាសាវ័ករបស់ព្រះសាស្តា ។

ខ្ញុំប្រកបរឿយ ៗ នូវវិវេក អាស្រ័យនៅក្នុងសេនាសនៈដ៏ស្ងាត់ ផលទាំងអស់ ខ្ញុំបានសម្រេចហើយ ក្នុងថ្ងៃនេះខ្ញុំមានកិលេសលះបង់ហើយ ។ ព្រះសព្វញ្ញូជាលោកនាយក ទ្រង់ជ្រាបនូវហេតុសព្វគ្រប់ របស់ខ្ញុំ ទើបទ្រង់គង់ក្នុងភិក្ខុ-សង្ឃ ហើយតាំងខ្ញុំ ក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភទ្ទិយកាឡិគោធាយបុត្តត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភទ្ទិយកាឡិគោធាយបុត្តត្ថេរាបទាន ។

## ឆដ្ឋំ សន្និដ្ឋាបកត្ថេរាបទានំ

[៦៦] អរញ្ញេ កុដិកំ កត្វា វសាមិ បព្វតន្តរេ
លាភាលាភេន សន្តុដ្ឋោ យសេន អយសេន ច ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
ភិក្ខុសតសហស្សេហិ(១) អាគច្ឆិ មម សន្តិកេ ។
ឧបាគតំ មហានាគំ ជលជុត្តមនាមកំ
តិណសន្ថរំ បញ្ញាបេត្វា អទាសឹ សត្ថុនោ អហំ ។
បសន្នចិត្តោ សុមនោ អាមណ្ឌំ ហរិយញ្ចហំ
អទាសឹ ឧជុភូតស្ស វិប្បសន្នេន ចេតសា ។
កប្បេតោ សតសហស្សេ យំ ផលមទទឹ តទា
ទុគ្គតឹ នាភិជានាមិ អាមណ្ឌស្ស ឥទំ ផលំ ។
ឯកបញ្ញាសកប្បម្ហិ ឯកោ អាសិ អរិន្ទមោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។

១ ម. វសីសតសហស្សេហិ ។



## សន្និដ្ឋាបកត្ថេរាបទាន ទី ៦

[៦៦] ខ្ញុំធ្វើខ្ទមក្នុងព្រៃ ត្រង់ចន្លោះភ្នំ ហើយនៅ ជាអ្នកសន្តោស ដោយលាភនិងឥតលាភផង ដោយយសនិងឥតយសផង ។ ព្រះសម្ពុទ្ធបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ទទួលនូវគ្រឿងបូជា ទ្រង់ស្តេចចូលមកក្នុងសំណាក់របស់ខ្ញុំ ជាមួយនឹងភិក្ខុសង្ឃ ប្រមាណមួយសែនអង្គ ។ ព្រះសម្ពុទ្ធ ជាមហានាគ ព្រះនាមបទុមុត្តរៈ ស្តេចយាងមកដល់ហើយ ខ្ញុំក្រាលកម្រាលស្មៅថ្វាយព្រះសាស្តា ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែល្ហុងប្រេងផង មឹគផង ចំពោះព្រះសាស្តា ទ្រង់មានសន្តានត្រង់ ដោយចិត្តដែលជ្រះថ្លា ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែល្ហុងប្រេង ។ ក្នុងកប្បទី៥១ ខ្ញុំបានជាស្តេចមួយព្រះអង្គ ឈ្មោះអរិន្ទមៈ ជាស្តេចចក្រពត្តិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ។
ឥត្ថំ សុទំ អាយស្មា សន្និដ្ឋាបកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

សន្និដ្ឋាបកត្ថេរស្ស អបទានំ សមត្តំ ។

# បញ្ចមំ បញ្ចហត្ថិយត្ថេរាបទានំ

[៤៧] សុមេធោ នាម សម្ពុទ្ធោ គច្ឆតេ អន្តរាបណេ
ឱក្ខិត្តចក្ខុ មិតភាណី សតិមា សំវុតិន្ទ្រិយោ ។
បញ្ច ឧប្បលហត្ថានិ អាវេឡត្ថមកាសុ មេ
តេន ពុទ្ធំ អបូជេសឹ បសន្នោ សេហិ បាណិភិ។
អារោបិតា ច តេ បុប្ផា ឆទនំ អស្សុ សត្ថុនោ
សមាធិំសុ មហានាគំ សិស្សា អាចរិយំ យថា[១]។

១ ម. យស្សា ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសន្និដ្ឋាបកត្ថេរ មានអាយុ បានសំដែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សន្និដ្ឋាបកត្ថេរាបទាន ។

# បញ្ចហត្ថិយត្ថេរាបទាន ទី ៥

[៤៧] ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ទ្រង់សង្រួមចក្ខុ ពោលពាក្យល្មមកំណត់ មានស្មារតី សង្រួមឥន្ទ្រិយ ទ្រង់និមន្តទៅក្នុងចន្លោះកណ្ដាលផ្សារ ។ ពួកជនទើបនាំឧប្បល ៥ ក្ដាប់ ឲ្យជាគ្រឿងប្រដាប់ក្បាលសម្រាប់ខ្ញុំ ខ្ញុំមានចិត្តជ្រះថ្លា បានយកគ្រឿងប្រដាប់ក្បាលនោះ បូជាព្រះពុទ្ធដោយដៃរបស់ខ្លួន ។ ផ្កាទាំងនោះ ដែលខ្ញុំលើកឡើងហើយ ក៏ទៅជាគ្រឿងបាំងម្លប់ ថ្វាយព្រះសាស្ដានោះ (ពោមរោម) ព្រះមហានាគក៏សមាធិ ដូចជាសិស្ស (ពោមរោម) អាចារ្យដូច្នោះដែរ ។

តិំសកប្បសហស្សម្ហិ យំ បុប្ផមភិរោបយិំ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ វីសកប្បសតេ អហេសុំ បញ្ច ខត្តិយា
ហត្ថិយា នាម នាមេន ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បញ្ចហត្ថិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បញ្ចហត្ថិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ បទុមច្ឆទនិយត្ថេរាបទានំ

(៤៨) និព្វុតេ លោកនាថម្ហិ វិបស្សិម្ហគ្គបុគ្គលេ
សុផុល្លំ បទុមំ គយ្ហ ចិតមារោបយិំ អហំ ។
អារោចិតេ ចិតកេ វេហាសំ នភមុគ្គមិ
អាកាសេ ឆទនំ កត្វា ចិតកម្ហិ អធារយិំ ។



ក្នុងកប្បទី ៣០.០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៤.០០០ អំពីកប្បនេះ ខ្ញុំបានជាក្សត្រិយ៍ ៥ អង្គ ព្រះនាមហត្ថិយៈដូចគ្នា ជាស្ដេចចក្រពត្តិ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចហត្ថិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បញ្ចហត្ថិយត្ថេរាបទាន ។

## បទុមច្ឆទនិយត្ថេរាបទាន ទី ៦

(៤៨) កាលព្រះលោកនាថ ជាអគ្គបុគ្គល ព្រះនាមវិបស្សី ទ្រង់បរិនិព្វានហើយ ខ្ញុំយកផ្កាឈូកដែលរីកល្អ លើកតំកល់លើជើងថ្ករ ។ លុះខ្ញុំលើកជើងថ្ករឡើង ផ្កាក៏អណ្ដែតក្រសែកទៅឯអាកាស ជាទីកំពូលនៃពួកសត្វស្លាប ធ្វើជាដំបូលបិទបាំងកំដៅថ្ងៃនាអាកាស ខ្ញុំក៏បានទ្រទ្រង់ជើងថ្ករនោះ ។

ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
សត្តតាឡីសិតោ កប្បេ បទុមិស្សរនាមកោ
ចាតុរន្តោ វិជិតាវី ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បទុមច្ឆទនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទុមច្ឆទនិយត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ សយនទាយកត្ថេរាបទានំ

(៩) សិទ្ធត្ថស្ស ភគវតោ មេត្តចិត្តស្ស តាទិនោ
សយនគ្គំ មយា ទិន្នំ ទុស្សភណ្ឌេន អត្ថតំ ។
បដិគ្គហេសិ ភគវា កប្បិយំ សយនាសនំ
ឧដ្ឋាយ សយនា តម្ហា វេហាសំ ឧគ្គមី ជិនោ ។



ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធ-បូជា ។ ក្នុងកប្បទី ៤៧ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ មាននាមជាបទុមិស្សរៈ ច្រើនឈ្នះសត្រូវ មានទីបំផុតទាល់នឹងសមុទ្រទាំង ៤ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមច្ឆទនិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទុមច្ឆទនិយត្ថេរាបទាន ។

## សយនទាយកត្ថេរាបទាន ទី ៧

(៦៩) ខ្ញុំថ្វាយទីព្រះបន្ទំដ៏ប្រសើរ ដែលក្រាលដោយសំពត់ ចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ទ្រង់មានមេត្តាចិត្ត មិនញាប់ញ័រដោយលោកធម៌ ។ ព្រះមានព្រះភាគ ទ្រង់ទទួលកប្បិយសយនាសនៈហើយ ព្រះជិនស្រី ទ្រង់ក្រោកឡើងអំពីទីព្រះបន្ទំនោះ ហើយទ្រង់ហោះឡើងទៅឯអាកាស ។

ចតុន្នវុតេ ឥតោ កប្បេ យំ សយនមទាសហំ
ទុគ្គតឹ នាភិជានាមិ សយនស្ស ឥទំ ផលំ ។
ឯកបញ្ញាសិតោ កប្បេ វរុណោ ទេវសវ្ហយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា សយនទាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

សយនទាយកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ បទុមទាយកត្ថេរាបទានំ

(៥០) អត្ថទស្សិស្ស មុនិនោ លោកជេដ្ឋស្ស តាទិនោ
ឥដ្ឋកាហិ ចិនិត្វាន ចង្កមំ ការយឹ អហំ ។
ឧច្ចតោ បញ្ចរតនំ ចង្កមំ សាធុ មាបិតំ
អាយាមតោ ហត្ថសតំ ភាវនីយំ មនោរមំ ។



ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន ថ្វាយទីសយនៈ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទីសយនៈ ។ ក្នុងកប្បទី ៥១ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ ព្រះនាមវរុណទេវៈ ទ្រង់បរិបូណ៌ ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសយនទាយកត្ថេរ មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សយនទាយកត្ថេរាបទាន ។

## បទុមទាយកត្ថេរាបទាន ទី ៨

(៥០) ខ្ញុំបានធ្វើជាទីចង្ក្រមក្រាលឥដ្ឋ (ថ្វាយ) ចំពោះ ព្រះមុនី ព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ទ្រង់មិន ញាប់ញ័រដោយលោកធម៌ ។ ទីចង្ក្រមនោះ មានកំពស់ ៥០ ហត្ថក្រពុំ បណ្តោយ ១០០ ហត្ថ ជាទីគួរសរសើរ គួររីករាយនៃចិត្ត ខ្ញុំបានកសាងហើយ ដោយប្រពៃ ។

បដិគ្គហេសិ ភគវា  អត្ថទស្សី នរុត្តមោ
ហត្ថេន បុប្ផំ គយ្ហ  ឥមា គាថា អភាសថ ។
ឥមិនា បុប្ផទានេន  ចិត្តំ សុការេន ច
សត្តរតនសម្បន្នំ  បុប្ផំ អនុភោស្សតិ ។
តីណិ កប្បានិ ទេវេសុ  ទេវរជ្ជំ ករិស្សតិ
អនុភោស្សតិ សម្បត្តិំ  អច្ឆរាហិ បុរក្ខតោ ។
មនុស្សលោកំ អាគន្ត្វា  រាជា រដ្ឋេ ករិស្សតិ
តិក្ខត្តុំ ចក្កវត្តី ច  មហិយា សោ ករិស្សតិ ។
អដ្ឋារសេ កប្បសតេ  យំ កម្មមករិំ តទា
ទុគ្គតិំ នាភិជានាមិ  ចន្ទនស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។



ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ដ៏ប្រសើរជាងពួកនរៈ ទ្រង់បានទទួល ហើយទ្រង់កាន់យកនូវផ្កា ដោយព្រះហស្ត ហើយសម្តែងនូវគាថាទាំងនេះថា

ដោយការឲ្យនូវផ្កានេះផង ដោយការធ្វើចិត្តឲ្យល្អនេះផង បុគ្គលនេះ នឹងបានទទួលនូវផ្កា ដ៏បរិបូណ៌ដោយកែវ ៧ ប្រការ ។ កុលបុត្តនោះ នឹងគ្រប់គ្រងទេវរជ្ជ សោយទិព្វសម្បត្តិ ជាស្តេចនៃទេវតា ក្នុងទេវលោក មានពួកស្រីអប្សរចោមរោម អស់ ៣ កប្ប ។ លុះត្រឡប់មកកាន់មនុស្សលោក នឹងបានជាស្តេចក្នុងដែន កុលបុត្តនោះ នឹងបានជាស្តេចចក្រពត្តិ លើផែនដី អស់ ៣ ដង ។

ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំ ធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃខ្លឹម ចន្ទន៍ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ចន្ទមាលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចន្ទមាលិយត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ សុភទ្ទត្ថេរាបទានំ

៩១] បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
ជនតំ ឧទ្ធរិត្វាន និព្វាយតិ មហាយសោ ។
និព្វាយន្តេ ច សម្ពុទ្ធេ ទសសហស្សី អកម្បថ
ជនកាយោ មហា អាសិ ទេវា សន្និបតុំ តទា ។
ចន្ទនំ បូរយិត្វាន តគរមល្លិកាហំ ច
ហដ្ឋោ ហដ្ឋេន ចិត្តេន អារោបេសិំ នរុត្តមំ ។
មម សង្កប្បមញ្ញាយ សត្ថា លោកេ អនុត្តរោ
និបន្នកោវ សម្ពុទ្ធោ ឥមា គាថា អភាសថ ។



បានឮថា ព្រះចន្ទមាលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចន្ទមាលិយត្ថេរាបទាន ។

## សុភទ្ទត្ថេរាបទាន ទី៩

[៩១] ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវត្រៃលោក គួរទទួលគ្រឿងបូជា មានយសច្រើន ទ្រង់ស្រោចស្រង់នូវប្រជុំជន ហើយទ្រង់បរិនិព្វាន ។ កាលព្រះសម្ពុទ្ធបរិនិព្វាន លោកធាតុមួយម៉ឺន ក៏ញាប់ញ័រ ពួកជនច្រើន និងពួកទេវតា ក៏ប្រជុំគ្នា ក្នុងកាលនោះ ។ ខ្ញុំបានញ៉ាំងទីនោះឲ្យពេញ ដោយខ្លឹមចន្ទន៍ ខ្លឹមក្រឹស្នា និងខ្លឹមក្លាំពាក់ ខ្ញុំមានចិត្តត្រេកអររីករាយ បានលើកឡើង នូវព្រះសម្ពុទ្ធ ទ្រង់ប្រសើរជាងពួកនរៈ ។ ព្រះសាស្តា ជាបុគ្គលប្រសើរផុតក្នុងលោក ទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំ ព្រះសម្ពុទ្ធ ទ្រង់ផ្ទំសម្តែងនូវគាថាទាំងនេះថា

យោ មេ បដ្ឋមកោ កាលេ ភត្តមាលេន ជានយំ
តមហំ ភិក្ខុយំ សង្ឃម្ហិ សុណាថ មម ភាសតោ ។
ឥតោ ចុតោ អយំ ហោសោ តុសិតកាយំ គមិស្សតិ
តត្ថ រជ្ជំ ការិត្វាន ជម្ពុទីបំ សោ គមិស្សតិ ។
ឯតេនេវ ឧបាយេន ជត្វា មលិំ វុត្តមំ
សកកម្មាភិរទ្ធោ សោ សម្បត្តិំ អនុភោស្សតិ ។
បុនាបិ តុសិតេ កាយេ និព្វត្តិស្សតិយំ នរោ
តម្ហា កាយា ចវិត្វាន មនុស្សត្តំ គមិស្សតិ ។
សក្យបុត្តោ មហានាគោ អគ្គោ លោកេ សទេវកេ
ពោធយិត្វា ពហូ សត្តេ និព្វាយិស្សតិ ចក្ខុមា ។
តទា សោ បគតោ សន្តោ សុក្កមូលេន ចោទិតោ
ឧបសង្កម្ម សម្ពុទ្ធំ បព្វជិស្សតិ តទា ។





ក្នុងកាលជាទីបំផុត នៃជន្មាយុ របស់តថាគត បុរសណា បានបំពេញនូវទឹកដល់តថាគត ដោយថ្វាយនូវគន្ធក្រអូប តថាគតនឹងសម្ដែងសរសើរនូវបុរសនោះ អ្នកទាំងឡាយ ចូរស្ដាប់តថាគតសម្ដែងចុះ ។ បុរសនោះ លុះច្យុតចាកអត្តភាពនេះ នឹងទៅកាន់ពួកទេវតា ក្នុងឋានតុសិត សោយរាជសម្បត្តិក្នុងឋានតុសិតនោះ ហើយនឹងទៅកាន់ឋានជម្ពូទ្វីបទៀត ។ បុរសនោះ បាននូវផែនដីដ៏ឧត្ដមប្រសើរ ដោយឧបាយនុ៎ះឯង ជាអ្នកត្រេកអរនូវកម្មរបស់ខ្លួន នឹងទទួលនូវសម្បត្តិ ។ នរជននេះ នឹងកើតក្នុងពួកទេវតា ក្នុងឋានតុសិតម្ដងទៀត លុះច្យុតចាកពួកទេវតា ក្នុងឋានតុសិតនោះ នឹងមកកាន់អត្តភាពជាមនុស្ស ។ ព្រះសក្យបុត្ត ជាមហានាគ ជាអគ្គបុគ្គល ក្នុងលោក ព្រមទាំងទេវលោក ទ្រង់មានបញ្ញាចក្ខុ បានញុំាងពួកសត្វច្រើន ឲ្យត្រាស់ដឹងហើយ នឹងបរិនិព្វាន ។ ក្នុងកាលនោះ បុរសនោះ បានចូលទៅ មានចិត្តស្ងប់រម្ងាប់ មានកុសលមូលដាស់តឿន ហើយក៏ចូលទៅគាល់ព្រះសម្ពុទ្ធ នឹងសូមបួស ក្នុងកាលនោះ ។

ហាសយិត្វាន សម្ពុទ្ធោ សព្វញ្ញូ លោកនាយកោ
បុព្វកម្មមភិញ្ញាយ(១) សច្ចានិ វិវរិស្សតិ ។
អាគន្ត្វា ច អយំ ចត្តោ តុដ្ឋោ ឯកគ្គមានសោ
សត្ថារំ អភិវាទេត្វា បព្វជ្ជំ យាចយិស្សតិ ។
បសន្នមានសំ ទិស្វា សកកម្មេន តោសិតំ
បព្វជិស្សតិ សោ ពុទ្ធោ អគ្គធម្មស្ស(២) កោវិទោ ។
វាយមិត្វានយំ បោសោ សម្មាសម្ពុទ្ធសាសនេ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សត្យនាសវោ ។

អដ្ឋមំ ភាណវារំ ។

បុព្វកម្មេន សំយុត្តោ ឯកគ្គោ សុសមាហិតោ
ពុទ្ធស្ស ឱរសោ បុត្តោ ធម្មតោម្ហិ(៣) សុនិម្មិតោ ។
ធម្មរាជំ ឧបាគម្ម អាបុច្ឆិំ បញ្ហមុត្តមំ
កថយន្តោ ច មេ បញ្ហំ ធម្មសោតំ ឧបានយិ ។

---

១ ម. បុញ្ញកម្មំ បរិញ្ញាយ ។ ២ ម. អគ្គធម្មស្ស ។ ៣ ម. ធម្មតោម្ហិ ។



ព្រះសម្ពុទ្ធ ជាសព្វញ្ញូ លោកនាយក ទ្រង់ញុំាងឲ្យកើតញញឹមហើយ នឹងបើកនូវសច្ចធម៌ទាំងឡាយ ព្រោះទ្រង់ជ្រាបនូវបុព្វកម្ម ។ បុរសនោះ ក្រោកប្រណម្យនេះហើយ ជាអ្នកត្រេកអរ មានចិត្តទល់ឯក នឹងថ្វាយបង្គំព្រះសាស្ដា ហើយសូមផ្នួស ។ ព្រះពុទ្ធនោះ ទ្រង់ជាបុគ្គលឈ្លាសក្នុងធម៌ដ៏ប្រសើរ ទ្រង់ឃើញបុរសនោះ មានចិត្តជ្រះថ្លា ត្រេកអរដោយកម្មរបស់ខ្លួនហើយ នឹងទ្រង់បំបួស ។ បុរសនេះ ព្យាយាមក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ចប់ ភាណវារៈ ទី ៨ ។

ខ្ញុំប្រកបព្រមហើយ ដោយបុព្វកម្មរបស់ខ្លួន មានចិត្តមូលតែមួយ មានចិត្តតាំងមាំ ជាធម្មនិម្មិត ជាបុត្រកើតអំពីទ្រូងរបស់ព្រះសម្មាសម្ពុទ្ធ ។ ខ្ញុំចូលទៅគន្ធិយ ជិតព្រះពុទ្ធជាធម្មរាជ ហើយសួរប្រស្នាដ៏ប្រសើរ ឯព្រះអង្គកាលនឹងសម្ដែង នូវប្រស្នាចំពោះខ្ញុំ ទ្រង់នាំមកនូវធម្មសោតៈ ។

តស្សាហំ ធម្មមញ្ញាយ វិហាសឹ សាសនេ រតោ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
សតសហស្សេ ឥតោ កប្បេ ជលជុត្តមនាយកោ
និព្វាយិ អនុបាទានោ ទីបោវ តេលសង្ខយា ។
សត្តយោជនិកំ អាសិ ថូបញ្ច រតនាមយំ
ធជំ តត្ថ អបូជេសឹ សព្វភទ្ទំ មនោរមំ ។
កស្សបស្ស ច ពុទ្ធស្ស តិស្សោ នាមគ្គសាវកោ
បុត្តោ មេ ឱរសោ អាសិ ទាយាទោ ជិនសាសនេ ។
តស្ស ហីនេន មនសា វាចំ ភាសឹ អភទ្ទកំ
តេន កម្មវិបាកេន បច្ឆា មេ អាសិ ភទ្ទកំ ។
ឧបវត្តនេ សាលវនេ បច្ឆិមេ សយនេ មុនិ
បព្វាជេសិ មហាវីរោ ហិតោ ការុណិកោ ជិនោ ។
អជ្ជេវ ទានិ បព្វជ្ជា អជ្ជេវ ឧបសម្បទា
អជ្ជេវ បរិនិព្វានំ សម្មុខា ទ្វិបទុត្តមេ ។



ខ្ញុំដឹងនូវធម៌ របស់ព្រះសម្ពុទ្ធនោះហើយ ត្រេកអរនឹងសាសនា កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ គន្លងកប្បទីមួយសែន អំពីភទ្ទកប្បនេះ ព្រះនាយក ព្រះនាមបទុមុត្តរៈ ទ្រង់បរិនិព្វាន មិនមានឧបាទាន ដូចប្រទីបដែលរលត់ ព្រោះអស់ប្រេង ។ ព្រះស្តូបជាវិការៈនៃកែវ ប្រកបដោយយោជន៍ ៧ ណា ខ្ញុំបានបូជាទង់ដ៏ល្អ ជាទង់ទាំងអស់ ជាទីរីករាយនៃចិត្ត ចំពោះព្រះស្តូបនោះ ។ កូនដែលកើតអំពីទ្រូងរបស់ខ្ញុំ ឈ្មោះតិស្សៈ ជាអគ្គសាវក របស់ព្រះពុទ្ធ ព្រះនាមកស្សបៈ ជាទាយាទក្នុងសាសនានៃព្រះជិនស្រី ។ ខ្ញុំមានចិត្តថោកទាប បានពោលពាក្យមិនពីរោះ ដល់ព្រះតិស្សៈនោះ ព្រោះផលកម្មប៉ុណ្ណោះ ទើបខ្ញុំមានសេចក្តីល្អ ក្នុងកាលជាខាងក្រោយបំផុត ។ ព្រះមុនីទ្រង់មានព្យាយាមធំ ស្ថិតនៅលើគ្រែជាទីបង្អស់ មានសេចក្តីករុណា ទ្រង់ឈ្នះកិលេស បានបំបួសខ្ញុំ ក្នុងឧបវត្តនៈ ក្នុងសាលវ័ន ជាទីសម្រាប់ចេញចូល ។ ថ្ងៃនេះ បព្វជ្ជា (របស់ខ្ញុំ) មានក្នុងថ្ងៃនេះ ឧបសម្បទា ក៏មានក្នុងថ្ងៃនេះ បរិនិព្វានក៏មានក្នុងថ្ងៃនេះ ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសម្ពុទ្ធទ្រង់ឧត្តមជាងសត្វជើងពីរ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សុភទ្ទោ ថេរោ ឥមា គា-
ថាយោ អភាសិត្ថាតិ ។

សុភទ្ទត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ បុត្តត្ថេរាបទានំ

(៤៦) សិទ្ធត្ថស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
អគ្ឃិយំ ការយិត្វាន ជាតិបុប្ផេហិ ឆាទយិំ ។
ឆិដ្ឋបេត្វាន តំ បុប្ផំ ពុទ្ធស្ស អភិឆាទយិំ(១)
បុប្ផាវសេសំ បគ្គយ្ហ ពុទ្ធស្ស អភិរោបយិំ ។
កាញ្ចនគ្ឃិយសង្កាសំ ពុទ្ធំ លោកគ្គនាយកំ
បសន្នចិត្តោ សុមនោ បុប្ផគ្ឃិយមុបានយិំ ។

១ ម. ឆាទយិំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុភទ្ទត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុភទ្ទត្ថេរាបទាន ។

## បុត្តត្ថេរាបទាន ទី ១០

(៤៦) ខ្ញុំធ្វើចេតិយ ស្រោបដោយផ្កាម្លិះទាំងឡាយ បូជាចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រ ដោយលោកធម៌ ។ លុះខ្ញុំរៀបចំស្រេចហើយ ទើបបង្អោនថ្វាយផ្កានោះ ចំពោះព្រះពុទ្ធ ហើយយកផ្កាដ៏សេសបន្ថែមថ្វាយទៀត ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ នាំចេតិយផ្កាទៅថ្វាយ ចំពោះព្រះពុទ្ធ ជាអគ្គនាយកក្នុងលោក ព្រះអង្គប្រាកដស្មើដោយចេតិយមាស ។

វិតិណ្ណភាវេត្វា សម្ពុទ្ធោ ទិណ្ណាយេហិ បុរក្ខតោ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
ចិត្វាកន្ទំ បកយន្តំ យោ មេ បុប្ផក្ខិយំ អទា
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
ឥតោ ចុតោ អយំ បោសោ ទេវសង្ឃបុរក្ខតោ
ជាតិបុប្ផេហិ បរិកិណ្ណោ ទេវលោកំ គមិស្សតិ ។
ឧព្វិទ្ធំ ភវនំ តស្ស សោវណ្ណំ មណីមយំ
ព្យម្ហ តាតុករិស្សន្តិ បុញ្ញកម្មបការិតា ។
ចតុសត្តតិក្ខត្តុំ សោ ទេវរជ្ជំ ករិស្សតិ
អនុភោស្សតិ សម្បត្តឹ អច្ឆរាហិ បុរក្ខតោ ។
បថព្យា រជ្ជំ តិសតំ វសុធំ អាវសិស្សតិ
បញ្ចសត្តតិក្ខត្តុញ្ច ចក្កវត្តិ ភវិស្សតិ ។



ព្រះសម្ពុទ្ធ មានសេចក្តីសង្វេគនូវចេតិយហើយ មានពួកព្រះខីណាស្រពដែលមានគុណធំផុតចោមរោមហើយ ព្រះអង្គគង់នៅកណ្តាលភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថា

កុលបុត្រណា បានថ្វាយផ្កាជាតិ នូវចេតិយដែលធ្វើជាយថ្ក មានចិត្តជ្រះថ្លាថ្វាយទៅ តថាគតនឹងសម្តែងសរសើរ នូវកុលបុត្រនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ បុរសនេះ លុះច្យុតចាកអត្តភាពនេះទៅ នឹងទៅកើតក្នុងទេវលោក មានពួកទេវតាចោមរោម ជាអ្នកបរិបូណ៌ដោយផ្កាម្លិះ ។ វិមានរបស់កុលបុត្រនោះ ខ្ពស់ជាងការៈនៃមាស និងកែវមណី ប្រាសាទទាំងឡាយ ដែលបុញ្ញកម្មតាក់តែងហើយ នឹងកើតប្រាកដ ។ កុលបុត្រនោះ នឹងសោយទេវរាជ្យ នឹងសោយទិព្វសម្បត្តិ មានពួកស្រីអប្សរចោមរោម អស់ ៧៤ ដង ។ នឹងបានសោយរាជសម្បត្តិ លើផែនដី គ្រប់គ្រងផែនដី អស់ ៣០០ ដង នឹងបានជាស្តេចចក្រពត្តិ អស់ ៧៥ ដង ។

ខត្តិយោ នាម នាមេន ហេស្សតិ មនុជាធិបោ
អនុភោត្វាន តំ បុញ្ញំ សកកម្មូបសំហិតោ ។
វិនិបាតំ អគន្ត្វាន មនុស្សត្តំ គមិស្សតិ
ហិរញ្ញំ តស្ស និចិតំ កោដិសតំបិ អនប្បកំ ។
និព្វត្តិស្សតិ យោនិម្ហិ ព្រាហ្មណោ សោ ភវិស្សតិ
វទ្ធគុស្ស សុតោ ធីមា សារិយា និរសោ បិយោ ។
សោ ច បច្ឆា បព្វជិត្វា អង្គីរសស្ស សាសនេ
ទូស្សកុត្តោតិ នាមេន ហេស្សតិ សត្ថុ សាវកោ ។
សាមណេរោ សោ សន្តោ ខីណាសវោ ភវិស្សតិ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សត្យនាសវោ ។
ឧបដ្ឋហិំ មហាវីរំ អញ្ញេ ច បេសលេ ពហូ
តាតរមេវុបដ្ឋាសឹ ឧត្តមត្ថស្ស បត្តិយា ។



កុលបុត្តនោះ នឹងកើតជាក្សត្រ ជាអធិបតីនៃមនុស្ស មាននាមជាខុជ្ជយៈ អាស្រ័យនូវបុញ្ញកម្មរបស់ខ្លួន ហើយនឹងនូវផលបុណ្យនោះ ។ កុលបុត្តនោះនឹងមិនទៅយកកំណើតជាវិនិបាតឡើយ ទៅយកអត្តភាពតែជាមនុស្ស កុលបុត្តនោះ បានសម្បត្តិប្រាក់ទុកច្រើន រាប់រយកោដិ ។ កុលបុត្តនោះ នឹងកើតក្នុងកំណើតជាព្រាហ្មណ៍ ជាអ្នកចេះដឹង មានប្រាជ្ញា ជាបុត្រជាទីស្រឡាញ់នៃវទ្ធព្រាហ្មណ៍ និងនាងសារីព្រាហ្មណី ។ លុះកាលជាខាងក្រោយ កុលបុត្តនោះមាននាមជាទូស្សទុត្តៈ នឹងបានបួសក្នុងសាសនា របស់ព្រះសម្ពុទ្ធ ជាអង្គីរសនឹងបានជាសាវ័ក របស់ព្រះសាស្តា ។ ទូស្សទុត្តៈនោះ ជាសាមណេរ មានសន្តានស្ងប់ស្ងាត់ បានជាព្រះខីណាស្រព កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំបានបម្រើព្រះសម្ពុទ្ធ មានព្យាយាមធំផង បម្រើពួកភិក្ខុអកមានសីលជាទីស្រឡាញ់ដទៃច្រើនអង្គផង បម្រើព្រះថេរៈជាបិតានៃខ្ញុំផង ដើម្បីសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ។

ទសមំ ចុន្ទត្ថេរាបទានំ

ភាតរំ មេ ឧបដ្ឋហិត្វា  ធាតុំ បត្តម្ហិ ឱចិយ
សម្ពុទ្ធំ ឧបនាមេសិំ  លោកជេដ្ឋំ នរាសភំ ។
ឧភោ ហត្ថេហិ បគ្គយ្ហ  ពុទ្ធោ លោកេ សទេវកេ
សន្ទស្សយន្តោ តំ ធាតុំ  កិត្តយិ អគ្គសាវកំ ។
ចិត្តញ្ច សុវិមុត្តំ មេ  សទ្ធា មយ្ហំ បតិដ្ឋិតា
សព្វាសវេ បរិញ្ញាយ  វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ចុន្ទោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចុន្ទត្ថេរស្ស អបទានំ សមត្តំ ។



ចុន្ទត្ថេរាបទាន ទី ១០

ខ្ញុំបម្រើព្រះថេរៈជាបង របស់ខ្ញុំរួចហើយ រើសព្រះធាតុដាក់ក្នុងបាត្រ នាំមកថ្វាយព្រះសម្ពុទ្ធ ជាប្រធានក្នុងលោក ដ៏ប្រសើរជាងនរៈ ។ ព្រះពុទ្ធ (ព្រះអង្គប្រសើរ) ក្នុងលោក ព្រមទាំងទេវលោក ទ្រង់ទទួលដោយព្រះហស្តទាំងពីរ ហើយបង្ហាញនូវព្រះធាតុនោះ ទើបប្រកាសតាំងខ្ញុំ ជាអគ្គសាវក ។ ឯចិត្តរបស់ខ្ញុំ រួចស្រឡះហើយ សទ្ធារបស់ខ្ញុំ តម្កល់ខ្ជាប់ហើយ ខ្ញុំកំណត់ដឹង នូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចុន្ទត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចុន្ទត្ថេរាបទាន ។

## ឧទ្ទានំ

ឧបាលិ សោណោ ភទ្ទិ ច សន្និដ្ឋាបកហត្ថិយោ
ឆទនំ សេយ្យចង្កមំ សុភទ្ទោ ចុន្ទសវ្ហយោ
គាថាសតំ ច ចត្តាលីសំ ឆក្កស្សោ ច តទុត្តរិ ។

ឧបាលិវគ្គោ ឆដ្ឋោ ។

---



## ឧទ្ទាន

ឧបាលិត្ថេរាបទាន ១ សោណកោឡិវិសត្ថេរាបទាន ១ កាឡិគោធាយបុត្តត្ថេរាបទាន ១ សន្និធាបកត្ថេរាបទាន ១ បញ្ចហត្ថិយត្ថេរាបទាន ១ បទុមច្ឆទនិយត្ថេរាបទាន ១ សយនទាយកត្ថេរាបទាន ១ ចង្កមទាយកត្ថេរាបទាន ១ សុភទ្ទត្ថេរាបទាន ១ ចុន្ទត្ថេរាបទាន ១ ក្នុងវគ្គនោះ មាន គាថា ១៦៦ ។

ចប់ ឧបាលិវគ្គ ទី ៦ ។

---

## ឆដ្ឋោ វីជនីវគ្គោ

### បឋមំ វិធូបនទាយកត្ថេរាបទានំ

(៥៣) បទុមុត្តរពុទ្ធស្ស  លោកជេដ្ឋស្ស តាទិនោ
វីជនិកា មយា ទិន្នា  ទិបទិន្ទស្ស តាទិនោ ។
សកំ ចិត្តំ បសាទេត្វា  បគ្គហេត្វាន អញ្ជលឹ
សម្ពុទ្ធំ អភិវាទេត្វា  បក្កាមិំ ឧត្តរាមុខោ ។
វីជនឹ បគ្គហេត្វាន  សត្ថា លោកគ្គនាយកោ
ភិក្ខុសង្ឃេ ឋិតោ សត្ថា  ឥមា គាថា អភាសថ ។
ឥមិនា វីជនីទានេន  ចិត្តស្ស បណិធីហិ ច
កប្បានំ សតសហស្សំ  វិនិបាតំ ន គច្ឆតិ ។
អារទ្ធវីរិយោ បហិតត្តោ  ចេតោគុណសមាហិតោ
ជាតិយា សត្តវស្សោហំ  អរហត្តំ អបាបុណឹ ។
សដ្ឋិកប្បសហស្សម្ហិ  វីជមានសនាមកា
សោឡសាសិំសុ រាជានោ  ចក្កវត្តី មហព្វលា ។

## វីជនីវគ្គ ទី ៦

### វិធូបនទាយកត្ថេរាបទាន ទី ១

(៥៣) ខ្ញុំបានថ្វាយផ្លិតមួយ ចំពោះព្រះបទុមុត្តរៈ ជាច្បងក្នុងលោក មិនញាប់ញ័រដោយលោកធម៌ ទ្រង់ជាធំជាងសត្វជើងពីរ ប្រកបដោយតាទិគុណ ។ ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយផ្គងអញ្ជលីថ្វាយបង្គំព្រះសម្ពុទ្ធ ហើយបែរមុខទៅទិសខាងជើង ដើរចេញទៅ ។ ព្រះសាស្តា ជាអគ្គនាយកក្នុងលោក លុះទ្រង់ទទួលយកផ្លិតហើយ ក៏ឋិតនៅក្នុងភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថា

ព្រោះការថ្វាយផ្លិតនេះផង ព្រោះការតំកល់ចិត្តនេះផង កុលបុត្រនេះ នឹងមិនទៅកាន់កំណើតជាវិនិបាត អស់មួយសែនកប្ប ។

ខ្ញុំមានអាយុ ៧ ឆ្នាំ បានប្រារព្ធព្យាយាម បញ្ជូនចិត្តទៅកាន់ព្រះនិព្វាន តំកល់ខ្ជាប់ក្នុងចេតោគុណ ក៏បានដល់ព្រះអរហត្ត ។ ក្នុងកប្បទី ៦០.០០០ ខ្ញុំបានជាស្តេចចក្រពត្តិ ១៦ ដង ព្រះនាមវីជមានៈ ដូចៗ គ្នា ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា វិទ្ធបនទាយកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

វិទ្ធបនទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ សតរំសិយត្ថេរាបទានំ

(៨៤) ឧព្ពិទ្ធំ សេលមារុយ្ហ និសីទិ បុរិសុត្តមោ
បព្វតស្សាវិទូរម្ហិ ព្រាហ្មណោ មន្តបារគូ ។
ឧបវិដ្ឋំ មហាវីរំ ទេវទេវំ នរាសភំ
អញ្ជលិំ បគ្គហេត្វាន សន្ថវិំ លោកនាយកំ ។
ឯស ពុទ្ធោ មហាវីរោ វរធម្មប្បកាសកោ
ជលតិ អគ្គិក្ខន្ធោវ ភិក្ខុសង្ឃបុរក្ខតោ ។
មហាសមុទ្ទោវក្ខោភោ អណ្ណវោវ ទុរុត្តរោ
មិគរាជាវសម្ភីតោ ធម្មំ ទេសេតិ ចក្ខុមា ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវិទ្ធបនទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វិទ្ធបនទាយកត្ថេរាបទាន ។

## សតរំសិយត្ថេរាបទាន ទី២

(៨៤) ព្រះបទុមុត្តរសម្ពុទ្ធ ជាបុរសដ៏ប្រសើរ ទ្រង់ឡើងគង់លើភ្នំ ខ្ញុំជាព្រាហ្មណ៍ដល់ត្រើយនៃមន្ត នៅក្នុងទីជិតភ្នំនោះ ។ ខ្ញុំផ្គងអញ្ជលី សរសើរព្រះលោកនាយក ជាមហាវីរបុរស ជាទេវតាក្រៃលែងជាងទេវតា ទ្រង់ជាឧសភៈ ដែលស្តេចចូលមកជិតដោយពាក្យថា ព្រះពុទ្ធនេះមានព្យាយាមធំ ទ្រង់ប្រកាសធម៌ដ៏ប្រសើរ មានភិក្ខុសង្ឃចោមរោម រុងរឿងដូចគំនរភ្លើង ។ ព្រះសម្ពុទ្ធមានបញ្ញាចក្ខុ ទ្រង់ដូចមហាសមុទ្រមិនកំរើក ឬដូចអន្លង់ដែលគេឆ្លងបានដោយក្រ ឬក៏ដូចស្តេចម្រឹគដែលមិនតក់ស្លុត តែងសម្តែងធម៌ ។

មម សង្កប្បមញ្ញាយ បទុមុត្តរនាមកោ
ភិក្ខុសង្ឃេ ឋិតោ សត្ថា ឥមា គាថា អភាសថ ។
យោ ជាយំ អញ្ជលិំ ទិន្នា ពុទ្ធសេដ្ឋំ ច ថោមិតោ
តឹសកប្បសហស្សានិ ទេវរជ្ជំ ករិស្សតិ ។
កប្បសតសហស្សម្ហិ អង្គីរសសនាមកោ
វិវដ្ដច្ឆទោ[១] សម្ពុទ្ធោ ឧប្បជ្ជិស្សតិ តាវទេ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
សតរំសីតិ នាមេន អរហា សោ ភវិស្សតិ ។
ជាតិយា សត្តវស្សោហំ បព្វជឹ អនគារិយំ
សតរំសិម្ហិ នាមេន បភា និទ្ធាវតេ មម ។
មណ្ឌបេ រុក្ខមូលេ វា ឈាយី ឈានរតោ អហំ
ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។
សដ្ឋិកប្បសហស្សានិ ចតុរោ រោមនាមកា[២]
សត្តរតនសម្បន្នា ចក្កវត្តី មហព្វលា ។

---

១ ម. វិវដ្ដច្ឆទ្ទោ ។ ២ ម. ភទនាមកា ។





ព្រះសាស្តា ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំ ស្តេចគង់នៅកណ្តាលភិក្ខុសង្ឃ ហើយសំដែងនូវគាថាទាំងនេះថា

កុលបុត្តណា ថ្វាយអញ្ជលីនេះផង សរសើរព្រះពុទ្ធដ៏ប្រសើរផង កុលបុត្តនោះ នឹងសោយទេវរាជសម្បត្តិ អស់ ៣០ ពាន់កប្ប ។ ក្នុងទីបំផុតមួយសែនកប្ប ព្រះសម្ពុទ្ធជាអង្គីរស មានគ្រឿងប្រក់គឺកិលេសបើកហើយ នឹងបានត្រាស់ដឹង (ក្នុងលោក) ។ កុលបុត្តនោះបានមកកើតជាបុរស មាននាមថា សតរំសី នឹងជាធម្មទាយាទ ជាធម្មនិម្មិត ជាឱរសរបស់ព្រះសម្ពុទ្ធនោះ នឹងបានជាព្រះអរហន្ត ។

ខ្ញុំមានអាយុ ៧ ឆ្នាំ រាប់អំពីកំណើតមក បានបួសក្នុងព្រះពុទ្ធសាសនា មាននាមថាសតរំសី រស្មីរបស់ខ្ញុំ ក៏ផ្សាយចេញ ។ ខ្ញុំត្រេកអរនឹងឈាន បម្រើនឈាន ក្នុងមណ្ឌល ឬជិតគល់ឈើ ខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនា របស់ព្រះសម្មាសម្ពុទ្ធ ។ ខ្ញុំបានជាស្តេចចក្រពត្តិ ៤ ដង ព្រះនាមរោមៈដូចគ្នា បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន អស់ ៦០.០០០ កប្ប ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា សតរំសិយោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

សតរំសិយត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ សយនទាយកត្ថេរាបទានំ

(៤៤) បទុមុត្តរពុទ្ធស្ស សព្វលោកានុកម្បិនោ
សយនំ តស្ស ទាទាសឹ វិប្បសន្នេន ចេតសា ។
តេន សយនទានេន សុខេត្តេ ពីជសម្បទា
ភោគា និព្វត្តរេ តស្ស(១) សយនស្ស ឥទំ ផលំ ។
អាកាសេ សេយ្យំ កប្បេមិ ធារេមិ បថវឹ ឥមំ
បាណេសុ មេ ឥស្សរិយំ សយនស្ស ឥទំ ផលំ ។

១ ម. ភោគា និព្វត្តរេ អស្ស ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសតរំសិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សតរំសិយត្ថេរាបទាន ។

## សយនទាយកត្ថេរាបទាន ទី ៣

(៤៤) ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនទីព្រះបន្ទំ ដល់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ដែលទ្រង់អនុគ្រោះសព្វសត្វលោក ។ ភោគសម្បត្តិ តែងកើតឡើងសម្រាប់ខ្ញុំ ព្រោះការឲ្យនូវទីព្រះបន្ទំនោះ ព្រោះបរិបូណ៌ដោយពូជ ក្នុងស្រែដ៏ល្អនោះ នេះជាផលនៃសយនៈនោះ ។ ខ្ញុំតាំងដេក ក្នុងអាកាសបាន ខ្ញុំរក្សាទ្រទ្រង់នូវផែនដីនេះបាន ឥស្សរិយយស របស់ខ្ញុំតក្រោយទៅ ក្នុងពួកសត្វ នេះជាផល នៃសយនៈ ។

ទុតិយំ សយនទាយកត្ថេរាបទានំ

បញ្ចកប្បសហស្សម្ហិ    អដ្ឋ អាសុំ មហារិហ(១)
ចតុត្តីសេ កប្បសតេ    ចតុរោ មហព្ពលា
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សយនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សយនទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ គន្ធោទកទាយកត្ថេរាបទានំ

(៩៦) បទុមុត្តរពុទ្ធស្ស    មហាពោធិមហោ អហុ
វិចិត្តំ ឃដមានាយ    គន្ធោទកមទាសហំ ។
ន្ហានកាលេ ច ពោធិយា    មហាមេឃោ បវស្សថ
និន្នាទោ ច មហា អាសិ    អសនិយា ផលន្តិយា ។

១ ម. មហារហា ។



សយនទាយកត្ថេរាបទាន ទី ៣

ក្នុងកប្បទី ៥ ពាន់ ខ្ញុំបានជាមហាវីរក្សត្រ ៨ អង្គ ក្នុងកប្បទី ៣.៤០០ ខ្ញុំបានជាក្សត្រមានកម្លាំងច្រើន ៤ អង្គ ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ

បានឮថា ព្រះសយនទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សយនទាយកត្ថេរាបទាន ។

## គន្ធោទកទាយកត្ថេរាបទាន ទី ៤

(៩៦) កាលនោះធ្វើពិធីបុណ្យមហាពោធិព្រឹក្ស របស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ខ្ញុំបានយកទឹកក្រអូបមួយក្អមដ៏វិចិត្រ ហើយស្រោចទឹកក្រអូបនោះ លើដើមពោធិនោះ ។ ក្នុងកាលដែលគេកំពុងតែស្រោចដើមពោធិ មហាមេឃក៏បង្អុរភ្លៀងផ្គរលាន់គឹកកងយ៉ាងខ្លាំង ព្រមទាំងរន្ទះបាញ់ ក៏កើតឡើង ។

តេន ភិសនិវេទេន   តត្ថ កាលកតោ អហំ

ទេវលោកេ ឋិតោ សន្តោ   ឥមា គាថា អភាសថ ។

អហោ ពុទ្ធា អហោ ធម្មា   អហោ នោ សត្ថុសម្បទា

ការេត្វាំ មេ បតិតំ   ទេវលោកេ រមាមហំ ។

ឧព្ភិទ្ធំ ភវនំ មយ្ហំ   សត្តភូមំ សមុគ្គតំ

កញ្ញាសតសហស្សានិ   បរិវារេន្តិ មំ សទា ។

អាពាធា មេ ន វិជ្ជន្តិ   សោកោ មយ្ហំ ន វិជ្ជតិ

បរិឡាហំ ន បស្សាមិ   បុញ្ញកម្មស្សិទំ ផលំ ។

អដ្ឋារសេ កប្បសតេ   រាជា សំវសិតោ អហុ

សត្តរតនសម្បន្នោ   ចក្កវត្តី មហព្វលោ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភត្តោទកទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភត្តោទកទាយកត្ថេរស្ស អបទានំ សមត្តំ ។



ខ្ញុំក៏បានធ្វើមរណកាល ក្នុងទីនោះ ដោយកម្មនឹងនូវឆន្ទៈនោះបាញ់ក្រៅ ខ្ញុំបានទៅកើតនៅក្នុងទេវលោក ហើយសម្ដែងនូវគាថានេះថា ឱ ព្រះពុទ្ធ ឱ ព្រះធម៌ ឱ សម្បត្តិនៃព្រះសាស្ដារបស់ខ្ញុំ សោកសោករបស់ខ្ញុំ ធ្លាក់ចុះហើយ ខ្ញុំបានមកត្រេកអរ ក្នុងទេវលោកនេះ ។ ភពជាទីនៅរបស់ខ្ញុំ មានជាន់ ៧ ខ្ពស់ត្រដែតត្រដើម ពួកនាងកញ្ញាមួយសែន តែងហោមរោមខ្ញុំ សព្វៗកាល ។ ខ្ញុំមិនមានអាពាធ ខ្ញុំមិនមានសោក ខ្ញុំមិនឃើញសេចក្ដីក្រហល់ក្រហាយ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៦.៨០០ ខ្ញុំបានជាស្ដេចចក្រពត្តិ គ្រប់គ្រងផែនដី បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភត្តោទកទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភត្តោទកទាយកត្ថេរាបទាន ។

## បញ្ចមំ ឧបរិដ្ឋត្ថេរាបទានំ

(៤៧) បទុមុត្តរពុទ្ធស្ស  អាជានីយំ អទាសហំ
និយ្យាទេត្វាន សម្ពុទ្ធេ[១]  អគមាសឹ សកំ ឃរំ ។
ទេវលោ នាម នាមេន  សត្ថុនោ អគ្គសាវកោ
វរធម្មស្ស ទាយាទោ  អាគញ្ឆិ មម សន្តិកំ ។
សព្វត្ថហារកោ ភគវា  អាជានេយ្យោ ន កប្បតិ
តវ សង្កប្បមញ្ញាយ  អធិវាសេសិ ចក្ខុមា ។
អគ្ឃាបេត្វា វាតជវំ  សិន្ធវំ សីឃវាហនំ
បទុមុត្តរពុទ្ធស្ស  ខមនីយំ អទាសហំ ។
យំ យំ យោនុបបជ្ជាមិ  ទេវត្តំ អថ មានុសំ[២]
អាជានីយា វាតជវា  និព្វត្តន្តិ មម[៣] ។
លាភា តេសំ សុលទ្ធា វ  យេ លភន្តុបសម្បទំ
បុនប្បយិរុបាសេយ្យំ  ពុទ្ធោ លោកេ សចេ ភវេ ។

---
១ ម. សម្ពុទ្ធំ ។ ២ ម. ទេវេ ច មានុសេ ភវេ ។ ៣ ឱ. ខមនីយំ ភគវតិ ចិត្តំ និព្វត្តរេ មម ។



## ឧបរិដ្ឋត្ថេរាបទាន ទី ៥

(៤៧) ខ្ញុំបានថ្វាយសេះអាជានេយ្យ ដល់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ លុះប្រគល់ចំពោះព្រះសម្ពុទ្ធហើយ ក៏ទៅកាន់ផ្ទះរបស់ខ្លួន ។ ព្រះថេរៈ ឈ្មោះទេវលៈ ជាអគ្គសាវ័ករបស់ព្រះសាស្តា ជាធម្មទាយាទដ៏ប្រសើរ បានមកកាន់សំណាក់របស់ខ្ញុំ ហើយ (មានថេរដីកា) នឹងខ្ញុំថា ព្រះមានព្រះភាគ ព្រះអង្គនាំមកនូវប្រយោជន៍ទាំងពួង ទ្រង់ជាអាជានេយ្យ មិនញាប់ញ័រ ព្រះចក្ខុមាន ទ្រង់ទទួលហើយ ព្រោះទ្រង់ជ្រាបនូវតម្រិះរបស់អ្នក ។

ខ្ញុំកាត់ថ្លៃសេះសិន្ធពៈ ជាពាហនៈដ៏លឿន មានសន្ទុះដូចខ្យល់ ជាពាហនៈរហ័សអត់ធន់ ហើយថ្វាយដល់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ។ ខ្ញុំចូលទៅកាន់កំណើតណា ៗ ទោះបីជាទេវតា ឬជាមនុស្ស សេះអាជានេយ្យទាំងឡាយ មានសន្ទុះដូចខ្យល់ ជាសម្បត្តិជាទីត្រេកអរ រមែងកើតសម្រាប់ខ្ញុំ ។ មួយទៀត លាភ កុលបុត្តទាំងឡាយនោះ បានល្អហើយ ព្រោះបាននូវឧបសម្បទា ប្រសិនបើ ព្រះពុទ្ធកើតមានក្នុងលោក ខ្ញុំសូមចូលទៅអង្គុយជិតព្រះអង្គទៀត ។

អដ្ឋវីសតិកប្បម្ហិ  រាជា អាសឹ មហព្ពលោ
ចាតុរន្តោ វិជិតាវី  ជម្ពុទីបស្ស(១) ឥស្សរោ ។
ឥមំ បច្ឆិមកំ មយ្ហំ  ចរិមោ វត្តតេ ភវោ
បត្តោម្ហិ អចលំ ឋានំ  ហិត្វា ជយបរាជយំ ។
ចតុត្តឹសេ សហស្សម្ហិ  មហាតេជោសិ(២) ខត្តិយោ
សត្តរតនសម្បន្នោ  ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឱបវុយ្ហោ ថេរោ ឥមា គា-ថាយោ អភាសិត្ថាតិ ។

ឱបវុយ្ហត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. ជម្ពុមណ្ឌស្ស ។ ២ មហាតេជោម្ហិ យុត្តតាំ ។



ខ្ញុំបានជាស្តេច មានកម្លាំងច្រើន ជាស្តេចឈ្នះសឹកសង្គ្រាម មានសមុទ្រទាំង ៤ ជាព្រំប្រទល់ ទ្រង់ជាឥស្សរៈ ក្នុងជម្ពូទ្វីប អស់ ២៨ កប្ប ។ (ខ្ញុំទ្រង់) នូវកាយនេះ ជាទីបំផុត ភពជាទីបំផុត កំពុងប្រព្រឹត្តទៅ ខ្ញុំលះបង់នូវការឈ្នះនិងការចាញ់ ហើយបានដល់នូវទីមិនកម្រើក គឺព្រះនិព្វាន ។ ក្នុងកប្បទី ៣៤.០០០ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ជាក្សត្រ មានតេជៈច្រើន ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឱបវុយ្ហត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឱបវុយ្ហត្ថេរាបទាន ។

## ឆដ្ឋំ សព្វាភិភាសនត្ថេរាបទានំ

(៨៨) បទុមុត្តរពុទ្ធស្ស　បិណ្ឌបាតំ អទាសហំ
គន្ត្វា កាលិង្គការាធំ　មល្លិកាហំ បរិក្ខិតំ ។
កម្ហាសនម្ហិ អាសីនោ　ពុទ្ធោ លោកគ្គនាយកោ
អភិក្កយំ បិណ្ឌបាតំ　ឧជុភូតោ សមាហិតោ ។
យថាបិ ភទ្ទកោ ខេត្តេ　ពីជំ អប្បម្បិ រោបិតំ
សម្មា ធារំ បវេច្ឆន្តេ　ផលំ តោសេតិ កស្សកំ ។
តថេវយំ បិណ្ឌបាតោ　សុខេត្តេ រោបិតោ តយា
ករេ ធិព្វត្តមានម្ហិ　ផលន្តេ តោសយិស្សតិ ។
ឥធំ វត្វាន សម្ពុទ្ធោ　ជលជុត្តមនាមកោ
បិណ្ឌបាតំ គហេត្វាន　បក្កាមិ ឧត្តរាមុខោ ។
សំវុតោ បាតិមោក្ខស្មិំ　ឥន្ទ្រិយេសុ ច បញ្ចសុ
បវិវេកមនុយុត្តោ　វិហរាមិ អនាសវោ ។



## សព្វាភិភាសនត្ថេរាបទាន ទី ៦

(៨៨) ខ្ញុំដើរទៅកាន់វិសៅហ្ន៍ ដែលគេគ្រប់ដោយផ្កាមល្លិកាតាំងឡាយ ហើយបានថ្វាយចង្ហាន់បិណ្ឌបាត្រ ដល់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។ ព្រះសម្ពុទ្ធ អគ្គនាយកនៃលោក ទ្រង់មានសន្តានត្រង់ មានព្រះឫហទ័យតាំងមាំ ទ្រង់គង់លើអាសនៈនោះ ហើយសម្តែងសរសើរ នូវចង្ហាន់បិណ្ឌបាត្រជា

ពូជសម្រាប់បង្កើតផលនៅសាសនាព្រះហើយ គឺស្រែដ៏ល្អ តាំងភ្លៀង កំបង្អុរទឹកដោយស្រួល ផលរមែងញ៉ាំងអ្នកម្ចាស់ស្រែឲ្យត្រេកអរ យ៉ាងណាមិញ ។ ចង្ហាន់បិណ្ឌបាត្រនេះ ដែលអ្នកតំកល់ទុកហើយ ក្នុងបុញ្ញក្ខេត្តដ៏ល្អ ផលដ៏ធ្វើអ្នកឲ្យត្រេកអរ ក្នុងកាលដែលអ្នកកើត ក៏យ៉ាងនោះដែរ ។

លុះព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ បានត្រាស់នូវពាក្យនេះហើយ ទ្រង់ទទួលចង្ហាន់បិណ្ឌបាត្រ បែរព្រះភក្ត្រឆ្ពោះទៅកាន់ទិសខាងជើង ទ្រង់ចៀសចេញទៅ ។ ខ្ញុំសង្រួមល្អក្នុងបាតិមោក្ខផង ក្នុងឥន្ទ្រិយទាំង៥ផង ប្រកបរឿយៗ នូវវិវេក ជាអ្នកមិនមានអាសវៈ គឺកិលេសជាគ្រឿងត្រាំក្នុងចិត្ត ។

បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា សបរិវារាសនោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

សបរិវារាសនត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ បញ្ចទីបកត្ថេរាបទានំ

(៨៧) បទុមុត្តរពុទ្ធស្ស  សព្វភូតានុកម្បិនោ
សុសទ្ធហិត្វា សទ្ធម្មេ  ឧជុទិដ្ឋិ អហោសហំ ។
បទីបទានមទាសិំ  បរិវារេត្វាន ពោធិយំ
សទ្ទហន្តោ បទីបានិ  អការឹ តាវទេវហំ ។
យំ យំ យោនុបបជ្ជាមិ  ទេវត្តំ អថ មានុសំ
អាកាសេ ឧក្កំ ធារេន្តិ  ទីបទានស្សិទំ ផលំ ។
តិរោកុឌ្ឌំ តិរោសេលំ  សមតិគ្គយ្ហ បព្វតំ
សមន្តា យោជនសតំ  ទស្សនំ អនុភោមហំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសបរិវារាសនត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សបរិវារាសនត្ថេរាបទាន ។

## បញ្ចទីបកត្ថេរាបទាន ទី៧

(៨៧) ខ្ញុំជឿស៊ប់ ក្នុងព្រះសទ្ធម្មរបស់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់អនុគ្រោះដល់សព្វសត្វ ទ្រង់មានទិដ្ឋិត្រង់ ។ ខ្ញុំបានថ្វាយប្រទីបជាទាន ក៏ឲ្យជុំវិញដើមពោធិព្រឹក្ស កាលខ្ញុំជឿហើយ បានថ្វាយប្រទីបទាំងឡាយ ក្នុងវេលានោះ លុះខ្ញុំទៅកើតក្នុងកំណើតណា ៗ ទោះបីជាទេវតា ឬជាមនុស្ស ពួកទេវតាតែងត្រោលបំភ្លឺចង្កៀង ក្នុងអាកាស នេះជាផលនៃការថ្វាយប្រទីប ។ ខ្ញុំបានទទួលនូវទស្សនកិច្ច (ឃើញរូបទាំងពួង) ចម្ងាយ ១០០ យោជន៍ ដោយជុំវិញ ឃើញធ្លុះទៅខាងក្រៅជញ្ជាំង ខាងក្រៅថ្ម និងភ្នំបាន ។

តេន កម្មាវសេសេន បត្តោម្ហិ អាសវក្ខយំ
ធារេមិ អន្តិមំ ទេហំ ជិនជិន្ទស្ស សាសនេ ។
ចតុត្តឹសេ កប្បសតេ សមន្តចក្ខុសនាមកា
រាជាហេសុំ មហាតេជា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បញ្ចទីបកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បញ្ចទីបកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ ធជទាយកត្ថេរាបទានំ

(៦០) បទុមុត្តរពុទ្ធស្ស ពោធិយា បាទបុត្តមេ
ហដ្ឋោ ហដ្ឋេន ចិត្តេន ធជមារោបយឹ អហំ ។



ដោយសេសផលនៃកុសលកម្មនោះ ខ្ញុំបានដល់នូវការអស់ទៅនៃអាសវៈ ខ្ញុំទ្រទ្រង់នូវរាងកាយ ជាទីបំផុតក្នុងសាសនា របស់ព្រះសម្ពុទ្ធ ជាធំជាងសត្វជើងពីរ ។ ក្នុងកប្បទី ៣.៤០០ ខ្ញុំបានជាស្តេចចក្រពត្តិច្រើនជាតិ មាននាមថា សមន្តចក្ខុ មានតេជះច្រើន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចទីបកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បញ្ចទីបកត្ថេរាបទាន ។

## ធជទាយកត្ថេរាបទាន ទី ៨

(៦០) ខ្ញុំមានចិត្តរីករាយ បានលើកឡើងនូវទង់ ជិតគល់ពោធិព្រឹក្សដ៏ឧត្តម របស់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ។

បតបត្តានិ គណ្ហិត្វា   ពហិទ្ធា ឆឌ្ឌយឹ អហំ
អន្តោសុទ្ធំ ពហិសុទ្ធំ   សុវិមុត្តំ អនាសវំ ។
សម្មុខា វិយ សម្ពុទ្ធំ   អវន្ទឹ ពោធិមុត្តមំ
អនុត្តរោ លោកវិទូ   អាហុតីនំ បដិគ្គហោ ។
ភិក្ខុសង្ឃេ ឋិតោ សត្ថា   ឥមា គាថា អភាសថ
ឥមិនា ចិត្តទានេន   ឧបដ្ឋានេន ចូភយំ ។
កប្បានំ សតសហស្សំ   ទុគ្គតឹ សោ ន គច្ឆតិ
ទេវេសុ ទេវសោភគ្គំ   អនុភោស្សត្យនប្បកំ ។
អនេកសតក្ខត្តុញ្ច   រាជា រដ្ឋេ ករិស្សតិ
ឧក្កកោ នាម នាមេន   ចក្កវត្តិ ភវិស្សតិ ។
សម្បត្តឹ អនុភោត្វាន   សុក្កមូលេន ចោទិតោ
គោតមស្ស ភគវតោ   សាសនេភិរមិស្សតិ ។



ខ្ញុំរើសស្លឹកឈើដែលជ្រុះមក យកទៅចោលខាងក្រៅឡើង ខ្ញុំបានថ្វាយបង្គំពោធិព្រឹក្សដ៏ប្រសើរ ដូចថ្វាយបង្គំព្រះសម្ពុទ្ធ ចំពោះព្រះភក្ត្រ ទ្រង់ស្អាតខាងក្នុង ស្អាតខាងក្រៅ ទ្រង់មានព្រះហឫទ័យផុតស្រឡះ ឥតមានអាសវៈ ។ ព្រះសាស្តា ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក គួរទទួលនូវគ្រឿងបូជា ទ្រង់ឋិតនៅក្នុងកណ្ដាលនៃភិក្ខុសង្ឃ ហើយសម្ដែងនូវគាថាទាំងនេះថា

កុលបុត្រនោះ នឹងមិនទៅកាន់ទុគ្គតិ អស់មួយសែនកប្ប ដោយផលទាំង ២ យ៉ាង គឺ ការថ្វាយចិត្ត និងការបម្រើនេះ ។ កុលបុត្រនោះ នឹងទទួលនូវភោគជាទេវតា មានជោគល្អ ជាច្រើនជាតិកប់មិនអស់ ក្នុងឋានទេវលោក ។ នឹងបានជាស្ដេចក្នុងដែន អស់ច្រើនរយជាតិ នឹងបានជាស្ដេចចក្រពត្តិ ព្រះនាមឧក្កកៈ ។ កុលបុត្រនោះ លុះទទួលសម្បត្តិហើយ មានកុសលមូលដាស់តឿន នឹងបានត្រេកអរក្នុងសាសនា របស់ព្រះមានព្រះភាគ ព្រះនាមគោតម ។

បជានំ បហិតត្តម្ហិ ឧបសន្តោ និរូបធិ
ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។
ឯកបញ្ញាសសហស្សេ កប្បេ ឧក្កសវ្ហយា
បញ្ញាសសហស្សេ ចម្មោ ខត្តិយោ ទេមសវ្ហយោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឧទកទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទកទាយកត្ថេរស្ស អបទានំ សមត្តំ ។

# នវមំ បទុមត្ថេរាបទានំ

(៦១) ចតុសច្ចំ បកាសេន្តោ វរធម្មប្បវត្តកោ
វស្សេត អមតំ វុដ្ឋឹ និព្វាបេន្តោ មហាជនំ ។
សទណ្ឌំ បទុមំ គយ្ហ អឌ្ឍកោសេ ឋិតោ អហំ
បទុមុត្តរមុនិស្ស ហដ្ឋោ ឧក្ខិបិមម្ពរេ ។



កាលបើបុគ្គល មានតម្រេកមិនទាន់ទៅប្រាស មានសេចក្តីពេញចិត្តមិនទាន់ទៅប្រាស មានសេចក្តីស្រឡាញ់មិនទាន់ទៅប្រាស មានសេចក្តីស្រេកឃ្លានមិនទាន់ទៅប្រាស មានសេចក្តីក្រហល់ក្រហាយមិនទាន់ទៅប្រាស មានតណ្ហាមិនទាន់ទៅប្រាសចាកវិញ្ញាណ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីតានតឹងក្នុងចិត្តតាំងឡាយ តែងកើតឡើង ព្រោះសេចក្តីប្រែប្រួលទៅជាយ៉ាងដទៃ នៃវិញ្ញាណនោះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលតិស្សៈ ប្រពៃហើយ ប្រពៃហើយ ម្នាលតិស្សៈ កាលបើបុគ្គល មានតម្រេកមិនទាន់ទៅប្រាសចាកវិញ្ញាណ យ៉ាងណា ដំណើរនុ៎ះ រមែងមានយ៉ាងនុ៎ះឯង ។

(១៩៦) ម្នាលតិស្សៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើបុគ្គល មានតម្រេកទៅប្រាសហើយ មានសេចក្តីពេញចិត្តទៅប្រាសហើយ មានសេចក្តីស្រឡាញ់ទៅប្រាសហើយ មានសេចក្តីស្រេកឃ្លានទៅប្រាសហើយ មានសេចក្តីក្រហល់ក្រហាយទៅប្រាសហើយ មានតណ្ហាទៅប្រាសហើយ ចាករូប តើសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីតានតឹងក្នុងចិត្តតាំងឡាយកើតឡើង ព្រោះសេចក្តីប្រែប្រួលទៅជាយ៉ាងដទៃ នៃរូបនោះដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ម្នាលតិស្សៈ ប្រពៃហើយ ប្រពៃហើយ ម្នាលតិស្សៈ

ហោតិ យថា តំ រូបេ វិគតរាគស្ស ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ វិគតរាគស្ស វិគតច្ឆន្ទស្ស វិគតបេមស្ស វិគតបិបាសស្ស វិគតបរិឡាហស្ស វិគតតណ្ហាស្ស តស្ស វិញ្ញាណស្ស វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ នោ ហេតំ ភន្តេ ។ សាធុ សាធុ តិស្ស ឯវំ ហេតំ តិស្ស ហោតិ យថា តំ វិញ្ញាណេ វិគតរាគស្ស ។ តំ កឹ មញ្ញសិ តិស្ស រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ តស្មាតិហ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។



កាលបើបុគ្គលមានតម្រេកទៅប្រាសហើយចាករូប យ៉ាងណា ដំណើរនុ៎ះរមែងមានយ៉ាងនុ៎ះឯង ។ កាលបើបុគ្គល មានតម្រេកទៅប្រាសហើយ មានសេចក្តីពេញចិត្តទៅប្រាសហើយ មានសេចក្តីស្រឡាញ់ទៅប្រាសហើយ មានសេចក្តីស្រេកឃ្លានទៅប្រាសហើយ មានសេចក្តីក្រហល់ក្រហាយទៅប្រាសហើយ មានតណ្ហាទៅប្រាសហើយ ចាកវេទនា ។ ចាកសញ្ញា ។ ចាកសង្ខារទាំងឡាយ ។ ចាកវិញ្ញាណ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីតានតឹងចិត្ត តែងកើតឡើង ព្រោះសេចក្តីប្រែប្រួលទៅជាយ៉ាងដទៃ នៃវិញ្ញាណនោះដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ម្នាលតិស្សៈ ប្រពៃហើយ ប្រពៃហើយ ម្នាលតិស្សៈ កាលបើបុគ្គល មានតម្រេកទៅប្រាសហើយចាកវិញ្ញាណ យ៉ាងណា ដំណើរនុ៎ះរមែងមានយ៉ាងនុ៎ះឯង ។ ម្នាលតិស្សៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ព្រោះហេតុនោះ អរិយសាវកក្នុងសាសនានេះ ។ បេ ។ យល់ឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(១៨៧) សេយ្យថាបិ តិស្ស ទ្វេ បុរិសា ឯកោ បុរិសោ អមគ្គកុសលោ ឯកោ បុរិសោ មគ្គកុសលោ តមេនំ សោ អមគ្គកុសលោ បុរិសោ អមុំ មគ្គកុសលំ បុរិសំ មគ្គំ បុច្ឆេយ្យ សោ ឯវំ វទេយ្យ ឯហិ ភោ បុរិស អយំ មគ្គោ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ ទ្វេធាបថំ តត្ថ វាមំ មុញ្ចិត្វា ទក្ខិណំ គណ្ហ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ តិព្វំ វនសណ្ឌំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ មហន្តំ និន្នំ បល្លលំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ សោព្ភំ បបាតំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ សមំ ភូមិភាគំ រមណីយំ ។ ឧបមា ខោ ម្យាយំ តិស្ស កតា អត្ថស្ស វិញ្ញាបនាយ អយំ ចេវេត្ថ អត្ថោ ។



(១៨៧) ព្រះមានព្រះភាគត្រាស់ថា ម្នាលតិស្សៈ ដូចជាបុរសពីរនាក់ បុរសម្នាក់ជាអ្នកមិនស្ទាត់ក្នុងផ្លូវ បុរសម្នាក់ជាអ្នកស្ទាត់ក្នុងផ្លូវ បុរសដែលមិនស្ទាត់ក្នុងផ្លូវនោះ សួរផ្លូវចំពោះ នឹងបុរសដែលស្ទាត់ក្នុងផ្លូវនោះ បុរសដែលស្ទាត់ក្នុងផ្លូវប្រាប់យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន នេះផ្លូវ ចូរអ្នកទៅតាមផ្លូវនោះបន្តិចចុះ លុះអ្នកទៅតាមផ្លូវនោះបន្តិចទៅ នឹងឃើញផ្លូវបែកជាពីរ បណ្ដាផ្លូវទាំងពីរនោះ ចូរអ្នកលះបង់ផ្លូវខាងឆ្វេង កាន់យកផ្លូវខាងស្ដាំ ចូរអ្នកទៅតាមផ្លូវខាងស្ដាំនោះបន្តិចទៀត លុះអ្នកទៅតាមផ្លូវខាងស្ដាំនោះបន្តិចទៅ នឹងបានឃើញដងព្រៃស្រោង ចូរអ្នកទៅតាមដងព្រៃស្រោងនោះ បន្តិចទៀត លុះអ្នកទៅតាមដងព្រៃស្រោងនោះ បន្តិចទៅ នឹងបានឃើញល្បាប់ទំនាបធំ ចូរអ្នកទៅតាមល្បាប់ទំនាបធំនោះ បន្តិចទៀត លុះអ្នកទៅតាមល្បាប់ទំនាបធំនោះបន្តិចទៅ នឹងបានឃើញអូរនិងជ្រោះ ចូរអ្នកទៅតាមអូរនិងជ្រោះនោះបន្តិចទៀត លុះអ្នកទៅតាមអូរនិងជ្រោះនោះបន្តិចទៅ នឹងបានឃើញភូមិភាគដ៏រាបស្មើគួរជាទីត្រេកអរ ។ ម្នាលតិស្សៈ តថាគតធ្វើសេចក្ដីឧបមានេះ ដើម្បីឲ្យអ្នកយល់សេចក្ដី នេះឯងជាសេចក្ដីអធិប្បាយក្នុងដំណើរនុ៎ះ ។

បុរិសោ អមគ្គកុសលោតិ ខោ តិស្ស បុថុជ្ជនស្សេតំ អធិវចនំ ។ បុរិសោ មគ្គកុសលោតិ ខោ តិស្ស តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ ទ្វេធាបថោតិ ខោ តិស្ស វិចិកិច្ឆាយេតំ អធិវចនំ ។ វាមោ មគ្គោតិ ខោ តិស្ស អដ្ឋង្គិកស្សេតំ មិច្ឆាមគ្គស្ស អធិវចនំ ។ សេយ្យថីទំ ។ មិច្ឆាទិដ្ឋិយា ។បេ។ មិច្ឆាសមាធិស្ស ។ ទក្ខិណោ មគ្គោតិ ខោ តិស្ស អរិយស្សេតំ អដ្ឋង្គិកស្ស មគ្គស្ស អធិវចនំ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិយា ។បេ។ សម្មាសមាធិស្ស ។ តិព្វោ វនសណ្ឌោតិ ខោ តិស្ស អវិជ្ជាយេតំ អធិវចនំ ។ មហន្តំ និន្នំ បល្លលន្តិ ខោ តិស្ស កាមានមេតំ អធិវចនំ ។ សោព្ភោ បបាតោតិ ខោ តិស្ស កោធុបាយាសស្សេតំ អធិវចនំ ។ សមោ ភូមិភាគោ រមណីយោតិ ខោ តិស្ស និព្ពានស្សេតំ អធិវចនំ ។ អភិរម តិស្ស



ម្នាលតិស្សៈ ពាក្យថា បុរសមិនស្ទាត់គន្លងផ្លូវនុ៎ះ ជាឈ្មោះរបស់បុថុជ្ជន ។ ម្នាលតិស្សៈ ពាក្យថា បុរសស្ទាត់គន្លងផ្លូវនុ៎ះ ជាឈ្មោះរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលតិស្សៈ ពាក្យថា ផ្លូវបែកជាពីរនុ៎ះ ជាឈ្មោះរបស់វិចិកិច្ឆា ។ ម្នាលតិស្សៈ ពាក្យថា ផ្លូវខាងឆ្វេងនុ៎ះ ជាឈ្មោះរបស់ផ្លូវខុសប្រកបដោយអង្គ ៨ ។ អង្គ ៨ តើដូចម្តេច ។ គឺ មិច្ឆាទិដ្ឋិ ។បេ។ មិច្ឆាសមាធិ ។ ម្នាលតិស្សៈ ពាក្យថា ផ្លូវខាងស្តាំនុ៎ះ ជាឈ្មោះរបស់ផ្លូវ ប្រកបដោយអង្គ ៨ ។ អង្គ ៨ តើដូចម្តេច ។ គឺ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលតិស្សៈ ពាក្យថា ដងព្រៃស្រោងនុ៎ះ ជាឈ្មោះរបស់អវិជ្ជា ។ ម្នាលតិស្សៈ ពាក្យថា ល្បាប់ទំនាបធំនុ៎ះ ជាឈ្មោះរបស់កាមទាំងឡាយ ។ ម្នាលតិស្សៈ ពាក្យថា អូរទឹកជ្រោះនុ៎ះ ជាឈ្មោះរបស់សេចក្តីក្រោធនិងសេចក្តីតានតឹងចិត្ត ។ ម្នាលតិស្សៈ ពាក្យថា ភូមិភាគដ៏រាបស្មើគួរជាទីត្រេកអរនុ៎ះ ជាឈ្មោះរបស់ព្រះនិព្វាន ។ ម្នាលតិស្សៈ ចូរអ្នកត្រេកអរចុះ

អភិរម តិស្ស អហមោវាទេន អហមនុគ្គហេន អហមនុសាសនិយាតិ[១] ។ ឥទមវោច ភគវា ។ អត្តមនោ អាយស្មា តិស្សោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

[១៨៨] ឯកំ សមយំ អាយស្មា សារីបុត្តោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន យមកស្ស នាម ភិក្ខុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ អស្សោសុំ ខោ សម្ពហុលា ភិក្ខូ យមកស្ស កិរ នាម ភិក្ខុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ អថ ខោ តេ ភិក្ខូ យេនាយស្មា យមកោ តេនុបសង្កមិំសុ

១ ឱ. អហមាមិសធម្មានុគ្គហេន មមោវាទេន មមានុសាសនិយាតិ ។



ម្នាលតិស្សៈ ចូរអ្នកត្រេកអរចុះថា គ្នាអញត្រេកអរដោយឱវាទ គ្នាអញត្រេកអរ ដោយសេចក្តីអនុគ្រោះ គ្នាអញត្រេកអរ ដោយពាក្យប្រៀនប្រដៅ ។ ព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ។ ព្រះតិស្សៈមានអាយុ មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

[១៨៨] សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក៏សម័យនោះឯង ភិក្ខុឈ្មោះយមកៈ កើតទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព បែកធ្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ ភិក្ខុទាំងឡាយច្រើនរូប បានឮថា យមកភិក្ខុ កើតទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព បែកធ្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ លំដាប់នោះ ភិក្ខុអម្បាលនោះ ចូលទៅរកយមកភិក្ខុ

ឧបសង្កមិត្វា អាយស្មតា យមកេន សទ្ធឹ សម្មោ-ទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ យមកំ ឯតទវោចុំ សច្ចំ កិរ តេ អាវុសោ យមក ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ ឯវំ ខ្វាហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ មា អាវុសោ យមក ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ ខីណាសវោ ភិក្ខុ



មានអាយុ លុះចូលទៅដល់ហើយ ក៏រាក់ទាក់ជាមួយនឹងយមកភិក្ខុមានអាយុ លុះបញ្ចប់ពាក្យគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុអម្បាលនោះអង្គុយក្នុងទីសមគួរហើយ ទើបពោលនឹងយមកភិក្ខុមានអាយុដូច្នេះថា ម្នាលអាវុសោយមកៈ ឮថាលោកកើតទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព បែកធ្លាយកាយហើយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀត ដូច្នោះមែនឬ ។ យមកភិក្ខុមានអាយុ ឆ្លើយថា ម្នាលអាវុសោ យ៉ាងហ្នឹងមែនហើយ ខ្ញុំយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព បែកធ្លាយកាយហើយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ ម្នាលអាវុសោយមកៈ លោកកុំពោលយ៉ាងនេះឡើយ លោកកុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ការពោលបង្កាច់ព្រះមានព្រះភាគ មិនល្អទេ ព្រោះព្រះមានព្រះភាគ មិនមែនត្រាស់យ៉ាងនេះថា ភិក្ខុជាខីណាស្រព

កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ ឯវំបិ ខោ អាយស្មា យមកោ តេហិ ភិក្ខូហិ វុច្ចមានោ តថេវ តំ បាបកំ ទិដ្ឋិគតំ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ យតោ ខោ តេ ភិក្ខូ នាសក្ខិំសុ អាយស្មន្តំ យមកំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុំ ។ អថ ខោ តេ ភិក្ខូ ឧដ្ឋាយាសនា យេនាយស្មា សារីបុត្តោ តេនុបសង្កមិំសុ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោចុំ យមកស្ស នាម អាវុសោ សារីបុត្ត ភិក្ខុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ សាធាយស្មា សារីបុត្តោ យេន យមកោ ភិក្ខុ តេនុបសង្កមតុ



បែកធ្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យមិនកើតទៀត យ៉ាងនេះទេ ។ កាលភិក្ខុអម្បាលនោះ ពោល (ហាមឃាត់) យ៉ាងនេះហើយ យមកភិក្ខុមានអាយុក៏នៅតែប្រកាន់ ស្ទាបអង្អែលទិដ្ឋិអាក្រក់នោះ ដូច្នោះដដែល ហើយពោលថា ខ្ញុំយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព បែកធ្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យបាត់ទៅ មិនកើតទៀតទេ ។ កាលបើភិក្ខុអម្បាលនោះ មិនអាចរំដោះយមកភិក្ខុមានអាយុ ចាកទិដ្ឋិអាក្រក់នេះបានទេ ។ ទើបភិក្ខុអម្បាលនោះ ក្រោកចាកអាសនៈ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត យមកភិក្ខុកើតទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព បែកធ្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ សូមព្រះសារីបុត្តមានអាយុ មេត្តាចូលទៅរកយមកភិក្ខុ

អនុគ្គហំ ឧបាទាយាតិ ។ អធិវាសេសិ ខោ អាយស្មា សារីបុត្តោ តុណ្ហីភាវេន ។

[១៨៨] អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា យមកោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា យមកេន សទ្ធឹ សម្មោទិ ។បេ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ យមកំ ឯតទវោច សច្ចំ កិរ តេ អាវុសោ យមក ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ ឯវំ ខ្វាហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា ខីណាសវោ ភិក្ខុ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។



ដើម្បីធ្វើនូវសេចក្តីអនុគ្រោះ ។ ព្រះសារីបុត្តមានអាយុ ក៏ទទួលដោយតុណ្ហីភាព ។

[១៨៨] លំដាប់នោះ ព្រះសារីបុត្តមានអាយុ ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅរកយមកភិក្ខុមានអាយុ លុះចូលទៅដល់ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងយមកភិក្ខុមានអាយុ ។បេ។ លុះព្រះសារីបុត្តមានអាយុ គង់ក្នុងទីសមគួរហើយ ក៏ពោលនឹងយមកភិក្ខុមានអាយុ ដូច្នេះថា ម្នាលអាវុសោយមកៈ ឮថាលោកកើតទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព កែខ្ទាយកាយហើយ ខាន់មុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀត ដូច្នេះ ពិតមែនឬ ។ យមកភិក្ខុមានអាយុឆ្លើយថា យ៉ាងហ្នឹងមែនហើយ ម្នាលអាវុសោ ខ្ញុំយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសំដែងហើយ ថា ភិក្ខុជាខីណាស្រព កែខ្ទាយកាយហើយ ខាន់មុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។

តំ កឹ មញ្ញសិ អាវុសោ យមក រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ អាវុសោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ អាវុសោ ។ តស្មាតិហ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។

(៦០០) តំ កឹ មញ្ញសិ អាវុសោ យមក រូបំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ វេទនំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។

(៦០១) តំ កឹ មញ្ញសិ អាវុសោ យមក រូបស្មឹ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ អញ្ញត្រ រូបា តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ អាវុសោ ។ វេទនាយ ។ បេ ។ អញ្ញត្រ វេទនាយ ។ បេ ។ សញ្ញាយ ។ អញ្ញត្រ សញ្ញាយ ។ សង្ខារេសុ ។ អញ្ញត្រ សង្ខារេហិ ។



ក្នុងកប្បទី ៦០ អំពីកប្បនេះ ខ្ញុំបានកើតជាមហាក្សត្រ១ព្រះអង្គ ព្រះនាមសុមេធៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអាបោបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អាបោបុប្ផិយត្ថេរាបទាន ។

## បច្ចាគមនិយត្ថេរាបទាន ទី ៣

(៦៩) កាលនោះ ខ្ញុំជាបក្សីចក្រពាក នៅនាឆ្នេរស្ទឹងសិន្ធុ ខ្ញុំមានសារាយស្អំជាអាហារផង ខ្ញុំសង្រួមល្អក្នុងសត្វទាំងឡាយផង ។ ខ្ញុំបានឃើញព្រះពុទ្ធ ជាបុគ្គលប្រាសចាក ធូលីគឺកិលេស កំពុងនិមន្តទៅឰដ៏អាកាស ខ្ញុំពាំនូវផ្កាក៏ដោយចំពុះ បង្អោនមកថ្វាយព្រះពុទ្ធ ព្រះនាមវិបស្សី ។

យស្ស សទ្ធា តថាគតេ អចលា សុប្បតិដ្ឋិតា
តេន ចិត្តប្បសាទេន ទុគ្គតឹ សោ ន គច្ឆតិ ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
វិហន្តមេន សទ្ធេន សុពីជំ រោបិតំ មយា ។
ឯកនវុតេ ឥតោ កប្បេ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
សុតានុសស្សុតា នាម អដ្ឋេតេ ឯកនាមកា
កប្បេ សត្តរសេ អាសុំ ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បច្ចាគមនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បច្ចាគមនិយត្ថេរស្ស អបទានំ សមត្តំ ។





សទ្ធាមិនញាប់ញ័រ ដែលបុគ្គលណា តំកល់ល្អហើយចំពោះព្រះតថាគត បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ ។

ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធ ព្រះអង្គជាបុគ្គលប្រសើរ ឱ! ពូជដ៏ល្អ គឺបុណ្យ ខ្ញុំបានបណ្តុះទុកល្អហើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ៨ អង្គ មានព្រះនាមដូចគ្នា គឺព្រះនាមថាសុតានុសស្សុតៈ ជាស្តេចចក្រពត្តិ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបច្ចាគមនិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បច្ចាគមនិយត្ថេរាបទាន ។

## ចតុត្ថំ បរប្បសាទកត្ថេរាបទានំ

[៦៦] ឧសភំ បវរំ វីរំ   មហេសឹ វិជិតាវិនំ
សុវណ្ណវណ្ណំ សម្ពុទ្ធំ   កោ ទិស្វា នប្បសីទតិ ។
ហិមវា វាបរិមេយ្យោ   សាគរោវ ទុរុត្តរោ[១]
តថេវ ឈានំ ពុទ្ធស្ស   កោ ទិស្វា នប្បសីទតិ ។
វសុធា យថាប្បមេយ្យា   ចិត្តា វនវដំសកា
តថេវ សីលំ ពុទ្ធស្ស   កោ ទិស្វា នប្បសីទតិ ។
អនិលញ្ជសាសង្ខុព្ភោ   យថាកាសោ អសង្ខិយោ
តថេវ ញាណំ ពុទ្ធស្ស   កោ ទិស្វា នប្បសីទតិ ។
ឥមាហិ ចតូហិ គាថាហិ ព្រាហ្មណោ សោនសវ្ហយោ[២]
ពុទ្ធសេដ្ឋំ ថវិត្វាន   សម្ពុទ្ធមបរាជិតំ ។

១ ម. ទុត្តរោ ។ ២ ម. សេនសវ្ហយោ ។



## បរប្បសាទកត្ថេរាបទាន ទី ៤

[៦៦] បុគ្គលណា ឃើញព្រះសម្ពុទ្ធ មានសម្បុរដូចមាស ជាឧសភបុរស ជាវីរបុរសប្រសើរ ទ្រង់ស្វែងរកនូវគុណធំ មានជ័យជំនះហើយ នឹងមិនជ្រះថ្លាម្ដេចបាន ។ ភ្នំហិមពាន្ត មានប្រមាណមិនបាន និងសមុទ្រសាគរ គេឆ្លងបានដោយក្រ យ៉ាងណាមិញ ឈានរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ បុគ្គលឃើញហើយ នឹងមិនជ្រះថ្លាម្ដេចបាន ។ ផែនដីមានប្រមាណមិនបាន របៀបផ្កាឈើក្នុងព្រៃ ដ៏ត្រកាល យ៉ាងណាមិញ សីលរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្ដេចបាន ។ អាកាស មិនញាប់ញ័រ ដោយផ្លូវខ្យល់ បុគ្គលរាប់មិនបាន យ៉ាងណាមិញ ញាណរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្ដេចបាន ។ ព្រាហ្មណ៍ ឈ្មោះសោនៈ សរសើរនូវព្រះសម្ពុទ្ធ ជាព្រះពុទ្ធប្រសើរ ព្រះអង្គឈ្នះកិលេសមារ ដោយគាថាទាំង ៤ នេះហើយ

ចតុន្នវុតិកប្បានិ ទុគ្គតឹ នុបបជ្ជិ
សុគតីសុ សុសម្បត្តឹ អនុភោសឹ អនប្បកំ ។
ចតុន្នវុតេ ឥតោ កប្បេ ថវិត្វា លោកនាយកំ
ទុគ្គតឹ នាភិជានាមិ ថោមនស្ស ឥទំ ផលំ ។
ចតុទ្ទសម្ហិ កប្បម្ហិ ចតុរោ អាសុមុគ្គតា
សត្តរតនសម្បន្នា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បរប្បសាទកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បរប្បសាទកត្ថេរស្ស អបទានំ សមត្តំ ។



មិនទៅកាន់ទុគ្គតិ អស់៩៤កប្ប ។

ខ្ញុំបានទទួលសម្បត្តិដ៏ល្អ ក្នុងសុគតិទាំងឡាយ មិនមែនតិចឡើយ ។ ក្នុងកប្បទី៩៤ អំពីកប្បនេះ ខ្ញុំសរសើរព្រះសម្ពុទ្ធ ជានាយកនៃសត្វលោក ហើយមិនស្គាល់នូវទុគ្គតិ នេះជាផលនៃការសរសើរព្រះពុទ្ធ ។ ក្នុងកប្បទី១៤ ខ្ញុំបានជាស្តេចចក្រពត្តិ ៤ដង ព្រះនាមឧគ្គតៈដូចគ្នា ទ្រង់បរិបូណ៌ដោយរតនៈ៧ប្រការ មានកម្លាំងច្រើន ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបរប្បសាទកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បរប្បសាទកត្ថេរាបទាន ។

## បញ្ចមំ ភិសទាយកត្ថេរាបទានំ

(៦៧) វេស្សភូ នាម នាមេន ឥសីនំ តតិយោ អហុ
កាននំ វនមោគ្គយ្ហ វិហាសិ បុរិសុត្តមោ ។
ភិសមុឡាលំ គណ្ហិត្វា អគមឹ ពុទ្ធសន្តិកេ
តញ្ច ពុទ្ធស្ស អទាសឹ បសន្នោ សេហិ បាណិភិ ។
ករេន ច បរាមដ្ឋោ វេស្សភូ វរពុទ្ធិនា
សុខាហំ នាភិជានាមិ សមំ តេន កុតុត្តរឹ(១) ។
ចរិមោ វត្តតេ មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ឯកត្តឹសេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ភិសទានស្សិទំ ផលំ ។
សមោធានា ច នាមេន សោឡស មនុជាធិបា
កប្បម្ហិ តេរសេ អាសុំ ចក្កវត្តី មហព្វលា ។

១ ម. សុខំ តេន កុតោត្តរឹ ។



## ភិសទាយកត្ថេរាបទាន ទី ៥

(៦៧) ព្រះពុទ្ធ ព្រះនាមវេស្សភូ ជាបុរសដ៏ឧត្តម ជាព្រះពុទ្ធទី ៣ របស់ពួកព្រះពុទ្ធ ទ្រង់ស្ទង់រក (ខ្ទង់ណាធំ) ស្តេចទៅគង់នៅក្នុងព្រៃផ្សៃ ។ ខ្ញុំមានចិត្តជ្រះថ្លា បានកាន់ក្រអៅឈូក ហើយដើរទៅក្នុងទីជិតនៃព្រះពុទ្ធ ថ្វាយក្រអៅឈូកនោះ ចំពោះព្រះពុទ្ធ ដោយដៃរបស់ខ្លួន ។ ព្រះពុទ្ធព្រះនាមវេស្សភូ មានព្រះប្រាជ្ញាដ៏ប្រសើរ ទ្រង់បានទទួលដោយព្រះហស្ត ខ្ញុំមិនដែលស្គាល់សុខណា ដ៏ស្មើឬលើស ជាងសុខដែលកើត អំពីបុណ្យនោះសោះឡើយ ។ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ភពទាំងពួង ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំផ្តាច់ចំណង ដូចជាដំរី (ផ្តាច់ទន្លីង) ហើយជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយក្រអៅឈូក ។ ក្នុងកប្បទី ១៣ ខ្ញុំបានជាស្តេចចក្រពត្តិ ១៦ អង្គ ព្រះនាម សមោធានៈដូចគ្នា ជាធំក្នុងពួកមនុស្ស មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភិសទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភិសទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ សុចិន្តិតត្ថេរាបទានំ

[៦៨] គិរិទុគ្គចរោ អាសឹ អភិជាតោវ កេសរី
មិគសង្ឃំ វធិត្វាន ជីវាមិ បព្វតន្តរេ ។
អត្ថទស្សី តុ ភគវា សព្វញ្ញូ វទតំ វរោ
មមុទ្ធរិតុកាមោ សោ អាគញ្ឆិ បព្វតុត្តមំ ។
បសទញ្ច មិគំ ហន្ត្វា ភក្ខិតុំ សមុបាគមឹ
ភគវា តម្ហិ សមយេ ភិក្ខាចារេ(១) ឧបាគមិ ។

១ ម. ភិក្ខហេតោ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភិសទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភិសទាយកត្ថេរាបទាន ។

## សុចិន្តិតត្ថេរាបទាន ទី៦

[៦៨] ខ្ញុំបានកើតជាកេសររាជសីហ៍ មានជាតិដ៏ខ្ពង់ខ្ពស់ ត្រាច់ទៅតាមជ្រោះភ្នំ សំឡាប់នូវពួកម្រឹគ ចិញ្ចឹមជីវិតក្នុងចន្លោះភ្នំ ។ គាប់ចួន ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ព្រះអង្គជាសព្វញ្ញូ ប្រសើរជាងពួកអ្នកប្រាជ្ញ ព្រះអង្គប្រាថ្នាស្រោចស្រង់ខ្ញុំ ទើបស្តេចមកកាន់ភ្នំដ៏ឧត្តម ។ ក្នុងសម័យនោះ ខ្ញុំសំឡាប់នូវបសទម្រឹគ យកមកបរិភោគ ព្រះមានព្រះភាគ ប្រព្រឹត្តបិណ្ឌបាត ស្តេចចូលមកជិតខ្ញុំ ។

## ឆដ្ឋំ សុចិន្តិតត្ថេរាបទានំ

វរមំសានិ បគ្គយ្ហ    អទាសឹ តស្ស សត្ថុនោ
អនុមោទិ មហាវីរោ    និព្វាបេន្តោ មមំ តទា ។
តេន ចិត្តប្បសាទេន    គិរិទុគ្គំ បវិសឹ អហំ
បីតឹ ឧប្បាទយិត្វាន    តត្ថ កាលកតោ អហំ ។
ឯតេន មំសទានេន    ចិត្តស្ស បណិធីហិ ច
បណ្ណរសេ កប្បសតេ    ទេវលោកេ រមឹ អហំ ។
អវសេសេសុ កប្បេសុ    កុសលំ ការិតំ មយា
តេនេវ មំសទានេន    ពុទ្ធានុស្សរណេន ច ។
អដ្ឋតឹសម្ហិ កប្បម្ហិ    អដ្ឋ ទីឃាយុនាមកា
សដ្ឋិម្ហិតោ កប្បសតេ    ទុវេ សរណនាមកា ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនំ ។



## សុចិន្តិតត្ថេរាបទាន ទី ៦

ខ្ញុំរើសយកសាច់ដ៏ល្អ ថ្វាយព្រះសាស្តានោះ ឯព្រះសាស្តា ជាមហាវីរបុរស (សម្តែងធម៌) ញ៉ាំងខ្ញុំឲ្យរលត់ទុក្ខ ហើយទ្រង់អនុមោទនា ក្នុងកាលនោះ ។ ខ្ញុំចូលទៅកាន់ជ្រោះភ្នំ ញ៉ាំងបីតិឲ្យកើតឡើង ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ ខ្ញុំក៏ធ្វើកាលកិរិយាក្នុងទីនោះ ។ ក្នុងកប្បទី ១.៥០០ ខ្ញុំបានរីករាយក្នុងទេវលោក ដោយទានសាច់នុ៎ះផង ដោយសេចក្តីតាំងទុកចិត្តនុ៎ះផង ។ ដោយអំណាច នៃទានសាច់នោះផង ដោយការរលឹកនូវព្រះពុទ្ធផង កុសល ខ្ញុំក៏បានធ្វើថែមទៀតក្នុងកប្បដ៏សេស ។ ក្នុងកប្បទី ៣៨ ខ្ញុំបានកើតជាស្តេច មាននាមថាទីឃាយុ ៨ ជាតិ ក្នុងកប្បទី ៦.០០០ អំពីកប្បនេះ ខ្ញុំបានជាស្តេចពីរជាតិ ព្រះនាមសរណៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា សុចិន្តិតោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុចិន្តិតត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ វត្ថទាយកត្ថេរាបទានំ

(៦៤) បក្ខិជាតោ តទា អាសិំ សុបណ្ណោ គរុឡាធិបោ

អទ្ទសំ វិរជំ ពុទ្ធំ គច្ឆន្តំ គន្ធមាទនំ ។

ជហិត្វា គរុឡវណ្ណំ មាណវកំ អកធយឹ(១)

ឯកវត្ថំ មយា ទិន្នំ ទ្វិបទិន្ទស្ស តាទិនោ ។

តញ្ច ទុស្សំ បដិគ្គយ្ហ ពុទ្ធោ លោកគ្គនាយកោ

អន្តលិក្ខេ ឋិតោ សត្ថា ឥមា គាថា អភាសថ ។

ឥមិនា វត្ថទានេន ចិត្តស្ស បណិធីហិ ច

បហាយ គរុឡយោនឹ ទេវលោកេ រមិស្សតិ ។

១ ម. អធារយឹ ។



បានឮថា ព្រះសុចិន្តិតត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុចិន្តិតត្ថេរាបទាន ។

## វត្ថទាយកត្ថេរាបទាន ទី៧

(៦៤) ក្នុងកាលនោះ ខ្ញុំកើតជាបក្សីគ្រុឌ ជាធំលើពួកគ្រុឌ បានឃើញព្រះពុទ្ធ ព្រះអង្គមានធូលីគឺកិលេសប្រាសចេញហើយ កំពុងស្តេចទៅកាន់ភ្នំគន្ធមាទន៍ ។ ខ្ញុំបានលះបង់ភេទជាគ្រុឌ ហើយប្លែងខ្លួនជាមាណព ខ្ញុំបានថ្វាយសំពត់មួយចំពោះព្រះពុទ្ធ ព្រះអង្គជាបុគ្គលនឹងនួន ទ្រង់ជាធំជាងសត្វជើងពីរ ។ ចំណែកខាងព្រះពុទ្ធ ជាអគ្គនាយកនៃសត្វលោក ជាសាស្តា ទ្រង់ទទួលនូវសំពត់នោះ នៅលើអាកាស ហើយសម្តែងនូវគាថាទាំងនេះថា បក្សីគ្រុឌនេះ លុះលះបង់នូវកំណើតគ្រុឌហើយ នឹងទៅត្រេកអរ ក្នុងទេវលោក ព្រោះទានសំពត់នេះផង ព្រោះការតាំងចិត្តនេះផង ។

សត្តមំ វត្ថទាយកត្ថេរាបទានំ

អត្ថទស្សី តុ ភគវា  លោកជេដ្ឋោ នរាសភោ
វត្ថជាតំ បសំសិត្វា  បក្កាមិ ឧត្តរាមុខោ ។
ភវេ និព្វត្តមានម្ហិ  ហោន្តិ មេ វត្ថសម្បទា
អាកាសេ ឆទនំ ហោតិ  វត្ថទានស្សិទំ ផលំ ។
អរុណសា សត្ត ជនា  ចក្កវត្តី មហព្ពលា
ឆត្តិសតិម្ហិ អាសីសុ  កប្បម្ហិ មនុជាធិបា ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វត្ថទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វត្ថទាយកត្ថេរស្ស អបទានំ សមត្តំ ។



វត្ថទាយកត្ថេរាបទាន ទី ៧

ចំណែកព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាចំបងក្នុងលោក ជានរាសភៈ ទ្រង់សរសើរទានសំពត់ ហើយទ្រង់ងាកព្រះភក្ត្រ ឆ្ពោះទៅទិសខាងជើង ទ្រង់ស្តេចចៀសចេញទៅ ។ កាលខ្ញុំកើតក្នុងភព ខ្ញុំតែងមានការបរិបូណ៌ដោយសំពត់ តែងមានគ្រឿងប្រក់បាំងក្នុងអាកាស នេះជាផលនៃទានសំពត់ ។ ក្នុងកប្បទី ៣៦ ខ្ញុំបានជាស្តេចចក្រពត្តិ ៧ ដង ព្រះនាមអរុណសៈ មានកម្លាំងច្រើន ជាអធិបតីលើពួកមនុស្ស ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវត្ថទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វត្ថទាយកត្ថេរាបទាន ។

## អដ្ឋមំ អម្ពទាយកត្ថេរាបទានំ

(៧០) អនោមទស្សី ភគវា និសិន្នោ បព្វតន្តរេ
មេត្តាយ អផរិ លោកេ អប្បមាណេ និរូបធិ ។
កបិ អហំ តទា អាសឹ ហិមវន្តេ នគុត្តមេ
ទិស្វា អនោមទស្សឹ ពុទ្ធំ ចិត្តំ បសាទយឹ ។
អវិទូរេ ហិមវន្តស្ស អម្ពាសុំ ផលិនោ តទា
តតោ បក្កំ គហេត្វាន អម្ពំ សមធុកំ អទំ ។
តម្មេ ពុទ្ធោ វិយាកាសិ អនោមទស្សី មហាមុនិ
ឥមិនា មធុទានេន អម្ពទានេន ចូភយំ ។
សត្តបញ្ញាសកប្បានិ ទេវលោកេ រមិស្សតិ
អវសេសេសុ កប្បេសុ វោកិណ្ណំ សំសរិស្សតិ ។



## អម្ពទាយកត្ថេរាបទាន ទី ៨

(៧០) ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ទ្រង់គង់នៅកណ្តាលភ្នំ ព្រះអង្គមិនមានឧបធិកិលេស (មានព្រះហឫទ័យ) ផ្សាយមេត្តាទៅ ក្នុងលោកមិនមានប្រមាណ ។ គ្រានោះ ខ្ញុំបានកើតជាស្វា លើភ្នំដ៏ឧត្តម ឈ្មោះហិមពាន្ត បានឃើញព្រះពុទ្ធ មានគុណមិនថោកថយ មានគុណដ៏ក្រៃលែង ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លា ចំពោះព្រះពុទ្ធ ។ ក្នុងគ្រានោះ មានដើមស្វាយមានផ្លែ ក្នុងទីមិនឆ្ងាយ អំពីភ្នំហិមពាន្ត ខ្ញុំក៏បានបេះផ្លែស្វាយទុំ មានរសផ្អែម អំពីដើមស្វាយនោះ ព្រមទាំងទឹកឃ្មុំ ហើយថ្វាយព្រះសម្ពុទ្ធ ។ ព្រះពុទ្ធព្រះនាមអនោមទស្សី ជាមហាមុនី ទ្រង់ព្យាករខ្ញុំនោះ ដោយទានរបស់ខ្ញុំ ទាំង ២ គឺទានទឹកឃ្មុំនេះ និងទានផ្លែស្វាយនេះជា ស្វានេះ នឹងរីករាយក្នុងទេវលោក អស់ ៥៧ កប្ប នឹងអន្ទោលទៅកាន់ភពដ៏ប្រឡូកប្រឡំ ក្នុងកប្បដ៏សេស ។

## អដ្ឋមំ អម្ពទាយកត្ថេរាបទានំ

ទេបេត្វា ឋាបកំ កម្មំ    បរិបក្កាយ វុទ្ធិយា
វិផិតា តានិ ហាគត្វា    ករិបេសេ ឈាបយិស្សតិ ។
ឆមេឆ យុត្តមេធាហំ    ឆមិតោម្ហិ មហេសិនា
បត្តោម្ហិ អចលំ ឋានំ    ហិត្វា ជយបរាជយំ ។
សត្តសត្តតិកប្បសតេ    អម្ពដ្ឋជយនាមកា
ចតុទ្ទសា តេ រាជានោ    ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អម្ពទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អម្ពទាយកត្ថេរស្ស អបទានំ សមត្តំ ។



## អម្ពទាយកត្ថេរាបទាន ទី ៨

លុះអស់បាបកម្ម មកអំពីអបាយភូមិ ទាំងអស់ក្រោយ ជាដើម (បានមកជាមនុស្ស) ហើយញុំាងកិលេសឲ្យរលីងសូន្យ ដោយសេចក្តីចម្រើនដ៏ចាស់ក្លា ។

ខ្ញុំផែលព្រះពុទ្ធ ស្វែងរកនូវគុណដ៏ធំ ខ្ញុំបានហើយ ដោយការខ្ជាន់ដ៏ឧត្តម ក៏បានលះបង់ នូវការឈ្នះនិងការចាញ់ ហើយដល់នូវទីមិនញាប់ញ័រ គឺព្រះនិព្វាន ។ ក្នុងកប្បទី ៧.៧០០ ខ្ញុំបានជាស្តេចចក្រពត្តិ ១៤ ដង ព្រះនាមអម្ពដ្ឋជ័យ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពទាយកត្ថេរាបទាន ។

## នវមំ សុមនវេត្តាបទានំ

(៧១) សុមនោ នាម នាមេន មាលាការោ អហំ តទា
អទ្ទសំ វិរជំ ពុទ្ធំ លោកាហុតិបដិគ្គហំ ។
ឧភោ ហត្ថេហិ បគ្គយ្ហ សុមនំ បុប្ផមុត្តមំ
ពុទ្ធស្ស អភិរោបេសិំ សិខិនោ លោកពន្ធុនោ ។
ឥមាយ បុប្ផបូជាយ ចេតនាបណិធីហិ ច
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ចត្តឹសតិម្ហិ កប្បម្ហិ ចត្តារស្សុ មហាយសា[១]
សត្តរតនសម្បន្នា រាជានោ ចក្កវត្តិនោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

១ ម. ចត្តារាសុំ មហាយសោ ។





## សុមនវេត្តាបទាន ទី ៩

(៧១) ក្នុងគ្រានោះ ខ្ញុំជាជាងមាលាការ (អ្នកធ្វើកម្រងផ្កា) ឈ្មោះសុមនៈ បានឃើញព្រះពុទ្ធ មានធូលីគឺកិលេសប្រាសចេញហើយ ព្រះអង្គជាអ្នកទទួលនូវគ្រឿងបូជា របស់សត្វលោក ។ ខ្ញុំលើកផ្កា នូវផ្កាមួយដ៏ឧត្តម ដោយដៃទាំងពីរ បញ្ជូនថ្វាយព្រះពុទ្ធព្រះនាមសិខី ព្រះអង្គជាផៅពង្សនៃលោក ។ ខ្ញុំមិនដែលស្គាល់ទុគ្គតិ ដោយការបូជាផ្កានេះផង ដោយការតាំងចេតនានេះផង នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៤៦ ខ្ញុំបានជាស្ដេចចក្រពត្តិ ៤ អង្គ ព្រះនាមមហាយសៈ ប្រកបដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា សុមនោ ថេរោ ឥមា គាថា-
យោ អភាសិត្ថាតិ ។

សុមនត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ បុប្ផចង្កោដិយត្ថេរាបទានំ

(៧៤) អភីតរូបំ សីហំវ    គរុឡគ្គំវ បក្ខិនំ
ព្យគ្ឃូសភំវ បវរំ    អភិជាតំវ កេសរឹ ។
សិខឹ តិលោកសរណំ    អនេជំ អបរាជិតំ
និសិន្នំ សមណគ្គំ    ភិក្ខុសង្ឃបុរក្ខតំ ។
ចង្កោដកេ ឋបេត្វាន    អនោជំ បុប្ផមុត្តមំ
សហាចង្កោដកេនេវ    ពុទ្ធសេដ្ឋំ សមោកិរឹ ។
តេន ចិត្តប្បសាទេន    ទិបទិន្ទ នរាសភ
បត្តោម្ហិ អចលំ ឋានំ    ហិត្វា ជយបរាជយំ ។
ឯកត្តឹសេ ឥតោ កប្បេ    យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ    ពុទ្ធបូជាយិទំ ផលំ ។



បានឮថា ព្រះសុមនត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមនត្ថេរាបទាន ។

## បុប្ផចង្កោដិយត្ថេរាបទាន ទី ១០

(៧៤) (ខ្ញុំបានឃើញ) ព្រះពុទ្ធព្រះនាមសិខី ព្រះអង្គមានសភាពមិនខ្លបខ្លាច ដូចសីហៈ ដូចគ្រុឌប្រសើរជាងពួកបក្សី ដូចខ្លាធំដ៏ល្អប្រសើរ ដូចកេសររាជសីហ៍ មានជាតិខ្ពង់ខ្ពស់ ព្រះអង្គជាសរណៈនៃលោកទាំង ៣ មិនញាប់ញ័រ ទ្រង់ឈ្នះមារ ប្រសើរជាងពួកសមណៈ ទ្រង់គង់នៅ ដោយមានភិក្ខុសង្ឃចោមរោម ។ ខ្ញុំបានដាក់ផ្កាខនោង ដ៏ប្រសើរក្នុងប្រអប់ ហើយថ្វាយទាំងប្រអប់ផ្កា ចំពោះព្រះពុទ្ធ ជាបុគ្គលប្រសើរ ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជានរាសភៈ ខ្ញុំលះបង់នូវការឈ្នះនិងការចាញ់ ហើយដល់នូវទីមិនកម្រើក គឺព្រះនិព្វាន ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើបូជាកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

សម្បុណ្ណោ តីសកប្បម្ហិ   ទេវត្តិសជាមកា
សត្តរតនសម្បន្នា   បញ្ចាសឹ ចក្កវត្តិនោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បុប្ផចង្កោដិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុប្ផចង្កោដិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

សកចិន្តី អវោបុប្ផី   បច្ចាគមនេន ច
បរប្បសាទកិសទោ   សុចិន្តិ វត្ថទាយកោ ។
អម្ពទាយី ច សុមនោ   បុប្ផចង្កោដិយោបិ ច
គាថាយោ សត្តតិ វុត្តា   គណិតា អត្ថទស្សិភិ ។

សកចិន្តិយវគ្គោ សត្តមោ ។

---



ក្នុងកប្បទី ៣០ គត់ ខ្ញុំបានជាស្តេចចក្រពត្តិ ៥ អង្គ ព្រះនាម ទេវគន្ធិសៈ ទ្រង់បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផចង្កោដិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុប្ផចង្កោដិយត្ថេរាបទាន ។

## ឧទ្ទាន

សកចិន្តនិយត្ថេរាបទាន ១ អវោបុប្ផិយត្ថេរាបទាន ១ បច្ចាគមនិយត្ថេរាបទាន ១ បរប្បសាទកត្ថេរាបទាន ១ ភិសទាយកត្ថេរាបទាន ១ វត្ថទាយកត្ថេរាបទាន ១ អម្ពទាយកត្ថេរាបទាន ១ សុមនត្ថេរាបទាន ១ បុប្ផចង្កោដិយត្ថេរាបទាន ១ ឯគាថាទាំងឡាយ ជាគ្រឿងសម្តែងនូវអត្ថ ដែលលោករាប់ហើយ កប់ទៅឃើញ ៧០ គាថា ។

ចប់ សកចិន្តនិយវគ្គ ទី ៧ ។

---

## អដ្ឋមោ នាគសមាលវគ្គោ

### បឋមំ នាគសមាលត្ថេរាបទានំ

(៧៣) អាបាដលឹ អហំ បុប្ផំ ឧជ្ឈិតំ សុមហាបថេ
ថូបម្ហិ អភិរោបេសឹ សិខិនោ លោកពន្ធុនោ ។
ឯកត្តឹសេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ថូបបូជាយិទំ ផលំ ។
ឥតោ បណ្ណរសេ កប្បេ ភូមិយោ នាម ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា នាគសមាលោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

នាគសមាលត្ថេរស្ស អបទានំ សមត្តំ ។

## នាគសមាលវគ្គ ទី ៨

### នាគសមាលត្ថេរាបទាន ទី ១

(៧៣) ខ្ញុំបានរើសផ្កាដែលគេបោះចោលក្នុងផ្លូវធំ ហើយបូជាព្រះស្តូបរបស់ព្រះសិខី ជាផៅពង្សនៃលោក ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់នូវទុគ្គតិ នេះជាផលនៃការបូជាចំពោះព្រះស្តូប ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ព្រះនាមភូមិយៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាគសមាលត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នាគសមាលត្ថេរាបទាន ។

## ទុតិយំ បទសញ្ញកត្ថេរាបទានំ

[៧៦] អក្កន្តញ្ច បទំ ទិស្វា  តិស្សស្សាទិច្ចពន្ធុនោ
ហដ្ឋោ ហដ្ឋេន ចិត្តេន  បទេ ចិត្តំ បសាទយឹ ។
ទ្វេនវុតេ ឥតោ កប្បេ  យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ  បទសញ្ញាយិទំ ផលំ ។
ឥតោ សត្តមកេ កប្បេ  សុមេធោ នាម ខត្តិយោ
សត្តរតនសម្បន្នោ  ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បទសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។



## បទសញ្ញកត្ថេរាបទានទី២

[៧៦] ខ្ញុំបានឃើញស្នាមព្រះបាទ របស់ព្រះតិស្សសម្មាសម្ពុទ្ធ ព្រះអង្គជាព្រះអាទិច្ចពន្ធុ ទ្រង់ជាន់ទុកហើយ ខ្ញុំមានចិត្តត្រេកអររីករាយ បានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះស្នាមព្រះបាទនោះ ។ ក្នុងកប្បទី៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសេចក្តីសំគាល់ ក្នុងស្នាមព្រះបាទ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសំគាល់ក្នុងស្នាមនៃព្រះបាទ ។ ក្នុងកប្បទី៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ឈ្មោះសុមេធៈ ជាស្តេចចក្រពត្តិ មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ៧ប្រការ ។ បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទសញ្ញកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទសញ្ញកត្ថេរាបទាន ។

## តតិយំ សុសញ្ញកត្ថេរាបទានំ

(៧៨) ទុមគ្គេ បំសុកូលិកំ លគ្គំ ទិស្វាន សត្ថុនោ

តតោ ហំ អញ្ជលិំ កត្វា បំសុកូលំ អវន្ទហំ ។

ឆន្នវុតេ ឥតោ កប្បេ យំ កម្មមករិំ តទា

ទុគ្គតិំ នាភិជានាមិ បំសុសញ្ញាយិទំ ផលំ ។

ឥតោ ចតុត្ថកេ កប្បេ ទុមសារោ សុ ខត្តិយោ

ចាតុរន្តោ វិជិតាវី ចក្កវត្តិ មហព្វលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សុសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។



## សុសញ្ញកត្ថេរាបទាន ទី ៣

(៧៨) ខ្ញុំឃើញសំពត់បង្សុកូល របស់ព្រះសាស្តា ដែលព្រះអង្គពាក់ទុកលើចុងមែកឈើ សំដាប់នោះ ខ្ញុំធ្វើនូវអញ្ជលីថ្វាយបង្គំ ចំពោះសំពត់បង្សុកូល ។ ក្នុងកប្បទី ៩៦ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់នូវទុគ្គតិ នេះជាផលនៃការសំគាល់នូវសំពត់បង្សុកូល ។ ក្នុងកប្បទី ៤ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រឈ្មោះទុមសារៈ ជាស្តេចចក្រពត្តិ មានកម្លាំងច្រើន មានសមុទ្រទាំង ៤ ជាព្រំប្រទល់ ជាស្តេចមានជ័យជំនះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុសញ្ញកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុសញ្ញកត្ថេរាបទាន ។

## ចតុត្ថំ ភិសាលុវទាយកត្ថេរាបទានំ

[៧៦] កាននំ វនមោគ្គយ្ហ  វសាមិ បវនេ អហំ
វិបស្សឹ អទ្ទសំ ពុទ្ធំ  អាហុតីនំ បដិគ្គហំ ។
ភិសាលុវញ្ច ទាទាសឹ  ឧទកំ ហត្ថធោវនំ
វន្ទិត្វា សិរសា បាទេ  បក្កាមិំ ឧត្តរាមុខោ ។
ឯកនវុតេ ឥតោ កប្បេ  ភិសាលុវំ អទឹ តទា(១)
ទុគ្គតឹ នាភិជានាមិ  បុញ្ញកម្មស្សិទំ ផលំ ។
ឥតោ ច តតិយេ កប្បេ  ភិសសម្មតខត្តិយោ
សត្តរតនសម្បន្នោ  ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភិសាលុវទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភិសាលុវទាយកត្ថេរស្ស អបទានំ សមត្តំ ។

ឆដ្ឋំ ភាណវារំ ។

១ ម. កត្ថចិ បោត្ថកេ ភិសាលមទុំ ឥតិ ទិស្សតិ ។



## ភិសាលុវទាយកត្ថេរាបទាន ទី ៤

[៧៦] ខ្ញុំចូលទៅក្នុងព្រៃធំ ហើយនៅក្នុងព្រៃ បានឃើញព្រះពុទ្ធព្រះនាមវិបស្សី ព្រះអង្គគួរទទួលគ្រឿងបូជា ។ ខ្ញុំបានថ្វាយក្រអៅឈូក និងទឹកសម្រាប់លាងព្រះហស្ត ខ្ញុំថ្វាយបង្គំចំពោះព្រះបាទាដោយត្បូង ហើយបែរមុខទៅកាន់ទិសខាងជើង ដើរចៀសចេញទៅ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយក្រអៅឈូក ក្នុងកាលនោះ ខ្ញុំក៏មិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៣ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ឈ្មោះភិសសម្មតៈ ជាស្តេចចក្រពត្តិ មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ៧ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភិសាលុវទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភិសាលុវទាយកត្ថេរាបទាន ។

ចប់ ភាណវារៈ ទី ៦ ។

## បញ្ចមំ ឯកសញ្ញកត្ថេរាបទានំ

[៧៧] ខណ្ឌោ នាមាសិ នាមេន វិបស្សិស្សគ្គសាវកោ
ឯកា ភិក្ខា មយា ទិន្នា លោកាហុតិបដិគ្គហោ ។
តេន ចិត្តប្បសាទេន ទិបទិន្ទ នរាសភ
ទុគ្គតឹ នាភិជានាមិ ឯកភិក្ខាយិទំ ផលំ ។
ចត្តាឡីសេ ឥតោ កប្បេ វរុណោ នាម ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។



## ឯកសញ្ញកត្ថេរាបទានទី ៥

[៧៧] ព្រះអគ្គសាវ័ក របស់ព្រះវិបស្សីសម្ពុទ្ធ មាននាមថាខណ្ឌត្ថេរ ជាអ្នកគួរទទួលនូវគ្រឿងបូជា របស់សត្វ-លោក ខ្ញុំបានថ្វាយភិក្ខាមួយមុខ (ចំពោះអគ្គសាវ័កនោះ) ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជានរាសភៈ ខ្ញុំមិនដែលស្គាល់ទុគ្គតិ ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ នេះជាផលនៃការថ្វាយភិក្ខាមួយមុខ ។ ក្នុងកប្បទី ៤០ អំពីកប្បនេះ ខ្ញុំបានជាក្សត្រឈ្មោះវរុណៈ បានជាស្តេចចក្រពត្តិ មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកសញ្ញកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកសញ្ញកត្ថេរាបទាន ។

## ឆដ្ឋំ តិណសន្ថារទាយកត្ថេរាបទានំ

(៧៨) ហិមវន្តស្ស អវិទូរេ   មហាជាតស្សរោ អហុ
សតបត្តេហិ(១) សញ្ឆន្នោ   នានាសកុណមាលយោ ។
តម្ហិ ន្ហាត្វា ច បិត្វា ច   អវិទូរេ វសាមហំ
អទ្ទសំ សមណានន្ទំ   គច្ឆន្តំ អនិលញ្ជសេ ។
មម សង្កប្បមញ្ញាយ   សត្ថា លោកេ អនុត្តរោ
អព្ភតោ ឱរោហិត្វាន   ភូមិយំ ឋាសិ តាវទេ ។
លាយនេន តិណំ គយ្ហ   និសីទនមទាសហំ
និសីទិ ភគវា តត្ថ   តិលោកបតិ នាយកោ ។
សកំ ចិត្តំ បសាទេត្វា   អវន្ទិំ លោកនាយកំ
ឧក្កុដិកោ អវសក្កិំ   និជ្ឈាយន្តោ មហាមុនិំ ។
តេន ចិត្តប្បសាទេន   និម្មានំ ឧបបជ្ជហំ
ទុគ្គតឹ នាភិជានាមិ   សន្ថារស្ស ឥទំ ផលំ ។

១ សតបត្តេហីតិ ភវតិ ។



## តិណសន្ថារទាយកត្ថេរាបទាន ទី ៦

(៧៨) មានស្រះកើតឯងធំមួយ នៅក្បែរទីជិតនៃព្រៃហិមពាន្ត ជាស្រះដេរដាសដោយឈូកជាតិឈ្មោះសតបត្តៈ(១) ជាលំនៅនៃបក្សីផ្សេងៗ ។ ខ្ញុំងូតផង ផឹកផង ក្បែរស្រះនោះ ហើយនៅក្បែរទីមិនឆ្ងាយ ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គប្រសើរបស់ពួកសមណៈ កំពុងស្តេចទៅ ក្នុងអាកាស ។ ព្រះសាស្តា ព្រះអង្គប្រសើរបំផុតក្នុងលោក បានជ្រាបបំណងរបស់ខ្ញុំ ហើយទ្រង់យាងចុះអំពីអាកាស មកប្រថាប់លើផែនដីក្នុងខណៈនោះ ។ ខ្ញុំបានយកកណ្តៀវច្រូតស្មៅ មកថ្វាយជាគ្រឿងគង់ ឯព្រះមានព្រះភាគ ព្រះអង្គជាម្ចាស់នៃលោកទាំង ៣ ជានាយក គង់លើស្មៅនោះ ។ ខ្ញុំបានញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយថ្វាយបង្គំព្រះលោកនាយក រួចដើរថយក្រោយ សំឡឹងមើលព្រះពុទ្ធ ជាមហាមុនី ។ ខ្ញុំក៏បានទៅកើតឯឋាននិម្មានរតី ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាល ។

១ ពាក្យ សតបត្តៈ នេះ ជាឈ្មោះឈូកដែលដុះនៅក្នុងទឹក មានស្លឹក ៥ ឬស្លឹកមានដែកពី ឬក៏ឈ្មោះមានត្របក ៣ ។

ឥតោ ទុតិយកេ កប្បេ មិគ្គសម្មតខត្តិយោ

សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិណសន្ថារទាយកោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

តិណសន្ថារទាយកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ សូចិទាយកត្ថេរាបទានំ

(៧៨) តិំសកប្បសហស្សម្ហិ សម្ពុទ្ធោ លោកនាយកោ

សុមេធោ នាម នាមេន ទ្វត្តិំសវរលក្ខណោ ។

តស្ស កញ្ចនវណ្ណស្ស និបនិដ្ឋស្ស តាទិនោ

បញ្ច សូចី មយា ទិន្នា សិព្វនត្ថាយ ចីវរំ ។





ក្នុងកប្បទី ២ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ឈ្មោះមិគ្គសម្មតៈ ជាស្តេចចក្រពត្តិ មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណសន្ថារទាយកត្ថេរ មានអាយុ បាន សំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណសន្ថារទាយកត្ថេរាបទាន ។

## សូចិទាយកត្ថេរាបទាន ទី ៧

(៧៨) ក្នុងកប្បទី ៣០.០០០ ព្រះសម្ពុទ្ធជានាយកនៃលោក ព្រះនាមសុមេធៈ មានព្រះលក្ខណៈ ៣២ ប្រការ ដ៏ប្រសើរ (កើតឡើង) ។ ខ្ញុំបានប្រគេនម្ជុល ៥ ចំពោះព្រះសុមេធៈ ជាធំជាងសត្វជើងពីរនោះ ព្រះអង្គមានសម្បុរដូចមាស មានព្រះហឫទ័យនឹងនួន ដើម្បីប្រយោជន៍ដល់ការដេរចីវរ ។

តេនេវ សុចិណ្ណេន   និបុណត្ថវិបស្សកំ
តិក្ខលហុញ្ញជាសុញ្ញ   ញាណំ មេ ឧបបជ្ជថ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
ធារេមិ អន្តិមំ ទេហំ   សម្មាសម្ពុទ្ធសាសនេ ។
ទិបជាធិបតិ នាម   រាជានោ ចតុរោ អហុំ
សត្តរតនសម្បន្នា   ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុចិណ្ណាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុចិតាយកត្ថេរស្ស អបទានំ សមត្តំ ។



ប្រាជ្ញាញាណដ៏មុតរហ័សផង ជាគ្រឿងឃើញច្បាស់នូវអត្ថដ៏ល្អិតផង ជាសុខសប្បាយផង បានកើតឡើងដល់ខ្ញុំ ព្រោះការថ្វាយនូវម្សៅនោះឯង ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញអស់ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនា នៃព្រះសម្មាសម្ពុទ្ធ ។ ខ្ញុំបានជាព្រះរាជា ៤ ដង ឈ្មោះទិបពាធិបតី ដូចគ្នា ជាស្តេចចក្រពត្តិ ប្រកបដោយកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុចិតាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុចិតាយកត្ថេរាបទាន ។

## អដ្ឋមំ បាដលិបុប្ផិយត្ថេរាបទានំ

(៨០) សុវណ្ណវណ្ណំ សម្ពុទ្ធំ គច្ឆន្តំ អន្តរាបណេ
កញ្ចនគ្ឃិយសង្កាសំ ទ្វត្តិំសវរលក្ខណំ ។
សេដ្ឋិបុត្តោ តទា អាសឹ សុខុមាលោ សុខេធិតោ
ឧច្ឆង្គេ បាដលីបុប្ផំ កត្វា តំ អភិរោបយឹ ។
ហដ្ឋោ ហដ្ឋេន ចិត្តេន បុប្ផេហិ អភិបូជយឹ
តិស្សំ លោកវិទុំ នាថំ នរទេវំ នមស្សហំ ។
ទ្វេនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ បុប្ផបូជាយិទំ ផលំ ។
ឥតោ តេសដ្ឋិកប្បម្ហិ អភិសម្មតនាមកោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។



## បាដលិបុប្ផិយត្ថេរាបទាន ទី ៨

(៨០) (ខ្ញុំបានឃើញ) ព្រះសម្ពុទ្ធ ព្រះអង្គមានសម្បុរដូចជាសម្បុរមាស កំពុងយាងទៅក្នុងចន្លោះផ្សារ មានព្រះលក្ខណៈ៣២ ប្រការដ៏ប្រសើរ ដូចជាចេតិយមាស ។ ក្នុងគ្រានោះ ខ្ញុំកើតជាសេដ្ឋីបុត្រ ជាសុខុមាលជាតិ បីតនៅក្នុងសេចក្តីសុខ បានដាក់ផ្កាប្រទាលឡៀនក្នុងថក់ ហើយបង្អោនផ្កានោះ (ថ្វាយព្រះអង្គ) ។ ខ្ញុំជាអ្នកមានចិត្តរីករាយស្រស់ស្រាយ បានបូជាផ្កានោះ ព្រមទាំងនមស្ការចំពោះព្រះពុទ្ធព្រះនាមតិស្សៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ទ្រង់ជាទីពឹង ជាវិសុទ្ធិទេព របស់ពួកជន ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើនូវបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការបូជាផ្កា ។ ក្នុងកប្បទី ៦៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មានព្រះនាមថាអភិសម្មតៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា បាដលិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បាដលិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ ឋិតញ្ជលិយត្ថេរាបទានំ

(៨១) មិគលុទ្ទោ បុរេ អាសឹ អរញ្ញេ កាននេ អហំ
តត្ថទ្ទសាសឹ សម្ពុទ្ធំ ទ្វត្តឹសវរលក្ខណំ ។
តស្សាហំ អញ្ជលឹ កត្វា បក្កាមឹ បាចិនាមុខោ
អវិទូរេ និសិន្នស្ស និយតេ បណ្ណសន្ថរេ[១] ។
តតោ មេ អសនីបាតោ មត្ថកេ និបតី តទា
សោហំ មរណកាលម្ហិ អកាសឹ បុនរញ្ជលឹ ។
ចតុន្នវុតេ ឥតោ កប្បេ អញ្ជលឹ អករឹ តទា
ទុគ្គតឹ នាភិជានាមិ អញ្ជលិស្ស ឥទំ ផលំ ។
ចតុបញ្ញាសកប្បម្ហិ មិគកេតុសនាមកោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។

១ ម. បណ្ណសន្ថកេ ។



បានឮថា ព្រះបាដលិបុប្ផិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បាដលិបុប្ផិយត្ថេរាបទាន ។

## ឋិតញ្ជលិយត្ថេរាបទាន ទី ៩

(៨១) ក្នុងកាលមុន ខ្ញុំជាព្រានម្រឹគនៅក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធមានព្រះលក្ខណ ៣២ ដ៏ប្រសើរ ក្នុងទីនោះ ។ ខ្ញុំធ្វើអញ្ជលីចំពោះព្រះអង្គ ព្រះអង្គគង់នៅលើកម្រាលស្លឹកឈើដែលខ្ញុំតាក់តែងទុក ក្នុងទីមិនឆ្ងាយអំពីទីនោះ ហើយខ្ញុំបែរមុខឆ្ពោះទៅទិសខាងកើត ដើរចៀសចេញទៅ ។ លំដាប់នោះ ការធ្លាក់ផ្គររន្ទះ ក៏ធ្លាក់ត្រូវក្បាលខ្ញុំ ក្នុងកាលនោះ ខ្ញុំក៏បានធ្វើអញ្ជលីម្ដងទៀត ក្នុងកាលជិតស្លាប់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវអញ្ជលីកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអញ្ជលីកម្ម ។ ក្នុងកប្បទី ៥៤ ខ្ញុំបានជាស្ដេចចក្រពត្តិព្រះនាមមិគកេតុ មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។

បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បិតញ្ញលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បិតញ្ញលិយត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ តិណបទុមិយត្ថេរាបទានំ

(៩៦) បទុមុត្តរោ នាម ជិនោ　　សព្វធម្មាន បារគូ
ទន្តោ ទន្តបរិវុតោ　　នគរា និក្ខមី តទា(១) ។
នគរេ ហំសវតិយា　　អហោសិំ មាលិកោ តទា
យំ តត្ថ ឧត្តមំ តីណិ　　បទុមបុប្ផានិ អគ្គហឹ ។
អទ្ទសំ វិរជំ ពុទ្ធំ　　បដិមគ្គន្តរាបណេ
សហ ទិស្វាន សម្ពុទ្ធំ　　សំវិគ្គោហំ តទា ។

១ ម. និគោ ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិតញ្ញលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បិតញ្ញលិយត្ថេរាបទាន ។

## តិណបទុមិយត្ថេរាបទាន ទី ១០

(៩៦) គ្រានោះ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់មានឥន្ទ្រិយទូន្មានហើយ ដែលសាវកមានឥន្ទ្រិយទូន្មានហើយចោមរោម ទ្រង់ស្តេចចេញអំពីទីក្រុង ។ គ្រានោះ ខ្ញុំជានាយមាលាការ ក្នុងក្រុងហង្សវតី បានកាន់ផ្កាឈូក ៣ ដែលជាផ្កាដ៏ឧត្តមក្នុងផ្កាទាំងនោះ ។ ក្នុងគ្រានោះ ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គមានធូលី គឺកិលេសប្រាសចេញហើយ ក្នុងចន្លោះផ្សារ ត្រង់ផ្លូវបត្តានោះ លុះឃើញព្រះសម្ពុទ្ធហើយ បានគិតយ៉ាងនេះថា

កឹ មេ ឥមេហិ បុប្ផេហិ   រញ្ញោ ឧបដ្ឋិតេហិ មេ
គាមំ វា គាមខេត្តំ វា   សហស្សំ វា លភេយ្យហំ ។
អនគ្គនមកំ វីរំ   សព្វសត្តសុខាវហំ
លោកនាថំ បូជេត្វា   លច្ឆាមិ អមតន្ទទំ ។
ឯវាហំ ចិន្តយិត្វាន   សកំ ចិត្តំ បសាទយឹ
តីណិ លោហិតកេ គយ្ហ   អាកាសេ ឧក្ខិបឹ តទា ។
មយា ឧក្ខិត្តមត្តម្ហិ   អាកាសេ បត្ថរឹសុ តេ
ធារឹសុ មត្ថកេ តត្ថ   ឧទ្ធំវណ្តា អធោមុខា ។
យេ កេចិ មនុជា ទិស្វា   ឧក្កុដ្ឋឹ សម្បវត្តយុំ
ទេវតា អន្តលិក្ខម្ហិ   សាធុការំ បវត្តយុំ ។



អញមានប្រយោជន៍ដូចម្តេច ដោយផ្កានេះ ដែលអញថ្វាយដល់ព្រះរាជា (ព្រោះបើថ្វាយ) អញបានតែត្រឹមស្រុក ១ ឬខេត្តរបស់ស្រុក ១ ឬទ្រព្យមួយពាន់ប៉ុណ្ណោះ ។ បើអញបូជាព្រះលោកនាថ ជាវីរបុរស អ្នកឈ្នះនូវបុគ្គលដែលមិនមានអ្នកឈ្នះ ព្រះអង្គនាំមកនូវសុខ ដល់សត្វទាំងពួងវិញ រមែងបាននូវទ្រព្យគឺអមតៈ ។ លុះខ្ញុំគិតយ៉ាងនេះហើយ ក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា កាលនោះ ខ្ញុំក៏បានយកផ្កាឈូកក្រហម ៣ បោះឡើងទៅក្នុងអាកាស ។ ផ្កាទាំងនោះដែលខ្ញុំគ្រាន់តែបោះឡើងទៅ ក៏ទ្រនៅលើអាកាស មានទងឡើងលើ មានមុខសំយុងចុះមកក្រោម តាំងនៅនាលើព្រះសិរ្សៈនៃព្រះពុទ្ធ ក្នុងទីនោះ ។ ពួកមនុស្សណាមួយបានឃើញហើយ ក៏នាំគ្នាញុំាងសម្លេងហ៊ោកឹកកង ឲ្យប្រព្រឹត្តទៅ ទាំងពួកទេវតា ក៏ញុំាងសាធុការឲ្យប្រព្រឹត្តទៅក្នុងអាកាសផង

អជ្ជុំ លោកេ ឧប្បន្នំ ពុទ្ធសេដ្ឋស្ស ភាសតោ
សព្វេ ជម្ពុ សុណិស្សាម បុញ្ញានំ ភាសតា មយំ ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
វិជិយត្វា ហិតោ សត្ថា ឥមា គាថា អភាសថ ។
យោ សោ ពុទ្ធំ អបូជេសិ រត្តបទ្មេហិ មាណវោ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
តិំសកប្បសហស្សានិ ទេវលោកេ រមិស្សតិ
តិំសក្ខត្តុ (១) ទេវិន្ទោ ទេវរជ្ជំ ការិស្សតិ ។
មហាវិត្ថារិកំ នាម ព្យម្ហំ ហេស្សតិ តាវទេ
តិយោជនសមុព្វិទ្ធំ និយ្យូហសតវិត្ថតំ ។
ចត្តារិ សតសហស្សានិ និយ្យូហា ច សុមាបិតា
កូដាគារវរូបេតា មហាសយនមណ្ឌិតា ។

១ ម. តិំសក្ខត្តុំ ។





ហេតុអស្ចារ្យ កើតហើយក្នុងលោក យើងទាំងអស់គ្នា នឹងស្តាប់ព្រះធម៌ តាមហេតុនៃព្រះពុទ្ធ ជាបុគ្គលប្រសើរ តាមហេតុនៃផ្កាទាំងឡាយ ។ ឯព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក គួរទទួលនូវគ្រឿងបូជា ទ្រង់ឈរក្នុងជុំ ត្រាស់នូវគាថាទាំងនេះថា

មាណពណា បានបូជាចំពោះព្រះពុទ្ធ ដោយផ្កាឈូកក្រហម តថាគតនឹងសំដែងសរសើរ នូវមាណពនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសំដែងចុះ ។ មាណពនេះនឹងរីករាយ ក្នុងទេវលោក អស់ ៣០ ពាន់កប្ប នឹងបានជាធំជាងទេវតា សោយទេវរជ្ជសម្បត្តិ អស់ ៣០ ដង ។ វិមាន ឈ្មោះមហាវិត្ថារិកៈ មានកំពស់ ៣០០ យោជន៍ ទទឹង ១៥០ យោជន៍ នឹងផុសឡើង (សម្រាប់មាណពនេះ) ក្នុងខណៈនោះ ។ ផ្ទះប្រាង្គទាំងឡាយ មានប្រមាណ ៤ សែន ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ សឹងប្រដាប់ដោយសេយ្យាសនៈដ៏ប្រសើរ ដែលបុគ្គលតម្កល់ល្អហើយ ។

កោដិសតសហស្សាយោ បរិវារេន្តិ អច្ឆរា

កុសលា នច្ចគីតស្ស វាទិតេ ច បទក្ខិណា ។

ឯតាទិសេ ព្យម្ហវរេ នារីគណសមាកុលេ

វស្សិស្សតិ បុប្ផវស្សា ទិព្វា លោហិតកោ គណា(១) ។

កិត្តិទិលេ ឆាកនន្ទេ ទ្វារពាហេ ច តោរណេ

ចក្កមត្តា លោហិតកា ឱលម្ពិស្សន្តិ តាវទេ ។

បត្តេន បត្តសញ្ឆន្នេ អន្តោ ព្យម្ហវរេ មមំ

អត្ថរិត្វា ចារុបិត្វា កុវដ្ឋិស្សន្តិ តាវទេ ។

ភវនំ បរិវារេត្វា សមន្តា សតយោជនំ(២)

តេ វិសុទ្ធា លោហិតកា ទិព្វគន្ធំ(៣) បវាយរេ ។

បញ្ចសត្តតិក្ខត្តុញ្ច ចក្កវត្តិ ភវិស្សតិ

បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។

---

១ ម. បទលោហិតកោ សត ។ ២ ម. សតយោជនេ ។ ៣ ម. កន្ទំ យោគ្គកេ ទិព្វគន្ធំ ទិស្សតិ ។



ពួកស្រីអប្សរប្រមាណមួយសែនកោដិ ជាអ្នកឈ្លាសក្នុងការរាំនិងការច្រៀងផង ក្នុងការប្រគំផង រមែងចោមរោមព្រៀបត្រាជានិច្ច ។ ក្នុងគ្រានោះ ភ្លៀងជាផ្កានៃផ្កាទិព្វមានពណ៌ក្រហម ក៏បង្អុរចុះលើវិមានដ៏ប្រសើរ ប្រាកដដូចជាដែលកុះករដោយពួកនារី ។ ផ្កាឈូកក្រហម ប៉ុនកង់រទេះសំយុងចុះគ្រង់សសរដញ្ចាំងផង គ្រង់ថែវករផង គ្រង់មេទ្វារផង គ្រង់ក្លោងទ្វារផង ក្នុងខណៈនោះ ។ ផ្កាឈូកទាំងនោះគ្រាលបិទបាំងនូវលំនៅនេះ ជាវិមានប្រសើរ ដែលគ្រោងគ្រាតដោយស្លឹកឈើគ្របពណ៌ វិលវន់នៅខាងក្នុង ក្នុងខណៈនោះ ។ ផ្កាឈូកក្រហមសុទ្ធទាំងនោះ ក៏ចូលនូវលំនៅមានប្រមាណ ១០០ យោជន៍ជុំវិញ ហើយផ្សាយនូវក្លិនជាទិព្វ ។ មាណពនេះ នឹងបានជាស្តេចចក្រពត្តិ អស់ ៧៥ ដង (នឹងសោយ) ប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាគ័ណនាមិនអស់ ។

## ទសមំ តិបទុមិយត្ថេរាបទានំ

សម្បត្តិយោ ទុវេ ភុត្វា　　អនីតិ អនុបទ្ទវោ
សម្បត្តេ បរិយោសានេ　　និព្វានំ បាបុណិស្សតិ ។
សុទិដ្ឋោ វត មេ ពុទ្ធោ　　វាណិជ្ជំ សុប្បយោជិតំ
បទ្មានិ តីណិ បូជេត្វា　　អនុភោសិំ តិសម្បទា ។
អជ្ជ មេ ធម្មបត្តស្ស　　វិប្បមុត្តស្ស សព្វសោ
សុបុប្ផិតំ លោហិតកំ　　ធារយិស្សតិ មត្ថកេ ។
មម កម្មំ កថេន្តស្ស　　បទុមុត្តរសត្ថុនោ
សតបាណសហស្សានំ　　ធម្មាភិសមយោ អហុ ។
សតសហស្សេ ឥតោ កប្បេ　　យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ　　តិណ្ណំ បទ្មានិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ　　ភវា សព្វេ សមូហតា
សព្វាសវា បរិក្ខីណា　　នត្ថិ ទានិ បុនព្ភវោ ។



## តិបទុមិយត្ថេរាបទាន ទី ១០

មានភពនោះ ទើបបានបរិភោគនូវសម្បត្តិទាំងពីរ មិនមានចង្រៃ ឧបទ្រព លុះដល់ទីបំផុត ទើបបានដល់ព្រះនិព្វាន ។

ព្រះពុទ្ធ ខ្ញុំបានឃើញច្បាស់ហើយ ពាណិជ្ជកម្ម ខ្ញុំបានប្រកបហើយ ខ្ញុំបូជានូវផ្កាឈូក ៣ ហើយ ទើបបាននូវសម្បត្តិបីប្រការ ។ ក្នុងថ្ងៃនេះ ផ្កាឈូកក្រហមរីកល្អ ទាំងលើក្បាលខ្ញុំ ដែលបាននូវធម៌ រួចស្រឡះដោយប្រការទាំងពួង ។ កាលព្រះសាស្ដា ព្រះនាមបទុមុត្តរៈ កំពុងសម្ដែងនូវបុព្វកម្មរបស់ខ្ញុំ ធម្មាភិសម័យគឺមគ្គផល ក៏កើតមានដល់ពួកសត្វ មានប្រមាណច្រើន ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ចំពោះព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្កាឈូក ៣ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំគាស់រំលើងចេញហើយ អាសវៈទាំងពួង ក៏អស់រលីងហើយ ក្នុងកាលឥឡូវនេះ ភពថ្មីមិនមានទេ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិបទុមិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិបទុមិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

ឆាតសមាលោ បទសញ្ញី សុសញ្ញា លុវទាយកោ
ឯកសញ្ញី តិណសន្ថរោ សូចិ បាដលិបុប្ផិយោ
ឋិតញ្ជលី តិបទុមី គាថាយោ បញ្ចសត្តតិ ។

ឆាតសមាលវគ្គោ អដ្ឋមោ ។

---



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិបទុមិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិបទុមិយត្ថេរាបទាន ។

## ឧទ្ទាន

ឆាតសមាលត្ថេរាបទាន ១ បទសញ្ញកត្ថេរាបទាន ១ សុសញ្ញកត្ថេរាបទាន ១ ភិសាលុវទាយកត្ថេរាបទាន ១ ឯកសញ្ញកត្ថេរាបទាន ១ តិណសន្ថារទាយកត្ថេរាបទាន ១ សូចិទាយកត្ថេរាបទាន ១ បាដលិបុប្ផិយត្ថេរាបទាន ១ ឋិតញ្ជលិយត្ថេរាបទាន ១ តិបទុមិយត្ថេរាបទាន ១ មានគាថា ៧៥ ។

ចប់ ឆាតសមាលវគ្គ ទី ៨ ។

---

## នវមោ តិមិរបុប្ផិយវគ្គោ

### បឋមំ តិមិរបុប្ផិយត្ថេរាបទានំ

[៨៣] ចន្ទភាគានទីតីរេ អនុសោតំ វជាមហំ
និសិន្នំ សមណំ ទិស្វា វិប្បសន្នមនាវិលំ ។
តស្ស(១) ចិត្តំ បសាទេសឹ(២) ឯវំ ចិន្តេសហំ តទា
តារយិស្សតិ តិណ្ណោយំ ទន្តោយំ ទមយិស្សតិ ។
អស្សាសិស្សតិ អស្សត្ថោ សន្តោ ច សមយិស្សតិ
មោចយិស្សតិ មុត្តោ ច និព្វាបេស្សតិ និព្វុតោ ។
ឯវាហំ ចិន្តយិត្វាន សិទ្ធត្ថស្ស មហេសិនោ
គហេត្វា តិមិរបុប្ផំ មត្ថកេ ឱកិរឹ តទា(៣) ។

១ ម. តត្ថ ។ ២ ម. បសាទេត្វា ។ ៣ ម. អហំ ។

## តិមិរបុប្ផិយវគ្គ ទី ៩

### តិមិរបុប្ផិយត្ថេរាបទាន ទី ១

[៨៣] ខ្ញុំដើរទៅតាមទំបណ្ដោយខ្សែទឹក ក្បែរឆ្នេរស្ទឹងចន្ទភាគា ក៏បានឃើញព្រះសមណសម្ពុទ្ធ ព្រះអង្គកំពុងគង់ មានព្រះកាយស្អាតថ្លា មិនមានសៅហ្មង ។ ខ្ញុំញ៉ាំងចិត្តឲ្យជ្រះថ្លាចំពោះព្រះអង្គនោះ ក្នុងគ្រានោះ ខ្ញុំគិតយ៉ាងនេះថា ព្រះពុទ្ធនេះ ព្រះអង្គឆ្លងរួចហើយ នឹងញ៉ាំងសត្វឲ្យឆ្លងផង ព្រះពុទ្ធនេះ មានឥន្ទ្រិយទូន្មានហើយ នឹងទូន្មាន (នូវពួកសត្វ) ផង ។ ព្រះអង្គជាអ្នកស្រស់ស្រាយ នឹងញ៉ាំងសត្វឲ្យស្រស់ស្រាយផង ព្រះអង្គជាអ្នកស្ងប់រម្ងាប់ នឹងញ៉ាំងសត្វឲ្យស្ងប់រម្ងាប់ផង ព្រះអង្គរលត់ទុក្ខហើយ នឹងញ៉ាំងសត្វឲ្យរលត់ផង ។ លុះខ្ញុំគិតយ៉ាងនេះហើយ ទើបកាន់យកនូវផ្កាតិមិរព្រឹក្ស ហើយព្រោយទៅលើព្រះសិរ្សៈនៃព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គស្វែងរកនូវគុណជាធំ ក្នុងកាលនោះ ។

អញ្ជលឹ បគ្គហេត្វាន　កត្វា ច នំ បទក្ខិណំ
វន្ទិត្វា សត្ថុនោ បាទេ　បក្កាមឹ អបរំ ទិសំ ។
អចិរំ គតមត្តំ មំ　មិគរាជា អបីឡយិ(១)
បបាតមនុគច្ឆន្តោ　តត្ថេវ បបតឹ អហំ ។
ចតុន្នវុតេ ឥតោ កប្បេ　យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ　ពុទ្ធបូជាយិទំ(២) ផលំ ។
ឆប្បញ្ញាសម្ហិ កប្បម្ហិ　សត្តាហេសុំ មហារហា
សត្តរតនសម្បន្នា　ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ　វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តិមិរបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិមិរបុប្ផិយត្ថេរស្ស អបទានំ សត្តមំ ។

---

១ ម. វិហេឋយិ ។ ២ ម. បុប្ផបូជាយិទំ ។



ខ្ញុំផ្គងអញ្ជលីធ្វើប្រទក្សិណ ចំពោះព្រះអង្គ ហើយថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា រួចដើរចេញទៅកាន់ទិសដទៃ ។ ស្តេចម្រឹគបានបៀតបៀនខ្ញុំ ដែលកំពុងតែដើរទៅ អស់កាលមិនយូរប៉ុន្មាន ខ្ញុំកាលដើរទៅតាមទីទៀបជ្រោះ ក៏ធ្លាក់ទៅក្នុងជ្រោះនោះឯង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥៦ ខ្ញុំបានជាស្តេចចក្រពត្តិ ៧ ដង ព្រះនាមមហារហៈ ប្រកបដោយកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិមិរបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិមិរបុប្ផិយត្ថេរាបទាន ។

## ទុតិយំ គតសញ្ញកត្ថេរាបទានំ

(៨៦) ជាតិយា សត្តវស្សោហំ បព្វជឹ អនគារិយំ

អវន្ទឹ សត្ថុនោ បាទេ វិប្បសន្នេន ចេតសា ។

សត្តឧប្បលកំបុប្ផេ(១) អាកាសេ ឧក្ខិបឹ អហំ

តិស្សំ ពុទ្ធំ សមុទ្ទិស្ស អនន្តគុណសាគរំ ។

សុគតានុគតំ មគ្គំ បូជេត្វា ហដ្ឋមានសោ

អញ្ជលិញ្ច តទាកាសឹ បសន្នោ សេហិ បាណិហិ ។

ទ្វេនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

ឥតោ អដ្ឋមកេ កប្បេ តយោ អគ្គិសិខា អហុ

សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា គតសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គតសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. សត្តុប្បលកំបុប្ផេ ។



## គតសញ្ញកត្ថេរាបទាន ទី ២

(៨៦) ខ្ញុំមានអាយុ ៧ ឆ្នាំ បានចូលទៅកាន់ផ្នួស បានថ្វាយបង្គំព្រះបាទានៃព្រះសាស្ដា ដោយចិត្តជ្រះថ្លា ។ ខ្ញុំបានបោះផ្កាឈើឈ្មោះសត្តុប្បលក ទៅលើអាកាស ចំពោះព្រះពុទ្ធ ព្រះនាមតិស្សៈ ព្រះអង្គមានគុណមិនមានទីបំផុត ប្រៀបដូចសាគរ ។ ខ្ញុំមានចិត្តត្រេកអរ បានបូជាផ្លូវដែលព្រះសុគតយាងមក ហើយមានចិត្តជ្រះថ្លា បានធ្វើអញ្ជលីកម្ម ដោយដៃទាំងពីរក្នុងគ្រានោះ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៨ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ៣ ដង ព្រះនាមអគ្គិសិខៈដូចគ្នា ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគតសញ្ញកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គតសញ្ញកត្ថេរាបទាន ។

## តតិយំ និបន្នញ្ជលិកត្ថេរាបទានំ

(៨៨) រុក្ខមូលេ និសិន្នោហំ ព្យាធិតោ បរមេនហំ
បរមការុញ្ញបត្តោម្ហិ អរញ្ញេ កាននេ ព្រហា ។
អនុកម្បំ ឧបាទាយ តិស្សោ សត្ថា ឧបេតិ មំ
សោហំ និបន្នកោ សន្តោ សិរេ កត្វាន អញ្ជលឹ ។
បសន្នចិត្តោ សុមនោ សព្វសត្តានមុត្តមំ
សម្ពុទ្ធំ អភិវាទេត្វា តត្ថ កាលង្កតោ អហំ ។
ទ្វេនវុតេ ឥតោ កប្បេ យំ វន្ទឹ បុរិសុត្តមំ
ទុគ្គតឹ នាភិជានាមិ វន្ទនាយ ឥទំ ផលំ ។
ឥតោ បញ្ចមកេ កប្បេ បញ្ចាសុំ មហាសិខា
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។



## និបន្នញ្ជលិកត្ថេរាបទាន ទី ៣

(៨៨) ខ្ញុំអង្គុយនៅទៀបគល់ឈើ ក្នុងព្រៃញាតស្បាតធំ ខ្ញុំត្រូវរោគដ៏ក្រៃលែងបៀតបៀន ហើយដល់នូវការគួរគេករុណាដ៏ក្រៃលែង ៗ ព្រះសាស្ដា ព្រះនាមតិស្សៈ ទ្រង់ចូលមកជិតខ្ញុំ ដោយអាស្រ័យសេចក្ដីអនុគ្រោះ ខ្ញុំនោះជាអ្នកដេកស្ងប់ស្ងៀម ហើយធ្វើអញ្ជលី (ចំពោះព្រះសាស្ដា) លើត្បូង ៗ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តល្អ បានថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះអង្គជាបុគ្គលឧត្តមជាងសត្វទាំងពួង ហើយធ្វើនូវកាលកិរិយា ក្នុងទីនោះ ៗ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយបង្គំនូវព្រះសម្ពុទ្ធ ជាបុរសឧត្តម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ៗ ក្នុងកប្បទី ៥ អំពីកប្បនេះ ខ្ញុំបានជាស្ដេចចក្រពត្តិ ៥ អង្គ ព្រះនាមមហាសិខៈដូចគ្នា ទ្រង់បរិបូណ៌ដោយរតនៈ ៧ ប្រការ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ៗ

ឥត្ថំ សុទំ អាយស្មា និបន្នញ្ជលិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

និបន្នញ្ជលិកត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ អធោបុប្ផិយត្ថេរាបទានំ

(៨៦) អភិភូ នាម សោ ភិក្ខុ សិខិនោ អគ្គសាវកោ
មហានុភាវោ តេវិជ្ជោ ហិមវន្តំ ឧបាគមិ ។
អហំបិ ហិមវន្តម្ហិ រមណីយស្សមេ ឥសិ
វសាមិ អប្បមញ្ញាសុ ឥទ្ធីសុ ច តទា វសី ។
បក្ខិជាតោ វិយាកាសេ បព្វតំ អធិបតយឹ
អធោបុប្ផំ គហេត្វាន អាគច្ឆឹ បព្វតំ អហំ ។
សត្ត បុប្ផានិ គណ្ហិត្វា មត្ថកេ ឱកិរឹ អហំ
អាលោកិតេ ច វីរេន បក្កាមឹ បាចិនាមុខោ[១] ។

១ ម. អាលោកិតេ ច វីរេន បក្កមឹ បាចិនមុខោ ។



បានឮថា ព្រះនិបន្នញ្ជលិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ និបន្នញ្ជលិកត្ថេរាបទាន ។

## អធោបុប្ផិយត្ថេរាបទាន ទី ៤

(៨៦) មានភិក្ខុមួយរូប ព្រះនាមអភិភូ ជាអគ្គសាវ័ក របស់ព្រះពុទ្ធព្រះនាមសិខី លោកមានអានុភាពច្រើន មានវិជ្ជា៣ បានចូលមកកាន់ភ្នំហិមពាន្ត ។ កាលនោះ ខ្ញុំជាឥសី ជាអ្នកស្ទាត់ក្នុងអប្បមញ្ញាធម៌និងឫទ្ធិ នៅក្នុងអាស្រមជាទីគួរត្រេកអរ ទៀបភ្នំហិមពាន្តនោះ ។ ខ្ញុំប្រាថ្នាកៅផ្កាឈើក្នុងព្រៃភ្នំ ដូចជាបក្សីកាលហើរទៅក្នុងអាកាស ខ្ញុំកាន់យកនូវផ្កាអធោពុប្ផិយ ហើយត្រឡប់មកឯភ្នំនោះវិញ ។ ខ្ញុំបានយកផ្កា៧ រោយលើព្រះសិរ្ស: (នៃអគ្គសាវ័កនោះ) លុះដល់អគ្គសាវ័ក ជាអ្នកប្រាជ្ញនោះ ក្រឡេកមើលមកចំខ្ញុំ ខ្ញុំក៏បែរមុខទៅទិសខាងកើត ហើយដើរចៀសចេញទៅ ។

អាកាសំ អភិសជ្ជេសឹ   បត្វាន អស្សមំ អហំ
ខារិភារំ គហេត្វាន   ចាយាសិំ បត្តគន្ថិំ ។
អជកកេចិ(១) ពីឡេស្សំ   យោវព្វកោ មហព្វលោ
ពុទ្ធកម្មំ សរិត្វាន   តត្ថ កាលំ កតោ អហំ ។
ឯកត្តឹសេ ឥតោ កប្បេ   យំ ពុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ   ពុប្ផបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អភយបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អភយបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ វិសិសញ្ញាកត្ថេរាបទានំ

(៨៧) បព្វតេ ហិមវន្តម្ហិ   ភិសំ កាលេ្យសហំ ពុរេ
អជិនុត្តរវាសោហំ   វសាមិ បព្វតន្តរេ ។

---
១ ម. អជិនតា ចំ ។



ខ្ញុំបានទៅដល់អាស្រមហើយ ក៏បានពាក់ចែងនូវគាវស ខ្លួន យកនូវគ្រឿងកះដើរទៅកាន់បន្ទោះភ្នំ ។ គាប់ជួន ពស់ថ្លាន់ មានរូបធំសម្បើម មានកម្លាំងច្រើន បៀតបៀន (ខ្ញុំ) ខ្ញុំក៏នឹកដល់ពុទ្ធកម្ម ហើយធ្វើកាលកិរិយា ក្នុងទីនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអភយបុប្ផិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អភយបុប្ផិយត្ថេរាបទាន ។

## វិសិសញ្ញាកត្ថេរាបទាន ទី ៥

(៨៧) ក្នុងកាលមុន ខ្ញុំសម្រេចការនៅ ក្បែរភ្នំហិមពាន្ត ខ្ញុំស្លៀកពាក់ឧត្តរសត្ថៈ ជាស្បែកខ្លា នៅក្រឹបន្ទោះភ្នំ ។

បញ្ចមំ វិសេសញ្ញកត្ថេរាបទានំ

សុវណ្ណវណ្ណំ សម្ពុទ្ធំ　　សតរំសឹវ ភាណុមំ
វនគ្គតំ ទិស្វា　　សាលរាជំវ បុប្ផិតំ ។
រំសេ ចិត្តំ បសាទេត្វា　　វិបស្សិស្ស មហេសិនោ
បគ្គយ្ហ អញ្ជលឹ វន្ទឹ　　សិរសា ឧក្កុដិកោ អហំ(១) ។
ឯកនវុតេ ឥតោ កប្បេ　　យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ　　វិសេសញ្ញាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា វិសេសញ្ញោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វិសេសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. សិរសុក្កុដិកោ អហំ ។



វិសេសញ្ញកត្ថេរាបទាន ទី ៥

ខ្ញុំឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស មានរស្មីច្រើន ដូចព្រះអាទិត្យ ឬដូចសាលព្រឹក្ស មានផ្ការីក ទ្រង់ធ្វើពុទ្ធដំណើរទៅ ក្នុងចន្លោះព្រៃ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ក្នុងរស្មីរបស់ព្រះមហេសី ព្រះនាមវិបស្សី ទើបអង្គុយច្រហោង ផ្គងអញ្ជលីថ្វាយបង្គំដោយសិរ្សៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសំគាល់នូវរស្មី ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវិសេសញ្ញកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វិសេសញ្ញកត្ថេរាបទាន ។

## ឆដ្ឋំ វិសិសញ្ញិកត្ថេរាបទានំ

(៨៨) បព្វតេ ហិមវន្តម្ហិ   វាកចីរធរោ អហំ
ចង្កមំ ច សមារូឡ្ហោ   និសីទឹ បាចិនាមុខោ ។
បព្វតេ សុគតំ ទិស្វា   ផុស្សំ ឈានគតំ សទា
អញ្ជលឹ បគ្គហេត្វាន   វិសេ ចិត្តំ បសាទយឹ ។
ចតុន្នវុតេ ឥតោ កប្បេ   យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ   វិសិសញ្ញាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វិសិសញ្ញិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វិសិសញ្ញិកត្ថេរស្ស អបទានំ សមត្តំ ។





## វិសិសញ្ញិកត្ថេរាបទាន ទី ៦

(៨៨) ខ្ញុំស្លៀកសំបកឈើ នៅលើភ្នំហិមពាន្ត ខ្ញុំឡើងកាន់ទីចង្រ្កម រួចអង្គុយបែរមុខទៅទិសខាងកើត ។ ខ្ញុំបានឃើញព្រះសុគត ព្រះនាមផុស្សៈនៅក្បែរភ្នំ ទ្រង់ត្រេកអរនឹងឈាន សព្វ ៗ កាល ហើយខ្ញុំផ្គងអញ្ជលី ញុំាងចិត្តឲ្យជ្រះថ្លាក្នុងទីស្មើ ៗ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសំគាល់ស្មើ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវិសិសញ្ញិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វិសិសញ្ញិកត្ថេរាបទាន ។

## សត្តមំ ផលទាយកត្ថេរាបទានំ

(៨៩) បព្វតេ ហិមវន្តម្ហិ ខរាជិនធរោ អហំ
ផុស្សំ ជិនវរំ ទិស្វា ផលហត្ថោ ផលំ អទំ ។
យមហំ ផលមទាសឹ វិប្បសន្នេន ចេតសា
ភវេ និព្វត្តមានម្ហិ ផលំ និព្វត្តតេ មម ។
ទ្វេនវុតេ ឥតោ កប្បេ យំ ផលំ អទទឹ អហំ
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

៤៩៣

## ផលទាយកត្ថេរាបទាន ទី ៧

(៨៩) ខ្ញុំស្លៀកស្បែកខ្លាតាំងក្រចក (នៅ) ជិតភ្នំហិមពាន្ត មានផ្លែឈើកាន់ដៃ បានឃើញព្រះជិនស្រីដ៏ប្រសើរ ព្រះនាមផុស្សៈ ហើយថ្វាយផ្លែឈើ (ចំពោះព្រះពុទ្ធនោះ) ។ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយផ្លែឈើណា កាលបើភពរបស់ខ្ញុំនៅមាន ផ្លែឈើនោះ តែងកើតដល់ខ្ញុំ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ផលទាយកត្ថេរាបទាន ។

## អដ្ឋមំ សទ្ទសញ្ញកត្ថេរាបទានំ

(៤០) បព្វតេ ហិមវន្តម្ហិ វសាមិ បណ្ណសន្ថរេ
ផុស្សស្ស ធម្មំ ភណតោ សទ្ទេ ចិត្តំ បសាទយឹ ។
ទ្វេនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ បុញ្ញកម្មស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សទ្ទសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សទ្ទសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ ពោធិសិញ្ចកត្ថេរាបទានំ

(៤១) វិបស្សិស្ស ភគវតោ មហាពោធិមហោ អហុ
បព្វជ្ជុបគតោ សន្តោ ឧបគញ្ឆិមហំ តទា ។





## សទ្ទសញ្ញកត្ថេរាបទាន ទី ៨

[៤០] ខ្ញុំនៅលើកម្រាលស្លឹកឈើ នាភ្នំហិមពាន្ត បាននាំចិត្តឲ្យជ្រះថ្លា ក្នុងសំឡេងរបស់ព្រះសម្ពុទ្ធ ព្រះនាមផុស្សៈ ដែលកំពុងសំដែងធម៌ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើនូវកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុញ្ញកម្ម ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសទ្ទសញ្ញកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សទ្ទសញ្ញកត្ថេរាបទាន ។

## ពោធិសិញ្ចកត្ថេរាបទាន ទី ៩

[៤១] មានពិធីស្រង់ព្រះមហាពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ក្នុងកាលនោះ ខ្ញុំជាអ្នកបួសមានចិត្តស្ងប់រម្ងាប់ ដើរចូលទៅ (ជិតដើមពោធិព្រឹក្សនោះ) ។

៩មំ ពោធិសិញ្ចកត្ថេរាបទានំ

កុសុម្ភោទកមាទាយ ពោធិយា ឱកិរឹ អហំ
មោចយិស្សតិ នោ មុត្តោ និព្វាបេស្សតិ និព្វុតោ ។
ឯកនវុតេ ឥតោ កប្បេ យំ ពោធឹ អភិសិញ្ចហំ(១)
ទុគ្គតឹ នាភិជានាមិ ពោធិសិញ្ចស្សិទំ(២) ផលំ ។
តេត្តឹសេ វត្តមានម្ហិ កប្បេ អាសុំ ជនាធិបា
ឧទកាសេចនា នាម អដ្ឋេតេ ចក្កវត្តិនោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ពោធិសិញ្ចកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពោធិសិញ្ចកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. ពោធិមភិសិញ្ចយិំ ។ ២ ម. ពោធិសិញ្ចាយិទំ ។



ពោធិសិញ្ចកត្ថេរាបទាន ទី ៩

ខ្ញុំដងទឹកក្រឡាំងស្រោចដើមពោធិព្រឹក្ស (ដោយគិតថា) ព្រះវិបស្សីសម្ពុទ្ធ ទ្រង់រួចចាកទុក្ខហើយ នឹងញ៉ាំងយើងឲ្យរួចទុក្ខផង ទ្រង់រលត់ទុក្ខហើយ នឹងញ៉ាំងយើងឲ្យរលត់ផង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានស្រោចស្រប់ដើមពោធិព្រឹក្ស ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្រោចពោធិព្រឹក្ស ។ កាលកប្បទី ៣៣ កំពុងប្រព្រឹត្តទៅ ខ្ញុំបានជាស្តេចចក្រពត្តិ ៨ ដង ជាធំលើពួកជន ទ្រង់ព្រះនាមឧទកាសេចនៈ ដូចគ្នា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិសិញ្ចកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពោធិសិញ្ចកត្ថេរាបទាន ។

# ទសមំ បទុមបុប្ផិយត្ថេរាបទានំ

(៩៦) ពោក្ខរវនំ បវិដ្ឋោ  ភញ្ជន្តោ បទុមានហំ
អទ្ទសំ(១) ផុស្សសម្ពុទ្ធំ  ទ្វត្តឹសវរលក្ខណំ ។
បទុមបុប្ផំ គហេត្វាន  អាកាសេ ឧក្ខិបឹ អហំ
បាបកម្មំ សរិត្វាន  បព្វជឹ អនគារិយំ ។
បព្វជិត្វាន កាយេន  មនសា សំវុតេន ច
វចីទុច្ចរិតំ ហិត្វា  អាជីវំ បរិសោធយឹ ។
ទ្វេនវុតេ ឥតោ កប្បេ  យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ  ពុទ្ធបូជាយិទំ ផលំ ។
បទុមាភាសនាមា(២)  អដ្ឋារស មហីបតី
អដ្ឋារសេសុ កប្បេសុ  អដ្ឋតាឡីសមាសិសុ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បទុមបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទុមបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

១ ឱ. អទ្ទសំ ។ ២ ឱ. បទុមាភាសមានា ច ។



# បទុមបុប្ផិយត្ថេរាបទាន ទី ១០

(៩៦) ខ្ញុំចូលទៅកាន់ព្រៃ ដែលមានស្រះឈូក កំពុងកាច់ផ្កាឈូក បានឃើញព្រះសម្ពុទ្ធ ព្រះនាមផុស្សៈ ទ្រង់មានលក្ខណៈ ៣២ ប្រការ ដ៏ប្រសើរ ។ ខ្ញុំបានយកផ្កាឈូក បោះឡើងទៅនាអាកាស (ថ្វាយព្រះអង្គ) ខ្ញុំរលឹកឃើញនូវបាបកម្មហើយ ក៏ចូលបួសក្នុងព្រះពុទ្ធសាសនា ។ លុះខ្ញុំបួសហើយ បានសង្រួមកាយនិងចិត្ត លះបង់នូវវចីទុច្ចរិត ជម្រះនូវអាជីវបារិសុទ្ធិសីល ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៨ ខ្ញុំបានកើតជាក្សត្រ ១៨ ដង និង ៤៨ ដង (៦៦) ជាធំលើផែនដី ទ្រង់ព្រះនាមបទុមភាសៈដូចគ្នា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសា-សនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទុមបុប្ផិយត្ថេរាបទាន ។

## ឧទ្ទានំ

តិមិរំ នង្គលិបុប្ផី  និបន្នញ្ជលិកោ អធោ
ទ្វេ រំសិសញ្ញី ផលទោ  សទ្ទសញ្ញី ច សេចកោ
បទុមបុប្ផី ច គាថាយោ  ឆបញ្ញាសា បកិត្តិតា ។

តិមិរបុប្ផិយវគ្គោ នវមោ ។

---



## ឧទ្ទាន

តិមិរបុប្ផិយត្ថេរាបទាន ១ គតសញ្ញកត្ថេរាបទាន ១ និបន្នញ្ជលិកត្ថេរាបទាន ១ អធោបុប្ផិយត្ថេរាបទាន ១ រំសិសញ្ញកត្ថេរាបទាន ២ ផលទាយកត្ថេរាបទាន ១ សទ្ទសញ្ញកត្ថេរាបទាន ១ ពោធិសិញ្ចកត្ថេរាបទាន ១ បទុមបុប្ផិយត្ថេរាបទាន ១ ឯគាថាចំនួន ៥៦ លោកបានសម្តែងហើយ ។

ចប់ តិមិរបុប្ផិយវគ្គ ទី ៩ ។

---

## ទសមោ សុធាវគ្គោ

### បឋមំ សុធាបិណ្ឌិយត្ថេរាបទានំ

[៤៣] បូជារហេ បូជយតោ ពុទ្ធេ យទិ វ សាវកេ
បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ ។
តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ
ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។
ចតុន្នមបិ ទីបានំ ឥស្សរំ យោធ ការយេ
ឯកិស្សា បូជនាយេតំ កលំ នាគ្ឃតិ សោឡសឹ ។
សិទ្ធត្ថស្ស នរគ្គស្ស ចេតិយេ ផុដ្ឋកន្តរេ
សុធាបិណ្ឌោ មយា ទិន្នោ វិប្បសន្នេន ចេតសា ។
ចតុន្នវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ បដិសង្ខារស្សិទំ ផលំ ។

## សុធាវគ្គ ទី ១០

### សុធាបិណ្ឌិយត្ថេរាបទាន ទី ១

[៤៣] កាលបុគ្គលបូជា ចំពោះបុគ្គលគួរបូជា គឺព្រះពុទ្ធ ឬសាវ័ក ដែលកន្លងផុតនូវធម៌ជាគ្រឿងយឺតយូរ ឆ្លងផុតនូវសេចក្តីសោកនិងការខ្សឹកខ្សួល ។ កាលបុគ្គលបូជាចំពោះបុគ្គលទាំងនោះ ដែលមានសភាពដូច្នោះ មានទុក្ខរលត់ហើយ លោកមិនមានភ័យអំពីទីណា បុគ្គលណាមួយមិនអាចនឹងរាប់បុណ្យថា បុណ្យនេះ មានប្រមាណប៉ុណ្ណេះ ឬមានប្រមាណប៉ុណ្ណោះឡើយ ។ ក្នុងលោកនេះ បុគ្គលណាមួយទទួលនូវរាជសម្បត្តិ ក្នុងទ្វីបទាំង ៤ ការទទួលនូវឥស្សរភាពនេះ របស់បុគ្គលនុ៎ះ មិនដល់មួយចំណែក ទី ១៦ នៃការបូជានេះឡើយ ។ ខ្ញុំមានចិត្តជ្រះថ្លា បានបូកបាយអក្នុងចន្លោះផ្ទៃចេតិយ របស់ព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថៈ ប្រសើរជាងពួកនរៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការជួសជុលចេតិយ ។

ឥតោ តឹសតិកប្បម្ហិ     បដិសន្ថារសវ្ហយា
សត្តរតនសម្បន្នា     តេរស ចក្កវត្តិនោ ។
បដិសម្ភិទា ចតស្សោ     វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា     កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សុជាបិណ្ឌិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុជាបិណ្ឌិយត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ សុប្បិយត្ថេរាបទានំ

(៩៦) តិស្សស្ស លោកនាថស្ស     សុទ្ធបីឋមទាសហំ
ហដ្ឋោ ហដ្ឋេន ចិត្តេន     ពុទ្ធស្សាទិច្ចពន្ធុនោ ។
អដ្ឋត្តឹសេ ឥតោ កប្បេ     រាជា អាសឹ មហារុចិ
ភោគោ ច វិបុលោ អាសិ     សយនញ្ច អនប្បកំ ។



ក្នុងកប្បទី ៣០ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ១៣ អង្គ មាននាមថាបដិសន្ថារៈ ប្រកបដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុជាបិណ្ឌិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុជាបិណ្ឌិយត្ថេរាបទាន ។

## សុប្បិយត្ថេរាបទាន ទី ២

(៩៦) ខ្ញុំមានចិត្តរីករាយ បានថ្វាយតាំងដ៏ស្អាត ចំពោះព្រះពុទ្ធ ព្រះនាមតិស្សៈជាលោកនាថ ជាផៅពង្សនៃព្រះអាទិត្យ ។ ក្នុងកប្បទី ៣៨ អំពីកប្បនេះ ខ្ញុំបានជាស្តេច ព្រះនាមមហារុចិ មានភោគៈច្រើន មានទីដេកច្រើន ។

បីឋំ ពុទ្ធស្ស ទត្វាន វិប្បសន្នេន ចេតសា
អនុភោមិ សកំ កម្មំ បុព្វេ សុកតមត្តនោ ។
ទ្វេនវុតេ ឥតោ កប្បេ យំ បីឋំ អទទឹ តទា
ទុគ្គតឹ ភិជានាមិ បីឋទានស្សិទំ ផលំ ។
អដ្ឋតឹសេ ឥតោ កប្បេ តយោ តេ ចក្កវត្តិនោ
រុចិ ឧបរុចិ ចេវ មហារុចិ តតិយកោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុបីបិយោ(១) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុបីបិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សុបិន្តកោ ។



ព្រោះតែខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយតាំង ចំពោះព្រះសម្ពុទ្ធ ទើបខ្ញុំទទួលនូវកុសលកម្មជារបស់ខ្លួន ដែលខ្លួនបានសាងល្អហើយក្នុងកាលមុន ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយតាំង ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយតាំង ។ ក្នុងកប្បទី ៣៨ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ៣ អង្គ ព្រះនាមរុចិ ១ ឧបរុចិ ១ មហារុចិ ១ ជាគំរប់ ៣ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុបីបិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុបីបិយត្ថេរាបទាន ។

## តតិយំ អន្ធប្បវេលកត្ថេរាបទានំ

(៤៨) សុស្សាហំ កតវេលា ខុបន្ធុទុស្សមធាសហំ

បរមការុញ្ញបត្តម្ហិ ទុក្ខេតេន សមប្បិតោ ។

ខុបន្ធុទុស្សំ ធត្វាន កប្បំ សគ្គម្ហិ មោទហំ

អវសេសេសុ កប្បេសុ កុសលញ្ចរិមហំ(១) ។

ឯកនវុតេ ឥតោ កប្បេ យំ ទុស្សមទទឹ តទា

ទុគ្គតឹ នាភិជានាមិ ទុស្សទានស្សិទំ ផលំ ។

ឯកបញ្ញាសកប្បម្ហិ(២) កជាតោ ចក្កវត្តិតោ

សមន្តទុទ្ធា នាម ខត្តិយាសុំ ផលាចិតា ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អន្ធប្បវេលកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អន្ធប្បវេលកត្ថេរស្ស អបទានំ និដ្ឋិតំ ។

១ ម. កុសលំ ការិតំ មយា ។ ២ ម. ឯកូនបញ្ញាសកប្បម្ហិ ។



## អន្ធប្បវេលកត្ថេរាបទាន ទី ៣

(៤៨) ខ្ញុំជាបុគ្គលពេញទៅដោយសេចក្ដីពល់ក្រ ដល់នូវភាពគួរគេអាណិតក្រៃពេក ខ្ញុំបានប្រគេនសំពត់ពាក់កណ្ដាល ចំពោះព្រះមានព្រះភាគ ព្រះនាមតិស្សៈ ។ លុះខ្ញុំថ្វាយសំ-ពត់ពាក់កណ្ដាលនោះហើយ បានរីករាយក្នុងឋានសួគ៌ អស់មួយកប្ប មិនតែប៉ុណ្ណោះ ខ្ញុំបានធ្វើកុសលកម្ម (ដទៃទៀត) ក្នុងកប្បទាំងឡាយដ៏សេសផង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយសំពត់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់ ។ ក្នុងកប្បទី ៥១ ខ្ញុំបានជាក្សត្រចក្រពត្តិ ជាធំជាងពួកជន ព្រះនាមសមន្តទុខៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ពាក្យប្រដៅ របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអន្ធប្បវេលកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អន្ធប្បវេលកត្ថេរាបទាន ។

## បត្ថំ សូចិទាយកត្ថេរាបទានំ

[៩៦] កម្មារោហំ បុរេ អាសិំ ពន្ធុមាយំ បុរុត្តមេ

សូចិទានំ មយា ទិន្នំ វិបស្សិស្ស មហេសិនោ ។

វជិរគ្គសមំ ញាណំ ហោតិ កម្មេន តាទិសំ

វិភតោម្ហិ(១) វិមុត្តោម្ហិ បត្តោម្ហិ អាសវក្ខយំ ។

អតីតា ច ភវា សព្វេ វត្តមានា ច អនាគតា

ញាណេន វិចិនី សព្វំ សូចិទានស្សិទំ ផលំ ។

ឯកនវុតេ ឥតោ កប្បេ សត្តាសុំ វជិរសមា(២)

សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សូចិទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សូចិទាយកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. វិភតោម្ហិ វិរត្តោម្ហិ ។ ២ ម. វជិរូបមា ។





## សូចិទាយកត្ថេរាបទាន ទី ៤

[៩៦] ក្នុងកាលមុន ខ្ញុំកើតជាជាងដែក ក្នុងបុរីដ៏ប្រសើរ ឈ្មោះពន្ធុមៈ ខ្ញុំបានថ្វាយម្ជុលដល់ព្រះវិបស្សី ព្រះអង្គស្វែងរកនូវគុណដ៏ធំ ។ ញាណ (របស់ខ្ញុំ) ស្មើចុងនៃកែវវជិរ ប្រាកដដូច្នោះ កើតប្រាកដ ដោយកម្មនោះ ខ្ញុំមានរាគៈវិនាសហើយ មានចិត្តរួចស្រឡះហើយ ដល់នូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ ។ អតីតភព បច្ចុប្បន្នភព អនាគតភព ទាំងអស់ណា ខ្ញុំពិចារណាឃើញភពទាំងអស់នោះ ដោយញាណ នេះជាផលនៃការថ្វាយម្ជុល ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ៧ ជំនាន់ ព្រះនាមវជិរសមៈ ដូចគ្នា បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសូចិទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ សូចិទាយកត្ថេរាបទាន ។

## បញ្ចមំ គន្ធមាលិយត្ថេរាបទានំ

(៤៧) សិទ្ធត្ថស្ស ភគវតោ　គន្ធថូបំ អកាសហំ
សុមនេហិ បដិច្ឆន្នំ　ពុទ្ធានុច្ឆវិកំ អហំ(១) ។
កញ្ចនគ្ឃិយសង្កាសំ　ពុទ្ធំ លោកគ្គនាយកំ
ឥន្ទីវរំ ជលិតំ　អាទិត្តំវ ហុតាសនំ ។
ព្យគ្ឃូសភំវ បវរំ　អភិជាតំវ កេសរឹ
និសិន្នំ សមណានគ្គំ　ភិក្ខុសង្ឃបុរក្ខតំ ។
វន្ទិត្វា សត្ថុនោ បាទេ　បក្កាមឹ ឧត្តរាមុខោ
ចតុន្នវុតេ ឥតោ កប្បេ　គន្ធមាលំ យតោ ទទឹ ។
ពុទ្ធេ កតស្ស ការស្ស　ផលេនាហំ វិសេសតោ
ទុគ្គតឹ នាភិជានាមិ　ពុទ្ធបូជាយិទំ ផលំ ។

---
១ ម. កតំ ។



## គន្ធមាលិយត្ថេរាបទាន ទី ៥

(៤៧) ខ្ញុំបានកសាងព្រះស្តូប ប្រកបដោយគ្រឿងក្រអូប ស្រោបបិទបាំងដោយផ្កាម្លិះ ដ៏សមគួរដល់ព្រះពុទ្ធ (ថ្វាយ) ចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ។ (ខ្ញុំថ្វាយបង្គំ) ព្រះសម្ពុទ្ធជាអគ្គនាយកក្នុងលោក ព្រោកផ្សាយដោយរស្មី ដូចភាជនៈនៃមាស ទ្រង់រុងរឿងដូចផ្កាកព្រឹក្ស ឬដូចភ្លើងកំពុងឆេះ ទ្រង់ប្រសើរ ដូចខ្លាធំនិងគោឧសភៈ ឬដូចកេសរាជសីហ៍មានជាតិដ៏ខ្ពស់ ទ្រង់គង់លើអាសនៈ ទ្រង់ជាកំពូលនៃពួកសមណៈ មានភិក្ខុសង្ឃហែហម ។ លុះខ្ញុំថ្វាយបង្គំព្រះបាទ របស់ព្រះសាស្តាហើយ បែរមុខទៅឧត្តរទិស ដើរចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ខ្ញុំបានថ្វាយគ្រឿងក្រអូប និងកម្រងផ្កា ក្នុងកាលណា ។ (ក្នុងកាលនោះ) ខ្ញុំមិនដែលស្គាល់ទុគ្គតិ ដោយផលនៃសក្ការៈដែលខ្ញុំធ្វើចំពោះព្រះពុទ្ធដោយវិសេស នេះជាផលនៃពុទ្ធបូជា ។

ចត្តារីសម្ហិ ឯកូនេ   កប្បេ អាសិំសុ សោឡស
ទេវគន្ធសនាមា តេ   រាជានោ ចក្កវត្តិនោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា គន្ធមាលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គន្ធមាលិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ តិបុប្ផិយត្ថេរាបទានំ

(៥៨) មិគលុទ្ទោ បុរេ អាសិំ   អរញ្ញេ កាននេ ព្រហេ
បាដលឹ ហរិតំ ទិស្វា   តីណិ បុប្ផានិ ឱកិរឹ ។
សុក្ខបណ្ណានិ(១) គណ្ហិត្វា   ពហិ ឆឌ្ឌេសហំ តទា
អន្តោសុទ្ធំ ពហិសុទ្ធំ   វិមុត្តំ ច អនាសវំ ។
សម្មុខា វិយ សម្ពុទ្ធំ   វិបស្សឹ លោកនាយកំ

១ ម. បរិបក្កានិ ។



ក្នុងកប្បទី ៣៩ ខ្ញុំបានជាក្សត្រចក្រពត្តិ ១៦ អង្គ ព្រះនាមទេវគន្ធៈដូចគ្នា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធមាលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គន្ធមាលិយត្ថេរាបទាន ។

## តិបុប្ផិយត្ថេរាបទាន ទី ៦

(៥៨) ក្នុងកាលមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ បានឃើញដើមប្រទៀល (ជាពោធិព្រឹក្ស) មានពណ៌ខៀវខ្ចី ហើយខ្ញុំរោយផ្កា ៣ ទង (ត្រង់គល់ប្រទៀលនោះ) ។ កាលនោះ ខ្ញុំរើសស្លឹកស្ងួតៗ យកទៅចោលខាងក្រៅ ហើយថ្វាយបង្គំដើមប្រទៀលនោះ ដូចជាថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាលោកនាយក ប្រុងស្អាតខាងក្នុង ស្អាតខាង

បាដលឹ អភិវាទេត្វា  តត្ថ កាលំ កតោ អហំ ។
ឯកនវុតេ ឥតោ កប្បេ  យំ ពោធឹ អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ  ពោធិបូជាយិទំ ផលំ ។
សមន្តបាសាទិកា នាម  តេរសាសឹសុ រាជិនោ
ឥតោ តឹសតិកប្បម្ហិ  ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិបុប្ផិយត្ថេរស្សាបទានំ សមត្តំ ។



ក្រៅ មានព្រះទ័យផុតស្រឡះ (ចាកកិលេស) មិនមានអាសវៈ ក្នុងទីចំពោះមុខ ហើយធ្វើកាលកិរិយាក្នុងទីនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាដើមពោធិព្រឹក្ស ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការបូជាដើមពោធិព្រឹក្ស ។ ក្នុងកប្បទី ៣០ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ១៣ អង្គ ព្រះនាម សមន្តបាសាទិកៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិបុប្ផិយត្ថេរាបទាន ។

## សត្តមំ មធុបិណ្ឌិកត្ថេរាបទានំ

[៨៨] វិវនេ(១) កាននេ វសំ អប្បសទ្ទេ និរាកុលេ
សិទ្ធត្ថំ ឥសិនំ សេដ្ឋំ អាហុតីនំ បដិគ្គហំ ។
និព្វុតិតំ(២) មហានាគំ និសភាជានិយំ យថា
ឱសធីវ វិរោចន្តំ ទេវសង្ឃនមស្សិតំ ។
វិត្តិ មេ បាហុនា តស្ស(៣) ញាណំ ឧប្បជ្ជិ តាវទេ
វុដ្ឋិតស្ស សមាធិម្ហា មធុំ ទត្វាន សត្ថុនោ ។
សិទ្ធត្ថស្ស ភគវតោ វិប្បសន្នេន ចេតសា(៤)
វន្ទិត្វា សិរសា បាទេ បក្កាមឹ បាចិនាមុខោ ។
ចតុត្តឹសម្ហិ កប្បម្ហិ រាជា អាសឹ(៥) សុទស្សនោ
មធុ ភិសេហិ សវតិ ភោជនម្ហិ ច តាវទេ
មធុវស្សំ បវស្សិត្ថ បុព្វកម្មស្សិទំ ផលំ ។

១ ម. វិបិនេ ។ ២ ម. និព្វុតត្តំ ។ ៣ ម. វិត្តិ មេ ពហុតា តតា ។ ៤ ម. សិទ្ធត្ថស្ស ភគវ-
តោ វិប្បសន្នេន ចេតសាតិ ទិស្សតិ ។ ៥ ម. អាសិ ។



## មធុបិណ្ឌិកត្ថេរាបទាន ទី ៧

[៨៨] ខ្ញុំបានឃើញព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថៈ ប្រសើរជាងពួកឥសី គួរទទួលនូវគ្រឿងបូជា គង់នៅព្រៃធំ ជាទីស្ងាត់មិនមានសំឡេង មិនមានការរំខាន ប្រដូចជាមហានាគ មានខ្លួនរលត់ហើយ ជាបុរសអាជានេយ្យដ៏ប្រសើរ ប្រដូចផ្កាយព្រឹក មានពួកទេវតានមស្ការហើយ ។ សេចក្តីត្រេកអររបស់ខ្ញុំ មានប្រមាណច្រើនកើតឡើងមុន ញាណក៏កើតឡើងក្នុងវេលានោះដែរ ខ្ញុំថ្វាយទឹកឃ្មុំចំពោះព្រះសាស្តា ដែលទើបចេញអំពីសមាធិ ។ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះបាទ របស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ដោយសិរ្សៈ ហើយបែរមុខទៅទិសខាងកើត ដើរចេញទៅ ។ ក្នុងកប្បទី ៣៤ ខ្ញុំកើតជាស្តេច ឈ្មោះសុទស្សនៈ មានទឹកឃ្មុំហូរចេញអំពីក្រអៅឈូក (ស្រក់ចុះទៅ) ក្នុងភោជនក្នុងវេលានោះ ទាំងភ្លៀងទឹកឃ្មុំ ក៏បង្អុរចុះ នេះជាផលនៃបុព្វកម្ម ។

ចតុន្នវុតេ ឥតោ កប្បេ យំ មធុំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ មធុទានស្សិទំ ផលំ ។
ចតុត្តឹសេ ឥតោ កប្បេ ចត្តារោ តេ សុទស្សនា
សត្តរតនសម្បន្នា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មធុបិណ្ឌិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មធុបិណ្ឌិកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ សេនាសនទាយកត្ថេរាបទានំ

(១០០) សិទ្ធត្ថស្ស ភគវតោ អទាសឹ បណ្ណសន្ថរំ
សមន្តា ឧបហារញ្ច កុសុមំ ឱកិរឹ អហំ ។





ក្នុងទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ ថ្វាយទឹកឃ្មុំ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទឹកឃ្មុំ ។ ក្នុងកប្បទី ៣៤ អំពីកប្បនេះ ខ្ញុំបានជាស្ដេចចក្រពត្តិ ៤ ដង ព្រះនាមសុទស្សនៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមធុបិណ្ឌិកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មធុបិណ្ឌិកត្ថេរាបទាន ។

## សេនាសនទាយកត្ថេរាបទាន ទី ៨

(១០០) ខ្ញុំបានថ្វាយកម្រាលស្លឹកឈើ ចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ទាំងបានរោយរាយផ្កាឈូក ជាឧបហារៈ (ជាប់កម្រាលស្លឹកឈើ) ដោយជុំវិញទៀត ។

បាសាទេ ច កុដិំ រម្មំ  អនុភោមិ មហារហំ
មហគ្ឃានិ ច បុប្ផានិ  សយនេភិវស្សន្តិ មេ ។
សយនេហំ តុវដ្ដាមិ  វិចិត្តេ បុប្ផសន្ថតេ
បុប្ផវុដ្ឋិ ច សយនេ  អភិវស្សតិ តាវទេ ។
ចតុន្នវុតេ ឥតោ កប្បេ  អទាសិំ បណ្ណសន្ថរំ
ទុគ្គតឹ នាភិជានាមិ  សន្ថរស្ស ឥទំ ផលំ ។
តិណសន្ថារកា នាម(១)  សត្តេតេ ចក្កវត្តិនោ
ឥតោ តេ បញ្ចមេ កប្បេ  ឧប្បជ្ជឹសុ ជនាធិបា ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សេនាសនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សេនាសនទាយកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. តិណសន្ថរកា នាម ។





(ដោយកុសលកម្មនេះ) ខ្ញុំបានសោយ (គ្រប់គ្រង) ប្រាសាទទាំងឡាយផង កុដាជាទីរីករាយ មានថ្លៃច្រើនផង ផ្កាទាំងឡាយមានថ្លៃច្រើន តែងធ្លាក់ចុះលើសយនៈ របស់ខ្ញុំផង ។ ខ្ញុំដេកនៅលើសយនៈដ៏វិចិត្រ ក្រាលដោយផ្កាឈើ ទាំងភ្លៀងជាវិការៈនៃផ្កាឈើ ក៏តែងធ្លាក់ចុះលើសយនៈ (របស់ខ្ញុំ) ក្នុងកាលនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយកម្រាលស្លឹកឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិទៀយ នេះជាផលនៃកម្រាលស្លឹកឈើ ។ ក្នុងកប្បទី ៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ផង ព្រះនាមតិណសន្ថារកៈដូចគ្នា ទ្រង់ជាធំជាងពួកជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសេនាសនទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សេនាសនទាយកត្ថេរាបទាន ។

## នវមំ វេយ្យាវច្ចកត្ថេរាបទានំ

[១០១] វិបស្សិស្ស ភគវតោ មហាបូគគណោ អហុ
វេយ្យាវច្ចករោ អាសឹ សព្វកិច្ចេសុ ព្យាវដោ ។
ទេយ្យធម្មោ ច មេ នត្ថិ សុគតស្ស មហេសិនោ
អវន្ទឹ សត្ថុនោ បាទេ វិប្បសន្នេន ចេតសា ។
ឯកនវុតេ ឥតោ កប្បេ វេយ្យាវច្ចំ អកាសហំ
ទុគ្គតឹ នាភិជានាមិ វេយ្យាវច្ចស្សិទំ ផលំ ។
ឥតោ ចដ្ឋមកេ កប្បេ រាជា អាសឹ សុចិន្តិយោ(១)
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វេយ្យាវច្ចកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វេយ្យាវច្ចកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. សុចិន្តិតោ ។



## វេយ្យាវច្ចកត្ថេរាបទាន ទី ៩

[១០១] ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាមេគណៈ ខ្ញុំជាអ្នកបម្រើ ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចទាំងពួង ។ ឯទេយ្យធម៌របស់ខ្ញុំគ្មាន ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា ជាព្រះសុគតស្វែងរកគុណដ៏ធំ ។ ក្នុងកប្បទី៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើការខ្វល់ខ្វាយបម្រើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការខ្វល់ខ្វាយបម្រើ ។ ក្នុងកប្បទី ៨ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ ព្រះនាមសុចិន្តិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវេយ្យាវច្ចកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វេយ្យាវច្ចកត្ថេរាបទាន ។

## ទសមំ ពុទ្ធុបដ្ឋាកត្ថេរាបទានំ

(១០៦) វិបស្សិនោ ភគវតោ អហោសិំ សង្ខធម្មកោ

និច្ចុបដ្ឋានយុត្តោម្ហិ សុគតស្ស មហេសិនោ ។

ឧបដ្ឋានផលម្បស្ស លោកនាថស្ស តាទិនោ

សដ្ឋិតុរិយសហស្សានិ បរិចារេន្តិ មំ សទា ។

ឯកនវុតេ ឥតោ កប្បេ ឧបដ្ឋឹ មហាឥសឹ

ទុគ្គតឹ នាភិជានាមិ ឧបដ្ឋានស្សិទំ ផលំ ។

ចតុន្នវុតេ ឥតោ កប្បេ មហានិគ្ឃោសនាមកា

សោឡសាសឹសុ រាជានោ ចក្កវត្តី មហព្ពលា ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ពុទ្ធុបដ្ឋាកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពុទ្ធុបដ្ឋាកត្ថេរស្ស អបទានំ សមត្តំ ។



## ពុទ្ធុបដ្ឋាកត្ថេរាបទាន ទី ១០

(១០៦) ខ្ញុំកើតជាអ្នកផ្លុំស័ង្ខ ជាអ្នកប្រកបដោយការបម្រើ ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាព្រះសុគត ព្រះអង្គស្វែងរកនូវគុណដ៏ធំ ជានិច្ច ។ ខ្ញុំកាន់ជួបផលនៃការបម្រើ ព្រះលោកនាថ ទ្រង់ប្រកបដោយតាទិគុណ គិតរៀបត្រឹម ៦០ ពាន់ កែងតែមកកាន់ខ្ញុំ សព្វៗ កាល ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបម្រើព្រះពុទ្ធ ជាមហាឥសី ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបម្រើ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ១៦ ដង ព្រះនាមមហានិគ្ឃោសៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធុបដ្ឋាកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធុបដ្ឋាកត្ថេរាបទាន ។

## ឧទ្ទានំ

សុធា ចិន្តេត្វា(១) ចេលញ្ច កម្មារោ(២) គន្ធមាលិយោ
តិបុប្ផិយោ មធុ សេនា វេយ្យាវច្ចោ ច ធម្មកោ(៣)
សមសដ្ឋិញ្ច គាថាយោ អស្មឹ វគ្គេ បកាសិតា ។

សុធាវគ្គោ ទសមោ ។

## អថ វគ្គុទ្ទានំ

ពុទ្ធវគ្គោ ហិ បឋមោ សីហាសនិ សុភូតិ ច
កុណ្ឌធានោ ឧបាលិ ច វីជនី សកចិត្តនី(៤)
នាគសមាលោ តិមិរំ សុធាវគ្គេន តេ ទស
ចតុទ្ទសសតា គាថា បញ្ចបញ្ញាសមេវ ច ។

ពុទ្ធវគ្គទសកំ ។

បឋមសតកំ សមត្តំ ។

១ ម. សុចិន្តិ ។ ២ ម. សូចិ ច ។ ៣ ម. វេយ្យាវច្ចោ ពុទ្ធុបដ្ឋាកោ ។ ៤ ម. ពីជនិ សកចិត្តិ ច ។



## ឧទ្ទាន

សុធាបិណ្ឌិយត្ថេរាបទាន ១ សុចិន្តិតត្ថេរាបទាន ១ អឌ្ឍចេលកត្ថេរាបទាន ១ សូចិទាយកត្ថេរាបទាន ១ គន្ធមាលិយត្ថេរាបទាន ១ តិបុប្ផិយត្ថេរាបទាន ១ មធុបិណ្ឌិយត្ថេរាបទាន ១ សេនាសនទាយកត្ថេរាបទាន ១ វេយ្យាវច្ចកត្ថេរាបទាន ១ ពុទ្ធុបដ្ឋាកត្ថេរាបទាន ១ ឯគាថាមានចំនួន ៩០ គត់ ដែលលោកសម្តែងហើយ ក្នុងវគ្គនេះ ។

ចប់ សុធាវគ្គ ទី ១០ ។

## មួយទៀត ឧទ្ទានវគ្គ

ពុទ្ធវគ្គ ជាបឋម ១ សីហាសនិយវគ្គ ១ សុភូតិវគ្គ ១ កុណ្ឌធានវគ្គ ១ ឧបាលិវគ្គ ១ វីជនីវគ្គ ១ សកចិត្តនិយវគ្គ ១ នាគសមាលវគ្គ ១ តិមិរបុប្ផិយវគ្គ ១ ជាគំរប់ ១០ ទាំងសុធាវគ្គ មានគាថា ១៤៥៥ ។

ចប់ ពុទ្ធវគ្គទសកៈ ។

ចប់ បឋមសតកៈ ។